ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ អង្គការអន្តរជាតិគួរផ្ដោតលើអតីតកាលនៅក្នុងសង្គមក្រោយជម្លោះ

◆ អត្ថន័យពីរយ៉ាងនៃថ្ងៃ១៧ មេសា តាមរយៈសម័យកាលកន្លងផុតទៅ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១១២ ខែមេសា ឆ្នាំ២០០៩

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១១២ ខែមេសា ឆ្នាំ២០០៩

## មាតិកា


◆អង្គការអន្តរជាតិគួរផ្តោតលើអតីតកាលនៅក្នុងសង្គមក្រោយជម្លោះ .........១

**ផ្នែកឯកសារ**

◆ចម្លើយសារភាពរបស់ ខេន ឃន.................................................២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆សុន្ទរកថារបស់អ្នកនាំពាក្យពីក្រសួងឃោសនា.....................................៦

◆ថ្ងៃ១៧មេសាៈឆ្លុះបញ្ចាំងដោយសង្ខេបទៅលើទីក្រុងភ្នំពេញ.................១០

◆អត្ថន័យពីរយ៉ាងនៃថ្ងៃ១៧មេសា .............................................១១

◆ការចូលរួមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ...........................១៤

◆ការអប់រំពីរបបខ្មែរក្រហមតាមរយៈល្ខោននិយាយ ............................១៦

◆ដំណើរទស្សនកិច្ចអប់រំពីអំពើប្រល័យពូជសាសន៍...............................១៩

**ផ្នែកច្បាប់**

◆ភាពមិនយល់ស្របគ្នារបស់សហព្រះរាជអាជ្ញា ..............................២៣

◆ជនឃោរឃៅដ៏ស្មៀមស្ងាត់ម្នាក់ ................................................៣០

◆តើប្រជាជនកម្ពុជាគួរតែអត់ឱនដល់មេដឹកនាំខ្មែរក្រហម .................៣៣

◆គួនាទីសំណាងបន្ថែមរបស់អង្គជំនុំជម្រះវិសាមញ្ញ...........................៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆នួន ជា កាលពីក្មេងនៅទីក្រុងបាងកក (១៩៤២-១៩៥០) .........៣៨

**ជំព័រស្រាវជ្រាវរកគ្រួសារ**

◆ចាំថ្ងៃស្អែក ......................................................................៥០






## រក្សាសិទ្ធិ


មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម/៩៩

ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នាដៃលេខនេះ ៖** អេង កុកថាយ, ជី ទេវិទ្ធ, កែវ ដាសុីល, សើ សាយ្យាណា, ចូណា ហ្វឺណែរ, ន័រមែន ហេនរី ប៉េនទេឡូវិច, រ៉ាលជី វីលៀម, លី សុខឃាង, អ៊ីជី មូ៉រ៉ាស៊ីម៉ា, និង ប៉ាល់ វណ្ណារក្ស **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, ទេស ម៉ារ៉ែម **អ្នកបកប្រែៈ** ជា ផល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# អង្គការអន្តរជាតិគួរផ្តោតលើអតីតកាលនៅក្នុងសង្គមក្រោយជម្លោះ

*នៅថ្ងៃទី២៣ ខែមីនា ខ្ញុំបានសរសេរសំបុត្រមួយច្បាប់ឆ្លើយតបទៅនឹងអត្ថបទមួយរបស់ប្រធានអង្គការយូអិនឌីភី (UNDP) លោក ចូ ស៊ូអឺ (Jo Scheuer) ដែលរៀបរាប់អំពីការបោសសម្អាតយុទ្ធភណ្ឌមិនទាន់ផ្ទុះដែលនៅសេសសល់ពីសម័យសង្គ្រាមវៀតណាមរវាងឆ្នាំ១៩៦៩-១៩៧៣ ពិសេសគឺគ្រាប់បែកដែលសហរដ្ឋអាមេរិកទម្លាក់មកលើប្រទេសកម្ពុជា ។ លោក ចូ ស៊ូអឺ បានរៀបរាប់អំពីសន្ធិសញ្ញាអន្តរជាតិដែលហាមប្រាមមិនឲ្យមានការប្រើប្រាស់គ្រាប់បែកកញ្ចុំ ដែលប្រទេសចំនួន១០០បានចុះហត្ថលេខាគាំទ្រ ប៉ុន្តែប្រទេសកម្ពុជានិងប្រទេសជាច្រើនទៀតមិនទាន់បានចុះហត្ថលេខានៅឡើយទេ ។ សន្ធិសញ្ញានេះទាមទារឲ្យមានការបោសសម្អាតដីស្រែចម្ការដែលមានគ្រាប់មិនទាន់ផ្ទុះក្នុងរយៈពេល១០ឆ្នាំ ហើយមានផែនការផ្តល់ជំនួយដល់ជនរងគ្រោះដោយសារគ្រាប់មិនទាន់ផ្ទុះ ។ ខ្ញុំមានការសប្បាយចិត្តណាស់ដែលបានឃើញសំបុត្ររបស់លោក ចូ ស៊ូអឺ ដែលមានបំណងល្អក្នុងការជួយប្រជាជនកម្ពុជាឲ្យរួចផុតពីគ្រោះថ្នាក់ដោយសារគ្រាប់មីន ។ ក៏ប៉ុន្តែសំបុត្ររបស់លោកហាក់បីដូចជាបង្ហាញអំពីការផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហានៅចំពោះមុខច្រើនជាងការផ្តោតទៅលើអតីតកាល និងមូលហេតុដែលនាំឲ្យមានបញ្ហាទាំងនោះកើតឡើង ។ គ្រាប់មិនទាន់ផ្ទុះ ពិសេសគ្រាប់បែកដែលបានទម្លាក់ដោយកងទ័ពសហរដ្ឋអាមេរិកនៅសម័យសង្គ្រាមឥណ្ឌូចិនបានកើតឡើង រួមជាមួយនឹងការរីកដុះដាលផ្នែកប្រជាប្រិយភាពរបស់ចលនាបដិវត្តន៍ខ្មែរក្រហម ។ របបខ្មែរក្រហមបានបន្តឲ្យមនុស្សជិតពីរលាននាក់ស្លាប់បាត់បង់ជីវិតដោយសារការប្រហារជីវិត ការធ្វើការបាក់កម្លាំង ការស្រេកឃ្លាននិងជំងឺ ។ កេរដំណែលរបស់របបខ្មែរក្រហមមកលើសង្គមកម្ពុជាបច្ចុប្បន្នមានច្រើនរូបភាពដូចជាការថយចុះធនធានមនុស្សដោយសារការសម្លាប់បញ្ញវន្ត ការបាត់បង់ធនធានសេដ្ឋកិច្ច អំពើហិង្សា ការបន្តឲ្យមានស្ត្រីមេម៉ាយ និងកូនកំព្រា ជាពិសេសការធ្វើឲ្យមានជំងឺផ្លូវចិត្ត ។ ខ្ញុំសូមសំណូមពរអង្គការអន្តរជាតិឲ្យមានការយកចិត្តទុកដាក់ទៅលើប្រវត្តិសាស្ត្រឲ្យបានកាន់តែទូលំទូលាយ នៅក្នុងប្រទេសក្រោយជម្លោះ ហើយបង្កើតជាគោលនយោបាយទូទៅមួយសម្រាប់ការអភិវឌ្ឍដែលយកប្រវត្តិសាស្ត្រជាកត្តាមូលដ្ឋាន ជាពិសេសគឺគោលនយោបាយសម្រាប់ប្រទេសកម្ពុជា ។ យុទ្ធភណ្ឌមិនទាន់ផ្ទុះមិនមែនជាសំណល់តែមួយគត់ពីអតីតកាលនោះទេ មានសំណល់ផ្នែកសង្គម និងសិទ្ធិមនុស្សជាច្រើនទៀតដែលសង្គ្រាមនៅដើមទសវត្សរ៍៧០ និងរបបខ្មែរក្រហមបានបង្កើតឡើង ហើយបន្តក្លាយជាឧបសគ្គសម្រាប់ការអភិវឌ្ឍប្រទេសសម្រាប់ពេលបច្ចុប្បន្ន ។ ប្រសិនបើយើងក្រឡេកមើលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជុំវិញ ការបន្តឲ្យមានយុទ្ធភណ្ឌមិនទាន់ផ្ទុះទាំងអស់នេះវាមានលក្ខណៈស្មុគស្មាញនិងទាក់ទងគ្នាទៅវិញទៅមកក្នុងកម្រិតខ្ពស់ ។ ហេតុនេះកេរដំណែលសិទ្ធិមនុស្សនិងសង្គមគួរត្រូវបានយកចិត្តទុកដាក់ដូចកេរដំណែលផ្សេងទៀតដែរ ។ រួមជាមួយនឹងការសិក្សាអំពីលទ្ធផលអវិជ្ជមាននៃអតីតកាលនិងការកែប្រែបញ្ហាទាំងឡាយដែលមានក្នុងពេលបច្ចុប្បន្ន យើងគួរសិក្សាពីមូលហេតុដែលនាំឲ្យមានបញ្ហាទាំងនោះនិងការពារកុំឲ្យបញ្ហាទាំងនោះកើតឡើងជាថ្មីម្តងទៀត ។ ខ្ញុំសង្ឃឹមថា យូអិនឌីភី នឹងពិចារណាសហការជាមួយរដ្ឋាភិបាល ដើម្បីបង្កើតមន្ទីរពេទ្យចិត្តសាស្ត្រជាតិមួយ ដែលបច្ចុប្បន្នពុំទាន់មានសម្រាប់អ្នករស់ពីរបបខ្មែរក្រហម ។*

**អេង កុកថាយ**

**កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**

*វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយលោក ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ផងចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។* **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ចម្លើយសារភាពរបស់ ខេន យន: ប្រធានក្រុមផ្នែកព្យាបាលនៅពេទ្យ ១៧

ខេន យន អាយុ២៩ឆ្នាំ មានស្រុកកំណើតនៅភូមិត្រពាំងស្វាច់ ឃុំម្កាក់ ស្រុកអង្គស្នួល តំបន់១៥ មានឪពុកឈ្មោះ ខេន (ស្លាប់) និងម្តាយឈ្មោះ ឃឹម (ស្លាប់) ព្រមទាំងមានបងប្អូនចំនួន៤នាក់ (ស្រី២នាក់និងប្រុស២នាក់) បានធ្វើសកម្មភាពក្បត់បដិវត្តន៍ ដោយបានបំផ្លាញសម្ភារៈពេទ្យអស់ជាច្រើន និងបានបញ្ចុះបញ្ចូលមនុស្សមួយចំនួនទៀតឲ្យចូលរួមប្រព្រឹត្តអំពើក្បត់ជាមួយខ្លួន។ ក្រោយមក យន ក៏ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៨។

ក្រោយពីឪពុកស្លាប់ចោល យន ត្រូវធ្វើស្រែ ធ្វើស្កូនិងដីកដីជាមួយម្តាយនិងឪពុកចុង។ ក្នុងខែតុលា ឆ្នាំ១៩៧០ យន ចូលបដិវត្តន៍នៅមន្ទីរតំបន់១៥ជាមួយឈ្មោះ វិន រហូតដល់ចុងឆ្នាំ១៩៧០ ទើបទៅរៀនពេទ្យនៅមន្ទីរតាំងពោធិ៍ ភូមិភាគនិរតី។

នៅខែកុម្ភៈ ឆ្នាំ១៩៧១ យន បានត្រឡប់មកមន្ទីរតំបន់វិញ។ ខែសីហា យន ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការនៅមន្ទីរពេទ្យ១៦ តំបន់១៥ ដោយឲ្យធ្វើជាបុគ្គលិកពេទ្យធម្មតា។ ពេលនោះ យន បានទទួលការអប់រំពីឈ្មោះ លឹម ដែលជាប្រធានពេទ្យ១៦ ឲ្យស្រឡាញ់យុវជនពីរនាក់ឈ្មោះ សុង និង សន ដែលអ្នកទាំងពីរនេះសុទ្ធតែជាយុវជនយោធាតំបន់១៥។ លឹម បាននិយាយប្រាប់ យន ថា ក្រោយពេលដែលយុវជនទាំងពីរនាក់នេះក្លាយជាមេបញ្ជាការ គេនឹងមកចូលស្តីដណ្តឹង ឲ្យតែ យន ព្រមស្រឡាញ់។ ដោយសារមានការអប់រំជាច្រើនលើក យន ក៏យល់ព្រមធ្វើតាមការអប់រំរបស់ លឹម ដោយបានធ្វើខុសសីលធម៌ជាមួយយុវជនទាំងពីរនោះ។

ខែកុម្ភៈ ឆ្នាំ១៩៧២ លឹម ក៏បានអប់រំ យន ជាច្រើនលើកទៀតឲ្យធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍។ នៅពេលដែល យន ជឿជាក់ហើយ លឹម ក៏ណែនាំ យន ឲ្យស្គាល់មនុស្សពីរនាក់ទៀតដែលមានឈ្មោះ លី (នារី) ជាអនុប្រធានពេទ្យព-៥ នៅភូមិភាគពិសេស និងឈ្មោះ លឿន (បុរស) ជាកងទ័ពតំបន់១៥ ឲ្យបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ដើម្បីបំផ្លាញបដិវត្តន៍ទៅថ្ងៃមុខ។ ក្រោយមកក្នុងខែមីនា លឹម បានប្រាប់ យន ឲ្យធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ដោយបំផ្លាញឧបករណ៍ពេទ្យជាមួយ ភន (នារី) ជាអ្នកចាក់ថ្នាំជាមួយគ្នា និងឈ្មោះ ជួន ជាយុវជនសេដ្ឋកិច្ច។ បន្ទាប់មក លឹម បានដាក់ភារកិច្ចឲ្យ យន ធ្វើការជាមួយ ភន ដោយក្នុងខែមេសានេះត្រូវបំផ្លាញសឺរ៉ាំង ម្ជុល និង បង់។ លុះចូលមកដល់ខែមេសា យន និង ភន ក៏បានធ្វើសកម្មភាពបំផ្លាញសឺរ៉ាំងអស់២ចាន៤ និងចំហុយបង់ឲ្យឆេះអស់២០ដុំ។ ក្នុងខែមិថុនា លឹម បានហៅ យន និង ភន ណែនាំម្តងទៀតឲ្យខិតខំធ្វើសកម្មភាពបំផ្លាញតទៅទៀត ដូចជាសឺរ៉ាំងចាក់ថ្នាំនិងម្ជុលដែលបដិវត្តន៍កំពុងតែខ្វះ។ លុះក្រោយមកទៀត យន ជាមួយ ភន បានស្ងោរម្ជុលចាក់ថ្នាំឲ្យខ្ទោចអស់២០ ធ្វើឲ្យឆេះបង់អស់មួយចំនួន និងបានធ្វើឲ្យបែកចានលាងរបួសអស់ចំនួន៥ទៀត។ ខែកញ្ញា យន និង ភន ក៏បានទាក់ទងជាមួយនឹង ជួន ដែលជាអ្នកសេដ្ឋកិច្ចពេទ្យ១៦ តំបន់១៥ម្នាក់ទៀត។ ដោយមានការទាក់ទងគ្នាទៅវិញទៅមក ជួន ក៏បានប្រាប់ យន និង ភន ថាគាត់ក៏ជាមនុស្សរបស់ លឹម ដែរ ហើយគាត់បានធ្វើសកម្មភាពបំផ្លាញកង់អស់មួយគ្រឿងទៀតផង។ ខែធ្នូ យន និង ភន ត្រឡប់ទៅធ្វើការខាងថ្នាំវិញ។ បន្ទាប់មក លឹម បានណែនាំឲ្យ យន និង ភន កុំឲ្យធ្វើគ្រប់តាមផែនការរបស់អង្គការ និងខិតខំបំផ្លាញឧបករណ៍ធ្វើថ្នាំថែមទៀត។ ហេតុនេះហើយ ក្នុងរយៈពេលដែលអង្គការដាក់ផែនការឲ្យធ្វើមួយខែឲ្យបាន៥ម៉ឺនគ្រាប់ យន និង ភន ធ្វើបានតែ ២៥,០០០គ្រាប់ ប៉ុណ្ណោះ។

ខែកុម្ភៈ ឆ្នាំ១៩៧៣ យន និង ភន ត្រឡប់មកនៅខាងព្យាបាលជំងឺវិញ។ ក្នុងរយៈពេលនោះ អ្នកទាំងពីរបានបំផ្លាញសឺរ៉ាំង៤ ថាសលាងរបួស៥ ធ្វើឲ្យឆេះបង់ចំនួន៣ដុំ និងធ្វើឲ្យបាក់ប្រដាប់ស្ទង់កំដៅមួយ។ មកដល់ខែកក្កដា យន និង ភន ត្រឡប់មកនៅខាងដាំបាយ តែ លឹម ត្រូវផ្លាស់ទៅកាន់ខាងកុមារនៅតំបន់១៥វិញ។ ក្នុងរយៈពេលនោះ អ្នកទាំងពីរបានបំផ្លាញចានអស់១០ ស្លាបព្រា២០ និងកែវ១០។ ខែវិច្ឆិកា យន និង ភន មកនៅខាងព្យាបាល តែ ជួន ត្រូវផ្លាស់ទៅនៅខាងកោះកុងវិញ។

ខែមករា ឆ្នាំ១៩៧៤ អង្គការបានស្នើឲ្យ យន ទៅធ្វើការនៅខាងពេទ្យ២៨វិញ ។ នៅពេលនោះ ពេលដែល លីម យកកុមារមកពិនិត្យជំងឺ យន ក៏បានជួបជាមួយ លីម រួចបានប្រាប់ពីដំណើររឿងដែលអង្គការនឹងផ្លាស់គាត់ឲ្យទៅពេទ្យ២៨ ។ ខែកុម្ភៈ យន ក៏ផ្លាស់ទៅពេទ្យ២៨របស់ភូមិភាគពិសេសវិញ ។ ខែមេសា អង្គការបានចាត់តាំង យន ឲ្យជ្រើសរើសបុគ្គលិកពេទ្យថ្មីចំនួន១៥នាក់នៅមន្ទីរតំបន់១៥ មកធ្វើការនៅពេទ្យ២៨ ។ តាមផ្លូវធ្វើដំណើរ យន បានជួបជាមួយ លីម នៅពាក់កណ្ដាលផ្លូវជិតមន្ទីរតំបន់១៥ ។ ពេលនោះ លីម បានប្រាប់ យន ឲ្យធ្វើការជាមួយឈ្មោះ ជាតិ ដែលជាប្រធានក្រុមនារីពេទ្យ២៨ ។ ក្រោយមក យន ក៏នាំបុគ្គលិកទាំង១៥នាក់នោះទៅកាន់មន្ទីរ២៨ ដោយ យន មានតួនាទីជាប្រធានក្រុមនារីខាងព្យាបាល ។ មួយរយៈក្រោយមក យន ក៏បានជួបជាមួយ ជាតិ នៅស្រះទឹក ។ ក្រោយពីសួរឆ្លើយឆ្លងគ្នារួចមក យន ក៏សួរ ជាតិ ថានៅពេទ្យ២៨នេះតើមានស្គាល់កម្មាភិបាលណាទេ? ជាតិ ថាមានស្គាល់ឈ្មោះ ភី, រីម, ស៊ុម និងខេង ។ ទាំងបួននាក់ជាមនុស្សដែល ជាតិ ណែនាំ យន ឲ្យធ្វើការទាក់ទងពេលធ្វើសកម្មភាព ។ ខែមិថុនា យន និង រីម ក៏សហការគ្នាធ្វើសកម្មភាពបំផ្លាញសម្ភារៈវះកាត់ ។ ខែកក្កដា រីម និង យន បានធ្វើឲ្យឆេះកូនកន្សែងពោះគោសម្រាប់វះកាត់ចំនួន២០ ស្បៃ៣០ដុំ រលាយស្រោមដៃអស់១០គូ និងទុយោ បង្ហូរឈាមចំនួន៣ ។ ខែកញ្ញា ដោយមានអ្នកជំងឺច្រើនពេក ប្រធានពេទ្យឈ្មោះ ខុន ក៏ចាត់ឲ្យ យន ជួយយាមអ្នកជំងឺ ។ ពេលនោះ យន និង ភី បានធ្វើសកម្មភាពបំផ្លាញសឺរ៉ាំងចាក់ថ្នាំអស់៥ ប្រដាប់ស្ទង់កម្ដៅ១និងធ្វើឲ្យឆេះបង់លាងរបួសចំនួន៣០ដុំ ។ ខែវិច្ឆិកា ដោយសារមានអ្នកជំងឺច្រើនពេក និងផលិតថ្នាំមិនទាន់ ប្រធានពេទ្យ២៨ក៏ដក យន ឲ្យជួយរែកទឹកលាងដបទឹកសេរ៉ូមជាមួយ ស៊ុម និង ខេង វិញ ។ ពេលដឹងថា ស៊ុម និង ខេង ជាគ្នាឯង យន និង ស៊ុម បានរួមគ្នាធ្វើសកម្មភាពឲ្យបែកដបសេរ៉ូមអស់ចំនួន១៥និងបែកកែវទឹកចំហុយធំមួយ ។ ខែធ្នូ ជាតិ ឲ្យ ស៊ុម និង ខេង ធ្វើសកម្មភាពរត់កាត់មន្ទីរ និងបាញ់បង្អើលប្រជាជន រួចស្រែកថាមានគិញរត់កាត់មន្ទីរដើម្បីឲ្យមានភាពច្របូកច្របល់ក្នុងមន្ទីរ ។ ក្រោយពីធ្វើសកម្មភាពហើយ មន្ទីរពេទ្យនោះត្រូវរើមកនៅព្រៃក្បាលចិនវិញ ដែលធ្វើឲ្យការព្យាបាលរបួសត្រូវស្ទះដំណើរការអស់រយៈពេល២ខែ ។

ខែមីនា ឆ្នាំ១៩៧៥ ដោយឃើញ យន ធ្វើការនៅខាងផ្ទះបាយ ជាតិ ក៏ណែនាំឲ្យ យន, រីម, ភី, ខេង និងស៊ុមធ្វើសកម្មភាពបន្តទៀត ។ ក្រោយមក យន ក៏ធ្វើសកម្មភាពបំផ្លាញចានអស់១០ស្លាបព្រា និងកែវមួយចំនួនទៀត ។ ខែមេសា ដោយសារសមរភូមិមុខមានការប្រយុទ្ធខ្លាំងក្លានិងមានអ្នករបួសច្រើន អង្គការក៏បើកសម្ភារៈនិងស្បៀងជាច្រើនមកឲ្យមន្ទីរពេទ្យ ។ នៅពេលនោះ ជាតិ បានណែនាំ យន ឲ្យធ្វើសកម្មភាពបំផ្លាញត្រីងៀត ត្រីឆ្អើរ អំបិល ប្រហុក និងចំណីផ្សេងៗទៀត ។ ជាលទ្ធផល យន បានធ្វើឲ្យត្រីឆ្អើរ និងសាច់ក្រកចំនួន៣០ដុំដុះផ្សិត ក្រួចរលួយ អស់៣បាវ ប្រហុក ១ពាងត្រូវដង្កូវចោះ និងម៉ាស៊ីនដេរប៉ាក់១គ្រឿងត្រូវខូច ។ ចំណែក ភី វិញ បានធ្វើឲ្យបែកពាងទឹកធំៗចំនួន២ និងឆេះបង់អស់មួយចំនួន ។ ខែឧសភា ក្រោយថ្ងៃរំដោះ អង្គការដកបុគ្គលិកពេទ្យ២៨មកនៅពេទ្យ១៧វិញទាំងអស់ លើកលែង ជាតិ និង ខេង ត្រូវធ្វើការនៅកន្លែងដដែល ។ ពេលមកដល់ពេទ្យ១៧ យន ធ្វើជាប្រធានពិនិត្យជំងឺទូទៅ ភី នៅខាងថតឆ្លុះ រីម ខាងផ្ទះបាយ ចំណែក ស៊ុម ត្រូវទៅធ្វើស្រែនៅភ្នំអង្គរស្បូ ។ ខែកញ្ញា លី ប្រធានពេទ្យ១៧ ដែលបច្ចុប្បន្នត្រូវចាប់ខ្លួន បានគំរាម យន ឲ្យធ្វើតាមការចាត់តាំងរបស់ខ្លួនដោយក្នុងរយៈពេល៤ខែ ត្រូវលះបង់ខ្លួនផ្ដួលសីលធម៌ឲ្យបានយ៉ាងតិច១០នាក់ដើម្បីអូសទាញកម្មាភិបាលផ្សេងទៀតឲ្យធ្វើសកម្មភាពក្បត់ បើមិនដូច្នោះទេ គាត់នឹងដក យន ចេញ ។ បន្ទាប់មកទៀត លី ក៏ប្រាប់ឈ្មោះ អ្នកដែល យន ត្រូវទាក់ទងជាមួយរួមមានៈ សារ៉ាន់, ថេន, សារ៉ាត, រីម, រិត, ណាត, ណៃ និង សុខា ។ ក្នុងចំណោមមនុស្សទាំងនេះ មួយចំនួនមិនបានអនុវត្តខូចសីលធម៌ទេ តែធ្វើសកម្មភាពបំផ្លាញ ។ ខែតុលា យន ពិភាក្សាជាមួយឈ្មោះ សារ៉ាត, សារ៉ាន់, រីម និង ថេន ដើម្បីចែកមុខសញ្ញាទាក់ទងយុវជន ។ ក្នុងនោះ សារ៉ាន់ និង ថេន ទាក់ទងជាមួយអ្នកជំងឺ ចំណែក យន, រីម និង សារ៉ាត ទាក់ទងបុគ្គលិកពេទ្យ ។ ក្រោយពីពិភាក្សាគ្នារួចហើយ ក្នុងអំឡុងពីខែតុលា ដល់ខែមករា ឆ្នាំ១៩៧៦ យន ទាក់ទងសីលធម៌បានខ្លួនជាមួយនឹងឈ្មោះ ប៊ី, រ៉ុ, ស៊ិន, បៀន, សែន, វៃ, អឹម, សៀម, យឿន និង ឈុនលី ។

មកដល់ចុងខែមករា ឆ្នាំ១៩៧៦ យន រាយការណ៍ប្រាប់

លី ថាខ្លួនបានទាក់ទងសីលធម៌ បាន១០នាក់ហើយ ប៉ុន្តែមិនទាក់ទងជាមួយរឿងក្បត់ទេ ។ ក្រោយមកទៀត លី ឲ្យ យន ទាក់ទងជាមួយខ្សែសីលធម៌ដើម្បីធ្វើសកម្មភាពបំផ្លាញម្តង ដោយឲ្យទាក់ទងជាមួយកម្មាភិបាលថ្មីចំនួន៤នាក់ដូចជា រឿន, សុះ, ខាន់ និងសាន ជាដើម ។ ចំណែកកម្មាភិបាលចាស់ៗដែលមានហើយ ត្រូវទាក់ទងតាមផ្នែកនីមួយៗ ។ ខែមីនា លី ហៅ យន, សុខា និង ណាត ណែនាំនៅផ្ទះបុគ្គលិកពេទ្យដែលស្ថិតនៅខាងក្រោមមន្ទីរពេទ្យ ឲ្យធ្វើសកម្មភាពបំផ្លាញសម្ភារៈពេទ្យមានដូចជា សឺរ៉ាំង និងម្ជុលជាដើម បូករួមទាំងដាក់ថ្នាំបំពុលនៅក្នុងបាយសម្លទៀតផង ។ ចំណែកកម្មាភិបាលទាំង១០នាក់ នោះ លី អប់រំរួចហើយ សព្វថ្ងៃ លី បានប្រគល់ឲ្យឈ្មោះ ម៉ៅ ដែលជាគណៈពេទ្យ១៧ ជាអ្នកដឹកនាំធ្វើសកម្មភាព ។ បន្ទាប់មក លី បញ្ជាក់ពីផែនការទៀតថា ផ្នែកយុវនគឺត្រូវដើរគាស់ឃ្លាំងសម្ភារៈ ឡើងគោះទ្វារផ្ទះនារីនិងលួចសម្ភារៈគ្នាទៅវិញទៅមកដើម្បីឲ្យមានភាពច្របូកច្របល់ក្នុងមន្ទីរពេទ្យ១៧នេះ ។ ចំណែកខាងផ្នែកនារី ត្រូវបំផុសពីរឿងសីលធម៌និងដើរទាក់ទងសីលធម៌ជាមួយយុវន ដើម្បីបំផ្លាញសម្ភារៈតាមផ្នែកនីមួយៗ ហើយម្យ៉ាងថ្នាំពេទ្យត្រូវទុកឲ្យខូចកករ និងបូមកុំឲ្យអស់ពីដប ឬក៏យកទៅបោះចោល ។ ខែមេសា យន និង ណាត ដែលធ្វើការផ្នែកព្យាបាលជាមួយគ្នា បានធ្វើឲ្យបែកសឺរ៉ាំងអស់៨ បាក់ប្រដាប់ស្ទង់កម្តៅចំនួន៣ និងធ្វើឲ្យបែកកែវទឹកចំនួន២០ ។ ខែឧសភា យន និង ណាត បានបំផ្លាញសឺរ៉ាំងអស់៨ ធ្វើឲ្យខូចប្រដាប់វាស់ឈាម១ និងប្រដាប់ស្ទង់កម្តៅចំនួន៤ កែវ១៥ យកកន្ត្រៃទៅបោះចោលអស់១៥ និងធ្វើឲ្យខូចម្ជុលមួយចំនួនទៀត ។ ខែមិថុនា យន និងអ្នកដែលចូលរួមធ្វើសកម្មភាពក្បត់ បានឡើងមករាយការណ៍ពីសកម្មភាពរបស់ខ្លួន រួចលី ក៏បញ្ជាក់ថាធ្វើយ៉ាងណាកុំឲ្យបែកការណ៍ទៅដល់អ្នកដទៃ បើមិនដូច្នោះទេ គាត់នឹងយកទៅសម្លាប់ចោល ។ ខែសីហា យន ជួបជាមួយ ម៉ៅ នៅខាងក្រោមផ្ទះ ហើយ ម៉ៅ និយាយប្រាប់ថាគាត់បានធ្វើសកម្មភាពខាងយុវជនដោយគប់ផ្ទះនារី គាស់សោឃ្លាំងសម្ភារៈនិងលួចនាឡិកាគ្នាទៅវិញទៅមក ។ សរុបមក ចាប់តាំងពីខែតុលាដល់ខែធ្នូ យន ធ្វើឲ្យបែកសឺរ៉ាំងអស់ចំនួន៨ ប្រដាប់ស្ទង់កំដៅ៤ កែវទឹក១៥ និងស្តេតូស្កាប់ជីបចរចំនួន១ ។ ម្យ៉ាងទៀត យន ឲ្យថ្នាំទៅដល់អ្នកជំងឺច្រឡំ និងប្រើប្រាស់ម្ជុលដោយគ្មានអនាម័យ ។

ខែមីនា ឆ្នាំ១៩៧៧ អឹម បានប្រាប់ យន ពីខ្សែបណ្តាញថ្មីរបស់ ម៉ៅ ម្នាក់ទៀតឈ្មោះ រឿន ដែលជាប្រធានក្រុមយុវជនផ្នែកធ្មេញនៅពេទ្យ១៧ ហើយដែលសព្វថ្ងៃកំពុងធ្វើសកម្មភាពជាមួយខ្លួននៅក្នុងមន្ទីរពេទ្យ ដោយលួចគាស់បន្ទប់យុវជនដូចគ្នានិងយកបានខោអាវខ្មៅមួយកំផ្លេ ។ ខែមេសា ទើប ម៉ៅ បានបញ្ជាក់ប្រាប់ យន ថា រឿន ជាមនុស្សដែលគាត់បានអប់រំរួចហើយ ។ ខែឧសភា ម៉ៅ ប្រាប់ យន ថាគាត់ទាក់ទងបានកម្មាភិបាលម្នាក់ទៀតហើយឈ្មោះ ដួល ហើយបច្ចុប្បន្នជាយុវជនផ្នែកធ្មេញនៅពេទ្យ១៧ ។ ម៉ៅ ក៏បញ្ជាក់ទៀតថា ដួល មានការទាក់ទងស្រឡាញ់នារី រិន ដូច្នេះបើមានការអី យន អាចទាក់ទងទៅ ដួល បាន ។ ក្នុងខែនោះ យន និង ណាត ធ្វើសកម្មភាពបំផ្លាញសឺរ៉ាំងអស់៩ ប្រដាប់ស្ទង់កំដៅ៤ ប្រដាប់វាស់ឈាម១ ធ្វើឲ្យម្ជុលស្ទះចំនួន១៥ បែកកែវទឹក១៥ និងបោះកន្ត្រៃចោល១០ ។ ខែមិថុនា ក្រោយពី យន និង ណាត រាយការណ៍ពីសកម្មភាពរបស់ខ្លួន លី ក៏បានប្រាប់ឲ្យអ្នកទាំងពីរផ្អាកសកម្មភាពមួយរយៈសិន និងរង់ចាំដល់ខែសីហាទើបគាត់រៀបចំផែនការថ្មីឲ្យធ្វើ ព្រោះផ្នែកនីមួយៗមិនទាន់បានរាយការណ៍អស់គ្រប់គ្នានៅឡើយ ។ លុះក្រោយមកទៀត នៅពេល យន ទៅបើកថ្នាំ ទើប អឹម ប្រាប់ យន ថា ម៉ៅ និង ប៊ី បានសម្លាប់ ហួត ដែលធ្វើការនៅឃ្លាំងថ្នាំតាមផែនការដែល លី បានដាក់ឲ្យធ្វើរួចហើយ ព្រោះឈ្មោះ ហួត នោះ លី អប់រំរួចហើយតែមិនព្រម ហើយថែមទាំងទៅរាយការណ៍ប្រាប់ ពឿន ទៀតផង ។ ក្រោយមកនៅខែកក្កដា អង្គការដក លី បាត់ទៅ ។ ពេលនោះដែរ យន ទៅជាមួយមិត្តយើងជាច្រើននាក់ដើម្បីជួយដាំដំឡូង ម៉ៅ នៅខាងត្បូងមន្ទីរពេទ្យ ។ ពេលនោះ យន បានឆ្លៀតទៅជួបជាមួយ ម៉ៅ នៅក្រោមផ្ទះដើម្បីប្រាប់ថាគាត់អប់រំបានកម្មាភិបាល២នាក់ទៀតឈ្មោះ ថន និង មាន ។ ម៉ៅ បន្តទៀតថា គាត់មានការព្រួយបារម្ភយ៉ាងខ្លាំងបន្ទាប់ពី លី ត្រូវអង្គការដកចេញ ប៉ុន្តែទោះជាយ៉ាងណាគាត់ត្រូវតែបន្តរក្សាការសម្ងាត់នេះតទៅទៀត ។ នៅដើមខែសីហា អង្គការដក ម៉ៅ ចេញទៀត ។ លុះមកដល់ពាក់កណ្តាលខែសីហា អង្គការក៏ដក យន, សុខា, លាន, ខាន់, ណៅ, ឈុនលី, យឿន, រ៉ុ, ថន, មាន, លៀម និង សែន ទៅនៅមន្ទីរក-១៣ធ្វើស្រែ ។ ខែកញ្ញា ពេល យន, សុខា, ណៅ, ខាន់,

និងសាន កំពុងដួតទឹកជាមួយគ្នា សុខា និយាយថាយើងត្រូវតែស្វែងរកបណ្ដាញរបស់យើងដើម្បីធ្វើសកម្មភាពបំផ្លាញអង្គការតទៅទៀតដូចជា បំផ្លាញសម្ភារៈ ធ្វើស្រែជាដើម ។ ខែតុលា យន, សុខា, សាន, និង ណេ ធ្វើសកម្មភាពដាន់ចបពន្លិចក្នុងប្រឡាយអស់ចំនួន៣ ពេលដែលជីកប្រឡាយ ។ ខែវិច្ឆិកា ពេលដែល យន នៅក្នុងផ្ទះបាយម្នាក់ឯង យន បាន ធ្វើសកម្មភាពដាំបាយឲ្យខ្លះដាំបបរឲ្យខ្លោច ធ្វើឲ្យបែកចានចំនួន៤ និង ធុងទឹក១គូត្រូវបែកអស់ ។ ថ្ងៃទី១៥ ខែវិច្ឆិកា នៅម៉ោង១០កន្លះយប់ ណេ បានឡើងមកគោះទ្វាផ្ទះ យន ហើយនិយាយប្រាប់ យន ថាគាត់កំពុងធ្វើការទាក់ទងជាមួយនឹងឈ្មោះ យ៉ង និង រី ។ រយៈពេល នោះ សុខា ណែនាំឲ្យ យន ធ្វើសកម្មភាពបន្តទៅទៀត បើមិនអ៊ីចឹងនឹងត្រូវអង្គការចាប់ខ្លួន ។ ដូច្នោះ សុខា ក៏ណែនាំឲ្យ យន ធ្វើការទាក់ទងជាមួយឈ្មោះ ភា ដែលបច្ចុប្បន្ននៅក-១៣ ។ ក្រោយមកពេលកំពុងដួតទឹកនៅស្រះទឹក យន អប់រំ ភា ថាមិត្តមកនេះសុទ្ធតែជាសមាសភាពមិនល្អ អង្គការមិនទុកចិត្តយើងទេ គេឲ្យយើងធ្វើការហើយគេតាមដានយើងទៀត ។ ដូច្នេះតើមិត្តសុខចិត្តធ្វើសកម្មភាពបំផ្លាញអង្គការឬទេ? ភា ក៏យល់ព្រម ។ លុះក្រោយមក យន ក៏ប្រាប់ថា ឈ្មោះអ្នកដែលត្រូវទាក់ទងធ្វើសកម្មភាព រួមមាន យន, សុខា, ណេ, ខាន់ និង សាន ។ ថ្ងៃទី៣០ ខែធ្នូ យន ជួបជាមួយសាន, ណេ, ខាន់ និង សុខា ។ បន្ទាប់មក សុខា ណែនាំឲ្យទាំងអស់គ្នាទាក់ទងជាមួយគ្នាឲ្យជាប់ដើម្បីទាំងអស់គ្នាចាប់ផ្ដើមធ្វើសកម្មភាពនៅខែមករា ឆ្នាំ១៩៧៨ ។ លុះស្អែកឡើង ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ អង្គការបានចាប់ខ្លួន យន និង សុខា ។

**ឆេស ម៉ារ៉ែម**

# លិខិតសំណូមពរ

នាងខ្ញុំឈ្មោះ បាយ សុភានី មានតួនាទីជាអ្នកប្រឹក្សាផ្នែកសុខភាពផ្លូវចិត្ត ដែលធ្វើការជាមួយនឹងលោកវេជ្ជបណ្ឌិត រិចឈឺរើ ។ នាងខ្ញុំក៏ធ្លាប់ធ្វើជាគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជា និងជាជនរងគ្រោះមួយរូបនៅក្នុងរបបខ្មែរក្រហមផងដែរ ។

មូលហេតុដែលនាងខ្ញុំសរសេរសំបុត្រនេះ ពីព្រោះនាងខ្ញុំចង់សំណូមពរឲ្យលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាដាក់សម្ពាធទៅលើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឲ្យដំណើរការការកាត់ក្ដីទៅមុខបានលឿនជាងនេះ ។ នាងខ្ញុំចង់ឃើញយុត្តិធម៌ ។ នាងខ្ញុំធ្លាប់បានឮ ឌុច ធ្វើការសូមទោសតាមរយៈវិទ្យុអាស៊ីសេរី ហើយនាងខ្ញុំក៏ចង់ឃើញឃាតករនៅគុកដទៃទៀតធ្វើការសូមទោសផងដែរ ប៉ុន្តែមេដឹកនាំទាំងនោះមានវ័យចាស់ជរាទៅហើយ ។ យ៉ាងណាមិញ ទោះបីជា ឌុច បានសូមទោសយ៉ាងណាក៏ដោយ ក៏ ឌុច មិនអាចចាកចេញពីមន្ទីរឃុំឃាំងបានឡើយ ពីព្រោះ ឌុច បានសម្លាប់មនុស្សអស់ជាច្រើន មិនត្រឹមតែនៅគុកទួលស្លែងប៉ុណ្ណោះទេ ថែមទាំងនៅតាមកន្លែងដទៃផ្សេងទៀតផងដែរ ដូច្នេះ ឌុច ត្រូវតែរស់នៅក្នុងគុកអស់មួយជីវិត ។ ជាមួយគ្នានេះ ឃាតករដែលនៅក្នុងគុកបួនរូបទៀតក៏ត្រូវតែរស់នៅក្នុងគុករហូតដែរ ។ ដូចគ្នានឹងជនរងគ្រោះដទៃទៀត នាងខ្ញុំបានទទួលរងនូវទុក្ខវេទនាគ្រប់បែបយ៉ាងនៅក្នុងរបបខ្មែរក្រហម ដោយបានបាត់បង់នូវសមាជិកគ្រួសារនិងកូនរបស់ខ្ញុំទាំងអស់ ។ គ្រួសារនិងកូនៗរបស់ខ្ញុំទាំងអស់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់យ៉ាងសាហាវឃោរឃៅ និងអាណោចអធ័មបំផុត ដូច្នេះខ្ញុំមិនអាចបំភ្លេចនូវរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបនោះបានឡើយ ។ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃបើកទំព័រនៃការសម្លាប់មួយដែលបានរំឭកខ្ញុំអំពីរឿងរ៉ាវទាំងនេះជារៀងរាល់ឆ្នាំនៅខែមេសាដែលពេលចូលឆ្នាំថ្មីរបស់ប្រជាជនកម្ពុជា ។ ខ្ញុំយល់ថា ប្រជាជនកម្ពុជាគ្រប់រូប គួរតែធ្វើពិធីបុណ្យបង្សុកូលឧទ្ទិសកុសលដល់ប្រជាជនទាំងអស់ដែលបានពលីជីវិតនៅក្នុងរបប ប៉ុល ពត ដើម្បីជាការចងចាំដល់អ្នកទាំងនោះ ។ ចុងបញ្ចប់ នាងខ្ញុំសូមជូនពរឆ្នាំថ្មីជូនចំពោះលោកនាយកព្រមទាំងក្រុមគ្រួសារ សូមឲ្យឆ្នាំថ្មីនេះនាំមកនូវសេចក្ដីសង្ឃឹម សន្តិភាព សុភមង្គល និងជោគជ័យគ្រប់ប្រការជូនដល់ប្រជាជនកម្ពុជាគ្រប់រូបនិងនាំមកនូវយុត្តិធម៌ជូនដល់ជនរងគ្រោះទាំងអស់នៅក្នុងរបបខ្មែរក្រហមផងដែរ ។ ដោយក្ដីគោរពអំពីខ្ញុំ!

**បាយ សុភានី**

# សុន្ទរកថារបស់អ្នកនាំពាក្យពីក្រសួងឃោសនាការ និង សារព័ត៌មានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

អ្នកនាំពាក្យពីក្រសួងឃោសនាការនិងសារព័ត៌មានក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុញ្ញាតដោយរាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឲ្យថ្លែងសុន្ទរកថាមួយដែលមានខ្លឹមសារដូចខាងក្រោមៈ

ដើម្បីលាក់បាំងពីសកម្មភាពសាហាវឃោរឃៅនៃការរំលោភនិងការឈ្លានពានមកលើដែនដីរបស់ប្រទេសកម្ពុជា និងដើម្បីបិទបាំងនូវមុខមាត់ជាមនុស្សសាហាវ មនុស្សវាតទីនិយមនិងជាមនុស្សដែលចង់លេបត្របាក់យកដែនដីខ្មែរប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យនិងប្រជាជនរបស់របបនេះ ភាគីវៀតណាម ព្រមទាំងរាជរដ្ឋាភិបាលរបស់ខ្លួនមិនបាននិយាយថាកងទ័ពវៀតណាមបានសម្រុកចូលយ៉ាងជ្រៅទៅក្នុងទឹកដីប្រទេសកម្ពុជាទេ គេគ្រាន់តែនិយាយអំពីបញ្ហាមួយដែលគេហៅថា «ជម្លោះព្រំដែនដ៏គួរឲ្យសោកស្តាយរវាងកម្ពុជានិងវៀតណាម» តែប៉ុណ្ណោះ ។

នេះជាសកម្មភាពនៃភាពមិនស្មោះត្រង់របស់ប្រជាជនវៀតណាមមួយផ្សេងទៀត ដែលទស្សនៈរបស់ប្រជាជនទូទាំងពិភពលោកត្រូវបានដឹងកាន់តែច្រើននិងបានស្អប់ខ្ពើម ។ វាជាការពិតដែលថាអ្នករំលោភឈ្លានពានតែងតែខ្លាចនូវការពិតនិងសច្ចធម៌ ដូច្នេះហើយអ្នកទាំងនោះព្យាយាមស្វះស្វែងរកគម្រោងការដើម្បីលាក់បាំងរាល់សកម្មភាពទាំងអស់របស់ខ្លួន ។

អ្នកនាំពាក្យរបស់ក្រសួងឃោសនាការនិងសារព័ត៌មាននៃរបបកម្ពុជាប្រជាធិបតេយ្យមានបំណងថ្លែងសុន្ទរកថាដ៏ជាក់លាក់ដែលមានចែងដូចខាងក្រោមៈ

តាមការពិត ដោយក្តាប់យកឱកាសនៅពេលដែលកងទ័ពនិងប្រជាជនកម្ពុជាកំពុងតែមមាញឹកនឹងការងារបង្កបង្កើនផលិតផលកសិកម្មដើម្បីជួយលើកកម្ពស់ជីវភាពរស់នៅនិងកសាងប្រទេសជាតិរបស់ខ្លួន ហើយបានដាក់កម្លាំងទ័ពសម្រាប់ការពារព្រំដែនតែមួយចំនួនតូច កងទ័ពរំលោភឈ្លានពានរបស់វៀតណាមបានធ្វើការវាយប្រយុទ្ធនិងឈ្លានពានចូលក្នុងទឹកដីរបស់កម្ពុជាយ៉ាងជ្រៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រមាណជាច្រើនគីឡូម៉ែត្រពីព្រំប្រទល់ខណ្ឌសីមាៈ

១) តាមដងផ្លូវជាតិលេខ៧ នៅក្នុងភូមិភាគខាងកើត កងទ័ពវៀតណាមបានចាប់ផ្តើមធ្វើការវាយប្រយុទ្ធនិងឈ្លានពានរបស់ខ្លួនចាប់ពីខែតុលា ឆ្នាំ១៩៧៧ ។ ក្នុងការវាយប្រហារលើកដំបូងរបស់កងទ័ពវៀតណាម ពួកវាបានឈ្លានពានយកបានស្រុកមេមត់



ក្រែក និងបានចូលទៅដល់ភូមិស្ពានក្នុងទឹកដីរបស់ប្រទេសកម្ពុជា ចម្ងាយ២០គីឡូម៉ែត្រពីព្រំប្រទល់ ។

បន្ទាប់ពីនេះ កងទ័ពវៀតណាមបានចាប់ផ្តើមធ្វើការវាយប្រហារជាលើកទីពីររបស់ខ្លួននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ ដែលជាថ្ងៃបន្ទាប់ពីការថ្លែងសុន្ទរកថារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានចេញផ្សាយបានរយៈពេលមួយថ្ងៃ ។ ពួកវាបានវាយចូលតាមផ្លូវជាតិលេខ៧ឡើងមកដល់ផ្លូវបំបែកបាធាយចម្ងាយ៣០គីឡូម៉ែត្រពីព្រំដែនប្រទេសកម្ពុជា ហើយក៏បានចូលដល់ប៉ែកខាងជើងនិងខាងត្បូងតាមផ្លូវនេះដូចគ្នា ។

ដូច្នេះ ទឹកដីកម្ពុជាដែលត្រូវបានកាន់កាប់ដោយកងទ័ពវៀតណាមនៅក្នុងតំបន់នេះមានប្រវែង៣០គីឡូម៉ែត្រពីព្រំដែនកម្ពុជា-វៀតណាមចាប់ប៉ែកខាងកើតដល់ប៉ែកខាងលិច និងមានទំហំ២០គីឡូម៉ែត្រទាំងសងខាងផ្លូវ ។



ប៉ុល ពត

នៅពេលបច្ចុប្បន្ន តំបន់ដែលកងទ័ពវៀតណាមកាន់កាប់ត្រូវបានហ៊ុមពទ្ធ័ដោយកងទ័ពនិងប្រជាជនកម្ពុជាដែលធ្វើការវាយប្រយុទ្ធពួកវាពីខាងមុខ ហ៊ុមពទ្ធ័ពីខាងក្រោយចាប់ពីប៉ែកខាងជើងនិងខាងត្បូង ដោយវាយបំបែកមូលដ្ឋានដែលពួកវាបានបោះទីតាំងនៅក្នុងទឹកដីកម្ពុជា ហើយលបវាយប្រហារពួកវាក្នុងតំបន់នេះតែម្តង ។ ពួកសត្រូវមិនអាចចូលទៅមុខ ហើយក៏មិនអាចដកខ្លួនរួចដែរ ។

តើនេះឬដែលភាគីវៀតណាមនិងរាជរដ្ឋាភិបាលរបស់ខ្លួនហៅថា «ជម្លោះព្រំដែនរវាងកម្ពុជានិងវៀតណាម» ជម្លោះដែលពួកវៀតណាមក្លែងធ្វើជាសោកស្តាយខ្លាំងណាស់នោះ? តើព្រំដែនប្រទេសវៀតណាមនៅឯណា? នៅឯមេមត់ ក្រែក បាធាយឬក៏នៅផ្លូវបំបែកពីផ្លូវលេខ៧ដល់ស្នួល? សូមឲ្យវៀតណាមផ្តល់ចម្លើយរាល់សំណួរទាំងនេះទៅកាន់មតិជុំវិញពិភពលោក ។

២) នៅខេត្តស្វាយរៀង កងទ័ពវៀតណាមបានវាយបំបែកចូលដល់ទឹកដីកម្ពុជាតាមផ្លូវជាតិលេខ១ ផ្លូវជាតិលេខ១៣ និងទាំងប៉ែកខាងជើងនិងខាងត្បូងផ្លូវជាតិលេខ១ ។ វាមានសភាពដូចគ្នានៅក្នុងតំបន់នេះ ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានចាប់ផ្តើមធ្វើការវាយឆ្មក់ ហើយក៏បានវាយបំបែកចូលទៅក្នុងទឹកដីកម្ពុជាយ៉ាងជ្រៅ ។

ក) នៅខាងក្នុងនិងតាមប៉ែកខាងត្បូងផ្លូវជាតិលេខ១ កងទ័ពវៀតណាមបានវាយយកស្រុកបាវិត ហើយបានចូលដល់ខេត្តពោធិ៍សាត់ចម្ងាយ៣០គីឡូម៉ែត្រពីព្រំប្រទល់ និង១០គីឡូម៉ែត្រទៀតពីក្រុងស្វាយរៀង ។

ខ) នៅតាមដងផ្លូវជាតិលេខ១៣ នៅប៉ែកខាងជើងផ្លូវជាតិលេខ១ កងទ័ពឈ្លានពានរបស់វៀតណាមបានវាយប្រយុទ្ធ និងបានកាន់កាប់ផ្លូវជាតិលេខ១៣ រហូតដល់ភូមិចក ចម្ងាយដប់គីឡូម៉ែត្រខាងជើងក្រុងស្វាយរៀង ។

គោលបំណងរបស់កងទ័ពវៀតណាមគឺធ្វើការវាយយកក្រុងស្វាយរៀង ។ ប៉ុន្តែ កងទ័ពឈ្លានពានរបស់វៀតណាមត្រូវបានហ៊ុមពទ្ធ័ដោយកងទ័ពនិងប្រជាជនកម្ពុជា ។ ពួកកងទ័ពវៀតណាមមិនអាចរុលទៅមុខ ហើយក៏មិនអាចដកខ្លួនរួចដែរ ។ កងទ័ព

និងប្រជាជនកម្ពុជាបានកាប់សម្លាប់ពួកកងទ័ពវៀតណាមទាំងនោះជាបំណែកដើម្បីកម្ចាត់ចោលកុំឲ្យមានសល់ ដោយគ្មានទុកឱកាសឲ្យពួកនេះរួចខ្លួនបានឡើយ ។ កាលពីព្រឹកថ្ងៃទី៥ ខែមករា កាលពីម្សិលមិញ យើងយកជ័យជម្នះបានមកវិញនូវភូមិចក ហើយយើងបានកម្ទេចចោលពួកសត្រូវទាំងនោះយ៉ាងជយ័ជម្នះ ។

តើនេះឬដែលភាគីវៀតណាមនិងរដ្ឋាភិបាលរបស់ខ្លួនហៅថា «ជម្លោះព្រំដែនរវាងកម្ពុជានិងវៀតណាម» ជម្លោះដែលពួកវៀតណាមក្លែងធ្វើជាសោកស្តាយខ្លាំងណាស់នោះ? តើព្រំដែនប្រទេសវៀតណាមនៅក្នុងខេត្តពោធិ៍សាត់ ឬនៅភូមិចក? សូមឲ្យភាគីវៀតណាមនិងរាជរដ្ឋាភិបាលរបស់ខ្លួនផ្តល់ចម្លើយរាល់សំណួរទាំងនេះទៅកាន់មតិពិភពលោក ។

៣) នៅខេត្តកំពតនិងតាកែវក៏មានស្ថានភាពដូចគ្នា ជាពិសេសក្នុងតំបន់ខាងត្បូងឆៀងខាងលិច ។ ក្នុងខែតុលា ឆ្នាំ១៩៧៧ កងទព័វៀតណាមបានធ្វើការវាយឆ្មក់និងបានវាយបំបែកចូលយ៉ាងជ្រៅក្នុងទឹកដីកម្ពុជា ៖

នៅខេត្តតាកែវ កងទព័វៀតណាមបានទម្លាយចូលដល់ឃុំរមេញ លើសពី១០គីឡូម៉ែត្រពីព្រំប្រទល់កម្ពុជា-វៀតណាម រហូតដល់ទីប្រជុំជនស្រុកកោះអណ្តែត គឺ៣០គីឡូម៉ែត្រពីព្រំដែន និងវាយយកបានទន្លាប់និងគីរីវង្ស ចម្ងាយ៣០គីឡូម៉ែត្រពីព្រំប្រទល់ ។

នៅក្នុងសមរភូមិនេះ កងទព័ឈ្លានពានវៀតណាមត្រូវបានហ៊ុមព័ទ្ធនិងវាយប្រហារយ៉ាងខ្លាំងក្លាពីកងទព័បដិវត្តន៍ និងប្រជាជនកម្ពុជា ។ នៅចុងបញ្ចប់ កងទព័វៀតណាមត្រូវបានទទួលបរាជ័យនិងបានបណ្តេញចេញយ៉ាងអាម៉ាស់ទៅកាន់វៀតណាមវិញ ។ ប៉ុន្តែ យើងចង់សួរទៅកាន់ភាគីវៀតណាមនិងរដ្ឋាភិបាលរបស់ខ្លួនម្តងទៀតថាតើនេះឬដែលភាគីវៀតណាមនិងរដ្ឋាភិបាលរបស់ខ្លួនហៅថា «ជម្លោះព្រំដែនរវាងកម្ពុជានិងវៀតណាម» ជម្លោះដែលពួកនេះក្លែងធ្វើជាសោកស្តាយខ្លាំងណាស់? តើព្រំដែនប្រទេសវៀតណាមនៅឃុំរមេញនៅខេត្តតាកែវឬ? នៅក្នុងទីប្រជុំជនស្រុកកោះអណ្តែតឬ? តើព្រំដែនប្រទេសវៀតណាមនៅស្រុកកំពង់ត្រាចឬ? សូមឲ្យភាគីវៀតណាមនិងរដ្ឋាភិបាលរបស់ខ្លួនផ្តល់ចម្លើយទៅកាន់មតិពិភពលោក ។

ជាមួយនឹងសមរភូមិធំៗទាំងប៉ុន្មាននេះ កងទព័វៀតណាមបានបាញ់គ្រាប់កាំភ្លើងធំម្តងហើយម្តងទៀត ហើយបាញ់កាំភ្លើងយន្តនិងបានចូលលុកលុយក្នុងប្រទេសកម្ពុជា គឺនៅខេត្តមណ្ឌលគីរី រតនគីរីនិងក្រចេះ ។

ទស្សនៈជុំវិញពិភពលោកបានដឹងនូវការពិតច្បាស់រួចទៅហើយ ។ មានការរៀបចំបង្កើតគោលនយោបាយដ៏ច្រើនសម្បើមនិងសកម្មភាពឈ្លានពានជាលក្ខណៈប្រពន្ធ័ផ្សេងៗដែលប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យដែលជារបបដ៏មានឯករាជ្យពេញលេញនិងជាប្រទេសដែលមានអំណាចត្រួតត្រា ។ ហេតុដូច្នេះ វាមិនមែនជា «ជម្លោះព្រំដែន» ដោយសារតែភាគីវៀតណាមនិងរដ្ឋាភិបាលរបស់វៀតណាមចង់បោកប្រាស់ទស្សនៈពិភពលោកដោយប្រើប្រាស់ចរិតពិតប្រាកដនៃភាពមិនស្មោះត្រង់និងការឈ្លានពានរបស់ខ្លួនទេ ។ សកម្មភាពរំលោភឈ្លានពានទាំងអស់នេះពិតជាច្បាស់ត្រឹមត្រូវណាស់ ។ ម្យ៉ាងទៀត កងទព័វៀតណាមមិនត្រឹមតែច្បាំងនិងឈ្លានពានយកទឹកដីប្រទេសកម្ពុជាប៉ុណ្ណោះទេ ។ កងទព័វៀតណាមបានបំផ្លិចបំផ្លាញនូវអំណាចរដ្ឋ សម្លាប់កម្មាភិបាលគ្រប់ជាន់ថ្នាក់ដែលជាមនុស្សរបស់របបកម្ពុជានៅគ្រប់ទីកន្លែងទាំងអស់ដែលពួកនេះបានទៅដល់ ។ ពួកកងទព័ក៏បានកេណ្ឌជនបំផ្លិចបំផ្លាញមួយចំនួនដែលនៅសល់ពីសង្គមចាស់របស់កម្ពុជាដើម្បីតែងតាំងអ្នកទាំងនោះជាថ្នាក់ដឹកនាំភូមិ និងឃុំ ដើម្បីទុកជាឧបករណ៍ដ៏សាហាវសម្រាប់ប្រឆាំងនឹងប្រជាជនកម្ពុជា ។ ប្រជាជនកម្ពុជាដែលស្ថិតនៅក្នុងទីតាំងខាងលើបាននាំគ្នារត់រួចពីកណ្តាប់ដៃកងទព័ឈ្លានពានវៀតណាម បន្ទាប់មកក៏ចាប់ផ្តើមវាយប្រយុទ្ធជិតៗគ្នាជាមួយនឹងកងទព័បដិវត្តន៍កម្ពុជានិងវាយតបប្រឆាំងនឹងពួកសត្រូវវិញ ។ ប៉ុន្តែកងទព័វៀតណាមបានចាប់ខ្លួនមនុស្សមួយចំនួនតូច ហើយបង្ខំនិងឃុំទុកក្នុងកន្លែងខាងផ្នែកយុត្តិសាស្ត្រតូចៗរបស់ខ្លួនដូចដែលពួកចក្រពត្តិនិយមរបស់សហរដ្ឋអាមេរិកធ្លាប់បានធ្វើ ។ តើនេះឬដែលភាគីវៀតណាមនិងរាជរដ្ឋាភិបាលរបស់ខ្លួនហៅថា «ជម្លោះព្រំដែន» ? នេះគឺជាសកម្មភាពដែលធ្វើឡើងដើម្បីផ្តួលរលំអំណាចរបស់ប្រជាជនកម្ពុជា ផ្តួលរលំរដ្ឋអំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យដែលជារដ្ឋអំណាចមួយមានឯករាជ្យភាពពេញលេញ និងប្រទេសដែលមានអំណាចត្រួតត្រា

ត្រឹមត្រូវ ។ តើនេះឬដែលភាគីវៀតណាមហៅថាការគោរពរដ្ឋអំណាចរបបកម្ពុជាប្រជាធិបតេយ្យ? ទោះជាប្រទេសវៀតណាមនិយាយយ៉ាងម៉េចក៏ដោយ នេះគឺចាត់ទុកជាការឈ្លានពានរបស់ប្រទេសវៀតណាមប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យនិងប្រជាជននៅក្នុងរបបនេះ ហើយវាក៏ជាការឈ្លានពានមួយដែលកងទ័ពបដិវត្តន៍និងប្រជាជនកម្ពុជាមិនអាចអាណិតអាសូរបានឡើយទោះក្នុងករណីណាក៏ដោយ ។

ដោយសារចរិតចង់ឈ្លានពាន ពង្រីកទឹកដីនិងវាតទីនិយមភាគីវៀតណាមនិងរដ្ឋាភិបាលរបស់ខ្លួនបានលាក់បាំងនូវភាពមិនស្មោះត្រង់របស់ខ្លួនតាំងពីយូរមកហើយ ។ ប៉ុន្តែឥឡូវនេះ ពួកគេមិនអាចធ្វើបែបនេះបានទៀតឡើយ ។

រឿងរ៉ាវនៃ «ជម្លោះព្រំដែន» នេះ គឺគ្រាន់តែជាលេសដោះសាក្នុងចំណោមការដោះសាជាច្រើនទៀតដែលវៀតណាមបានបង្កើតឡើងដើម្បីធ្វើការរំលោភឈ្លានពាន គំរាមកំហែង ដាក់កម្រិតនិងធ្វើការបង្ខិតបង្ខំមកលើកម្ពុជាដើម្បីឲ្យការយល់ព្រមចុងក្រោយរបស់កម្ពុជាសុខចិត្តចុះចាញ់និងយល់ព្រមអនុវត្តតាមយុត្តិសាស្ត្រឥណ្ឌូចិនរបស់វៀតណាម ។ វៀតណាមបានបង្ខំឲ្យកម្ពុជាចូលរួមក្នុង «សហពន្ធ័ឥណ្ឌូចិន» ដោយធ្វើការគោរពតាមគោលការណ៍របស់ខ្លួនដើម្បីឲ្យខ្លួនអាចចូលនិងលេបយកទឹកដីកម្ពុជាបានយ៉ាងស្រួល ហើយនិងដើម្បីឲ្យខ្លួនក្លាយជាពួកវាតទីនិយមដែលមានអំណាចធំធេងក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ប្រជាជនកម្ពុជាក៏ដូចជាប្រជាជាតិតូចៗទាំងអស់និងប្រជាជននៃប្រទេសតូចៗទាំងឡាយជុំវិញពិភពលោក គឺពិតជាមានឆន្ទៈគោរពនិងឲ្យតម្លៃលើខ្លួនឯងពុះពារការពារនិងមានបំណងចង់រស់នៅក្នុងឯករាជភាព និងអំណាចដ៏ពេញលេញដើម្បីក្តាប់នូវវាសនាជាតិ ការពាររដ្ឋអំណាចនិងបូរណភាពដែនដីរបស់ខ្លួន ។ កាលពីអតីតកាល ប្រជាជាតិនិងប្រជាជនកម្ពុជាបានធ្វើការបរិច្ចាគយ៉ាងច្រើនលើសលប់ក្នុងដំណាក់កាលតស៊ូដើម្បីសេរីភាពរបស់ខ្លួន ។ កងទ័ពបដិវត្តន៍កម្ពុជានិងប្រជាជនកម្ពុជាបានធ្វើការបរិច្ចាគដ៏ធំធេងដើម្បីធ្វើឲ្យខ្លួនគេមានសេរីភាពចេញពីអំណាចដ៏ធំនេះ គឺមិនមែនដើម្បីធ្វើឲ្យពួកគេក្លាយជាទាសករដោយអំណាចមួយផ្សេងទៀតនោះទេ ។

ប៉ុន្តែនេះគឺដើម្បីរស់នៅដោយមានឯករាជ្យនិងរដ្ឋអំណាចដែលស្តែងចេញឲ្យឃើញនូវការគោរពនិងឲ្យតម្លៃចំពោះខ្លួនឯង ។ ដូច្នេះ ក្នុងករណីខ្លះប្រជាជននិងកងទ័ពបដិវត្តន៍កម្ពុជានឹងមិនធ្វើតាមការបញ្ជារបស់វៀតណាមដែលបង្ខំឲ្យកម្ពុជាចូលរួមក្នុង «សហពន្ធ័ឥណ្ឌូចិន» នេះទេ ។ ដោយសារតែហេតុផលនេះហើយទើបបក្សប្រជាជនវៀតណាមនិងរាជរដ្ឋាភិបាលរបស់ខ្លួនបានចងចាំទុកនូវភាពអាក់អន់ចិត្តនេះដើម្បីប្រឆាំងនឹងរបបកម្ពុជាប្រជា-ធិបតេយ្យ រួមទាំងកងទ័ពបដិវត្តន៍និងប្រជាជននៅក្នុងរបបនេះផងដែរ ។ ចំពោះបញ្ហាដទៃទៀតដូចជាបញ្ហាព្រំដែនដែលប្រទេសវៀតណាមនិយាយថា «ជាព្រំដែនមិនបានកំណត់ឲ្យច្បាស់លាស់» នោះ រឿងរ៉ាវទាំងអស់នេះគឺគ្រាន់តែជាលេសដោះសាដែលប្រឌិតឡើងប៉ុណ្ណោះ ។

ដូច្នេះ រវាងរបបកម្ពុជាប្រជាធិបតេយ្យនិងរបបសាធារណរដ្ឋសង្គមនិយមវៀតណាម បញ្ហានេះគឺមិនមែនជាបញ្ហាជម្លោះព្រំដែនធម្មតានោះទេ ប៉ុន្តែវាជាបញ្ហាមួយដែលវៀតណាមមានគោលជំហរធ្វើជាពួកឈ្លានពាន ពួកវាតទីនិយម ពួកប្រឆាំងនឹងដែនដីកម្ពុជា ដើម្បីដាក់កម្ពុជាឲ្យនៅក្រោមឯករាជភាពរបស់ខ្លួនដែលមានចែងក្នុង «សហពន្ធ័ឥណ្ឌូចិន» និងដើម្បីរឹតបន្តឹងឥទ្ធិពលនិងអំណាចរបស់ខ្លួននៅពេលអនាគតក្នុងចំណោមប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ ។

ចំពោះបញ្ហានៃកិច្ចចរចាដែលវៀតណាមធ្វើជាចង់ស្នើសុំនោះ កិច្ចចរចាទាំងនេះអាចធ្វើការកិច្ចប្រជុំបានលុះត្រាតែសេចក្តីជឿជាក់រវាងគ្នាត្រូវបានបង្កើតជាមុនសិន ហើយនោះគឺជាពេលដែលវៀតណាមឈប់ធ្វើការឈ្លានពានមកលើកម្ពុជា ដកកងទ័ពរបស់ខ្លួនចេញពីទឹកដីកម្ពុជា ឈប់អនុវត្តនូវគម្រោងការមិនស្មោះត្រង់របស់ខ្លួនដើម្បីបង្ខំឲ្យកម្ពុជាចូលរួមក្នុង «សហពន្ធ័ឥណ្ឌូចិន» ។ ប្រសិនបើវៀតណាមមិនព្រមដកកងទ័ពរបស់ខ្លួនចេញពីទឹកដីកដ៏ស័ក្តិសិទ្ធរបស់កម្ពុជាទេ នោះកងទ័ពបដិវត្តន៍កម្ពុជាមានតែជ្រើសប្រើផ្លូវតែមួយគត់ គឺកម្ចាត់សត្រូវវៀតណាមដែលបានចូលមកលេបយកទឹកដីកម្ពុជាចោលទាំងអស់គ្មានឲ្យនៅសល់ម្នាក់ឡើយ ។ នេះជាសិទ្ធិពេញលេញរបស់កងទ័ពបដិវត្តន៍កម្ពុជានិងប្រជាជនកម្ពុជាទាំងអស់ ។ ភ្នំពេញ, ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៨

**ឯកសារ D២៩០៨៦**

# ថ្ងៃ១៧ មេសា : ការឆ្លុះបញ្ចាំងដោយសង្ខេបទៅលើ ទីក្រុងភ្នំពេញ កាលពីមុននិងបច្ចុប្បន្ន

ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ កំណត់ពីការចាប់ផ្តើមរបបកាប់សម្លាប់យ៉ាងសាហាវបំផុតនៅប្រទេសកម្ពុជា ។ នោះគឺជាថ្ងៃដែលខ្មែរក្រហមឡើងកាន់អំណាច ហើយក៏ជាថ្ងៃកាប់សម្លាប់បានចាប់ផ្តើមឡើងដែរ ។ នៅក្នុងទីក្រុងភ្នំពេញ អ្នករស់នៅទីក្រុងត្រូវបានបង្ខំឲ្យចាកចេញពីលំនៅស្ថានរបស់ខ្លួន ហើយត្រូវបានដកហូតនូវសិទ្ធិជាមូលដ្ឋាន សិទ្ធិ និងភាពជាកម្មសិទ្ធិផ្សេងទៀត ។ អ្នកទីក្រុងទាំងនោះត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅក្នុងវាលស្រែនិងការដ្ឋាននៅទីជនបទ ។ ដោយសារត្រូវបានចាត់ទុកជាបរ៉ាសិត អ្នកទីក្រុងត្រូវបានរើសអើងនិងដៅសម្រាប់ការប្រហារជីវិត ជាពិសេសអ្នកដែលពាក់ព័ន្ធនឹងអតីតរដ្ឋាភិបាលលន់នល់និងអ្នកដែលមានការអប់រំ ។ នៅពេលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ អ្នកទីក្រុងមានត្រឹមតែមួយចំនួនតូចប៉ុណ្ណោះក្នុងចំណោមអ្នកទីក្រុងប្រហែល ១លាននាក់ បានរស់រានមានជីវិត ហើយវិលត្រឡប់មកកាន់លំនៅស្ថានរបស់ខ្លួនវិញ ។ ទីក្រុងភ្នំពេញកាលពីមុនត្រូវបានពិពណ៌នាថាជា «ទីក្រុងខ្មោច» ។

ថ្ងៃ១៧ ខែមេសា ឆ្នាំ២០០៩ ទីក្រុងភ្នំពេញជាទីក្រុងមួយដែលខុសឆ្ងាយពីមុន ជាមួយនឹងផ្លូវក្រាលកៅស៊ូ អគារខ្ពស់ៗ ភោជនីយដ្ឋាន និងធនាគារពាសពេញទីក្រុង ។ ភ្នំពេញមានការរីកចម្រើនយ៉ាងសម្បើម ហើយមានស្ថិរភាពនយោបាយអស់រយៈកាល៣-៤ឆ្នាំមុននេះ ទោះបីជាខណៈពេលដែលប្រទេសថៃដែលធ្លាប់ជាប្រទេសជិតខាងមានឥទ្ធិពលនិងស្ថិរភាពបានធ្លាក់ចូលទៅក្នុងអស្ថិរភាពនយោបាយមិនចេះដាច់ក៏ដោយ ។ ចំនួនប្រជាជនរស់នៅទីក្រុងភ្នំពេញកើតឡើងរហូតដល់ជិត២លាននាក់ ដែលប្រជាជនភាគច្រើនគឺជាអ្នកដែលមកពីតាមខេត្តមករស់នៅទីក្រុង ។ ដូច្នេះហើយ ក្នុងអំឡុងពេលរដូវបុណ្យទាន ដូចជាចូលឆ្នាំខ្មែរ នៅពេលដែលប្រជាជនវិលត្រឡប់ទៅកាន់ស្រុកកំណើតវិញ ទីក្រុងភ្នំពេញក្លាយជាទីក្រុងដែលត្រូវបានបោះបង់ទៀត ។

ខែមេសា ឆ្នាំ២០០៩ ក៏កត់សម្គាល់នូវចំណុចរបត់មួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាផងដែរ ។ និទ្ទណ្ឌភាពដែលអតីតមេដឹកនាំនៃរបបខ្មែរក្រហមធ្លាប់តែទទួលបានជាយូរមកហើយត្រូវបានបញ្ចប់ ។ ឌុច អតីតប្រធានមន្ទីរ ស-២១ បច្ចុប្បន្នកំពុងត្រូវបានកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលគាត់បានឆ្លើយសារភាព ចំពោះការទទួលខុសត្រូវ រួមមានការសម្លាប់និងធ្វើទារុណកម្មមនុស្សជាង១២ពាន់នាក់ដែលរបបនោះចាត់ទុកថា «ជាសត្រូវ» ។ អតីតមេដឹកនាំខ្មែរក្រហមដទៃទៀតក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាលាក្តីខ្មែរក្រហមដែលកំពុងរង់ចាំការចោទប្រកាន់និងសវនាការដែរ ។ **ឌី ឆេរិទ្ធិ**



ភ្នំពេញក្នុងឆ្នាំ១៩៧៥

# អត្ថន័យពីរយ៉ាងនៃថ្ងៃ១៧មេសា តាមរយៈសម័យកាលកន្លងផុតទៅ

ថ្ងៃបុណ្យចូលឆ្នាំប្រពៃណីខ្មែរ គឺជាថ្ងៃមួយដ៏ប្រសើរបំផុត និងអាក្រក់បំផុតនៅក្នុងជីវិតរបស់ប្រជាជនកម្ពុជា ។ កាលបរិច្ឆេទនៃថ្ងៃ១៧មេសា ជាថ្ងៃមួយដែលប្លែកខុសពីថ្ងៃធម្មតា ពីព្រោះវាបានកត់ត្រានូវប្រវត្តិសាស្ត្រពីរខុសប្លែកគ្នាទាំងស្រុង គឺថ្ងៃចុងក្រោយនៃបុណ្យចូលឆ្នាំខ្មែរ និងថ្ងៃចាប់ផ្តើមនៃរបបខ្មែរក្រហម ។ អត្ថន័យពីរយ៉ាងនៃថ្ងៃ១៧មេសា គឺប្រជាជនខ្មែរគ្រប់រូបសុទ្ធតែបានឆ្លងកាត់ដើម្បីធ្វើការផ្លាស់ប្តូរកម្រិតនៃការយល់ដឹង បទពិសោធន៍ និងអារម្មណ៍ដែលចែកចេញជាពីរ ជាពិសេសរូបភាពនៃការសប្បាយរីករាយដែលបានមកពីការជួបជុំគ្នានៅក្នុងវត្តអារាម និងគេហដ្ឋានរបស់សាច់ញាតិ បងប្អូន ដែលនេះខុសគ្នាទាំងស្រុងទៅនឹងរូបភាពនៃការជម្លៀសប្រជាជនចេញពីទីក្រុងដោយប្រើកាណុងកាំភ្លើង ។ ដោយសារតែការអត្ថន័យពីរយ៉ាងនេះហើយ ទើបទីក្រុងភ្នំពេញបានក្លាយជាអត្ថន័យមួយដែលពិបាកនឹងពិពណ៌នា និងជាការចងចាំមួយដែលពិបាកនឹងកែប្រែបាននូវពេលវេលាមួយដែលពោរពេញទៅដោយការភ័យរន្ធត់ ការសប្បាយនិងភាពឃោរឃៅ ការស្លាប់និងការរស់ ។ ចំពោះអ្នកដែលរស់នៅកន្លែងនោះ ថ្ងៃ១៧មេសា គឺជាអត្ថន័យពីរយ៉ាងដែលពួកគាត់ត្រូវតែប្រឈមមុខនិងធ្វើការផ្សះផ្សា ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះ វាច្រើនជាងអ្វីដែលធ្លាប់មានពីមុនមក ពីព្រោះភាពខ្មៅងងឹតនៃថ្ងៃ១៧មេសា ត្រូវបានដកចេញពីក្នុងចិត្តរបស់ប្រជាជាតិតាមរយៈការរកយុត្តិធម៌តាមផ្លូវច្បាប់ និងសៀវភៅសិក្សានៅសាលារដ្ឋ ។ ព្រឹត្តិការណ៍ដែលខុសស្រឡះទាំងពីរនេះផ្តល់នូវអត្ថន័យដល់ថ្ងៃ១៧មេសាឲ្យកាន់តែជ្រួតជ្រាបនិងមានសារសំខាន់ថែមទៀត ។

ដើម្បីធ្វើការបង្ហាញនិងបញ្ជាក់អត្ថន័យពីរយ៉ាងនេះ ជាដំបូងអនុញ្ញាតឲ្យយើងធ្វើការលើកយកអំពីកុមារភាព ដែលប្រហែលជាបទពិសោធន៍ដែលស្អាតស្អំនិងមានឧត្តមគតិនៅក្នុងឆាកជីវិតមនុស្ស ។ ជាមធ្យមចំពោះកុមារដែលធំធាត់នៅក្នុងទីក្រុងភ្នំពេញនៅពាក់កណ្តាលទសវត្សរ៍៦០ គឺមានជីវភាពរស់នៅល្អដោយមានសុវត្ថិភាពនិងធ្វើតាមតែទម្លាប់របស់ខ្លួនដដែលៗ ។ ថ្ងៃ១៧មេសាជាពេលវេលាឈប់សម្រាកពីសាលារៀនដែលមានរយៈពេលប្រហែលជាបីសប្តាហ៍ ។ ដូច្នេះចំពោះសិស្សសាលា ការរៀបចំនិងការប្រារព្ធពិធីបុណ្យចូលឆ្នាំគឺចាប់ផ្តើមមួយសប្តាហ៍មុន ហើយបញ្ចប់នៅសប្តាហ៍ បន្ទាប់នៃថ្ងៃឈប់សម្រាករយៈពេលបីថ្ងៃដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ។ ជាធម្មតា ទោះបីជាថ្នាក់រៀនខ្លះមិនបានរៀនតាំងពីដើមខែមេសាក៏ដោយ ក៏សិស្សានុសិស្សនៅតែទៅសាលានៅក្នុងសប្តាហ៍ទីមួយនៃខែមេសាដែរ ដើម្បីធ្វើការសម្អាត និងតុបតែងថ្នាក់រៀនខណៈពេលដែលលោកគ្រូ-អ្នកគ្រូហៅមកប្រជុំ ។ នៅថ្ងៃបន្ទាប់ពីការតុបតែងរួច ពិធីជប់លៀងអបអរសាទរមុនចូលឆ្នាំក៏ត្រូវបានប្រារព្ធឡើងនៅក្នុងសាលារៀន ។

ចំពោះផ្នែកនៃការរៀបចំពិធីវិញក៏មានការដើរទិញគ្រឿងផ្សំផងដែរ ។ នេះជារឿងធម្មតាសម្រាប់កូនសិស្សក្នុងការទៅផ្សារទិញម្ហូបក្រោយពីចេញពីសាលាក្នុងសម្លៀកបំពាក់ឯកសណ្ឋានសិស្ស ហើយមិនត្រូវបាននរណាគ្រប់គ្រង ។ កាលណោះទីក្រុងទាំងមូលគឺស្ថិតក្នុងសន្តិភាព ហើយឪពុកម្តាយអនុញ្ញាតឲ្យកូនរបស់ខ្លួនដើរចេញពីផ្ទះទៅសាលារៀនជាមួយមិត្តភក្តិរបស់គេឬក៏ដើរតែម្នាក់ឯង ។ នៅមុនថ្ងៃអបអរសាទរពិធីបុណ្យចូលឆ្នាំ អ្នកនឹងអាចឃើញសិស្សានុសិស្សជាច្រើនកំពុងតែជ្រើសរើសនិងតថ្លៃផ្លែឈើ បន្លែ និងសាច់នៅមុខផ្សារអូឡាំពិក ។

នៅពេលព្រឹកព្រលឹមថ្ងៃបន្ទាប់ មិត្តរួមថ្នាក់ទាំងអស់បាននាំគ្នាប្រមូលផ្តុំនៅផ្ទះរបស់សិស្សម្នាក់ដើម្បីធ្វើម្ហូបក្រៀមក្រោះប៉ុន្មានមុខ ។ នេះមិនមែនជារឿងធម្មតាទេ ពីព្រោះក្នុងមួយថ្នាក់អាចមានសិស្សចាប់ពី៣០ទៅ៤០នាក់ ។ ចំពោះសិស្សានុសិស្សទាំងនេះគឺតែងតែរួមសហការគ្នានៅក្នុងផ្ទះបាយ ដែលមានការជួយជ្រោមជ្រែងពីម្តាយរបស់ម្ចាស់ផ្ទះ ដោយគាត់បានចាត់តាំងឲ្យមានអ្នកហាន់ អ្នកលាង និងអ្នកកូរ ។ ការខិតខំប្រឹងប្រែងជួយគ្នានាពេលព្រឹកនោះគឺបានធ្វើចេញនូវម្ហូបឈ្ងុយឆ្ងាញ់ជាច្រើនមុខដូចជាសម្លការីសាច់មាន់ជាមួយនំបុ័ងបារាំង និងបង្អែមខ្ទប់ស្លឹកចេក ។

ម្ហូបទាំងនោះត្រូវបានសិស្សយកទៅញាំនៅទីលានសាលា ។

ចំណែកថ្នាក់រៀនដែលទើបតែតុបតែងរួចរាល់នោះ សិស្សានុសិស្សបានរីករាយនឹងលទ្ធផលនៃវិជ្ជាធ្វើម្ហូបរបស់គេ ។ ការទទួលទានអាហារនិងការនិយាយរឿងកំប្លែងមិនមែនជាអ្វីតែមួយគត់ក្នុងកម្មវិធីជប់លៀងនោះទេ គឺរួមមានទាំងការច្រៀងនិងរាំកម្សាន្តទៀតផង ។ ចំពោះក្រុមក្មេងផ្សាយបន្តផ្ទាល់វិញគឺមានប្រគំតន្ត្រីសម័យរបស់លោក ស៊ិន ស៊ីសាមុត និង រស់ សេរីសុទ្ធា ដែលជាញឹកញាប់ថវិកាដែលចំណាយនេះប្រមូលបានពីថ្នាក់ខ្ពស់ៗ ។ នាពេលថ្ងៃត្រង់ កូនសិស្សនាំគ្នាត្រឡប់ទៅផ្ទះវិញដើម្បីចាប់ផ្តើមវិស្សមកាលរយៈពេលបីថ្ងៃរបស់ពួកគេ ។

ក្នុងឱកាសថ្ងៃបុណ្យចូលឆ្នាំខ្មែរនៅទីក្រុងភ្នំពេញ ការរាំដើបរំជួល និងសេចក្តីសប្បាយរីករាយកើតមានគ្រប់ទីកន្លែងទាំងអស់ដូចជាលើផ្លូវក្នុងទីវត្តអារាម មុខព្រះបរមរាជវាំង និងគេហដ្ឋាន ។ ឪពុកម្តាយនាំកូនរបស់ខ្លួនទៅបួងសួងនៅវត្តអារាមនិងទៅសួរសុខទុក្ខបងប្អូនញាតិសន្តានទៀតផង ។ ចំណែកឯកូនៗវិញក៏នាំគ្នាទៅលេងមិត្តភក្តិរបស់ខ្លួនដែលនៅជិតៗនោះ ហើយក៏នាំគ្នាលេងល្បែងប្រជាប្រិយដូចជា បោះអង្គុញ ចោលឈូង និងលាក់កន្សែងដែរ ។ ការប្រារព្ធពិធីនេះមានរហូតដល់ថ្ងៃ១៧ តែក៏អាចបន្តរហូតដល់ចុងខែមេសាផងដែរ ។ ចំពោះសិស្សដែលខស្សហ៍ព្យាយាមគឺចេះលៃលកពេលមើលសៀវភៅក្នុងអំឡុងពេលឈប់សម្រាកនេះ តែសិស្សខ្លះទៀតគឺរីករាយនឹងថ្ងៃឈប់សម្រាកនេះខ្លាំងណាស់ដោយទៅមើលកុនជាញឹកញាប់ជាជាងការមើលសៀវភៅ ។

នេះជាអ្វីដែលអ្នកទីក្រុងភ្នំពេញនឹកឃើញកាលពីកុមារភាពរបស់ពួកគាត់នៅអំឡុងថ្ងៃបុណ្យចូលឆ្នាំខ្មែរក្នុងទសវត្សរ៍៦០ ដែលឥឡូវនេះពួកគាត់មានអាយុប្រហែលជា៥០-៦០ឆ្នាំទៅហើយ ។ ជាការពិតណាស់ ទោះបីជាការចងចាំទាំងនេះមានលក្ខណៈបំផ្លើសបន្តិចក៏ដោយ តែកម្រិតនៃភាពខុសគ្នារវាងពាក់កណ្តាលទសវត្សរ៍៦០ និងឆ្នាំ១៩៧៥ពិតជាខុសគ្នាខ្លាំងណាស់ដែលនឹងមិនអាចបំផ្លើសនោះទេ ។ ក្រោយពីឆ្នាំ១៩៧៥មក ថ្ងៃ១៧មេសាគឺលែងក្លាយជាថ្ងៃមួយដែលគ្រាន់តែសម្រាប់ប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរនិងថ្ងៃវិស្សមកាលទៀតហើយ ។

នៅក្នុងខែនៃការឈានចូលមកដល់នៃការគ្រប់គ្រងរបស់ខ្មែរក្រហមក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញមើលទៅមានសភាពទទេស្អាត មិនដូចអ្វីដែលធ្លាប់មាននៅទសវត្សរ៍៦០នោះទេ ។ រដ្ឋប្រហារ សង្គ្រាមស៊ីវិល ការទម្លាក់គ្រាប់បែករបស់អាមេរិក ការជម្លៀសអ្នកភូមិចេញយ៉ាងច្រើនកុះករ គឺបានផ្លាស់ប្តូរទិដ្ឋភាពនៃទីក្រុងភ្នំពេញ ។ ទីក្រុងទាំងមូលមិនមានសុវត្ថិភាពទៀតទេ ដោយសារតែទាហានខ្មែរក្រហមផ្ទុះអាវុធជាមួយកងទ័ពលន់ នល់ ដែលបន្ទីនូវគ្រាប់កាំភ្លើង គ្រាប់រ៉ុក្កែត និងកាំភ្លើងត្បាល់ជាច្រើន ។ ឪពុកម្តាយខ្លះបានខំខ្នប់ខ្ទឹមឲ្យកូនរបស់ពួកគេយកទៅសាលារៀន ព្រោះពួកគាត់ជឿជាក់ថា ក្លិនខ្ទឹមនឹងអាចជួយបន្សាបខស្ម័នពុលដែលចេញពីផ្សែងកាំភ្លើង ។ តែក៏មានឪពុកម្តាយខ្លះទៀតហាមប្រាមកូនក្នុងការទៅសាលារៀនដែរ ។

ប្រជាជនទាំងអស់នៅក្នុងទីក្រុងសុទ្ធតែដឹងថា កាលដែលសម្ងំស្ងៀមនៅផ្ទះគឺជាជម្រើសមួយដ៏មានសុវត្ថិភាពជាទីបំផុតសម្រាប់កូនៗរបស់គាត់ ។ ទិដ្ឋភាពនៃរោងភាពយន្តដែលត្រូវបានបំផ្លាញដោយគ្រាប់កាំភ្លើងត្បាល់បានដុតសម្លាប់អ្នកដែលជាប់នៅខាងក្នុងរោងភាពយន្តនោះ បូកផ្សំនឹងទិដ្ឋភាពនៅតាមដងវិថីដែលពោរពេញទៅដោយលំនៅឋានបណ្តោះអាសន្នដែលមានសុទ្ធតែជនភៀសខ្លួន ។ បរិយាកាសដែលសប្បាយអ៊ូអរ និងរស់រវើកនៃថ្ងៃបុណ្យចូលឆ្នាំខ្មែរបានកន្លងផុតអស់ ។ តែក៏មានប្រជាជនខ្លះដែលមានសេចក្តីក្លាហានមិនអៀនប្រៀនបិទបាំងក្នុងការព្យាយាមប្រារព្ធពិធីដូចកាលពីមុនទេ ។ គ្រាន់តែកន្លងផុតថ្ងៃបុណ្យចូលឆ្នាំខ្មែរបានតែបន្តិច កងទ័ពខ្មែរក្រហមដែលទទួលបានជ័យជម្នះនោះក៏បានបង្ខំប្រជាជនឲ្យជម្លៀសចេញពីទីក្រុងភ្នំពេញទាំងអស់ ។ ម្យ៉ាងវិញទៀត មានទាហានខ្មែរក្រហមខ្លះគំរាមកំហែងថានឹងបាញ់សម្លាប់ចោល ប្រសិនបើអ្នកទាំងនោះមិនព្រមចាកចេញពីផ្ទះរបស់ខ្លួន ។ ការគំរាមកំហែងនេះមានខ្លះពិតជាកើតឡើងមែន ។ យ៉ាងណាមិញ អ្វីដែលកើតឡើងក្រោយរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ គឺថារបបកម្ពុជាប្រជាធិបតេយ្យអាចត្រូវបានដាក់ងារថាជារដ្ឋាភិបាលដែលសាហាវឃោរឃៅនិងចម្លែកជាទីបំផុតនៅក្នុងសកលលោកនេះ ។

៣០ឆ្នាំក្រោយបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ការប្រារព្ធពិធីចូលឆ្នាំខ្មែរប្រពៃណីជាតិនៅទីក្រុងភ្នំពេញ ទោះបីជា



មានសភាពអ៊ូអរសប្បាយរីករាយក៏ដោយ ក៏វាមានសភាពមិនដូចគ្នាទៅនឹងទសវត្សរ៍៦០ដែរ ។ នៅតាមផ្លូវនៃទីក្រុងភ្នំពេញគឺលែងមានសុវត្ថិភាពដូចកាលពីមុនទៀតហើយ ។ ឪពុកម្តាយដែលមានទ្រព្យសម្បត្តិពុំសូវអនុញ្ញាតឲ្យកូនៗរបស់ខ្លួនចេញទៅខាងក្រៅដោយគ្មានអ្នកបើកបរឲ្យ ឬក៏អង្គរក្សនោះទេ ។ សាលាមិនអនុញ្ញាតឲ្យសិស្សឈប់សម្រាកបីសប្តាហ៍ដូចកាលពីទសវត្សរ៍៦០នោះឡើយ គឺបានត្រឹមតែប៉ុន្មានថ្ងៃនៃបុណ្យចូលឆ្នាំប៉ុណ្ណោះ ។ ដោយសារតែអ្នកទីក្រុងភាគច្រើន ត្រូវបានសម្លាប់នៅក្នុងសម័យខ្មែរក្រហម ទើបធ្វើឲ្យចំនួនប្រជាជនថ្មីនៅក្នុងទីក្រុង ក្រោយឆ្នាំ១៩៧៩ ភាគច្រើនមានសុទ្ធតែប្រជាជនស្រុកស្រែចម្ការដែលធ្វើចំណាកស្រុកមកទីក្រុង ហើយក៏តាំងទីលំនៅតែម្តង ។ អាស្រ័យហេតុនេះហើយ ទើបធ្វើឲ្យអំឡុងថ្ងៃបុណ្យចូលឆ្នាំខ្មែរ ប្រជាជនថ្មីទាំងនោះនាំកូនចៅរបស់ខ្លួនត្រឡប់ទៅកាន់ភូមិស្រុកកំណើតនៅតាមទីជនបទវិញ ។ ប្រជាជនទាំងនោះនាំគ្នាធ្វើដំណើរទៅកាន់ស្រុកកំណើតក្នុងចំនួនមួយដ៏ច្រើនបំផុត ដែលធ្វើឲ្យចំនួនប្រជាជននៅទីក្រុងភ្នំពេញមើលទៅហាក់ដូចជាថយចុះអស់ពាក់កណ្តាលអ៊ីចឹងនៅក្នុងអំឡុងពេលដ៏ខ្លីនេះ ។

ជាពិសេសនោះគឺថា មានកូនក្មេងជាច្រើននៅតែមិនដឹងឬមិនអើពើនឹងរបបខ្មែរក្រហមនោះទេ ដែលជាហេតុធ្វើឲ្យពួកគេមិនអាចយល់ និងជឿជាក់ទៅលើវិសាលភាពនៃការបំផ្លិចបំផ្លាញនិងការសម្លាប់ដែលបង្កឡើងដោយខ្មែរក្រហម ។ ចំណែកក្មេងៗដែលមានឪពុកម្តាយធ្លាប់ធ្វើជាអតីតខ្មែរក្រហមបានស្តាប់ព្រឹត្តិការណ៍ផ្សេងៗគ្នាដែលកើតឡើងបន្តបន្ទាប់ថ្ងៃទី១៧ មេសា ១៩៧៥ ។

គម្រោងផែនការអប់រំដែលអនុញ្ញាតដោយរដ្ឋាភិបាលជាតិឥឡូវនេះកំពុងតែចាប់ផ្តើម ដើម្បីធ្វើការផ្លាស់ប្តូរចំណុចទាំងនេះ ។ ការដាក់បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យទូទាំងប្រទេសនៅថ្ងៃខាងមុខនេះនឹងធ្វើឲ្យសិស្សានុសិស្សទាំងឡាយអាចយល់ច្បាស់ពីភាពសាហាវយោរយៅដែលកើតឡើងនៅក្នុងប្រទេសរបស់ខ្លួន ។ ជាពិសេសសិស្សានុសិស្សនឹងស្គាល់ច្បាស់ពីសារសំខាន់នៃថ្ងៃ១៧មេសាថាមិនមែនត្រឹមតែជាថ្ងៃប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីនោះទេ ប៉ុន្តែក៏ជាថ្ងៃមួយនៅក្នុងឆ្នាំដ៏ខ្មៅងងឹតបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាដែរ ។ គេអាចនឹងយល់ឃើញថា ទន្ទឹមនឹងពេលចូលឆ្នាំថ្មីដែលនាំមកនូវឱកាសថ្មីសម្រាប់ការរីកចម្រើននិងការផ្លាស់ប្តូរ យើងគួរតែរំឭកទៅដល់អតីតកាលផងដែរ ។ បើសិនបើទាំងកូននិងឪពុកម្តាយអាចប្រឈមមុខទៅនឹងអត្ថន័យពីរយ៉ាងនេះជាមួយគ្នាបាន នោះសោកនាដកម្មនៅក្នុងប្រទេសកម្ពុជានឹងអាចចៀសវាងបាននៅក្នុងពេលអនាគត ។

**កែវ ដាស៊ីល**

# ការចូលរួមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយពិព័រណ៌យុវជននៅខេត្តបាត់ដំបង

នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបញ្ជូនបុគ្គលិកចំនួន៥នាក់ ទៅចូលរួមពិព័រណ៌យុវជនលើកទី៧ ដែលប្រារព្ធធ្វើនៅសួនច្បារនាគបាញ់ទឹក ខេត្តបាត់ដំបង ។ ការតាំងពិព័រណ៌នេះរៀបចំដោយក្រុមប្រឹក្សាយុវជនកម្ពុជានិងវិទ្យាស្ថានសាធារណៈអន្តរជាតិ ។ នៅវេលាម៉ោង៤រសៀលថ្ងៃដដែល ក្រុមពិព័រណ៌បានទៅពិនិត្យមើលស្តង់ពិព័រណ៌របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់ឲ្យ ប៉ុន្តែដោយសារការរៀបចំមានការយឺតយ៉ាវ ធ្វើឲ្យយើងមានលំបាកក្នុងការកំណត់ទីតាំងនិងរចនាស្តង់ឲ្យបានទាន់ពេលវេលា ។

នៅវេលាម៉ោង៨ព្រឹកថ្ងៃបន្ទាប់ ក្រុមពិព័រណ៌បានទៅពិនិត្យមើលស្តង់ម្តងទៀត ប៉ុន្តែការរៀបចំនៅមិនទាន់រួចរាល់ដដែល ។ ក្រុមពិព័រណ៌ត្រូវរង់ចាំរហូតដល់ម៉ោង៥រសៀល ទើបការរៀបចំស្តង់បានកំណត់រួចរាល់ ។ យើងទទួលបានស្តង់ពិព័រណ៌ដែលមានបណ្តោយ៤ម៉ែត្រ និងទទឹង៣ម៉ែត្រ ព្រមទាំងមានទីតាំងក្នុងសួនច្បារនាគបាញ់ទឹកបែរមុខទៅរកស្ទឹងសង្កែ ដែលនៅខាងឆ្វេងជាប់នឹងស្តង់ពិព័រណ៌របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម និងខាងស្តាំជាប់នឹងសមាគមយុវជនខ្មែរ ។ ក្រុមពិព័រណ៌បានរៀបចំតុបតែងលម្អអំពូលភ្លើង និងចងព្យួរបដា ដែលសរសេរជាអក្សរធំៗថា មជ្ឈមណ្ឌលឯកសារកម្ពុជា, ស្វែងរកការពិត, យុត្តិធម៌និងការចងចាំ ។ ការងាររៀបចំនេះបានប្រព្រឹត្តទៅរហូតដល់ម៉ោង៨:៣០នាទីយប់ទើបចប់សព្វគ្រប់ ។ ស្តង់ពិព័រណ៌របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានលក្ខណៈខុសប្លែកពីស្តង់ពិព័រណ៌ដទៃទៀត ដោយមានការរៀបចំលម្អដោយពណ៌ចម្រុះនិងផ្កាភ្ញីដែលធ្វើឲ្យមានការទាក់ទាញអារម្មណ៍ភ្ញៀវជាច្រើនមកឈរទស្សនា ។

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង៩ព្រឹក កម្មវិធីក៏បានចាប់ផ្តើមបើកសម្ពោធដោយមានការចូលរួមពីគណៈអធិបតីលោកអភិបាលរងខេត្តបាត់ដំបង, តំណាងអង្គការ សមាគម និងក្រុមហ៊ុនឯកជននានា ។ បន្ទាប់ពីថ្លែងសុន្ទរកថាចប់ គណៈប្រតិភូបានដើរសាកសួរនិងទស្សនាសកម្មភាពនៃការតាំងពិព័រណ៌នៅតាមបណ្តាស្តង់នីមួយៗ ។ ក្រោយមក មានពិធីរាប់បាត្រព្រះសង្ឃចំនួនប្រមាណ១០០អង្គ ដែលនិមន្តមកពីវត្តនានាក្នុងខេត្តបាត់ដំបង បាននិមន្តមកប្រោះព្រំដល់ក្រុមការងារទាំងអស់ដើម្បីសុំសេចក្តីសុខចម្រើននិងឲ្យដំណើរការកម្មវិធីប្រព្រឹត្តទៅយ៉ាងរលូន ។ នៅក្នុងថ្ងៃដដែល មានអង្គការ សមាគមនិងក្រុមហ៊ុនឯកជនដូចជា ក្រុមហ៊ុនបណ្តាញទូរស័ព្ទចល័តម៉ូប៊ីតែល និងធនាគារអេអុិនហ្សិត រ៉ូយ៉ាល់ បានបង្ហាញពីសកម្មភាពការងារ ។ ក្រៅពីនេះគឺមានកម្មវិធីផ្សេងៗទៀតដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់ភ្ញៀវឲ្យចូលមកទស្សនា ដូចជាមានសិក្ខាសាលា ការពិភាក្សាដេញដោល ការអប់រំពីសិទ្ធិក្នុងការចូលរួមបោះឆ្នោត និងការប្រគំតន្ត្រីកម្សាន្តនៅពេលរាត្រី ដោយមានការចូលរួមពីសិស្សដែលបានចុះឈ្មោះប្រលងចម្រៀងប្រមាណ១៥០នាក់ និងក្រុមតារាសម្តែងល្បីៗមកពីទីក្រុងភ្នំពេញ ។ ជាមួយគ្នានេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានដាក់តាំងសៀវភៅជាច្រើនក្បាលដូចជា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដំណើរឆ្ពោះទៅរកសេរីភាព សត្រូវបងប្អូនឯង ឋាននរកកម្ពុជាប្រជាធិបតេយ្យ នៅពេលសង្គ្រាមផុតរលត់ទៅ និងសៀវភៅជា



ស្តង់ពិព័រណ៌របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ភាសាអង់គ្លេសជាច្រើនក្បាលទៀត ព្រមទាំងមានកម្មវិធីចែកជូនទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរឆ្នាំ២០០៨ គ្រប់លេខដោយឥតគិតថ្លៃ ។ នៅក្រោមកម្ដៅថ្ងៃក្ដៅចាំងចែងមានភ្ញៀវជាច្រើនដូចជាសិស្ស និស្សិត ព្រះសង្ឃ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធបានចូលមកអានសៀវភៅ និងសាកសួរព័ត៌មានផ្សេងៗទាក់ទងទៅនឹងរឿងរ៉ាវនៅសម័យខ្មែរក្រហម តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងសកម្មភាពការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឆោម សុភាព អាយុ១១ឆ្នាំ បានមកអានសៀវភៅប្រាប់ថា «ខ្ញុំចង់ដឹងពីរបបខ្មែរក្រហម ហើយខ្ញុំចង់បានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» និង «ប្រសិនបើពាក្យណាដែលខ្ញុំអានមិនរួច ខ្ញុំនឹងយកសៀវភៅនេះទៅឲ្យបងប្រុសរបស់ខ្ញុំអានឲ្យស្ដាប់» ។ វ៉ែន សារឿន អាយុ១៩ឆ្នាំ ជាសិស្សថ្នាក់ទី៩នៃវិទ្យាល័យស្ទឹងបានប្រាប់ថា «សៀវភៅទស្សនាវដ្ដីនិងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងផ្ដល់ចំណេះដឹងយ៉ាងច្រើនពីរបបខ្មែរក្រហមដល់ខ្ញុំ» ។ នៅពេលរសៀលថ្ងៃដដែលមានភ្ញៀវជាច្រើននៅតែបន្តចូលមកអានសៀវភៅរហូតដល់ម៉ោង៦ល្ងាច នៅខណៈពេលដែលមានមនុស្សកកស្ទះចូលមកទស្សនាការប្រគំតន្ត្រី ទើបក្រុមពិព័រណ៍បិទស្តង់សៀវភៅ ។

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៩ ជាថ្ងៃបញ្ចប់នៃការដាក់តាំងពិព័រណ៍ ។ នៅវេលាម៉ោង៨:៣០នាទីព្រឹក ក្រុមពិព័រណ៍បានបើកស្ដង់សៀវភៅម្ដងទៀត ដែលមានភ្ញៀវច្រើនជាងថ្ងៃទីមួយបានចូលមកអានសៀវភៅ និងខ្លះទៀតស្នើសុំសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ព្រះតេជគុណ ធឿន ថេង ព្រះជន្ម ២២វស្សា មានពុទ្ធដីកាថា «អាត្មាមិនជឿថា ខ្មែរក្រហមបានបង្ខំឲ្យធ្វើការជាទម្ងន់ បង្អត់អាហារនិងកាប់សម្លាប់មនុស្សទេ» ។ ដូច្នេះ «អាត្មាចង់បានឯកសារដែលទាក់ទងនឹងរបបខ្មែរក្រហមដើម្បីយកទៅអាននិងស្វែងយល់ថែមទៀត» ។ សួន សោភា ជានិស្សិតឆ្នាំទី១នៃសកលវិទ្យាល័យបាត់ដំបង




បានប្រាប់ថា «យើងជាកូនខ្មែរត្រូវតែសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្ររបស់ខ្មែរថា ហេតុអ្វីបានជាមានការកាប់សម្លាប់យ៉ាងរង្គាលបែបនេះ ហើយយើងត្រូវកែប្រែអំពើសាហាវទាំងនេះទៅជាការអប់រំសម្រាប់ក្មេងជំនាន់ក្រោយវិញ» ។ នៅថ្ងៃរសៀល មានភ្ញៀវជាច្រើននាក់បានចូលមកអានសៀវភៅ ហើយក្រុមពិព័រណ៍ក៏បានចែកជូនសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាច្រើនក្បាលទៅឲ្យសិស្ស និស្សិត និងមន្ត្រីរាជការដែលចង់អាន ចង់ស្វែងយល់ និងស្រាវជ្រាវពីរបបខ្មែរក្រហម ។ ស្តង់តាំងសៀវភៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើករហូតដល់ម៉ោង៧យប់ទើបរៀបចំបិទ ។ នៅក្នុងយប់ថ្ងៃដដែលក៏មានកម្មវិធីជាច្រើនសម្រាប់យុវជនដូចជាការប្រគំតន្ត្រី ការសម្ដែងល្ខោន សំណួរចម្លើយ ការប្រកាសឈ្មោះអ្នកទទួលជ័យលាភីពីការប្រកួតប្រឡងចម្រៀង ។

នេះជាលើកទី៧នៃការចូលរួមតាំងពិព័រណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលប្រារព្ធធ្វើនៅខេត្តបាត់ដំបង កំពង់ចាម តាកែវ ស្វាយរៀង ពោធិ៍សាត់ និងលើកនេះនៅខេត្តបាត់ដំបងម្ដងទៀត ។ ក្នុងរយៈពេលពីរថ្ងៃ គឺពីថ្ងៃទី២១-២២ ខែមីនា ឆ្នាំ២០០៩ នៃការតាំងពិព័រណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកសៀវភៅទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរគ្រប់លេខដែលបោះពុម្ពផ្សាយនៅឆ្នាំ២០០៨ ចំនួន២៥០ក្បាល និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចំនួន ៥០ក្បាល ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលភ្ញៀវដែលចូលមកអានសៀវភៅមានចំនួនប្រមាណ៥០០នាក់ ដែលមកពីស្រុកនានាក្នុងខេត្តបាត់ដំបង ។ នេះជាតួលេខតិចបើប្រៀបធៀបទៅនឹងការតាំងពិព័រណ៍លើកមុនៗ ដោយសារមានសំឡេងធុងបាស់ និងសំឡេងមីក្រូខ្លាំងៗរំខានដល់អ្នកចូលមកអានសៀវភៅ ។ម្យ៉ាងវិញទៀត សិស្សនិងនិស្សិតនៅតាមសាលារដ្ឋ និងឯកជននានាត្រូវប្រឡងប្រចាំឆមាស ។ ទោះជាយ៉ាងនេះក្ដី ការរៀបចំតាំងពិព័រណ៍នេះជាការខិតខំយ៉ាងខ្លាំងក្លាដើម្បីបង្ហាញពីសកម្មភាពការងាររបស់ក្រុមពិព័រណ៍ ក៏ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្សព្វផ្សាយពីរឿងរ៉ាវសម័យខ្មែរក្រហមដល់ប្រជាជនកម្ពុជាគ្រប់រូបឲ្យបានដឹងនិងស្វែងយល់ថែមទៀត ។

**សោម ប៊ុនថន**

# ការអប់រំពីរបបខ្មែរក្រហមតាមរយៈល្ខោននិយាយៈ រឿងទម្លាយភាពស្ងប់ស្ងាត់

ជាមួយស្នាដៃនិពន្ធរបស់អ្នកស្រី អាណាមារី ព្រីនស៍ រឿង «ទម្លាយភាពស្ងប់ស្ងាត់» បានបង្ហាញពីការលាក់កំបាំងពីរឿងរ៉ាវផ្ទាល់របស់ជនរងគ្រោះ និងជនដៃដល់ដែលរស់ក្នុងភូមិជាមួយដែលនៅតែមានការសង្ស័យនិងមិនអាចដោះស្រាយអ្វីបានទាំងអស់ ។ អត្ថន័យនៃសាច់រឿងនៅក្នុងល្ខោននិយាយទម្លាយភាពស្ងប់ស្ងាត់ បានលើកឡើងពីការជួបជជែកពិភាក្សាគ្នាផ្ទាល់មាត់ដើម្បីឈានទៅរកដំណោះស្រាយសមរម្យមួយតាមរយៈការលើកឡើងពីហេតុផលនិងការសូមអនុគ្រោះទោស ។

ទោះជារបបនេះបានដួលរលំទៅអស់រយៈពេលជាង៣០ឆ្នាំហើយក៏ដោយ ក៏ប្រជាជនកម្ពុជាដែលរងគ្រោះដោយសាររបបខ្មែរក្រហមបានរស់នៅក្នុងស្ថានភាពទុក្ខសោកនិងការបាក់ស្បាតដែរ ។ ប្រជាជននៅតែព្យាយាមលាក់បាំងពីរឿងរ៉ាវផ្ទាល់ខ្លួនគាត់និងមិនចង់រំឭកឡើងវិញពីរឿងអតីតកាលរបស់គាត់ ដែលនេះធ្វើឲ្យការចងចាំនៃប្រវត្តិសាស្ត្រនៃរបបនេះបាត់បង់បន្តិចម្តងៗ ។

នាពេលថ្មីៗនេះ ល្ខោននិយាយរឿង ទម្លាយភាពស្ងប់ស្ងាត់ បានសម្តែងជូនប្រជាជនទស្សនានៅក្នុងទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តកំពង់ចាម កណ្តាល និងខេត្តតាកែវ ។ ល្ខោននិយាយនេះមានគោលបំណងលើកទឹកចិត្តឲ្យប្រជាជនកម្ពុជាទាំងជនរងគ្រោះនិងជនដៃដល់ហ៊ាននិយាយពីបទពិសោធន៍ជីវិតពិតឡើងវិញ និងស្វែងរកវិធីផ្សះផ្សារបួសផ្លូវចិត្តពីអតីតកាលនិងធ្វើយ៉ាងណាឲ្យគេចេះរស់នៅជាមួយគ្នាប្រកបដោយការអត់ឱននិងការយោគយល់ ។ ល្ខោននិយាយនេះ បានធ្វើឲ្យមានការចងចាំនិងការជជែកពិភាក្សាពីរបបកម្ពុជាប្រជាធិបតេយ្យកាន់តែទូលំទូលាយថែមទៀតក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា ។

នៅថ្ងៃទី២៨-២៩ ខែកុម្ភៈ ឆ្នាំ២០០៩ ក្រុមល្ខោនបានធ្វើដំណើរទៅដល់ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានជ្រើសរើសយកទីតាំងសាលាឃុំរកាពប្រាំ ធ្វើជាទីកន្លែងសម្តែងជំនួសឲ្យការបញ្ចាំងខ្សែភាពយន្តរបស់គម្រោងការិយាល័យព័ត៌មានសាធារណៈ ដែលមានទស្សនិកជនប្រមាណជាង១០០០នាក់រួមមាន ប្រជាជន មន្ត្រីរាជការ ព្រះសង្ឃ និស្សិត សិស្ស និងគ្រូបង្រៀនប្រមាណ២០នាក់មកពី



វិទ្យាល័យត្បូងឃ្មុំ បានមកទស្សនាការសម្តែងផងដែរ ។ នៅពេលសម្តែង ទស្សនិកជនបានខិតខំស្តាប់និងទស្សនាដោយយកចិត្តទុកដាក់នូវគ្រប់ឆាកនៃល្ខោននិយាយនេះ ដែលរួមមានចំនួន៧វគ្គ អមទៅដោយបទភ្លេងនិងចម្រៀងស្រដេះស្រដោចដែលធ្វើឲ្យទស្សនិកជនផ្តោតអារម្មណ៍ទៅលើការសម្តែងកាន់តែខ្លាំង ។ ក្រោយចប់ការសម្តែង មានអ្នកភូមិម្នាក់សួរសំណួរថា មូលហេតុ

*អ្វីបានជាមានរបបខ្មែរក្រហម? និងសូមឲ្យពន្យល់ពីអត្ថន័យនៅក្នុងរឿងល្ខោននិយាយរឿង ទម្លាយភាពស្ងប់ស្ងាត់។ ការលើកឡើងនូវចម្ងល់ទាំងនោះបានធ្វើឲ្យមានការពិភាក្សាកាន់តែមានភាពផុសផុលឡើងនិងទាក់ទាញការចាប់អារម្មណ៍របស់ទស្សនិកជនជាមួយនឹងប្រវត្តិរឿងរ៉ាវសម័យខ្មែរក្រហម ។*

*នៅថ្ងៃទី២៨ ខែកុម្ភៈ និងថ្ងៃទី១ ខែមីនា ឆ្នាំ២០០៩ ក្រុមល្ខោនបានធ្វើដំណើរទៅដល់ឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ក្រុមបានជ្រើសរើសយកយកទីតាំងសាលាឃុំអំពៅព្រៃធ្វើជាកន្លែងសម្តែងដែលមានប្រជាជនប្រមាណជាង៦០០*



*នាក់មកទស្សនា ។ លោកតា អ៊ឹម គ្រឿង អាយុ៧៥ឆ្នាំ រៀបរាប់ទាំងសំឡេងយំខ្សឹបខ្សួលថា «ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនទៅឃុំឃាំងនៅគុកសង់ និងបានបង្ខំឲ្យលើកញញួរដែលមានទម្ងន់១០គីឡូក្រាមដំដែកធ្វើកាំបិត ពូថៅ ចប ប៉ែល ហើយប្រសិនបើខ្ញុំធ្វើមិនបានតាមការកំណត់ អង្គការនឹងដាក់ពិន័យ» ។ មុី អាយុ១៦ឆ្នាំ បាននិយាយថា «កាលពីមុនខ្ញុំបានត្រឹមតែឮឪពុកម្តាយនិយាយប្រាប់ពីរឿងរ៉ាវនៅក្នុងសម័យខ្មែរក្រហមប៉ុណ្ណោះ ប៉ុន្តែពេលនេះ ខ្ញុំបានឃើញផ្ទាល់ភ្នែកទើបធ្វើឲ្យខ្ញុំជឿជាក់» ។ មុី បន្តថា «ប៉ុន្តែមានឈុតខ្លះនៅក្នុងសាច់រឿង វាធ្វើខ្ញុំមានការភ័ន្តច្រឡំតួអង្គ និងពិបាកយល់ ចំណែកការស្លៀកពាក់គឺខុសពីអ្វីដែលឪពុកម្តាយខ្ញុំបាននិយាយប្រាប់» ។ ទោះជាមានការចូលរួមទស្សនាយ៉ាងច្រើនសន្ធឹកសន្ធាប់ពីអ្នកភូមិក៏ដោយ ក៏មានក្មេងៗខ្លះពិបាកយល់ពីខ្លឹមសារនៃការសម្តែងនេះដែរ ព្រោះល្ខោននិយាយរឿងទម្លាយភាពស្ងប់ស្ងាត់នេះបានបង្កប់អត្ថន័យយ៉ាងជ្រាលជ្រៅជាមួយនឹងការផ្សះផ្សា និងការអត់ឱនទោស ។*

*នៅថ្ងៃទី៧-៨ ខែមីនា ឆ្នាំ២០០៩ ក្រុមល្ខោនបានធ្វើដំណើរទៅដល់ឃុំបាស្រែ ស្រុកអង្គរបុរី ខេត្តតាកែវ ។ ក្រុមល្ខោនបានជ្រើសរើសយកទីតាំងវត្តរំលកធ្វើជាទីតាំងសម្តែង ដែលមានអ្នកភូមិប្រមាណជាង៦០០នាក់បានមកចូលរួមទស្សនា ។ មឹង ហង់ ងី អាយុ៤១ឆ្នាំ ប្រជាជនមកពីភូមិតាអី ឃុំបាស្រែ បានលើកឡើងថា «នេះជាលើកទីមួយហើយដែលមានក្រុមសិល្បៈល្ខោនអំពីរឿងរ៉ាវសម័យខ្មែរក្រហមមកសម្តែងជូនអ្នកភូមិបានទស្សនា» ។ នៅក្នុងរបបខ្មែរក្រហម ងី ដែលទើបតែមានអាយុ១៨ឆ្នាំត្រូវខ្មែរក្រហមបំបែកឲ្យទៅលើកភ្លឺស្រែ ស្ទូងស្រូវ និងធ្វើជីនៅការដ្ឋានឆ្ងាយពីភូមិ ។ ងី បានរំឭកឡើងវិញថា «ថ្ងៃមួយខ្ញុំបានឃើញប្រជាជនដែលជម្លៀសមកពីស្រុកផ្សេងត្រូវខ្មែរក្រហមដោតបាតដៃជាមួយនឹងលួសបន្លាបណ្តើរចូលក្នុងភូមិបន្ទាប់មកអ្នកជម្លៀសទាំងនោះបានត្រូវខ្មែរក្រហមសម្លាប់ចោលទាំងអស់» ។ ងី បានបន្តថា «នៅក្នុងឈុតខ្លះនៅក្នុងល្ខោននិយាយនេះគឺជារឿងពិតដែលគាត់បានជួបប្រទះ» ។ ចុងក្រោយ ងី បានសម្តែងការបារម្ភថា «នៅពេលខ្ញុំនិយាយរឿងរ៉ាវរបស់ខ្ញុំនៅក្នុងសម័យខ្មែរក្រហមប្រាប់ទៅកូនៗ ពួកគេបែរជាសើចនិងតបមកវិញថា មិនដែលមានរឿងដូច្នេះកើតឡើងនោះទេ» ។*

*នៅថ្ងៃទី១០-១១ ខែមីនា ឆ្នាំ២០០៩ ល្ខោនបានធ្វើដំណើរទៅដល់ភូមិសាលា ឃុំទៀន ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ក្រុមល្ខោនបានជ្រើសរើសទីវាលខាងចុងភូមិដើម្បីធ្វើជាកន្លែងសម្តែងដែលមានប្រជាជន សិស្ស គ្រូបង្រៀន ប្រមាណ៥០០នាក់មកទស្សនា ។ អ៊ំ ថា អាយុ៤២ឆ្នាំ ប្រធានភូមិសាលា បានមាន*

ប្រសាសន៍ «ខ្ញុំគាំទ្រឲ្យមានការសម្ដែងល្ខោននិយាយនៅភូមិរបស់គាត់ដើម្បីអប់រំឲ្យក្មេងជំនាន់ក្រោយបានដឹង» ។ ហើយបានបន្តថា «ប៉ុន្តែខ្ញុំសំណូមពរឲ្យតួអង្គសម្ដែងទាំងអស់ស្លៀកពាក់ខ្មៅ និងសូមមិនឲ្យមានតួអង្គស្មាព្រោះធ្វើឲ្យទស្សនិកជនគិតថា ជារឿងកំប្លែងសើចសប្បាយទៅវិញ» ។ ចុងក្រោយគាត់បានសំណូមពរ «តួអង្គទាំងអស់ស្លៀកពាក់ឲ្យដូចទៅនឹងសម័យខ្មែរក្រហម និងត្រូវមានតួអង្គតំណាងឲ្យគ្រប់ឈុតទាំងអស់នៅក្នុងសាច់រឿង» ។

អ្នកភូមិឈ្មោះ វ៉ាង សំ បានលើកឡើងថា «លើកទីមួយហើយដែលមានក្រុមសម្ដែងល្ខោននិយាយពីសម័យខ្មែរក្រហម» មកសម្ដែងនៅក្នុងភូមិ ។ ក្មេងជំនាន់ក្រោយពិតជាមិនសូវដឹងថា មានរបបខ្មែរក្រហមទេ ព្រោះគេកើតមិនទាន់របបនោះ ។

គឹម អាយុ១៨ រៀនថ្នាក់ទី៩ឆ្នាំ វិទ្យាល័យទៀន បាននិយាយថា «ខ្ញុំចង់ឲ្យមានការផ្សព្វផ្សាយសិល្បៈនេះនៅតាមសាលារៀនដើម្បីឲ្យក្មេងបានឃើញ និងដឹងពីពិតប្រាកដ ព្រោះខ្ញុំគ្រាន់តែបានឮពីលោកគ្រូ-អ្នកគ្រូ និងឪពុកម្ដាយនិយាយប្រាប់ប៉ុណ្ណោះ» ។ ផន សុផុន អាយុ១៧ឆ្នាំ ប្រាប់ថា «ពីមុនខ្ញុំមិនជឿទេ ប៉ុន្តែនៅពេលបានរៀននៅសាលានិងបានទៅទស្សនានៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដោយផ្ទាល់ភ្នែក ធ្វើឲ្យខ្ញុំជឿថាពិតជាមានរបបខ្មែរកើតឡើងពិតមែន» ។ សុផុន បានបន្ត «ខ្ញុំចង់មានការបញ្ចាំងកុនឯកសារពីរបបខ្មែរនៅតាមភូមិនិងនៅតាមសាលាថែមទៀត» ។

នៅក្នុងប្រទេសកម្ពុជា ទោះបីក្មេងៗទាំងនោះបានរៀនសូត្រពីរបបខ្មែរក្រហមនៅតាមសាលា ឮតាមការនិយាយប្រាប់ពីចាស់ទុំនៅក្នុងភូមិឬពីឪពុកម្ដាយក្ដី ក៏គេនៅមានភាពស្ទាក់ស្ទើរក្នុងការជឿជាក់ថាពិតជាមានរបបខ្មែរក្រហមមែន ។ ដូច្នេះប្រជាជនកម្ពុជាទាំងអស់ត្រូវតែចាប់អារម្មណ៍ ចូលរួមថែរក្សា និងចងចាំនូវរបបខ្មែរក្រហម ។ ជាមួយគ្នានេះ ល្ខោនក៏មាននាទីសំខាន់ដើម្បីបង្ហាញឲ្យទស្សនិកជនបានទស្សនា និងស្ដាប់ឮនូវរឿងរ៉ាវពិតរបស់ប្រជាជនខ្មែរដែលបានជួបប្រទះនៅក្នុងសម័យនោះ ។ ការអប់រំតាមរយៈល្ខោននិយាយរឿងទម្លាយភាពស្ងប់ស្ងាត់ ក្មេងក៏នឹងយល់កាន់តែច្បាស់ថែមទៀតពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

**សោម ប៊ុនថន**




សិស្សានុសិស្សថតរូបអនុស្សាវរីយ៍ក្នុងដំណើរទស្សនកិច្ចអប់រំពីអំពើប្រល័យពូជសាសន៍

# ដំណើរទស្សនកិច្ចអប់រំពីអំពើប្រល័យពូជសាសន៍

កាលពីថ្ងៃទី២៩-៣១ ខែមីនា ឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយទីភ្នាក់ងារភីសខបកម្ពុជា បានរៀបចំកម្មវិធីដំណើរទស្សនកិច្ចអប់រំពីអំពើប្រល័យពូជសាសន៍ ដោយមានដូចជា កម្មវិធីស្តាប់រឿងរ៉ាវជីវិតសម័យខ្មែរក្រហមរបស់លោកជំទាវ អ៊ឹ សាវឿន ជាសមាជិកសភានិងតំណាងរាស្ត្រខេត្តកំពង់ស្ពឺ ការស្តាប់វាគ្មិនបកស្រាយពីប្រវត្តិសាស្ត្រខ្មែរក្រហម ការអត់ឱននិងការផ្សះផ្សា តាមរយៈធម៌ព្រះពុទ្ធនិងក្នុងគម្ពីរសាសនាឥស្លាម កិច្ចប្រជុំពិភាក្សា សំណួរចម្លើយ ការទស្សនាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានចំណងជើងថា «នៅក្រោយជញ្ជាំងស-២១» និងទស្សនកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាដជើងឯក និងទីតាំងអគារតុលាការខ្មែរក្រហម ។ នៅក្នុងដំណើរទស្សនកិច្ចនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញសិស្សានុសិស្សចំនួន៣០០នាក់មកពីវិទ្យាល័យនានាទូទាំងព្រះរាជណាចក្រកម្ពុជាគឺវិទ្យាល័យឈូក ខេត្តកំពត វិទ្យាល័យក្រូចឆ្មារ ខេត្តកំពង់ចាម វិទ្យាល័យក្រឡាញ់ ខេត្តសៀមរាប និងវិទ្យាល័យអន្លង់វិល ខេត្តបាត់ដំបង ។ កម្មវិធីទស្សនកិច្ចអប់រំពីអំពើប្រល័យពូជសាសន៍នេះមានរយៈពេល២ថ្ងៃគឺៈ

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង១ៈ៣០នាទី សិស្សានុសិស្សមកពីខេត្តទាំងអស់ត្រូវមកជួបប្រជុំគ្នានៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ទាប់មក ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចេញដំណើរទៅធ្វើទស្សនកិច្ចនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលជាអតីតមន្ទីរឃុំឃាំង ស-២១ក្នុងសម័យខ្មែរក្រហមដែលអ្នកទោសប្រមាណជាងមួយម៉ឺន៧ពាន់នាក់ត្រូវបានធ្វើទារុណកម្មនិងសម្លាប់យ៉ាងឃោរឃៅក្រោមការគ្រប់គ្រងរបស់ប្រធានគុកឈ្មោះ ឌុច ។ នៅវេលាម៉ោង៣ៈ៣០នាទី ពេលបញ្ចប់ការដើរទស្សនា សិស្សានុសិស្សបានមកប្រមូលផ្តុំគ្នា រួចហើយចេញដំណើរទៅសាលប្រជុំនៃព្រឹទ្ធសភាដើម្បីទស្សនាការការបញ្ចាំងខ្សែភាពយន្តឯកសាររយៈពេល៣០នាទី ដែលមានចំណងជើងថា «នៅក្រោយជញ្ជាំងស-២១» ។ នៅមុនពេលទស្សនាខ្សែភាពយន្ត សិស្សានុសិស្សបានទទួលសំបុត្រមួយច្បាប់របស់លោក ឆាំង យុ ដែលដាក់ចំណងជើងថា «ថ្ងៃកាត់ទោសមេគុកទួលស្លែង គឺជារបត់ដ៏សំខាន់មួយសម្រាប់កម្ពុជា» ដែលជាដំណើរដ៏វែងឆ្ងាយរបស់ប្រជាជនកម្ពុជាដើម្បីទាមទារយុត្តិធម៌និងការចងចាំ ហើយក៏ជាថ្ងៃបកស្រាយពីអំពើឃោរឃៅ និងការផ្សះផ្សារវាងជនដៃដល់និងជនរងគ្រោះផងដែរ ។ អ្នកស្រី ជា គីម ប្រធានបណ្ណាល័យព្រឹទ្ធសភាបានណែនាំទីតាំងអគារ ការិយាល័យធ្វើការ រចនាសម្ព័ន្ធការងារនិងបណ្ណាល័យព្រឹទ្ធសភាដែលអនុញ្ញាតឲ្យសិស្សានុសិស្សទាំងអស់ចូលអាននិងខ្ចីសៀវភៅដោយពុំគិតថ្លៃ ។ បន្ទាប់មក កញ្ញា សើ សាយ្យាណា បានរៀបរាប់ពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានិងកម្មវិធីក្នុងពេលដំណើរទស្សនកិច្ច ។ ចុងក្រោយលោក ឆាំង យុ ណែនាំពីរចនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងគុកទួលស្លែងដែលមានជនរងគ្រោះប្រមាណ១៨០០០នាក់ ត្រូវបានចាប់មកដាក់នៅមន្ទីរ ស-២១ ដោយអ្នកទាំងនោះត្រូវបានសម្លាប់និងសួរចម្លើយ ។ បន្ទាប់មក គាត់បានប្រាប់អំពីអ្នកទោសចំនួន៤នាក់ដែលត្រូវបានកងទ័ពវៀតណាមរំដោះបានដោយកុមារទាំងបួននាក់នេះអាចរស់រានមានជីវិតបានដោយសារពួននៅក្នុងគំនរខោអាវ ដោយមកដល់បច្ចុប្បន្ននេះម្នាក់មានអាយុ៣៩ឆ្នាំ ម្នាក់អាយុ៣៥ឆ្នាំ និងពីរនាក់ទៀតមិនដឹងជារស់នៅទីកន្លែងណា ។ លោក ឆាំង យុ បានណែនាំអំពីតុលាការខ្មែរក្រហមនិងប្រវត្តិរបស់មេដឹកនាំខ្មែរក្រហម កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាប្រធានគុកទួលស្លែង និងការសួរចម្លើយបែងចែកជាបីក្រុម គឺក្រុមអង្កៀម ក្រុមក្តៅ និងក្រុមត្រជាក់ ។ បន្ទាប់មក គាត់បានអនុញ្ញាតឲ្យសិស្សានុសិស្សទាំងអស់ឡើងសួរសំណួរទាក់ទងទៅនឹងសម័យខ្មែរក្រហម រួចបានសង្ខេបសាច់រឿងខ្លីៗក្នុងខ្សែភាពយន្ត «នៅក្រោយគៀនជញ្ជាំងមន្ទីរស-២១» ដែលក្នុងសាច់រឿងនេះមានតួអង្គបីនាក់គឺ ប៊ូ ម៉េង

អ្នកគូរគំនូរនៅក្នុងរបបខ្មែរក្រហម ជុំ ម៉ាញ ហៅ មុី ជាជាងម៉ាស៊ីនរថយន្ត និង ហ៊ឹម ហ៊ុយ ជាប្រធានក្រុមចាប់ចងនៅមន្ទីរស-២១ ។ នៅក្នុងខ្សឹមសាររឿង អ្នកនិពន្ធបានជួបសម្ភាសន៍ផ្ទាល់ជាមួយជនរងគ្រោះនៅក្នុងគុកទួលស្លែងដែលបានរៀបរាប់ពីការស្ទួរចម្លើយ ការធ្វើទារុណកម្មនិងការសម្លាប់យ៉ាងសាហាវឃោរឃៅ ព្រមជាមួយគ្នានោះក៏បានជួបសម្ភាសន៍ជាមួយជនដៃដល់ដែលបានបង្ហាញពីវិធីសាស្ត្របង្ខំឲ្យអ្នកទោសឆ្លើយសារភាព ការធ្វើទារុណកម្មនិងវិធីសាស្ត្រនៃការសម្លាប់ ។ ជាមួយអាកាសធាតុក្តៅហប់ក្នុងអំឡុងពេលបញ្ចាំងខ្សែភាពយន្ត សិស្សានុសិស្សបានខិតខំស្តាប់និងទស្សនាយ៉ាងយកចិត្តទុកដាក់ ។ ក្រោយពេលខ្សែភាពយន្តបានបញ្ចប់ លោក ឆាំង យុ ស្នើឲ្យសិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូបញ្ចេញយោបល់រៀងៗខ្លួនចំពោះតួអង្គទាំង៣នៅក្នុងខ្សែភាពយន្តថាតើពួកគេអាចផ្សះផ្សាគ្នាបានដែរឬទេ និងមានយន្តការអ្វីដើម្បីឲ្យពួកគេអាចផ្សះផ្សាគ្នាបាន? នៅពេលនោះ សិស្ស និងលោកគ្រូអ្នកគ្រូបានលើកឡើងពីទស្សនៈរៀងៗខ្លួន ដោយសិស្សម្នាក់មកពីវិទ្យាល័យក្រឡាញ់ ខេត្តសៀមរាបបានលើកឡើងថា វិធីដោះស្រាយកំហឹងតាមរយៈធម៌ព្រះពុទ្ធសាសនាគឺ *«មេត្តាអនុគ្រោះ, អត់ឱន និងមិនសងសឹកគ្នាទៅវិញទៅមក»* ។ លោកគ្រូម្នាក់មកពីវិទ្យាល័យមេមត់ បានលើកឡើងថា *«ការដោះស្រាយដែលនាំឲ្យយើងរស់នៅជាមួយគ្នាប្រកបដោយសន្តិភាព និងសុភមង្គលគឺការដោះស្រាយតាមរយៈផ្លូវច្បាប់»* ។ បន្ទាប់មក លោក ឆាំង យុ បានធ្វើការសរុបដោយលើកឡើងថា *«ដើម្បីឲ្យមានការផ្សះផ្សាក្នុងសង្គម យើងទាំងអស់គ្នាត្រូវខិតខំរៀនសូត្រ, ផ្សព្វផ្សាយឲ្យបានទូលំទូលាយពីអំពើប្រល័យពូជសាសន៍ ព្រមជាមួយនោះយើងក៏មានការដោះស្រាយតាមរយៈផ្លូវច្បាប់ដែរ»* ។

នៅវេលាម៉ោង៧:៣០ព្រឹក ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ សិស្សទាំងអស់ត្រូវមកចូលរួមប្រជុំនៅសាលប្រជុំវិទ្យាស្ថានជាតិអប់រំ ដោយទទួលបានឯកសារមួយកញ្ចប់ រួមមានកម្មវិធីទស្សនកិច្ចអប់រំពីអំពើប្រល័យពូជសាសន៍ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ទស្សនាវដ្តីស្វែងរកការពិតលេខ១០៧ ខែវិច្ឆិកា ឆ្នាំ២០០៨ សៀវភៅកត់ត្រា ខ្មៅដៃ និងប៊ិច ។ កិច្ចប្រជុំព្រឹកនេះមានការអញ្ជើញចូលរួមពីលោកសាស្ត្រាចារ្យ សំបូរ ម៉ាណ្ណារ៉ា



សិស្សានុសិស្សស្តាប់ការពន្យល់របស់សាស្ត្រាចារ្យ សំបូរ ម៉ាណ្ណារ៉ា

អនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ ព្រះតេជគុណ ស៊ូ សឿម មកពីសមាគមពុទ្ធសាសនាដើម្បីការអភិវឌ្ឍនៅខេត្តបាត់ដំបង លោក អេង កុកថាយ នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជាជាវាគ្មិន ។ នៅក្នុងកិច្ចស្វាគមន៍ លោក អេង កុកថាយ បានរៀបរាប់ពីលទ្ធផលកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានសម្រេចកន្លងមក និងការជ្រើសរើសបុគ្គលិកឲ្យចូលបម្រើការងារតាមរយៈការស្ម័គ្រចិត្ត ។ ចុងបញ្ចប់លោកលើកទឹកចិត្តឲ្យសិស្សានុសិស្សទាំងអស់ខិតខំប្រឹងប្រែងរៀនសូត្រឲ្យបានពូកែ ដើម្បីជួយកិច្ចការងារសង្គម ក៏ដូចជាការចូលមកធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ ។ បន្ទាប់មកព្រះតេជគុណ ស៊ូ សឿម បានលើកពីបុណ្យបាប កម្មផល



ដោយអ្នកធ្វើអំពើអាក្រក់នឹងទទួលបានផលអាក្រក់នៅថ្ងៃខាងមុខ ។ លោកសាស្ត្រាចារ្យ សំបូរ ម៉ាណ្ណារ៉ា បានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានអនុញ្ញាតឲ្យរូបគាត់មកធ្វើជាវាគ្មិននៅក្នុងកម្មវិធីទស្សនកិច្ចអប់រំពីអំពើប្រល័យពូជសាសន៍នេះ ។ លោកសាស្ត្រាចារ្យបានធ្វើអត្ថាធិប្បាយពីដំណាក់កាលប្រវត្តិសាស្ត្រប្រទេសចាប់ពីទសវត្សរ៍៦០ រហូតដល់មានវត្តមានខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

នៅចុងបញ្ចប់នៃកម្មវិធី ទូន សុះ ស្ទេះ ជានាយកវិទ្យាល័យរស្មីឥស្លាមកម្ពុជាបានឡើងមានប្រសាសន៍ពីបាបបុណ្យ កម្មពៀរការសម្លាប់នៅក្នុងគម្ពីរសាសនាឥស្លាម ។ កម្មវិធីប្រជុំបានបញ្ចប់នៅវេលាម៉ោង៩:៣០ សិស្សទាំងអស់បានចេញដំណើរទៅជួបជាមួយលោកជំទាវ អ៊ំ សារឿន សមាជិកសភានៅគេហដ្ឋានរបស់គាត់ក្នុងទីរួមខេត្តកំពង់ស្ពឺ ។ ពេលទៅដល់នាវេលាម៉ោង១១:៣០នាក់លោកជំទាវបានចេញមកទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា សិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូព្រមទាំងមាននំអាកោគ្នោតជាអាហារសម្រន់ផងដែរ ។ ក្រោយពីសម្រាកពិសារអាហាររួច សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូបានមកប្រជុំគ្នានៅក្រោមម្លប់ដើមស្វាយនិងដើមល្មុត ដើម្បីស្តាប់លោកជំទាវមានប្រសាសន៍ ។ លោកជំទាវបានរៀបរាប់ប្រាប់សិស្សក៏ដូចជាលោកគ្រូអ្នកគ្រូអំពីបទពិសោធន៍និងរឿងរ៉ាវជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហមនិងពេលបច្ចុប្បន្ន ។ ចាប់ពីឆ្នាំ១៩៧៩-១៩៩៣ គាត់បានចូលបម្រើការងារនៅមន្ទីរខេត្តនិងចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា ។ រយៈពេលពី២-៣ឆ្នាំគាត់ត្រូវបានបក្សដំឡើងឋានៈរហូតមក ដូចជាសមាជិកគណៈមជ្ឈិមការ ធ្វើរបាយការណ៍លើកទិសដៅឲ្យបក្ស គណៈចាត់តាំង ។ ចុងក្រោយ គាត់បានឡើងឋានៈជាសមាជិកព្រឹទ្ធសភា ដោយសារតែ ១) អាស្រ័យដោយការជឿទុកចិត្តរបស់បក្ស ២) គាត់ទទួលបានប្រជាប្រិយភាពពីមហាជន និង៣) ដោយសារតែគាត់ជាមនុស្សមានសមត្ថភាព ។ នៅចុងបញ្ចប់ លោកជំទាវមានប្រសាសន៍ថាសូមឲ្យសិស្សទាំងអស់ខិតខំរៀនសូត្រពីលោកគ្រូ-អ្នកគ្រូ ឪពុកម្តាយនិងញាតិមិត្តជិតខាង ។ ព្រមជាមួយគ្នានេះ គឺត្រូវចេះគោរពច្បាប់នៅក្នុងសង្គម ចៀសវាងការប្រើថ្នាំញៀន លេងល្បែងពាលាអាវ៉ាសែ ដែលខូចសណ្តាប់ធ្នាប់សង្គម ។ បន្ទាប់មកលោកជំទាវបានអនុញ្ញាតឲ្យសិស្សសួរសំណួរ ដោយមានសិស្សម្នាក់មកពីវិទ្យាល័យត្បូងឃ្មុំសួរថាតើសម័យខ្មែរក្រហមលោកជំទាវមានតួនាទីជាអ្វី? និងតើអ៊ំមានអារម្មណ៍យ៉ាងណាដែរនៅពេលមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនិងចង់ឲ្យកាត់ទោសមេដឹកនាំខ្មែរក្រហមយ៉ាងណាដែរ?

បន្ទាប់មក យើងទាំងអស់គ្នាក៏បានចាកចេញពីផ្ទះរបស់គាត់ទៅហូបអាហារថ្ងៃត្រង់នៅកណ្តោលជុំ ។ ក្រោយពីទទួលទានអាហាររួចនៅប្រហែលម៉ោង១-៣០នាទី យើងក៏ធ្វើដំណើរទៅកាន់អគ្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកាកម្ពុជាដែលហៅកាត់ថាតុលាការខ្មែរក្រហម ដើម្បីឲ្យសិស្ស និងលោកគ្រូ-អ្នកគ្រូអាចចូលទៅ

មើលអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយមាន លោក រាជ សម្បត្តិ អ្នកនាំពាក្យសាលាក្តីខ្មែរក្រហមជាអ្នកបង្ហាញ ។ ដោយសារការចំណាយពេលវែង ដើម្បីជួបលោក ជិទាវ សារឿន និងទស្សនាតុលាការខ្មែរក្រហម យើងក៏បានផ្លាស់ប្តូរពីកម្មវិធីទៅទស្សកិច្ចវាលវិយាដជើងឯក មកទស្សនាព្រះបរមរាជវាំងវិញ ។ នៅអំឡុងពេលដើរទស្សនាប្រាសាទនានានៅក្នុងព្រះបរមរាជវាំង សិស្សឈ្មោះ ហេង មកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន មេមត់ បានប្រាប់ថា «នេះជាលើកទីមួយដែលខ្ញុំបានចូលរួមក្នុងទស្សកិច្ចនេះ ខ្ញុំមានអារម្មណ៍សប្បាយ ព្រោះបានជួបជុំមិត្តភក្តិ» ជាងនេះទៅទៀត «ខ្ញុំអាចស្គាល់មជ្ឈដ្ឋានខាងក្រៅទីតាំងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងទីតាំងអង្គជំនុំជម្រះវិសាមញ្ញ ។ ហេង បានបន្តថា «កាលពីមុនពេលឪពុកម្តាយនិយាយប្រាប់ ខ្ញុំមិនជឿគាត់ទេ ព្រោះខ្ញុំមិនបានជួបនិងឃើញផ្ទាល់ភ្នែក» ។ ហេង បានបន្តថា «ដើម្បីកុំឲ្យរបបនេះកើតឡើងម្តងទៀត យើងជាសិស្សត្រូវផ្សព្វផ្សាយប្រវត្តិសាស្ត្រខ្មែរក្រហមទៅឲ្យអ្នកផ្សេងទៀតឲ្យបានដឹង និងត្រូវបេះសាមគ្គីគ្នា» ។ លោកគ្រូ សុង ប៉េងអៀង បង្រៀនថ្នាក់ទី១១ មកពីវិទ្យាល័យប៊ុនរ៉ានី-ហ៊ុន សែន មេមត់ មានប្រសាសន៍ថា «ដំណើរទស្សនកិច្ចមានសារសំខាន់ណាស់សម្រាប់ឲ្យសិស្សបានដឹង និងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបានស្គាល់ពីកន្លែងផ្សេងៗទៀត» ។ ហើយសម្រាប់អារម្មណ៍ខ្លួនខ្ញុំផ្ទាល់គឺសប្បាយ ទន្ទឹមនេះក៏មានការពិបាកក្នុងការគ្រប់គ្រងកូនសិស្សដែរ ។ លោកគ្រូបានបន្ថែមថា នៅមុនពេលចូលរួមកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នេះ សិស្សទាំងអស់ត្រូវឆ្លងកាត់ការរៀនសូត្រពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ រយៈពេល៤ខែ ជារៀងរាល់ថ្ងៃអាទិត្យ ដែលធ្វើឲ្យពួកគេយល់កាន់តែច្បាស់ថែមទៀត ។

នៅវេលាម៉ោង៥:៣០នាទី សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ បានចូលរួមពិសាអាហារពេលល្ងាចនៅភោជនីយដ្ឋានស៊ឹងមាស ។ នៅមុនពេលចាប់ផ្តើមពិសាអាហារ តំណាងលោកគ្រូ-អ្នកគ្រូរបស់ទីភ្នាក់ងារភីសខបកម្ពុជា បានឡើងថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានរៀបចំកម្មវិធីនេះឡើង ។ បន្ទាប់មក លោកគ្រូម្នាក់មកពីវិទ្យាល័យក្រូចឆ្មារ ខេត្តកំពង់ចាម បានប្រគល់ជូនកម្រងរូបថតសិស្សដែលថតក្នុងអំឡុងពេលសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់មជ្ឈមណ្ឌល ។ នៅក្នុងកិច្ចថ្លែងអំណរគុណដល់សិស្ស លោក ឆាំង យុ បានអញ្ជើញលោកវុត្ថា ជានិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈឡើងច្រៀងចម្រៀងមួយបទដែលមានចំណងជើងថា «ទន្លេឈាម» ដែលបានរៀបរាប់ពីទុក្ខសោកនៃការសម្លាប់ និងការផ្សះផ្សាជាតិនៅថ្ងៃអនាគត ។ បន្ទាប់មក លោកបានសំណូមពរសិស្សស្ម័គ្រចិត្តឡើងច្រៀងចម្រៀងទន្លេឈាមនេះប្រកបដោយបរិយាកាសស្ងប់ស្ងាត់និងផ្ចង់ស្តាប់អត្ថន័យ ។ ចុងក្រោយ សិស្សទាំងអស់បានឡើងរាំនិងច្រៀងបទប្រពៃណីខ្មែរប្រកបដោយក្តីសប្បាយរីករាយ ភាតរភាព និងសាមគ្គីភាព ។

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់បានចែកអាហារពេលព្រឹកដល់សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ រួចជូនគាត់ទៅដាក់តាមចំណតរថយន្តដើម្បីចេញដំណើរទៅគេហដ្ឋានរៀងៗខ្លួន ។

នេះជាលើកទីមួយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំកម្មវិធីអញ្ជើញសិស្សមកពីតាមបណ្តាខេត្តឆ្ងាយៗដូចជា ខេត្តសៀមរាប បាត់ដំបង កំពង់ចាម និងខេត្តកំពត ក្នុងគោលបំណងដើម្បីឲ្យសិស្សយល់កាន់តែច្បាស់ពីរឿងរ៉ាវសម័យខ្មែរក្រហមដែលមិនត្រឹមតាមរយៈការរៀននៅតាមសាលា ឬតាមការនិយាយប្រាប់របស់ឪពុកម្តាយ ឬអ្នកជិតខាងនោះទេ ថែមទាំងបានមកទស្សនាដោយផ្ទាល់ភ្នែកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានប្រមូលចងក្រងឯកសាររាប់សែនសន្លឹករួមមាន រូបថត ខ្សែអាត់សំឡេង សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ទីតាំងអគារតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងព្រះបរមរាជវាំងដែលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានឃុំឃាំងរាជវង្សានុវង្សរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុ នៅទីនេះ ។ មិនត្រឹមតែប៉ុណ្ណោះ ទស្សនកិច្ចនេះបានធ្វើឲ្យសិស្សមកពីតំបន់ផ្សេងៗស្គាល់គ្នា និងស្វែងយល់ពីគ្នាទៅវិញទៅមកដែលធ្វើឲ្យចំណងមិត្តភាព និងសាមគ្គីភាពកាន់តែរឹងមាំដើម្បីឈានទៅរកការសិក្សាឲ្យកាន់តែមានលក្ខណៈទូលំទូលាយថែមទៀត ។

**តាត លក្ខិណា**

# ភាពមិនយល់ស្របគ្នារបស់សហព្រះរាជអាជ្ញានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្តីអំពីថាតើត្រូវធ្វើការស៊ើបអង្កេតបន្ថែមលើជនសង្ស័យបន្ថែមទៀតដែរឬអត់

មកដល់ពេលនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានធ្វើការចោទប្រកាន់ជនសង្ស័យ៥នាក់ ។ សហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិកំពុងតែស្ថិតនៅក្នុងការមិនព្រមព្រៀងគ្នាទាក់ទងទៅនឹងភាពសមស្របដើម្បីចាប់ផ្តើមធ្វើការស៊ើបអង្កេតថ្មីទៅលើជនសង្ស័យបន្ថែមទៀត ។ សហព្រះរាជអាជ្ញាអន្តរជាតិ រ៉ូបឺត ពេទិត បានស្នើឲ្យមានការស៊ើបអង្កេតបន្តទៅមុខដោយផ្តល់ទឡ្ហីករណ៍ថា តម្រូវការខាងលក្ខន្តិកៈត្រូវបានបំពេញរួចហើយ ពោលគឺមានហេតុផលជាច្រើនអាចឲ្យមានការពិចារណាលើបទឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានធ្វើឡើង ។ ទោះបីជាសហព្រះរាជអាជ្ញាជាតិ ជា លាង មិនបានជំទាស់នឹង ពេទិត ទេដែលថាតម្រូវការចាំបាច់នៃគោលបំណងនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីធ្វើការស៊ើបអង្កេតបន្ថែមត្រូវបានបំពេញក៏ដោយ ក៏ប៉ុន្តែមានអារម្មណ៍ថា ឧក្រិដ្ឋកម្មមិនគួរស៊ើបអង្កេតបន្ថែមឡើយ ដោយសារ ១) អស្ថិរភាពកាលពីអតីតកាលរបស់កម្ពុជានិងតម្រូវការឲ្យមានការផ្សះផ្សាជាតិ ២) ស្មារតីរបស់កិច្ចព្រមព្រៀងឆ្នាំ ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការចោទប្រកាន់ក្រោមច្បាប់កម្ពុជាទៅលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ «កិច្ចព្រមព្រៀងតាមក្របខណ្ឌការងារ» និងច្បាប់ឆ្នាំ២០០៤ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីធ្វើការចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ «ច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» និង ៣) រយៈពេលនិងធនធានមានកំណត់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ស្តង់ការនៃការត្រួតពិនិត្យ

បច្ចុប្បន្ននេះ អង្គបុរេជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងប្រឈមមុខជាមួយកិច្ចការដោះស្រាយជម្លោះដែលមិនធ្លាប់មានពីមុនមក ។ កិច្ចព្រមព្រៀងតាមក្របខណ្ឌការងារនិងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញកំណត់កិច្ចការនេះថាជាតួនាទីចម្បងរបស់អង្គបុរេជំនុំជម្រះគឺ យន្តការដោះស្រាយជម្លោះដើម្បីដោះស្រាយភាពមិនយល់ស្របគ្នារវាងសហព្រះរាជអាជ្ញានិងរវាងសហចៅក្រមស៊ើបអង្កេត ។ ដូច្នេះហើយ នៅពេលដែលធ្វើសេចក្តីសម្រេចចិត្តទៅលើជម្លោះផ្ទៃក្នុង អង្គបុរេជំនុំជម្រះធ្វើសកម្មភាពនៅក្នុងមានអាណត្តិនៃលក្ខន្តិកៈរបស់ខ្លួន ។ បន្ថែមពីនេះទៀត វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់ឲ្យអង្គបុរេជំនុំជម្រះនូវឧបករណ៍ដើម្បីត្រួតពិនិត្យនូវអង្គហេតុដ៏ច្រើនសន្ធឹកសន្ធាប់ប្រកបដោយយុត្តិធម៌នៅពេលមានជម្លោះកើតឡើង ។ ឧទាហរណ៍ មាត្រា៧១នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តល់ដល់អង្គបុរេជំនុំជម្រះនូវសិទ្ធិអំណាចដើម្បីធ្វើការត្រួតពិនិត្យឲ្យបានល្អិតល្អន់ទៅលើអង្គហេតុនៅពីខាងក្រោយការមិនព្រមព្រៀងគ្នានេះ ។ មាត្រា៧១(៤)(ខ) បានផ្តល់ដល់អង្គជំនុំជម្រះនូវសិទ្ធិអំណាចក្នុងការចេញដីកាឲ្យបង្ហាញខ្លួនរបស់សហព្រះរាជអាជ្ញា ព្រមទាំងការបង្ហាញជូននូវការរកឃើញ ។ ការពិចារណាទាំងនេះបង្ហាញថាអង្គបុរេជំនុំជម្រះមានសិទ្ធិអំណាចនិងធ្វើការពិនិត្យទៅលើការមិនព្រមព្រៀងគ្នាថ្មីៗទៀត ។

## វិសាលភាពនៃការត្រួតពិនិត្យ

ដោយសារតែសហព្រះរាជអាជ្ញាហាក់ដូចជាមិនយល់ស្របថា ខ្លួនមានទាំងយុត្តាធិការនិងភ័ស្តុតាងគ្រប់គ្រាន់ក្នុងការស្នើសុំឲ្យមានការស៊ើបអង្កេតខាងផ្លូវច្បាប់បន្ថែមទៀត មិនចាំបាច់តម្រូវឲ្យអង្គបុរេជំនុំជម្រះធ្វើការស៊ើបអង្កេតទៅលើចំណុចចាប់

ផ្តើមដោយសត្យានុម័តដើម្បីធ្វើការស៊ើបអង្កេតឡើយ ប៉ុន្តែអង្គបុរេជំនុំជម្រះគួរតែកំណត់វិសាលភាពនៃការត្រួតពិនិត្យទៅលើប្រធានបទដែលសហព្រះរាជអាជ្ញាមិនយល់ស្រប ៖ ថាតើ ១) វាសមស្របដែរឬទេសម្រាប់សហព្រះរាជអាជ្ញាជាតិស្តីអំពីការស៊ើបអង្កេតបន្ថែមដោយផ្អែកលើកត្តាអត្តនោម័ត និង២) ប្រសិនបើដូច្នេះមែន ថាតើកត្តាទាំងបីដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិជំទាស់ទៅនឹងការបើកការស៊ើបអង្កេតដូវច្បាប់បន្ថែមទៀតដែរឬអត់ ។

## វិសាលភាពទៅលើឆន្ទានុសិទ្ធិចោទប្រកាន់

ដោយត្រឡប់ទៅកាន់សំណួរទីមួយ ថាតើវាសមស្របដែរឬអត់សម្រាប់សហព្រះរាជអាជ្ញាជាតិក្នុងការជំទាស់ទៅនឹងការស៊ើបអង្កេតបន្ថែមទៀតដោយផ្អែកលើលើកត្តាអត្តនោម័ត នោះវាមានសារសំខាន់ក្នុងការកត់សម្គាល់ថា សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចជាសហព្រះរាជអាជ្ញានៃសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិមានឆន្ទានុសិទ្ធិទូលំទូលាយ នៅក្នុងការជ្រើសរើសរឿងក្តីនិងជនដែលដល់ដើម្បីធ្វើការស៊ើបអង្កេតនិងចោទប្រកាន់ ។ ទោះបីជាយ៉ាងណាក៏ដោយ វិសាលភាពទៅលើឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញាត្រូវបានកម្រិតដោយកត្តាមួយចំនួនរួមមានភាពចាំបាច់សម្រាប់សហព្រះរាជអាជ្ញា ដើម្បីរក្សាភាពឯករាជ្យក្នុងការចោទប្រកាន់ និងគោរពតាមអាណត្តិរបស់តុលាការ (រួមមានការកម្រិតទៅតាមពេលវេលា ភូមិសាស្ត្រ បទល្មើស និងយុត្តាធិការទៅលើបុគ្គល) ។

ឆន្ទានុសិទ្ធិចោទប្រកាន់ទូលំទូលាយនេះគឺត្រូវបានកម្រិតផងដែរដោយភារកិច្ចជាទូទៅរបស់សហព្រះរាជអាជ្ញាក្រោមច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីស៊ើបអង្កេតនិងចោទប្រកាន់ឧក្រិដ្ឋកម្មស្ថិតនៅក្នុងដែនអាជ្ញាយុកាលរបស់តុលាការ ។ វិធានផ្ទៃក្នុង៥៣ (១) របស់អង្គជំនុំជម្រះវិសាមញ្ញចែងដោយផ្អែកថា «ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលក្នុងការជឿថា ឧក្រិដ្ឋកម្មស្ថិតក្នុងដែនអាជ្ញាយុកាលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានធ្វើឡើង ឧក្រិដ្ឋកម្មទាំងនោះគួរតែបើកការស៊ើបអង្កេតដូវច្បាប់ដោយបញ្ជូនសំណុំរឿងស៊ើបសួរបឋមទៅសហចៅក្រមស៊ើបអង្កេត...» ។ បន្ទាប់មកសហចៅក្រមស៊ើបអង្កេតត្រូវតែធ្វើការស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មទាំងនោះ ៖ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៥៥ (១) ធ្វើឲ្យការស៊ើបអង្កេតតាមផ្លូវច្បាប់ដោយសហចៅក្រមស៊ើបអង្កេត «មានភាពបង្ខំចាំបាច់ចំពោះឧក្រិដ្ឋកម្មស្ថិតនៅក្នុងដែនអាជ្ញាយុកាលរបស់អង្គជំនុំជម្រះវិសាមញ្ញ» ។ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតត្រូវតែចោទប្រកាន់ជនត្រូវចោទ ប៉ុន្តែលុះត្រាតែអំពើនោះមិនមែនជាឧក្រិដ្ឋកម្មស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញឬមិនមានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងជនដែលដល់ ។

ភារកិច្ចដើម្បីស៊ើបអង្កេតគឺត្រូវបានបន្ថែមដោយវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៧១(៤)(គ) ដែលចែងថា នៅពេលមានជម្លោះរវាងសហព្រះរាជអាជ្ញាទៅលើថាតើត្រូវស៊ើបអង្កេតឬអត់ ការស៊ើបអង្កេតនឹងធ្វើដំណើរទៅមុខតែឯង លុះត្រាតែមតិភាគច្រើនរបស់ចៅក្រមនៅអង្គបុរេជំនុំជម្រះបោះឆ្នោតដើម្បីបញ្ឈប់នូវការស៊ើបអង្កេត ៖ «ប្រសិនបើមតិភាគច្រើនដូចបានតម្រូវមិនអាចសម្រេចបានមុនពេលអង្គបុរេនោះទេ....ការសម្រេចចិត្តតែឯងនេះគឺថាសកម្មភាពឬការសម្រេចចិត្តដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាម្នាក់នឹងអាចធ្វើទៅបានឬក៏ថាសកម្មភាពឬការសម្រេចចិត្តដូចបានស្នើឡើងដោយសហព្រះរាជអាជ្ញាម្នាក់នឹងអាចធ្វើឡើង» ។

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតម្រូវយ៉ាងច្បាស់ឲ្យសហព្រះរាជអាជ្ញាពិចារណាតែទៅលើកត្តាសត្យានុម័តនៅក្នុងការជ្រើសរើសរឿងក្តីសម្រាប់ការស៊ើបអង្កេតនិងចោទប្រកាន់ ។ លក្ខន្តិកៈរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន មានលក្ខណៈស្រដៀងគ្នានេះដែរ ។ ទោះបីយ៉ាងណាក៏ដោយ ក្នុងស្ថានភាពជាក់ស្តែង សហព្រះរាជអាជ្ញារបស់តុលាការអន្តរជាតិក៏ពិចារណាទៅលើកត្តាមួយចំនួនធំក្នុងការជ្រើសរើសចុងចោទសម្រាប់ការស៊ើបអង្កេតនិងចោទប្រកាន់ ។ បន្ថែមពីនេះទៀត ព្រះរាជអាជ្ញារបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានតម្រូវឲ្យពិចារណាលក្ខណៈវិនិច្ឆ័យបន្ថែមទៀតទៅតាម

បែបបទនៃ «ផលប្រយោជន៍យុត្តិធម៌» ខណៈពេលដែល «មូលដ្ឋានសមហេតុផលមួយដើម្បីដំណើរការ» ត្រូវបានបង្កើតឡើង ។ ក្នុងនាមជាអតីតរដ្ឋអាជ្ញានៅឯសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា លូីស អាប៊ួរ ទទួលស្គាល់ភ្លាមៗថា ÷

> *ឆន្ទានុសិទ្ធិដើម្បីចោទប្រកាន់នៅចំពោះមុខសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិមានភាពធំធេងខ្លាំងជាងនៅចំពោះមុខតុលាការក្នុងស្រុក ហើយលក្ខណៈវិនិច្ឆ័យអាស្រ័យលើឆន្ទានុសិទ្ធិចោទប្រកាន់ដែលត្រូវធ្វើឡើងគឺកំណត់មិនបានល្អនិងស្មុគស្មាញ ។ តាមបទពិសោធន៍របស់ខ្ញុំ ផ្អែកទៅលើការងារនៅក្នុងសាលាក្តីទាំងពីររហូតមកដល់ពេលនេះ ខ្ញុំជឿជាក់ថា បញ្ហាពិតប្រាកដដែលកើតមានចំពោះព្រះរាជអាជ្ញា គឺត្រូវជ្រើសរើសចេញពីពាក្យបណ្តឹងសំខាន់ៗជាច្រើននូវពាក្យបណ្តឹងដែលសមរម្យដើម្បីធ្វើអន្តរាគមន៍ជាលក្ខណៈអន្តរជាតិ ។*

ការពិត បើពិនិត្យមើលទៅលើចំនួនដ៏ច្រើនរបស់ចុងចោទសំខាន់ៗ និងការរឹតត្បិតជាក់ស្តែង ការពិចារណាទៅលើកត្តាដទៃទៀតដោយព្រះរាជអាជ្ញាអន្តរជាតិ មិនត្រឹមតែសមរម្យទេ ប៉ុន្តែថែមទាំងចាំបាច់ទៀត ។

**កត្តាអត្តនោម័តដែលពាក់ព័ន្ធ**

កត្តាអត្តនោម័តមួយចំនួនដែលព្រះរាជអាជ្ញាអន្តរជាតិពិចារណានៅក្នុងការកំណត់ថាអ្នកណាដែលត្រូវស៊ើបអង្កេតនិងចោទប្រកាន់ ធ្វើឲ្យមានការព្រួយបារម្ភផ្សេងៗដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិ ។ ការព្រួយបារម្ភទាំងនេះរួមមាន ៖ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ កម្រិតនៃការទទួលខុសត្រូវរបស់ជនដែលដែលត្រូវបានចោទប្រកាន់ សណ្តាប់ធ្នាប់សាធារណៈ ធនធានមានកំណត់ និងការផ្សះផ្សាជាតិ ។ ទោះបីយ៉ាងណាក៏ដោយ គ្មានកត្តាណាមួយក្នុងចំណោមកត្តាទាំងឡាយដែលសហព្រះរាជអាជ្ញាជាតិលើកឡើងធ្វើឲ្យមានការជំទាស់ខ្លាំងនឹងការស៊ើបអង្កេតបន្ថែមឡើយ ។

ការផ្សះផ្សាជាតិដែលជាការព្រួយបារម្ភទី១របស់សហ-ព្រះរាជអាជ្ញាជាតិគឺផ្តោតនៅក្នុងលំនាំដើមនៃកិច្ចព្រមព្រៀងក្របខណ្ឌការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនមានភាពច្បាស់លាស់ទាល់តែសោះថា ការស្វែងរកការផ្សះផ្សានៅប្រទេសកម្ពុជានឹងអាចរកបានដោយការកម្រិតចំនួននៃការចោទប្រកាន់ ។ ជាការពិតណាស់ អ្នកដែលពាក់ព័ន្ធជាមួយការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជឿថា ការចោទប្រកាន់នឹងដើរតួនាទីជាវិជ្ជមានក្នុងការផ្សះផ្សា ។ តាមរបាយការណ៍ក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិបានឲ្យដំបូន្មានថា ព្រះរាជអាជ្ញារបស់ខ្មែរក្រហមក្នុងពេលអនាគតគួរតែ «នៅក្នុងករណីគោលនយោបាយចោទប្រកាន់...ប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនទាក់ទិននឹងការស៊ើបអង្កេតការចោទប្រកាន់ និងសវនាការដើម្បីពិនិត្យពិចារណាទៅលើទិសដៅក្លោះសម្រាប់ការទទួលខុសត្រូវបុគ្គលនិងការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា ។

របាយការណ៍បានអត្ថាធិប្បាយបន្ថែមទៀតថា អង្គបុរេជំនុំជម្រះមានភាពចាំបាច់ដើម្បីជួយប្រទេសកម្ពុជាឲ្យទទួលបានការផ្សះផ្សាជាតិកម្ពុជាដ៏ពេញលេញ «ប្រសិនបើអនុសាសន៍ទាំងនេះនិងអនុសាសន៍ផ្សេងទៀតរបស់យើងត្រូវអនុវត្ត...យើងជឿជាក់ថា អនុសាសន៍ទាំងអស់នេះនឹងនាំទៅរកដំណើរការមួយដែលនឹងបន្តលក្ខណៈដល់ប្រទេសកម្ពុជាឲ្យចាកផុតពីអតីតកាលប្រកបដោយសោកនាដកម្មមិនអាចគណនាបាន និងបង្កើតឲ្យមានទម្រង់ពិតប្រាកដនៃការផ្សះផ្សាជាតិនាពេលអនាគត» ។ ជាពិសេសមិនមានការស្នើឡើងនៅក្នុងរបាយការណ៍នេះដើម្បីគាំទ្រសេចក្តីអះអាងរបស់សហព្រះរាជអាជ្ញាជាតិ ជា លាង ដែលការជំរុញបន្ថែមនូវទិសដៅនៃការផ្សះផ្សាជាតិនាំឲ្យមានការកម្រិតចំនួនលើការចោទប្រកាន់ ។ ជាជំនួសវិញ របាយការណ៍ក៏បានផ្តល់ដំបូន្មានធ្វើឲ្យមានតុល្យភាពរវាងការផ្សះផ្សាជាតិនិងការទទួលខុសត្រូវរបស់បុគ្គល ។

តុលាការអន្តរជាតិ ជាពិសេសតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានដោះស្រាយការព្រួយបារម្ភចំពោះការផ្សះផ្សាជាតិ ដោយលើកទឹកចិត្តឲ្យមានការប្រព្រឹត្តទៅលើជនដែលស្មើភាពគ្នាពីភាគីជម្លោះទាំងសងខាង ។ ឧទាហរណ៍

រដ្ឋអាជ្ញារបស់តុលាការខ្មែរក្រហមអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានគូសបញ្ជាក់ថា ការស៊ើបអង្កេតរបស់ខ្លួនមិនត្រឹមតែទៅលើជនជាតិហ៊ូទូទេ ព្រមទាំងជនដែលទុតស៊ី បើទោះជាថាគ្មានការកាត់ទោសជនជាតិទុតស៊ីកន្លងមកក៏ដោយ ។ លុក កូតេ ជាអតីតសមាជិកការិយាល័យរដ្ឋអាជ្ញារបស់តុលាការខ្មែរក្រហមអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានអត្ថាធិប្បាយ «ទាក់ទងទៅនឹងអាណត្តិដែលបានផ្តល់ដល់តុលាការអន្តរជាតិដើម្បីរួមចំណែកដល់ដំណើរការផ្សះផ្សាជាតិ ព្រមទាំងការស្តារនិងថែរក្សាសន្តិភាព...លក្ខណៈវិនិច្ឆ័យដែលទាក់ទងទៅនឹងសម្ភារៈរបស់ចុងចោទ និងភាពជាប់ពាក់ព័ន្ធទៅនឹងក្រុមមួយចំនួនហាក់ដូចជាមានភាពស្របច្បាប់» ក្នុងការជ្រើសរើសចុងចោទដើម្បីធ្វើការចោទប្រកាន់ ។

ជាងនេះទៅទៀត ដោយភ្ជាប់ទៅនឹងគំនិតការផ្សះផ្សាជាតិ គឺជាកាតព្វកិច្ចរបស់តុលាការដើម្បីនិយាយ «រឿងរ៉ាវទាំងស្រុង» អំពីអ្វីដែលបានកើតឡើង ហើយនរណាជាអ្នកទទួលខុសត្រូវ ការពិចារណាដែលត្រូវបានដកស្រង់ជារឿយៗគឺដើម្បីធ្វើការពន្យល់ទៅលើការជ្រើសរើសជនជាប់ចោទ ។ ជាពិសេសការិយាល័យរដ្ឋអាជ្ញារបស់តុលាការខ្មែរក្រហមអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានគូសបញ្ជាក់យ៉ាងច្បាស់អំពីសារសំខាន់នៃបរិបទឬប្រវត្តិសាស្ត្រចាប់តាំងពីការងាររបស់តុលាការ ។ ហ្គ្រាហាម ប្លេវីត ជារដ្ឋអាជ្ញារងរបស់តុលាការខ្មែរក្រហមអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានធ្វើអត្ថាធិប្បាយថា ការិយាល័យរបស់រដ្ឋអាជ្ញាបានព្យាយាមស្វែងរកសំណុំរឿងក្តីដែលមានលក្ខណៈសំខាន់ផ្នែកប្រវត្តិសាស្ត្រ ដូចជាការសម្លាប់រង្គាលនៅស្រេប្រេនីកា ។ ស្រដៀងគ្នានេះដែរ មីណា ស្ត្រាក ជារដ្ឋអាជ្ញាម្នាក់ទៀតបានបញ្ជាក់អំពីការគោរពតាមដីកាប្រឆាំងទៅនឹងអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មនៅជំរំឃុំឃាំងរបស់អូម៉ាស្កា ។

យើងចោទប្រកាន់មេបញ្ជាការជំរំពីបទប្រល័យពូជសាសន៍ ហើយគាត់និងអ្នកផ្សេងៗទៀត ក៏ត្រូវបានចោទប្រកាន់ពីបទរំលោភលក្ខន្តិកៈរបស់តុលាការដែរ ។ យើងគិតថា ដីកានេះមានសារសំខាន់ជាពិសេស ដោយសារតែអូម៉ាស្កាជាជំរំដំបូងនៅបូស្នៀ ដែលអ្នកកាសែតអន្តរជាតិទទួលបានការអនុញ្ញាតឲ្យចូលមើលនិងថតខ្សែភាពយន្ត...ដោយសារតែកិច្ចការរបស់អ្នកទាំងអស់នេះហើយទើបសហគមន៍អន្តរជាតិចាប់ផ្តើមដោះស្រាយអំពើរំលោភសិទ្ធិមនុស្ស ដែលកើតឡើងនៅក្នុងអតីតប្រទេសយូហ្គោស្លាវី ។

ស្រដៀងគ្នានេះដែរ រដ្ឋអាជ្ញារបស់តុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានគូសបញ្ជាក់អំពីសារសំខាន់នៃការនិយាយប្រាប់រឿងរ៉ាវទាំងស្រុងអំពីបទឧក្រិដ្ឋកម្មនៅក្នុងប្រទេសរ៉្វាន់ដា ហើយបានសង្កត់ធ្ងន់ទៅលើការលាតសន្ធឹងខាងភូមិសាស្ត្រក្នុងការជ្រើសរើសមុខសញ្ញាធ្វើការចោទប្រកាន់ ។ ក្នុងកម្រិតខ្លះការលាតសន្ធឹងខាងភូមិស្ត្រអាចធានាបានថាបទពិសោធន៍តាមតំបន់ខុសៗគ្នាត្រូវបានចងក្រងជាឯកសារទុក ។ ទស្សនៈនេះត្រូវបានពិភាក្សាគ្នាជាពិសេសនៅក្នុងច្បាប់ស្តីពីសំណុំរឿងក្តីនៅឯតុលាការខ្មែរក្រហមអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ពោលគឺនៅក្នុងសំណុំរឿងក្តីរបស់ នូយ៉ាហាកា ដែលអង្គតុលាការបានផ្តល់ញត្តិដល់រដ្ឋអាជ្ញាឲ្យដកដីកានេះចេញ ។ អង្គតុលាការនៅឯតុលាការខ្មែរក្រហមអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានបញ្ជាក់អំពីទឡ្ហីករណ៍របស់រដ្ឋអាជ្ញាដែលថា «ការដកចេញនូវដីកាចោទប្រកាន់អាចមានភាពសមស្រប ដោយសារតែទិសដៅរបស់រដ្ឋអាជ្ញាត្រូវផ្តោតទៅលើហេតុការណ៍ដែលកើតមានឡើងនៅក្នុងប្រទេសរ៉្វាន់ដានៅក្នុងឆ្នាំ១៩៩៤ ហើយបានគូសបញ្ជាក់អំពីទិដ្ឋភាពទាំងស្រុងស្តីពីអំពើឧក្រិដ្ឋកម្មដែលប្រព្រឹត្តនាពេលនោះ ហើយថាទិសដៅបែបនេះនឹងមិនអាចសម្រេចបានតាមរយៈការចោទប្រកាន់នោះទេ» ។ តុលាការខ្មែរក្រហមសម្រាប់ប្រទេសរ៉្វាន់ដាបានបញ្ជាក់បន្ថែមទៀតថា នេះជាកាតព្វកិច្ចពិសេសរបស់រដ្ឋអាជ្ញាក្នុងការបង្កើតយុត្តិសាស្ត្រចោទប្រកាន់ដែលរាប់បញ្ចូលទាំងទិសដៅនៃ «ការផ្តោត» ទៅលើអំពើឃោរឃៅនៅក្នុងប្រទេសរ៉្វាន់ដា ។

របាយការណ៍ឆ្នាំ២០០៦ស្តីអំពីយុទ្ធសាស្ត្រក្នុងការកាត់ទោសរបស់តុលាការខ្មែរក្រហមអន្តរជាតិបានបញ្ជាក់ថា ឧប្បត្តិហេតុទាំងឡាយគួរត្រូវបានជ្រើសរើសដើម្បីផ្តល់ជាគំរូដែលអាចឆ្លុះបញ្ចាំងហេតុការណ៍ធំនិងចាំបាច់បំផុត និងឆ្លុះបញ្ចាំងអំពីប្រភេទដ៏ចម្បងនៃការធ្វើទុកបុកម្នេញដល់ជនរងគ្រោះ ។ តាមរយៈរបាយការណ៍នេះអាចស្មានបានថា តុលាការខ្មែរក្រហមអន្តរជាតិមិនបានផ្តោតទៅលើមេដឹកនាំខ្ពស់បំផុតទេ ឬជនណាដែលមានការទទួលខុសត្រូវនិងឆន្ទៈខ្ពស់បំផុត ដូចទៅនឹងតុលាការផ្សេងទៀតក៏ត្រូវ

បានយកមកពាក់ព័ន្ធដែរ ហើយជាអ្នកដែលដឹងរឿងរបស់មេដឹកនាំខ្ពស់បំផុត ។ លោក លូអ៊ីស ម៉ូនរ៉េណូអូខាំប៉ូ ព្រះរាជអាជ្ញារបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានគូសបញ្ជាក់ពីសារសំខាន់នៃការស៊ើបអង្កេតដោយធ្វើយ៉ាងណាឲ្យមានលក្ខណៈលំទូលាយជាងនេះថា «ការផ្តោតទៅលើការស៊ើបអង្កេតអាចធ្វើឲ្យបានទូលំទូលាយជាងការស៊ើបអង្កេតមន្ត្រីជាន់ខ្ពស់ ប្រសិនបើស៊ើបអង្កេតទៅលើប្រភេទនៃបទឧក្រិដ្ឋណាមួយ ហើយការស៊ើបអង្កេតទៅលើមន្ត្រីនៅក្រោមខ្សែរយៈនៃការបញ្ជាមានសារសំខាន់ណាស់ដើម្បីឲ្យដឹងពីបទឧក្រិដ្ឋទាំងមូល» ។

ដើម្បីឲ្យមានការបង្រួបបង្រួមជាតិ គប្បីត្រូវតែមានយល់ដឹងអំពីហេតុការណ៍ពីអតីតកាល ។ របាយការណ៍របស់ក្រុមអ្នកជំនាញបានកត់សម្គាល់ថា រដ្ឋាភិបាលកម្ពុជាបានធ្វើសំណើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បី «លើកទឹកចិត្តឲ្យមានការសញ្ជឹងគិតមួយក្នុងចំណោមប្រជាជនកម្ពុជា បំពេញនូវតម្រូវការ ហើយបើសិនចាំបាច់ដើម្បីបង្កើតជាយន្តការក្នុងការនិយាយការពិតដើម្បីផ្តល់ឲ្យមានការដឹងឮ និងយល់ដឹងកាន់តែច្រើនស្តីអំពីអំពើឃោរឃៅរបបកម្ពុជាប្រជាធិបតេយ្យ» ។ របាយការណ៍ដដែលនេះដែរបានបន្ថែមទៀតថា «រដ្ឋាភិបាលកម្ពុជាបានឆ្លើយតបទៅនឹងអ្វីដែលបានបញ្ជាក់អំពីការចង់បានរបស់ប្រជាជនកម្ពុជាសម្រាប់ភាពយុត្តិធម៌ និងការយល់ដឹងដែលមិនអាចធ្វើទៅបានទេ បើសិនជាអតីតកាលត្រូវបានបំភ្លេចចោល ។ ជាការពិតណាស់ថា ចាំបាច់ត្រូវតែយល់ដឹងពីអតីតកាល ហើយត្រូវតែធ្វើដំណើរទៅមុខជានិច្ច» ។ សារសំខាន់នៃការបើកកកាយរឿងរ៉ាវដែលអាចនាំទៅរកការបង្រួបបង្រួមជាតិ គឺគួរតែមានការកាត់ទោសចំនួនមនុស្សឲ្យច្រើនជាងនេះ ។

ក្នុងកថាមុខនៃកិច្ចព្រមព្រៀងរបស់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជាក៏បានភ្ជាប់ការបង្រួបបង្រួមជាតិទៅនិងការថែរក្សានូវសន្តិភាពនិងស្ថិរភាពផងដែរ ។ ប៉ុន្តែក៏មានការបញ្ជាក់មួយផងដែរថា អ្នកជំនាញរបស់អង្គការសហប្រជាជាតិដែលពិចារណាក្នុងរឿងបង្កើតឲ្យមានអង្គជំនុំជម្រះនេះឡើងមិនបានគិតដល់ទស្សនៈរបស់សាធារណជន ហើយគ្មានព្រះរាជអាជ្ញាអន្តរជាតិណាម្នាក់លើកឡើងអំពីក្តីបារម្ភរបស់សាធារណជនក្នុងកិច្ចពិភាក្សាដើម្បីធ្វើការសម្រេចរបស់ខ្លួនទេ ។ មុននឹងការបង្កើតអង្គជំនុំជម្រះក្នុងតុលាការកម្ពុជាឡើង ក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិមួយក្រុមរកឃើញថា ការពិចារណាទៅលើទស្សនៈរបស់សាធារណជន «មិនបានធានាឲ្យមានការការពារនូវអ្វីដែលនឹងកើតឡើង...ការកាត់ទោស» ។ របាយការណ៍របស់ក្រុមជំនាញការបានកត់សម្គាល់ថាៈ ជនសង្ស័យជាច្រើនមិនមានកងប្រដាប់អាវុធទេ ។ បើសិនជាករណីណាមួយ អ្នកដែលបានចុះចូលសារភាព ហើយមានបំណងកេណ្ឌកម្លាំងទ័ពរបស់ខ្លួនឡើងវិញដើម្បីប្រឆាំងជាមួយរដ្ឋាភិបាល យើងបានដឹងច្បាស់ថា អតីតកូនទាហានរបស់ជននោះនឹងមិនដើរតាមផ្លូវដដែលទៀតទេ ហើយនិងមិនយល់ព្រមតាមការអំពាវនាវរបស់អតីតមេរបស់ខ្លួនទៀតដែរ ។ អតីតកូនទាហានទាំងនោះសុខចិត្តរស់នៅប្រកបមុខរបរក្នុងគ្រួសារជាជាងរត់ចូលព្រៃតស៊ូម្តងទៀត ។ សំខាន់ជាងនោះទៅទៀត ដោយសារតែគោលដៅនៃការស៊ើបអង្កេតកំណត់ត្រឹមតែអ្នកដែលមានឋានៈខ្ពស់ក្នុងរវាងឆ្នាំ ១៩៧៥ និង ១៩៧៩ ហើយមិនមែនសំដៅទៅលើអតីតកម្មាភិបាលដែលមានអំណាចក្រោយឆ្នាំ១៩៧៩ ហើយជាអ្នកដែលមិនបានប្រព្រឹត្តបទឧក្រិដ្ឋពីឆ្នាំ១៩៧៥ ដល់១៩៧៩ ទេ ការដែលបារម្ភថា អ្នកនឹងផ្តាច់ខ្លួនពីរដ្ឋាភិបាលនោះមានលទ្ធភាពតិចតួចណាស់ ។

ទោះបីជាសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះរបស់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជាបានលើកបញ្ហាអំពីមតិសាធារណៈដែលអះអាងថាការបន្តឃុំខ្លួនជនជាប់ចោទគឺជាករណីយកិច្ចដ៏សំខាន់ ចៅក្រមស៊ើបអង្កេតនិងអង្គបុរេជំនុំជម្រះទាំងមូលមិនបានបង្ហាញការបកស្រាយច្បាស់ថា សាធារណជនអាចនឹងទទួលរងនូវផលលំបាកណាមួយបើសិនជាជនសង្ស័យត្រូវបានដោះលែង ។ គួរឲ្យកត់សម្គាល់ផងដែរថា តាមរយៈការការសិក្សាថ្មីមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជាក់ថាក្នុងចំណោមប្រជាជនកម្ពុជាជាងមួយពាន់នាក់ដែលមជ្ឈមណ្ឌលនេះបានធ្វើការសម្ភាសន៍ទាក់ទងទៅនឹងទស្សនៈនៃការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញា ដោយជាងពាក់កណ្តាលក្នុងចំណោមប្រជាជនទាំងនោះមានជំនឿថា ការនាំយកជនជនសង្ស័យបន្ថែមមកកាត់ទោសនឹងមិនអាចធ្វើឲ្យសង្គមមានអស្ថិរភាពឬអំពើហិង្សាទេ ។ លើស

ពីនោះទៅទៀត រដ្ឋាភិបាលមានលទ្ធភាពនិងមធ្យោបាយគ្រប់គ្រាន់ក្នុងការដោះស្រាយ ប្រសិនជាបាតុភូតអាក្រក់ណាមួយកើតឡើង ។

ក្តីបារម្ភមួយទៀតដែលលើកឡើងដោយសហព្រះរាជអាជ្ញាជាតិគឺស្តីអំពី «ទម្រង់នៃកិច្ចព្រមព្រៀង» ហើយមានការទាក់ទងទៅនឹងដែនកំណត់របស់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជាក្នុងការកាត់ទោសមេដឹកនាំជាន់ខ្ពស់និងជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់បំផុតក្នុងបទឧក្រិដ្ឋកម្ម ។ ការអនុវត្តរបស់តុលាការអន្តរ-ជាតិយល់ឃើញថា កម្រិតនៃជនជាប់ចោទដែលទទួលខុសត្រូវក្នុងបទឧក្រិដ្ឋគឺមិនមានប្រភេទច្បាស់លាស់ទេ ប៉ុន្តែគួរតែពិចារណាក្នុងការកាត់ទោសបន្ថែមទៀត ។ ប្រភេទនៃជនជាប់ចោទដែលត្រូវកាត់ទោសគឺមិនមែនចង់សំដៅលើកាត់ទោសអ្នកខាងក្រោមទៀតទេ ប៉ុន្តែដើម្បីឲ្យដឹងអំពីខ្សែរយៈក្នុងការបញ្ជាក់ពីខាងក្រោមរហូតដល់មេដឹកនាំថ្នាក់លើ ។ ព្រះរាជអាជ្ញា ខាឡា ឌេល ផុនតេ របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់ប្រទេសយូហ្គោស្លាវី និងវ៉ាន់ដា បានបកស្រាយថា «បុគ្គលមួយចំនួនដែលមិនមានតំណែងសំខាន់បានដឹងខ្លួនឯងរួចស្រេចទៅហើយថា ខ្លួនបានប្រព្រឹត្តបទឧក្រិដ្ឋជាច្រើន ហើយអំពើទាំងនោះត្រូវបានគេដឹងជាទូទៅ... បុគ្គលទាំងនេះគឺផ្តល់តួនាទីយ៉ាងសំខាន់ក្នុងការធ្វើជាគំរូ...ប្រព្រឹត្តបទល្មើសជាច្រើន» ។

ការរំពឹងទុកថា បេក្ខជនច្រើនជាងប្រាំនាក់នឹងត្រូវយកមកកាត់ទោស ដែលគាំទ្រដោយតុលាការក្រុមជំនាញការរបស់អង្គការសហប្រជាជាតិបានបដិសេធគំនិតដែលថាការកាត់ទោសគួរតែកំណត់ចំនួនយ៉ាងជាក់លាក់ទៅលើបុគ្គលដែលត្រូវចោទប្រកាន់ដោយអង្គជំនុំជម្រះក្នុងតុលាការកម្ពុជា ដោយបានអះអាងថា «ការកំណត់ចំនួនគឺមិនមានលក្ខណៈសមស្របទាល់តែសោះ...ការកំណត់ចំនួននេះគឺជាការធ្វើមិនដឹងមិនឮដល់ជនប្រព្រឹត្តបទល្មើសដែលនឹងត្រូវជាប់ក្នុងបណ្តាញជាមួយនិងកម្រិតនៃការទទួលខុសត្រូវចំពោះបុគ្គល មិនមែនប៉ះពាល់ដល់នយោបាយទេ ហើយភាពយុត្តិធម៌គឺឋិតក្នុងភាពផងនឹតផងល់» ។ ក្រុមជំនាញការបានបញ្ជាក់បន្ថែមក្នុងរបាយការណ៍ទៀតថា «យើងមិនចង់ឲ្យមានការកំណត់បុគ្គលច្រើននាក់...ដែលជាមុខសញ្ញាក្នុងការស៊ើបអង្កេតទេ...នេះគឺជាការយល់ឃើញរបស់ក្រុមជំនាញការដែលថា...ចំនួនមនុស្សដែលនិងត្រូវចោទប្រកាន់គឺរវាងពី២០ ទៅ៣០នាក់...ក្រុមជំនាញការបានជំទាស់ទៅនឹងការបង្កើតតុលាការដែលត្រូវកំណត់ចំនួនទុកជាមុនដើម្បីកាត់ទោសជនជាប់ចោទដែលមានស្រាប់» ។

នៅពេលដែលសមត្ថភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាខាមទារយុត្តិធម៌ជូនប្រជាជនធ្វើឡើងតាមតែការកំណត់នៃជនដែលត្រូវកាត់ទោស មានកត្តាជាច្រើនត្រូវបានពិចារណាដោយតុលាការអន្តរជាតិ រួមមានការបង្រួបបង្រួមជាតិ ។ ហើយកត្តាទាំងនេះនាំឲ្យសន្និដ្ឋានថា ការកាត់ទោសជនដៃដល់ច្រើនជាងនេះអាចនឹងមានផលប្រយោជន៍ច្រើនទម្រង់នៃកិច្ចព្រមព្រៀងរបស់អង្គជំនុំជម្រះវិសញ្ញក្នុងតុលាការកម្ពុជា ហើយការកាត់ទោសច្រើនជាងប្រាំនាក់អាចធ្វើឲ្យជនរងគ្រោះយល់ដឹងកាន់តែច្រើននៃកិច្ចការរបស់កម្ពុជាប្រជាធិតេយ្យ ។

ជាចុងក្រោយ ពេលវេលាស្ទួចស្ទើងនិងការខ្វះខាតធនធានហិរញ្ញវត្ថុមិនមែនជាបញ្ហាសំខាន់ក្នុងការសម្រេចចិត្តក្នុងការកំណត់ជនដៃដល់នៃតុលាការអន្តរជាតិទេ បើទោះណាជាកង្វះខាតទាំងនោះប៉ះពាល់ដល់ការពិចារណាក៏ដោយ ។ ឧទាហរណ៍មួយដូចជាក្នុងករណីជនជាប់ចោទ សេឡេប៊ីស៊ី តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីបានបញ្ជាក់ថា ការកាត់ទោសមាន «ធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់ ហើយមិនអាចរំពឹងថានឹងធ្វើកាត់ទោសរាល់ជនជាប់ចោទទាំងអស់ដែលអនុលោមតាមច្បាប់» ។ ជាមួយគ្នានោះដែរ កង្វះខាតខាងហិរញ្ញវត្ថុមិនមែនជាឧបសគ្គក្នុងការមិនបាននាំយកជនដៃដល់បន្ថែមមកធ្វើការកាត់ទោសនោះទេ ។

ហេតុដូច្នេះ ទោះបីជាអន្តរជាតិបានស្នើដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យពិចារណារឿងការស៊ើបអង្កេតបន្ថែម ក៏ការវិភាគបន្ថែមទៀតបានបង្ហាញថា មិនមានការតវ៉ាណាមួយលើកឡើងដោយសហព្រះរាជអាជ្ញាជាតិទេដែលដាក់ទម្ងន់ដល់ការស៊ើបអង្កេតថ្មីៗតាមផ្លូវច្បាប់ ។

**ការបង្ហាញការពិត**

ការពិតដែលថា ជម្លោះអំពីការកាត់ទោសជនដៃដល់បន្ថែមដែលថានឹងយកមកពិចារណាតាមការដែលលើកឡើងដោយសហ

 

ព្រះរាជអាជ្ញាជាតិថា ការធ្វើនេះគឺលើសពីច្បាប់កំណត់ក្នុងការស៊ើបអង្កេត ចំណែកឯសហព្រះរាជអាជ្ញាគិតថា ខ្លួនមានតួនាទីខាងផ្លូវច្បាប់ក្នុងការស៊ើបអង្កេតនិងកាត់ទោសជនជាប់ចោទ ។ ហេតុការណ៍ជម្លោះនេះបញ្ជាក់ឲ្យឃើញថា សហព្រះរាជអាជ្ញាត្រូវតែបង្ហាញការពិតដែលក្តីបារម្ភនោះគួរតែត្រូវយកមកពិចារណា ហើយការណ៍នេះដែរអាចសន្និដ្ឋានបានថា ការកាត់ទោសបន្ថែមមានលទ្ធភាពតិចតួចណាស់ដែលនិងអាចធ្វើទៅរួចទេ ។ ដូចបានរៀបរាប់ខាងលើរួចហើយថា គ្មានតុលាការអន្តរជាតិណាមួយមានព្រះរាជអាជ្ញាពីរក្រុមទេ ហើយក៏គ្មានយន្តការក្នុងការដោះស្រាយជម្លោះរវាងព្រះរាជអាជ្ញាដែរ ។ ទោះបីមានការបកស្រាយយ៉ាងនេះ ការលើកឡើងដោយតុលាការអន្តរជាតិនានាក្នុងការធ្វើការសម្រេចចិត្តទៅលើជនដែលត្រូវចោទប្រកាន់គួរតែទុកនាទីនេះទៅសហព្រះរាជអាជ្ញាជាតិ ។

តុលាការខក្រិដ្ឋកម្មអន្តរជាតិគឺជាអង្គកាត់ក្តីខក្រិដ្ឋកម្មអន្តរជាតិតែមួយគត់ ដែលស្រដៀងគ្នាទៅនឹងអង្គបុរេជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គបុរេជំនុំជម្រះរបស់តុលាកាខក្រិដ្ឋកម្មអន្តរជាតិមានសិទ្ធិនិងពិនិត្យឡើងវិញនូវសេចក្តីសម្រេចក្នុងការស៊ើបអង្កេតក្នុងកាលៈទេសៈមួយ ពោលគឺនៅពេលដែលព្រះរាជអាជ្ញារបស់តុលាការខក្រិដ្ឋកម្មអន្តរជាតិបានផ្តួចផ្តើមគំនិតក្នុងការស៊ើបអង្កេតអំពីស្ថានការណ៍ណាមួយមិនមែនធ្វើឡើងតាមការណែនាំរបស់រដ្ឋណាមួយ ឬក្រុមប្រឹក្សាសន្តិសុខទេ ។ ក្នុងស្ថានការណ៍នេះ អង្គបុរេជំនុំជម្រះរបស់តុលាការខក្រិដ្ឋកម្មអន្តរជាតិនៅពេលដែលរកឃើញ «មូលដ្ឋានសមហេតុផលណាមួយ» ដើម្បីដំណើរការផងត្រូវតែមានសិទ្ធិក្នុងការធ្វើការស៊ើបអង្កេតឲ្យមានលក្ខណៈពេញលេញ ។

ទាល់តែព្រះរាជអាជ្ញារបស់តុលាការខក្រិដ្ឋកម្មអន្តរជាតិសម្រេចថានឹងមិនបន្តដំណើរការកាត់ទោសបន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត ទើបបុរេអង្គជំនុំជម្រះធ្វើការពិនិត្យសេចក្តីសម្រេចនោះ ហើយទាល់តែមានការស្នើដោយរដ្ឋ និងក្រុមប្រឹក្សាសន្តិសុខ ឬដោយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រសិនបើការសម្រេចរបស់ព្រះរាជអាជ្ញាធ្វើឡើងដោយមានបំណងតែមួយគឺ «ផលប្រយោជន៍ខាងស្វែងរកយុត្តិធម៌» ។

ហេតុដូច្នេះ អង្គបុរេជំនុំជម្រះរបស់តុលាការខក្រិដ្ឋកម្មអន្តរជាតិមានសិទ្ធិខាងផ្លូវច្បាប់ដ៏មានវិសាលភាពដើម្បីពិនិត្យនូវសិទ្ធិក្នុងការធ្វើការកាត់ទោសនៅពេលដែលការសម្រេចចិត្តធ្វើឡើងដោយកត្តាសំខាន់ដូចជា ការរកឃើញដែលថាការកាត់ទោសនោះនឹងមិនបម្រើផលប្រយោជន៍យុត្តិធម៌ ។ បើនិយាយពីជម្លោះរវាងសហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាំឲ្យអាចសន្និដ្ឋានបានថា បើមិនមានជម្លោះទាក់ទងទៅនឹងមូលដ្ឋានសមហេតុផលដើម្បីដំណើរការក្តី ការសម្រេចរបស់ព្រះរាជអាជ្ញាអន្តរជាតិដើម្បីដំណើរការក្តីនេះគួរតែធ្វើឡើងដោយការសម្រេចមានកម្រិតខ្ពស់ ។ ហើយនេះជាសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញាជាតិ ដែលមិនដំណើរការនេះគឺដើម្បីបម្រើផលប្រយោជន៍ខាងយុត្តិធម៌ដែលគួរតែយកចិត្តទុកដាក់ឲ្យបានខ្ពស់បំផុត ។

ចំនួនភ័ស្តុតាងដែលសហព្រះរាជអាជ្ញាជាតិត្រូវបង្ហាញអាចនឹងមានលក្ខណៈស្រដៀងគ្នាទៅនិងការអនុវត្តរបស់តុលាការខក្រិដ្ឋកម្មអន្តរជាតិ ។ ដូចបានរៀបរាប់ខាងលើហើយថា នៅឯតុលាការខក្រិដ្ឋកម្មអន្តរជាតិ ក៏ដូចនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ព្រះរាជអាជ្ញាត្រូវផ្តួចផ្តើមគំនិតក្នុងការស៊ើបអង្កេត ប្រសិនបើមានមូលដ្ឋានហេតុផលដើម្បីដំណើរការ ។ ប៉ុន្តែនៅឯតុលាការខក្រិដ្ឋកម្មអន្តរជាតិ ព្រះរាជអាជ្ញាអាចនឹងជ្រើសរើសមិនដំណើរការប្រសិនបើមានហេតុផលត្រឹមត្រូវដែលអាចជឿថាការស៊ើបអង្កេតនឹងមិនបម្រើផលប្រយោជន៍យុត្តិធម៌ ។ ហេតុផលត្រឹមត្រូវស្រដៀងគ្នាមួយអាចមានលក្ខណៈសមស្របក្នុងការមិនយល់ព្រមនៅមុខអង្គបុរេជំនុំជម្រះ ។ អនុលោមតាមបែបបទនេះការស៊ើបអង្កេតតាមផ្លូវច្បាប់គឺតែបើកចំហរលុះត្រាតែសហព្រះរាជអាជ្ញាជាតិអាចផ្តល់ហេតុផលត្រឹមត្រូវថាហេតុអ្វីបានជាកត្តាដែលសហព្រះរាជអាជ្ញាជាតិលើកពីកាលកំណត់ដែលមិនឲ្យមានការចោទប្រកាន់មនុស្សបន្ថែម ។ បើសិនជាសហព្រះរាជអាជ្ញាជាតិមិនបានបង្ហាញភ័ស្តុតាងត្រឹមត្រូវ អង្គបុរេជំនុំជម្រះគួរតែអនុញ្ញាតឲ្យមានការស៊ើបអង្កេតបន្ថែមទៀត ហើយនឹងមានការកាត់ទោសនៅថ្ងៃអនាគត ។

**ចូណា ហ្វីរ៉ៃណាច**

 

# ជនឃោរឃៅដ៏ស្ងៀមស្ងាត់ម្នាក់

វាពិតជាកម្រណាស់ក្នុងការក្លាយជាបុគ្គលតំណាងឲ្យអំពើសាហាវឃោរឃៅ ហើយមានចម្ងល់តិចតួចណាស់ដែលថា កាំង ហ្គេកអ៊ាវ គឺជាជនតំណាងឲ្យភាពសាហាវឃោរឃៅ ។ កាំង ហ្គេកអ៊ាវ បានសារភាពពីបទឧក្រិដ្ឋកម្មរបស់ខ្លួនដ៏គួរឲ្យភ្ញាក់ផ្អើលដែលវាធ្វើឲ្យមានការលំបាកនៅក្នុងការរកពាក្យមកពិពណ៌នាពីឧក្រិដ្ឋកម្មទាំងនោះ ។ ប៉ុន្តែពាក្យនោះគឺផ្តោតទៅលើថ្ងៃដំបូងនៃការកាត់ក្តីដ៏សំខាន់របស់ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ។

បន្ទប់សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺផ្នែកខ្លះមើលទៅជាវេទិកាពិភាក្សាច្បាប់ ហើយផ្នែកខ្លះដូចជាវេទិកាល្ខោន ។ ទស្សនិកជនត្រូវបានផ្តល់កន្លែងឲ្យអង្គុយដែលស្ថិតនៅខាងក្រោយជញ្ជាំងឈើ និងកញ្ចក់ដ៏ធំមួយមានរាងជាបន្ទាត់កោងដែលអនុញ្ញាតឲ្យទស្សនិកជនអាចមើលឃើញពីដំណើរការកាត់ក្តី ក៏ដូចជាមើលឃើញរូបខ្លួនឯងដែលចាំងផ្លាតពីកញ្ចក់ ។ «ទស្សនិកជន» (សំដៅទៅលើមនុស្ស និងទីកន្លែងអង្គុយ) បានចូលទៅក្នុងបន្ទប់តុលាការបន្ទាប់ពីបានឆ្លងកាត់កន្លែងត្រួតពិនិត្យសន្តិសុខ ។ មនុស្សជាច្រើនបានឈរជាជួរដើម្បីចូលក្នុងបន្ទប់តុលាការ ហើយអ្នកយាមវិញគឺសុទ្ធតែមានជំនាញច្បាស់លាស់ដើម្បីធ្វើឲ្យដំណើរការចេញចូលចំណាយរយៈពេលខ្លី ។ ដោយបានធ្វើការឆ្លងកាត់ឧបករណ៍ដែកស៊ើបរកអ៊ីវ៉ាន់មួយក្នុងចំណោមពីរនៃឧបករណ៍នោះ ភ្ញៀវចូលរួមទស្សនាត្រូវបានផ្លាស់ចូលទៅក្នុងផ្លូវដើរដ៏វែងមានរបងអមសងខាងដើម្បីឆ្ពោះចូលទៅក្នុងអគារតុលាការ ។ ក្រុមអ្នកសារព័ត៌មានបានមកឈរតម្រៀបជួរគ្នានៅខាងក្រៅរបង រួចថតរូបអ្នកគ្រប់គ្នាដែលដើរកាត់ទីនោះ ។

អគារតុលាការហាក់បីដូចជាបន្ទប់រៀននៅវិទ្យាល័យមួយច្រើនជាងជាបន្ទប់តុលាការ ។ កាំជណ្តើរដែលធ្វើពីឥដ្ឋនិងស៊ីម៉ង់ភ្ជាប់ជាមួយបង្កាន់ដៃដែកបាននាំអ្នកចូលរួមទៅរកឧបករណ៍ស៊ើបរកអីវ៉ាន់ដែលមានជាតិដែកមួយផ្សេងទៀតដែលជាកន្លែងចាប់យកម៉ាស៊ីនថត ទូរស័ព្ទដៃ ស្ករគ្រាប់ និងស្ករកៅស៊ូ បន្ទាប់ពីការស្កេនដំបូងត្រូវបានប្រមូលយកមកដាក់នៅលើតុ ហើយរក្សាទុកនៅក្រៅបន្ទប់តុលាការ ។

នៅខាងក្នុងបន្ទប់មានកៅអីជាច្រើនស្ថិតនៅលើ «ឆាក» ទោះបីជាស្ថិតនៅឆ្ងាយពីបន្ទប់កាត់ក្តីបន្តិចក៏ដោយ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិងបុគ្គលិកបម្រើការងារនៅក្នុងតុលាការដទៃទៀតបានដើរចូលទៅក្នុងបន្ទប់តុលាការជាជួរ ហើយចូលទៅកាន់ទីកន្លែងអង្គុយរបស់ខ្លួន ដោយមានពាក់ឯកសណ្ឋានដ៏វែង មានពណ៌ខុសប្លែកគ្នា ខ្មៅឬស្វាយ និងរួមទាំងក្រវ៉ាត់កពណ៌ស ។ នៅពេលដែលក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិងបុគ្គលិកបម្រើការឲ្យអង្គតុលាការបានដើរចូល ទស្សនិកជនបានមើលទៅពួកគេដូចជាសត្វនៅក្នុងទ្រុង ខណៈពេលដែលទស្សនិកជនកំពុងតែពិនិត្យមើលលើបញ្ជីឈ្មោះដើម្បីសម្គាល់ថាអ្នកណាជាមេធាវី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលស្ថិតនៅក្នុងជាំងកញ្ចក់នោះ ។

គ្រាន់តែឮស្នូរកណ្តឹងរោទិ៍ភ្លាម ទស្សនិកជនបានក្រោកឈរដោយភាពស្ងៀមស្ងាត់ ហើយចៅក្រមទាំង៧រូបបានដើរចូលទៅក្នុងអង្គសវនាការ ។ គ្រប់ៗគ្នាបានពាក់ប្រដាប់ស្តាប់សំឡេងរបស់ខ្លួន ហើយត្រៀមចាំស្តាប់ ។ លោកប្រធានចៅក្រម និល ណុល បានបញ្ជាឲ្យអ្នកយាមគុកនាំយក ឌុច ចូលក្នុងក្របកសេះ ។ ទស្សនិកជនបាននាំគ្នាមើលដោយផ្ចិតផ្ចង់នៅពេលឃើញបុរសរាងតូចស្តើងម្នាក់ដែលមានត្រចៀកធំៗ ពាក់អាវពណ៌សជ្រះបានដើរកាត់មុខមេធាវីរបស់ខ្លួន រួចអង្គុយនៅលើកៅអីដែលបានរៀបចំរួចជាស្រេច ។ លោកប្រធានអង្គចៅក្រមបានសួរសំណួរអំពីជីវប្រវត្តិរបស់ ឌុច ថាតើគាត់មកពីខេត្តណា? តើឪពុកម្តាយគាត់នៅរស់ឬទេ? ហើយតើមានឈ្មោះអ្វីខ្លះដែល ឌុច បានប្រើនៅក្នុងដំណើរជីវិតរបស់គាត់? ឌុច បានឆ្លើយនឹងសំណួរទាំងនោះដោយសំឡេងគ្រលរខ្សោយៗ ។ គេសង្កេតឃើញថា ឌុច មានអារម្មណ៍តានតឹងនៅពេលសួរអំពីព័ត៌មានទាំងអស់នេះ ដែលហាក់ដូចជាថ្មីនិងបានលាតត្រដាងពីអាថ៌កំបាំងរបស់គាត់ បើទោះបីជា

ព័ត៌មានទាំងអស់នេះត្រូវបានគេដឹងតាំងពេលពីមុនរួចហើយក៏ដោយ ប៉ុន្តែយើងត្រូវតែគោរពទៅតាមបែបផែនរបស់ដំណើរការក្តីនេះ ។

លោកប្រធានអង្គចៅក្រមបានប្រកាសប្រាប់អ្នកចូលរួមថាក្រឡាបញ្ជីនឹងអានកថាខណ្ឌ១០រហូតកថាខណ្ឌ១៦២នៃដីកាដំណោះស្រាយដែលស្តីអំពីសេចក្តីសន្និដ្ឋានដ៏ជាក់លាក់ទាក់ទងនឹងបទដែលបានចោទប្រកាន់លើ ឌុច ។ ក្រឡាបញ្ជីបានចាប់ផ្តើមនិយាយ ចំណែកឯអ្នកចូលរួមអង្គុយចាំស្តាប់ថាតើអ្វីខ្លះដែល ឌុច កំពុងតែត្រូវបានចោទប្រកាន់ ។

ការស្តាប់និងការបកប្រែបានចាប់ផ្តើមដំណើរការ ។ មានអ្នកចូលរួមមួយចំនួនចង់ស្តាប់សំឡេងដែលឮខ្លាំងបំផុតក្នុងបន្ទប់សវនាការ ប៉ុន្តែជាអកុសលសំឡេងទាំងនោះមិនបាននិយាយជាភាសាដែលអ្នកស្តាប់អាចយល់បានទេ ។ ដូច្នេះ យើងត្រូវតែយកចិត្តទុកដាក់លើសំឡេងដែលមាននៅក្នុងប្រដាប់ស្តាប់សំឡេងរបស់យើងជំនួសវិញ ។ ប្រព័ន្ធលកសំឡេងមិនមានដំណើរការល្អប្រសើរទេ ។ ចំណែកអ្នកបកប្រែក៏មានសមត្ថភាពដើម្បីគ្រប់គ្រងដំណើរការកាត់ក្តីដែរ ប៉ុន្តែពេលខ្លះក៏បានបង្អាក់សកម្មភាពរបស់តុលាការ ដោយសារតែបញ្ហារអាក់រអួលផ្នែកបច្ចេកទេសកំពុងត្រូវបានកែសម្រួល ។


កាំង ហ្គេកអ៊ាវ ហៅ ឌុច

សំឡេងរបស់ក្រឡាបញ្ជីកំពុងតែប្រាប់យើងអំពីរឿងរ៉ាវដ៏អាក្រក់ដែលយើងស្ទើរតែមិនជឿថាជាការពិត និងដែលយើងប្រាថ្នាថាមិនអាចក្លាយជាការពិត ។ ប៉ុន្តែ ឌុច បានយល់ព្រមសារភាពទៅលើបទឧក្រិដ្ឋកម្មមួយចំនួនធំដែលគាត់ត្រូវបានចោទប្រកាន់ ហើយក៏មិនយល់ស្របលើព័ត៌មានមួយចំនួនតូចដែលថាគាត់មានបំណងប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះ ហើយថាគាត់បានដឹងពីរឿងនេះ ប៉ុន្តែមិនមែនដូចទៅនឹងការចោទប្រកាន់ទាំងស្រុងនោះទេ ។

ពេញមួយព្រឹក ឌុច កម្រងើបមុខឡើងលើណាស់ ។ ឌុច បានពាក់វ៉ែនតារបស់គាត់ ហើយអានដីកាដំណោះស្រាយស្របតាមក្រឡាបញ្ជី ។ សកម្មភាពរបស់ ឌុច មានសភាពយឺតៗ និងច្បាស់លាស់ដែលគ្មានអ្វីដែលធ្វើឲ្យភ្ញាក់ផ្អើលដល់អ្នកយាមដែលអង្គុយក្បែរគាត់ឡើយ ។

នៅពេលសៀល តុលាការបានធ្វើការឈប់សម្រាករយៈពេលមួយម៉ោងកន្លះ ។ ដោយការអានដីកាដំណោះស្រាយបានស៊ីពេលអស់កន្លះម៉ោង ទស្សនិកជនមានភាពសោះអង្គើយ និងមានអារម្មណ៍ថារំខានព្រោះរយៈពេលពីរម៉ោងស្តាប់តែអំពីការស្លាប់និងទុក្ខវេទនាដែលគ្មាននរណាអាចទ្រាំបាននោះទេ ។

បន្ទាប់ពីការសម្រាកពេលសៀល ឌុច បានត្រឡប់មកកាន់តុលាការវិញ ហើយចាប់ផ្តើមដំណើរការកាត់ទោសបន្ត ។ ក្រឡាបញ្ជីបានអានបន្ត ចំណែកអ្នកចូលរួមមានភាពអន្ទះអន្ទែងថាពេលណាទើបការកាត់ទោសមានដំណើរការទៅមុខ និងពេលណាទើបសេចក្តីថ្លែងការណ៍ជាបឋមចាប់ផ្តើមឡើង ។ ម្តងនេះ ឌុច នៅស្ងៀមមិនមានប្រតិកម្មឡើយ ដោយគ្រាន់តែបើកអត្ថបទចោទប្រកាន់ពីទំព័រមួយទៅទំព័រមួយ ហើយកម្រនឹងងើបមុខឡើងណាស់ ។ នៅចុងបញ្ចប់ ដីកាដំណោះស្រាយបានអានចប់ ហើយបន្ទាប់មក មេធាវីការពារក្តីរបស់គាត់ លោក ហ្វ្រង់ស័រ រូ បានក្រោកឈរនិយាយ ។ លោក ហ្វ្រង់ស័រ រូ បានសំណូមពរឲ្យអង្គជំនុំជម្រះអានកថាខណ្ឌទាំង១០បន្តទៀតពីព្រោះវាជាកថាខណ្ឌ

ដែលលោកបញ្ជាក់ថាអាចជួយសម្រាលទោសដល់គាត់បាន ។ អង្គសវនាការបានផ្អាករយៈពេលកន្លះម៉ោងដើម្បីធ្វើការពិចារណា ហើយបន្ទាប់ពីត្រឡប់មកវិញ អង្គសវនាការបានបដិសេធលើសំណូមពររបស់គាត់ ដោយផ្អែកលើមូលដ្ឋានច្បាប់ត្រឹមត្រូវសម្រាប់ការសម្រេចចិត្តរបស់ចៅក្រម ។

ចៅក្រមបានសួរទៅសហព្រះរាជអាជ្ញាថាតើមានអ៊ីចង់ធ្វើសេចក្តីថ្លែងការណ៍ជាបឋមរបស់ខ្លួនដែរឬទេ ចំណែកសហព្រះរាជអាជ្ញាខ្មែរបានមើលម៉ោង (ម៉ោង៣) និង ស្មានទុកពីរយៈពេលសម្រាប់ការអានសេចក្តីថ្លែងការណ៍បឋម (រយៈពេល២ម៉ោង) រួចបានស្នើសុំថា សេចក្តីថ្លែងការណ៍បឋមគួរតែចាប់ផ្តើមដំណើរការនៅព្រឹកថ្ងៃស្អែក ។ ការពិភាក្សាមួយភ្លែតរបស់ចៅក្រមបានសម្រេចយល់ព្រមថាផ្អាកការកាត់ទោសត្រឹមថ្ងៃនេះសិនដែលសំឡេងប្រតិកម្មរបស់អ្នកចូលរួមបានបញ្ជាក់ថា នេះអាចជាការសម្រេចចិត្តមួយដែលអ្នកចូលរួមមិនពេញចិត្ត ។ អ្នកចូលរួមទាំងអស់នេះអញ្ជើញមកស្តាប់ដំណើរការកាត់ទោសមិនមែនមកស្តាប់ការអានឯកសារដែលត្រូវបានអានពុំៗជាសាធារណៈនោះទេ ។

ឌុច បានចាកចេញពីបន្ទប់តុលាការយ៉ាងស្ងប់ស្ងាត់ ហើយបន្ទាប់ពីចេញទៅបាត់ វាពិតជាពិបាកណាស់ក្នុងការចាំថា ឌុច បានមានវត្តមាននៅទីនេះ ។ វត្តមានរបស់ ឌុច គឺមិនមែនជាវត្តមានធំដុំទេ ។ ប្រសិនបើទុកឲ្យ ឌុច ស្ថិតនៅក្នុងកាលៈទេសៈមួយដែលដាច់ដោយឡែកតែឯងនោះ វាប្រាកដណាស់ថាយើងអាចមិនចាំថាគាត់មិនមានវត្តមាននៅក្នុងបន្ទប់សវនាការ ។ ប៉ុន្តែ យើងមិនអាចបំភ្លេចពាក្យទាំងអស់ដែលពិពណ៌នារាល់សកម្មភាពដែលគាត់បានប្រព្រឹត្តនោះទេ ។ លើសពីនេះទៅទៀត យើងមិនអាចធ្វើព្រងើយកន្តើយលើបទឧក្រិដ្ឋកម្មរបស់ ឌុច បានឡើយ ។ ថ្ងៃស្អែក ថ្ងៃស្អែកបន្ទាប់ទៀត និងថ្ងៃបន្ទាប់ទៀត ឌុច នឹងដើរចូល ដើរចេញពីបន្ទប់តុលាការជាមួយនឹងឥរិយាបថដ៏ស្ងប់ស្ងាត់របស់គាត់ ហើយប្រឈមមុខនឹងការកាត់ទោសសម្រាប់អំពើប្រល័យពូជសាសន៍ដ៏សាហាវឃោរឃៅបំផុតដែល ឌុច បានប្រព្រឹត្តលើមនុស្សល្អទាំងនោះ ។ ហើយយើងទាំងអស់គ្នានឹងរង់ចាំមើល ។

**ន័រម៉ែន ហេនរី ប៉េនធេឡូវិច**



សិស្សានុសិស្សតម្រង់ជួរចូលស្តាប់សវនាការ ឌុច

# តើប្រជាជនកម្ពុជាគួរតែអត់ឱនដល់មេដឹកនាំខ្មែរក្រហមដែរឬទេ?

យោងតាមសារព័ត៌មានគ្រីស្ទៀនសាយអ៊ិនម៉ូនីទ័រ ចេញផ្សាយថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៩ កាំង ហ្កេកអ៊ាវ ដែលស្គាល់ជាទូទៅថា ឌុច គឺជាមនុស្សម្នាក់ក្នុងចំណោមអតីតមេដឹកនាំខ្មែរក្រហម៥នាក់ដែលបានឆ្លើយសារភាពកំហុសនិងសម្តែងការសោកស្តាយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ មេដឹកនាំ៤នាក់ទៀតនៅតែរក្សាមនោគមន៍វិជ្ជាកុម្មុយនីស្តដែលថាអំពើរបស់ខ្លួនបានបង្កការឈឺចាប់ ប៉ុន្តែជាជំហានសំខាន់ដែលទាមទារឲ្យមានដើម្បីប្រែក្លាយប្រទេសកម្ពុជាទៅជាសង្គមកុម្មុយនីស្ត ។

ទាក់ទងទៅនឹងរយៈពេលដ៏យូរដែលប្រជាជនកម្ពុជារង់ចាំយុត្តិធម៌និងចំនួនមេដឹកនាំខ្មែរក្រហមដែលបានរត់គេចខ្លួនឬស្លាប់មុនពេលដែលពួកគេឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មរបស់ខ្លួននេះអាចយល់បានថាប្រជាជនកម្ពុជាជាច្រើននាក់មានអារម្មណ៍រំជើបរំជួលខ្លាំងទាក់ទិននឹងអ្នកដែលត្រូវកាត់ទោស ។

តាមពាក្យរបស់ព្រះពុទ្ធ មេដឹកនាំទាំង៤នាក់ដែលត្រូវកាត់ទោសគឺកំពុងទទួលរងពីភាពភាន់ភាំង ។ ខ្ញុំគួរតែគាំទ្រពាក្យរបស់ព្រះពុទ្ធរៀងរាល់ថ្ងៃ ពេញ១ថ្ងៃ មេដឹកនាំទាំងនោះគួរតែដាក់ឲ្យប្រឈមមុខនឹងការពិតចំពោះអ្វីដែលគោលនយោបាយនិងសកម្មភាពរបស់គេដែលបានដឹកនាំការរស់នៅរបស់ប្រជាជន ។ មេដឹកនាំទាំងនោះគួរតែដាក់ឲ្យប្រឈមមុខនឹងអ្វីដែលជនកុម្មុយនីស្តហៅថា «ការកសាងខ្លួន» ដូច្នេះទើបអាចបង្ខំឲ្យមេដឹកនាំទាំងនោះទទួលស្គាល់ថា ពួកគេមិនត្រឹមត្រូវឡើយដែលថាអំពើរបស់ខ្លួនគឺជាការចាំបាច់ ។ ខ្ញុំគិតថា ប្រជាជនកម្ពុជាគ្រប់រូបដែលមានសមាជិកគ្រួសារម្នាក់ត្រូវបានសម្លាប់ឬធ្វើទារុណកម្មគួរតែមានសិទ្ធិដើម្បីនិយាយផ្ទាល់ជាមួយអ្នកនោះម្នាក់ក្នុងចំណោមអ្នកទោសទាំងនេះ ។ មិនគួរមានទណ្ឌកម្មផ្នែករាងកាយទៅលើអ្នកទោសទាំងនេះឡើយ ប៉ុន្តែពួកគេគួរតម្រូវឲ្យស្តាប់ពាក្យរបស់ប្រជាជនដែលជីវិតរបស់ពួកគេត្រូវបានរងការប៉ះទង្គិច ។ អ្នកទោសទាំងនេះគួរតែស្តាប់នូវការថ្លែងរបស់ជនរងគ្រោះនិងប្រជាជនកម្ពុជាគ្រប់រូបដែលបានទទួលរងគ្រោះក្រោមរបបខ្មែរក្រហម ដោយមានឱកាសនិយាយទៅកាន់ពួកគេ មិនថាពេលវេលាច្រើនប៉ុណ្ណាដែលគួរតែចំណាយនោះទេ ។ ប្រសិនបើវាចំណាយពេលច្រើនឆ្នាំ យ៉ាងហោចណាស់នោះគឺជាអ្វីដែលប្រជាជនកម្ពុជាសមនឹងទទួលបាន ។

ផ្ទុយទៅនឹងមេដឹកនាំទាំង៤នាក់ដែលមិនមានការសោកស្តាយ អ្នកទោសទី៥ ឌុច បានសារភាពកំហុសរបស់ខ្លួន ហើយទទួលស្គាល់កំហុសចំពោះអ្វីដែលគាត់បានធ្វើ ។ នេះពិតជាចម្លើយដ៏ប្រសើរ ហើយសង្ឃឹមថាសេចក្តីថ្លែងអំពីការសុំទោសរបស់គាត់នឹងក្លាយជាការលួងចិត្តខ្លះដល់អ្នកដែលត្រូវបានធ្វើបាប ។ ដោយបានសារទោសកំហុស ឌុច មិនគួរទទួលរងទណ្ឌកម្មផ្នែករាងកាយ ឬការកសាងខ្លួនដែលអ្នកទោសដទៃទៀតគួរតែទទួលឡើយ ។

ប៉ុន្តែបន្ថែមទៅនឹងចំណុចនេះ ឌុច ស្នើសុំការអត់ឱនពីប្រជាជនកម្ពុជាដោយសំដៅដល់សាសនាគ្រីស្តដែលគាត់បានចូល ។ ខ្ញុំនឹងបង្ហាញជូនអំពីគំនិតរបស់ខ្ញុំក្នុងនាមជាមនុស្សម្នាក់ដែលធ្លាប់ត្រូវបានចិញ្ចឹមឲ្យក្លាយជាគ្រីស្តសាសនិក ។ ទោះបីឥឡូវនេះ ខ្ញុំគឺជាពុទ្ធសាសនិកនៅក្នុងជំនឿរបស់ខ្ញុំ ក៏ខ្ញុំស្គាល់ច្បាស់អំពីគំនិតរបស់សាសនាគ្រីស្តដែរ ។ តាមការពិត នៅពេលខ្ញុំនៅក្មេង ខ្ញុំមានជំនឿយ៉ាងខ្លាំងថា គោលដៅរបស់ខ្ញុំនៅក្នុងជីវិតត្រូវក្លាយជារដ្ឋមន្ត្រីសាសនាគ្រីស្តម្នាក់ ។

ខ្ញុំយល់ច្បាស់ខ្លាំងណាស់ថាហេតុអ្វីបានជាគ្រីស្តសាសនាមានការទាក់ទាញយ៉ាងខ្លាំងចំពោះមនុស្សម្នាក់ដូចជា ឌុច ។ ពុទ្ធសាសនិកជឿលើកម្មផល ហើយថាអ្វីដែលកើតឡើងចំពោះយើងគឺដោយសារតែអំពើរបស់យើងកាលពីអតីតកាល ។ គ្មានផ្លូវណាដែលអាចគេចផុតពីកម្មផលឡើយ ។ សម្រាប់មនុស្សម្នាក់ដែលបានប្រព្រឹត្តបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរចំពោះអ្នកដទៃ ដូចជា ឌុច ព្រះពុទ្ធសាសនាមិនផ្តល់ក្តីសង្ឃឹមឲ្យមានការរួចខ្លួនចំពោះលទ្ធផលអាក្រក់ដែលកើតមកពីអំពើអាក្រក់ឡើយ ។ អ្វីៗដែលគាត់អាចធ្វើបានគឺព្យាយាមធ្វើអំពើល្អនៅពេលអនាគតដើម្បីកែប្រែអំពើបាបរបស់ខ្លួន ។ ប៉ុន្តែគាត់មិនអាចគេចផុតពីបាបកម្មនោះទេ ។

ផ្ទុយស្រឡះមកវិញ សាសនាគ្រីស្ទមានភាពខុសប្លែកចំពោះការអត់ឱន ។ យោងតាមគ្រីស្ទ សាសនិក ដោយគ្រាន់តែសុំព្រះយេស៊ូឲ្យអត់ឱន ហើយសន្យាធ្វើតាមព្រះយេស៊ូអស់មួយជីវិត មនុស្សម្នាក់អាចត្រូវបានលើកលែងទោសចំពោះអំពើពីអតីតកាល មិនថាអំពើធ្ងន់ធ្ងរប៉ុណ្ណាឡើយ ។ ទស្សនៈអត់ឱនមិនដែលមានលក្ខខណ្ឌបែបនេះគឺជាហេតុផលមួយក្នុងចំណោមហេតុផលសំខាន់ៗជាច្រើនដែលធ្វើឲ្យសាសនាគ្រីស្ទបានរីករាលដាលជាច្រើនសតវត្សរ៍មកនេះ ។ បុគ្គលណាក៏ដោយអាចសុំអង្វរឲ្យព្រះអត់ឱនមិនថាអំពើរបស់ខ្លួនអាក្រក់យ៉ាងណាឡើយ ។

ចេញពីអ្វីដែលខ្ញុំបានអាន ខ្ញុំមិនមានការសង្ស័យថា ឌុច ស្មោះស្ម័គ្រទទួលយកគ្រីស្ទសាសនាឡើយ ។ នរណាមួយដែលមិនមានភាពម៉ឺងម៉ាត់ក្នុងការធ្វើតាមសាសនាដែលផ្តល់ការអត់ឱនទោសចំពោះឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មជាច្រើនរបស់ប្រទេស? ខ្ញុំរីករាយដែលថា ឌុច បានសហការជាមួយអ្នកស៊ើបអង្កេត ។ ប្រសិនបើ ឌុច ពិតជាស្មោះត្រង់អស់ពីចិត្ត ជឿលើការសន្យារបស់ព្រះគ្រីស្ទនូវឋានសួគ៌បន្ទាប់ពីគាត់ស្លាប់ នោះគាត់នឹងទទួលបានរង្វាន់ក្នុងការជួយបន្ធូរដល់មនសិការរបស់គាត់ ។

ទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំជឿទាស់យ៉ាងខ្លាំងថា រាល់ការកាត់សេចក្តីទៅលើ ឌុច មិនគួរត្រូវបានប៉ះពាល់ដោយសារការអះអាងរបស់គាត់ក្នុងការជឿលើសាសនាគ្រីស្ទឡើយ ។ តុលាការត្រូវតែអព្យាក្រឹតតាមបែបបទរបស់ខ្លួន ហើយមិនអាចផ្តល់ការអនុគ្រោះនិយមចំពោះសាសនាមួយលើសាសនាដទៃទៀតឡើយ ។ សាសនាគ្រីស្ទបានជួយ ឌុច ឲ្យទទួលយកភាពជាក់ស្តែងចំពោះសារជាតិបទឧក្រិដ្ឋរបស់គាត់ ហើយរាល់ការកាត់សេចក្តីគួរតែទទួលស្គាល់ការសហការរបស់គាត់ជាមួយការស៊ើបអង្កេត ។ ខ្ញុំមិនប្រាថ្នាឃើញ ឌុច ទទួលរងការឈឺចាប់ទេ ។ ប៉ុន្តែវាសំខាន់សម្រាប់អនាគតរបស់មនុស្សជាតិដែលថាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិគួរតែមិនអាចគេចផុតពីផលវិបាកនៃសកម្មភាពរបស់ខ្លួនដោយសារការអះអាងផ្នែកជំនឿសាសនាឡើយ ។

ឌុច ទទួលបានរង្វាន់របស់គាត់រួចហើយ សម្រាប់ការធូរស្បើយខាងផ្លូវចិត្តដែលគាត់មានអារម្មណ៍ថាដូចជាមនុស្សម្នាក់ដែលត្រូវបានអត់ឱនដោយសាសនាថ្មីរបស់គាត់ ។ ប្រសិនបើបានប្រព្រឹត្តអំពើឧក្រិដ្ឋសាហាវប្រឆាំងនឹងមនុស្សដូច្នោះ ខ្ញុំក៏ប្រហែលជាស្វែងរកសាសនាដែលជួយឲ្យខ្ញុំចៀសផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មកាលពីអតីតកាលដែរ ។ ហើយខ្ញុំទំនងជាបញ្ចុះបញ្ចូលខ្លួនឯងថាខ្ញុំស្មោះស្ម័គ្រនៅក្នុងជំនឿរបស់ខ្ញុំ ។

នៅសហរដ្ឋអាមេរិក មួយភាគធំនៃអ្នកទោសដែលកំពុងប្រឈមមុខនឹងការប្រហារជីវិតគឺជាគ្រីស្ទសាសនិក ។ ប៉ុន្តែការជឿលើព្រះយេស៊ូមិនមែនជាហេតុផលដើម្បីសុំឲ្យតុលាការកាត់បន្ថយការកាត់សេចក្តីឡើយ ។ នេះគួរតែអនុវត្តដូចគ្នាទៅនឹងតុលាការកម្ពុជាឬតុលាការអន្តរជាតិដទៃទៀត ។

ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលខ្ញុំមិនគាំទ្រការកាត់ទោសប្រហារជីវិត ដោយសារតែការកាត់ទោសប្រហារជីវិតមានការអត់ឱនខ្លាំងពេក ។ បុគ្គលម្នាក់ត្រូវបានប្រហារជីវិត ហើយក្រោយមកគឺជាចុងបញ្ចប់នៃជីវិតរបស់បុគ្គលនោះ ។ តាមទស្សនៈរបស់ខ្ញុំ បុគ្គលដែលបានប្រព្រឹត្តបទឧក្រិដ្ឋសាហាវឃោរឃៅគួរតែទទួលបានការឃុំឃាំងអស់មួយជីវិត ។ ពួកគេគួរតែដកចេញពីសង្គមដោយសារហេតុផលពីរយ៉ាង ។ ទី១) ដើម្បីការពារសង្គមពីឥទ្ធិពលអវិជ្ជមានដែលអាចកើតមាននៅពេលអនាគត ។ ទោះបីជា ឌុច មិនបានធ្វើអ្វីឲ្យលើសពីការផ្សព្វផ្សាយសាសនាគ្រីស្ទ ខ្ញុំនឹងមិនទុកចិត្តថា ឥទ្ធិពលរបស់គាត់អាចមិនល្អចំពោះអនាគតរបស់ប្រទេសកម្ពុជា ។ ទី២) អ្នកដែលប្រព្រឹត្តអំពើឧក្រិដ្ឋគួរតែឆ្លុះបញ្ចាំងទៅលើសារជាតិបទឧក្រិដ្ឋរបស់ខ្លួនសម្រាប់ជីវិតរស់នៅរបស់ខ្លួនដែលសេសសល់ ។ រាល់ថ្ងៃពួកគេគួរតែក្រឡេកមើលរូបថតរបស់មនុស្សដែលខ្លួនបានសម្លាប់ ។ មិនត្រូវដកពួកគេឲ្យចេញពីការទទួលខុសត្រូវចំពោះការឈឺចាប់ដែលខ្លួនបានបង្កឡើយ ។ កុំសម្លាប់ពួកគេ ពន្យារពេលអាយុជីវិតរបស់ខ្លួនដែលអាចឲ្យពួកគេមានពេលវេលាច្រើនដើម្បីឆ្លុះបញ្ចាំងទៅលើភាពជាក់ស្តែង ។ ត្រូវប្រាកដថា ពួកគេប្រឈមមុខនឹងការទទួលខុសត្រូវរបស់ខ្លួនជារៀងរាល់ថ្ងៃ ។

អ្នកទោសដទៃទៀតអាក្រក់ជាង ឌុច ទៅទៀត ពីព្រោះពួកគេមិនដែលទទួលស្គាល់កំហុសចំពោះអំពើសាហាវឃោរឃៅដែលពួកគេបានអុចអាលលើអ្នកដទៃ ហើយពួកគេមិនសហការជាមួយអាជ្ញាធរដើម្បីជួយផ្សះផ្សាដែលនៅតែរាលដាលនៅក្នុង

សង្គមកម្ពុជា ។ ប៉ុន្តែនោះមិនមែនបន្ទូរឲ្យ ឌុច រួចផុតពីការទទួលខុសត្រូវដែលគាត់ត្រូវតែប្រឈមឡើយ ។ ប្រសិនបើគាត់ពិតជាភ្ញាក់ខ្លួនមែន គាត់នឹងប្រើប្រាស់ជីវិតរស់នៅរាល់ថ្ងៃរបស់គាត់ដែលនៅសេសសល់ និយាយនិងសរសេរចេញនូវកំហុសចំពោះអំពើរបស់គាត់ ដូច្នេះនេះនឹងអាចក្លាយជាភ័ស្តុតាងសម្រាប់ប្រើប្រាស់ក្នុងការទប់ស្កាត់ការកើតឡើងវិញនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅពេលអនាគត ។ គាត់អាចបង្កើតការសរសេរអំពីតម្លៃដ៏អស្ចារ្យសម្រាប់មនុស្សជំនាន់ក្រោយ ប្រសិនបើគាត់អាចពន្យល់ថា យ៉ាងម៉េចទើបអាចធ្វើឲ្យគាត់យល់ថាអំពើដែលបានធ្វើគឺជាការត្រឹមត្រូវ ។ គាត់បានស្នើសុំឲ្យប្រជាជនកម្ពុជាអត់ឱនឲ្យគាត់ ។ នោះគឺអាស្រ័យលើបុគ្គលម្នាក់ៗដើម្បីសម្រេចចិត្តថាតើពួកគេអត់ឱនឲ្យគាត់ឬអត់ ។ ប្រសិនបើប្រជាជនកម្ពុជាអាចធ្វើបានដូច្នេះមែន នោះគឺជាការកត់សម្គាល់មួយដ៏អស្ចារ្យនៃការផ្សះផ្សាដែលកើតចេញពីអំពើឃោរឃៅពីអតីតកាល ។ ប៉ុន្តែសម្រាប់តុលាការផ្ទាល់ លុះត្រាតែខ្លួនប្រមែប្រមូលឲ្យបាននូវសេចក្តីប៉ងប្រាថ្នាចេញពីរាល់បុគ្គលម្នាក់ៗដែលត្រូវបានទទួលរងការធ្វើបាប នៅពេលនោះទើបតុលាការគ្មានអំណាចដោះលែងឌុច ឲ្យចេញពីមន្ទីរឃុំឃាំងឡើយ ។ ជំនឿសាសនានាពេលបច្ចុប្បន្នរបស់ ឌុច គួរតែមិនមានការជាប់ពាក់ព័ន្ធនឹងការកាត់សេចក្តីដែលផ្តល់ដោយតុលាការនៅក្នុងរឿងក្តីរបស់គាត់ទេ ។ **ឪលធី ឌីរលៀម**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលិកទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តនៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិរ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# តួនាទីសំណងបន្ថែមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដោយមានការយល់ស្របពីរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់ ដែលត្រូវទទួលខុសត្រូវចំពោះការស្លាប់ប្រជាជនប្រមាណ ១,៧លាននាក់ នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ យើងសង្ឃឹមថាយន្តការរបស់តុលាការពិសេសនេះនឹងផ្តល់នូវវិធីសាស្ត្រមួយដើម្បីនាំយកនូវយុត្តិធម៌ទៅឲ្យជនរងគ្រោះនៅកម្ពុជា ។ ប្រជាជនកម្ពុជាជាច្រើនសង្ឃឹមថា នៅអំឡុងពេលកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម គេនឹងអាចឮការពិតអំពីរបបនោះ រួមទាំងមូលហេតុដែលថាហេតុអ្វីបានជាមេដឹកនាំទាំងនោះបង្កើតគោលនយោបាយដែលបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់ជាច្រើន ។ ទោះបីនោះជាការសម្រេចចិត្តរបស់ចៅក្រមថាតើត្រូវកាត់ទោសជនដែលត្រូវចោទឲ្យនៅជាប់ឃុំឬដោះលែង ក៏ជនរងគ្រោះជាច្រើនដែលបានបាត់បង់អ្នកជាទីស្រឡាញ់របស់ខ្លួននិងអ្នកដែលបានជួបប្រទះការឈឺចាប់ដោយផ្ទាល់ចង់ឃើញមេដឹកនាំខ្មែរក្រហមត្រូវបានដាក់ទោសឲ្យធ្ងន់ស្មើនឹងឧក្រិដ្ឋកម្មដែលគេបានធ្វើមកលើប្រជាជននៅអំឡុងពេលកាន់អំណាចដែរ ។

មានសំណួរថាតើតើយុត្តិធម៌ដោយការដាក់ទោសនឹងមានប្រសិទ្ធភាពក្នុងការធ្វើឲ្យជនរងគ្រោះនៃរបបខ្មែរក្រហមអាចសម្រេចបាននូវការផ្សះផ្សាផ្ទាល់ខ្លួននិងកសាងសហគមន៍បានឬទេ? ជនរងគ្រោះនិងអ្នកដែលបានបង្ហាញទស្សនៈរបស់ខ្លួននៅពេលបំពេញបែបបទចូលរួមជាជនរងគ្រោះនៅអង្គជំនុំជម្រះតែងតែសម្តែងពីសេចក្តីពេញចិត្តនឹងយន្តការយុត្តិធម៌ សំណងរបស់អង្គជំនុំជម្រះក្រោយពេលកាត់ក្តីចប់ ។ អាស្រ័យហេតុនេះ ទស្សនៈរបស់ជនរងគ្រោះមានភាពស្រដៀងគ្នាទៅនឹងជនរងគ្រោះផ្សេងទៀតនៅក្នុងពិភពលោក ។ អ៊ីនេសតូ វែដេហ្សា បានទទួលស្គាល់សុពលភាពនៃសំណើនេះថា «សំណងត្រូវបានចាត់ទុកជាគោលនយោបាយនិងទស្សនៈក្នុងបំណងស្តារឡើងវិញនូវតម្លៃនៃសីលធម៌និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ព្រមទាំងលុបបំបាត់ការធ្វើឲ្យសង្គមអន់ថយនិងការដាក់ឲ្យសេដ្ឋកិច្ចនៅដាច់តែឯង ដែលជាគោលដៅរបស់គេដើម្បីប្រែក្លាយស្ថានភាពរបស់ប្រជាពលរដ្ឋ» ។ ក៏ដូចជា វែដេហ្សា អេដ្រ ម៉ាតា មីនូ បានធ្វើកំណត់សម្គាល់ថាយុត្តិសាស្ត្រផ្តល់សំណងអាចធ្វើឲ្យជនរងគ្រោះ «បំបាត់កំហឹងនិងភាពខ្សោយ ព្រមទាំងធ្វើឲ្យជនដែលអាចចូលរួមជាមួយសហគមន៍ម្តងទៀត» ។ យោងទៅតាមសារសំខាន់នៃយុត្តិសាស្ត្រផ្តល់សំណង វាចាំបាច់ដើម្បីធ្វើការស្ទាបស្ទង់ទស្សនៈរបស់ប្រជាជនកម្ពុជាថាតើសំណងប្រភេទណាដែលគេចង់បាន ។

ជនរងគ្រោះកម្ពុជាបានធ្វើសំណើសុំជាសំណងផ្សេងៗគ្នាសម្រាប់អ្វីដែលគេបានបាត់បង់និងការឈឺចាប់ដែលគេបានទទួលនៅក្នុងសម័យខ្មែរក្រហម ។ នៅក្នុងករណីខ្លះ ជនរងគ្រោះបានស្នើសុំសំណងជាសម្ភារៈ ជាបុគ្គលចំពោះការទទួលរងការឈឺចាប់លើផ្លូវកាយ ការបាត់បង់ទ្រព្យសម្បត្តិ និងការស្លាប់សាច់ញាតិរបស់គេ ។ ជាក់ស្តែងដូចជា ជុំ ម៉ី អតីតអ្នកទោសទួលស្លែងដែលបានទទួលទារុណកម្ម និងសកម្មភាពអមនុស្សធម៌ផ្សេងៗទៀត និង ស៊ុម រិទ្ធី អតីតអ្នកទោសនៅសៀមរាប ចង់បានសំណងជាបុគ្គល ។ ជាការពិត ជងរងគ្រោះជាច្រើនចង់បានសំណងប្រាក់ជាបុគ្គលពីព្រោះអ្នកទាំងនោះជាជនក្រីក្រ ហើយមិនមានលទ្ធភាពចិញ្ចឹមជីវិត ។ ជនរងគ្រោះផ្សេងទៀតមិនយល់ស្របនឹងយុត្តិសាស្ត្រនេះទេ ដោយធ្វើការបង្ហាញថាសំណងជាប្រាក់មិនអាចធ្វើឲ្យសាច់ញាតិដែលបានស្លាប់រស់ឡើងវិញទេ ហើយក៏មិនអាចធ្វើឲ្យសុខភាពមិនល្អដែលបណ្តាលមកពីការធ្វើការងារធ្ងន់និងការបង្អត់អាហារនៅក្នុងរបបនោះល្អប្រសើរឡើងវិញដែរ ។ ដើម្បីឆ្លើយតបនឹងសំណើសុំសំណងប្រាក់ជាបុគ្គល គង់ ស្រ៊ឹម ប្រធានតុលាការកំពូលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសង្កត់ធ្ងន់ថា អង្គជំនុំជម្រះមិនអាចផ្តល់សំណងបែបនោះបានទេ ។ ទស្សនៈរបស់លោកគឺយោងទៅតាមវិធាន២៣នៃវិធានផ្ទៃក្នុងដែល «អនុញ្ញាតឲ្យជនរងគ្រោះស្នើសុំសំណងជារួមតែប៉ុណ្ណោះ» ។ យោងទៅតាមវិសាលភាពនៃវិធាននេះ សំណងជាបុគ្គលដែលនឹងធ្វើឡើងដោយ

អង្គជំនុំជម្រះនឹងមិនអាចធ្វើទៅរួចទេ ។ ជាងនេះទៅទៀត ខណៈពេលដែលប្រជាជនកម្ពុជាទាំងអស់រួមទាំងគ្រប់ជាតិពន្ធ ជាតិសាសន៍ ពូជសាសន៍ និងក្រុមនយោបាយ ដែលជាជនរងគ្រោះនៃរបបខ្មែរក្រហមដ៏ឃោរឃៅនេះ វានឹងមិនអាចធ្វើទៅបានទេក្នុងការផ្តល់សំណងជាប្រាក់ដល់បុគ្គលម្នាក់ៗ ។

អាស្រ័យហេតុនេះ យើងត្រូវតែផ្តោតទៅលើថាតើសំណងជារូមប្រភេទណាដែលអាចផ្តល់បាន ។ អ្នកនៅរស់រាប់រយនាក់ដែលបានបំពេញពាក្យបណ្តឹងជាជនរងគ្រោះនៅអង្គជំនុំជម្រះបានធ្វើសំណើសុំសំណង ។ ភាគច្រើននៃជនរងគ្រោះទាំងនេះចង់បានសំណងរួមជានិមិត្តរូបមួយដើម្បីរក្សាការចងចាំអ្នកដែលស្លាប់និងជាប្រយោជន៍ដល់ជនរងគ្រោះនិងក្មេងៗជំនាន់ក្រោយ ។ យោបល់របស់អ្នកទាំងនោះរួមមាន អគារសាលារៀន វិហារអ៊ីស្លាម វត្តបូជនីយដ្ឋាន មណ្ឌលសុខភាពនិងហេដ្ឋារចនាសម្ព័ន្ធសង្គម ។ សំណើរបស់ជនរងគ្រោះត្រូវបានបង្កើតឡើងដោយស្របទៅនឹងបរិបទវប្បធម៌និងសហគមន៍ ។ ជាឧទាហរណ៍ លោក សាន្ត សុខ ដែលជាអ្នកស្រុករស់នៅខេត្តតាកែវបានស្នើឲ្យសាងសង់បូជនីយដ្ឋានមួយដើម្បីរំឭកដល់អ្នកបានស្លាប់នៅក្នុងរណ្តៅសាកសពរួមដែលមានទីតាំងនៅក្នុងសហគមន៍របស់គាត់ ។ ដើមបណ្តឹងផ្សេងទៀតចង់បានមណ្ឌលសុខភាពសម្រាប់សហគមន៍របស់ខ្លួន ។ សម្រាប់សហគមន៍ខ្មែរ-អ៊ីស្លាមគឺចង់បានវិហារអ៊ីស្លាមដើម្បីជាសំណងដល់ការបាត់បង់សមាជិកសហគមន៍របស់គេ ។

កម្មវិធីសំណងជាយន្តការដ៏សំខាន់មួយក្នុងការទទួលស្គាល់តម្លៃនិងភាពថ្លៃថ្នូររបស់ជនរងគ្រោះ ។ រដ្ឋាភិបាលកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អន្តរជាតិគួរតែដើរតួនាទីសំខាន់ដើម្បីជួយដល់ជនរងគ្រោះទាក់ទងបញ្ហានេះ ។ ជាក់ស្តែងរដ្ឋាភិបាលកម្ពុជាគួរតែដឹកនាំកម្មវិធីសំណងដែលមានការគាំទ្រពីរដ្ឋ ។ កម្មវិធីបែបនេះអាចនឹងឆ្លើយតបសេចក្តីសម្រេចរបស់មហាសន្និបាតកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥ ដែលថា «រដ្ឋគួរតែព្យាយាមបង្កើតកម្មវិធីជាតិសម្រាប់សំណងនិងផ្តល់ជាជំនួយផ្សេងទៀតដល់ជនរងគ្រោះក្នុងករណីភាគីដែលត្រូវទទួលខុសត្រូវចំពោះការឈឺចាប់មិនអាចធ្វើទៅបាន ។ ដើម្បីជាផ្នែកមួយនៃកម្មវិធីនេះ សហគមន៍ជនជាតិ ភាគតិច ឬក៏ឃុំនីមួយៗគួរតែស្នើជាសំណងរួមមួយ ។ យោបល់ទាំងនេះនឹងដាក់ស្នើទៅរដ្ឋាភិបាលសម្រាប់ធ្វើការសម្រេចចិត្ត ។ បន្ទាប់ពីទទួលបានយោបល់របស់ជនរងគ្រោះ រដ្ឋាភិបាលនឹងប៉ាន់ប្រមាណមើលលទ្ធភាពរបស់ខ្លួននិងធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងសហគមន៍អន្តរជាតិដើម្បីជ្រើសរើសនិងអនុវត្តន៍គម្រោងសំណងជារួមដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាជនកម្ពុជា ។ **លី សុខឃៀង**



សិស្សានុសិស្សទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

# នួន ជា កាលពីក្មេងនៅទីក្រុងបាងកក (១៩៤២-១៩៥០) និងបក្សកុម្មុយនីស្តថៃ៖ ជីវិតរបស់បុរសនេះនៅទីក្រុងបាងកកដែលបានក្លាយជា"បងធំទី២" នៅក្នុងរបបខ្មែរក្រហម

***(តពីលេខមុន)***

នៅខែតុលា ឆ្នាំ២០០៣ អ្នកនិពន្ធទទួលបានលេខទូរស័ព្ទរបស់ ឧត្តម ពី ប្រាឈួប អាំផាសាវ៉េត (ដែលកើតក្នុងឆ្នាំ១៩១៩) ដែលរៀននៅថ្នាក់បញ្ចប់ជំនាន់ទី២ នៃវគ្គត្រៀមនៅសាកលវិទ្យាល័យធម្មសាត ហើយក៏ជាមិត្តភក្តិជិតស្និតរបស់ ឧត្តម ដែរ ។ អ្នកនិពន្ធបាននិយាយថា គាត់បានការណែនាំពី ប្រាឈួប, ដូនឹង ឧត្តម បានប្រាប់ ឧត្តម ថា នៅក្នុងខែសីហា គាត់បានជួប រុងឡឹត នៅក្នុងប្រទេសកម្ពុជា ដែលនៅចាំបានពីឈ្មោះ ឧត្តម ហើយគាត់មានរូបថតដែលគាត់បានថតរូប រុងឡឹត ព្រមទាំងប្រាប់ទៀតថា គាត់ចង់ជួប ឧត្តម ខ្លាំងណាស់ ហើយបានឮអំពីបទពិសោធន៍របស់គាត់ ។ ឧត្តមមានប្រតិកម្មតបតមកវិញយ៉ាងឆាប់រហ័សបន្ទាប់ពីបានឮឈ្មោះ រុងឡឹត ដោយបានសួររាងភ្ញាក់ផ្អើលថាតើ រុងឡឹត នៅរស់នៅឡើយទេ ហើយនិយាយថាគាត់បានឮកាលពីមុនថា រុងឡឹត បានធ្លាក់ពីលើខ្នងសេះស្លាប់ហើយ ។ បន្ទាប់ពីនិយាយគ្នាបានមួយភ្លែតមក ឧត្តម យល់ព្រមជួបសម្ភាសន៍ ប្រសិនបើការសម្ភាសន៍នោះធ្វើឡើងជាមួយ ប្រាឈួប ដែលជាមិត្តភក្តិដ៏ជិតស្និទ្ធរបស់គាត់ ។

នាថ្ងៃរសៀល នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៣ អ្នកនិពន្ធបានជួបជាមួយ ឧត្តម និង ប្រាឈួប នៅសណ្ឋាគារថៃ ដែលជាសណ្ឋាគារមួយនៅក្បែរអគារសភាជាតិ ដែលប្រើប្រាស់ដោយអ្នកនយោបាយថៃ ហើយបានធ្វើសម្ភាសន៍រយៈពេល៣ម៉ោងជាមួយបុរសទាំងពីរនាក់នេះ ។ បើទោះជាទើបតែជួបគ្នាលើកដំបូងក៏ដោយ ឧត្តម បាននិយាយយ៉ាងល្អ ទោះបីគាត់ហាក់ដូចជាមានភាពស្ទាក់ស្ទើរនៅត្រង់ចំណុចមួយចំនួនក៏ដោយ ។ ប៉ុន្តែទាំងអស់នេះយើងត្រូវរំពឹងគិតថានឹងកើតឡើង ដោយសារតែជាការសម្ភាសន៍លើកដំបូង ។ នោះក៏ជាអ្វីដែលអ្នកនិពន្ធធ្លាប់បានជួបប្រទះជារឿយៗនៅក្នុងបទសម្ភាសន៍ជាច្រើនជាមួយអ្នកនយោបាយថៃ ។ ដើម្បីឲ្យបានព័ត៌មានលម្អិតនិងច្បាស់លាស់ អ្នកធ្វើសម្ភាសន៍ត្រូវជួបជាមួយនឹងអ្នកផ្តល់សម្ភាសន៍ឲ្យបានច្រើនដងហើយកសាងភាពជឿទុកចិត្ត ។ រឿងមួយដែល ឧត្តម និង ប្រាឈួប ចង់ធ្វើនោះគឺការធ្វើទស្សនកិច្ចទៅប៉ៃលិន និងជួបជាមួយសមមិត្តចាស់របស់ខ្លួន ឈ្មោះ រុងឡឹត នោះជាអ្វីដែលអ្នកទាំងពីរសង្ឃឹមថា អ្នកនិពន្ធនឹងអាចរៀបចំបាន ។ ដោយមានគំនិតបែបនេះនៅក្នុងចិត្តរយៈពេលមួយឆ្នាំកន្លះក្រោយមក រហូតដល់ខែឧសភា ឆ្នាំ២០០៥ អ្នកនិពន្ធមានឱកាសនិយាយតាមទូរស័ព្ទជាមួយ ឧត្តម ជាច្រើនដង ។ នៅក្នុងខែធ្នូ ឆ្នាំ២០០៣ នៅពេលដែលគាត់ទៅទស្សនកិច្ចទីក្រុងភ្នំពេញ អ្នកនិពន្ធបានទូរស័ព្ទទៅ នួន ជា ហើយទទួលបានការយល់ព្រមឲ្យ ឧត្តម និង ប្រាឈួប ទៅសួរសុខទុក្ខ ។ តែទោះជាយ៉ាងណាក៏ដោយ ដូចដែលហេតុការណ៍បានបង្ហាញអឺចឹង ឧត្តម ហាក់មិនសូវសប្បាយរីករាយ ចំពោះការសួរសុខទុក្ខ នួន ជា ដូច ប្រាឈួប ទេ ។ បើទោះជាមានវ័យចំណាស់និងពិបាកស្តាប់សំឡេង ប្រាឈួប មានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការសិក្សាអំពីប្រវត្តិសាស្ត្រថៃបែបទំនើប ។ ប៉ុន្តែ ឧត្តម ហាក់ដូចជាបារម្ភថា បើពិនិត្យមើលអំពីអតីតកាលរបស់គាត់ជាជនកុម្មុយនីស្ត ការធ្វើទស្សនកិច្ចទៅកាន់កន្លែងមេដឹកនាំខ្មែរក្រហមធំៗបែបនេះអាចនឹងមានផលអាក្រក់ដល់មិត្តភក្តិជិតស្និទ្ធរបស់ខ្លួនដែលជាមនុស្សម្នាក់មានភាពជោគជ័យក្នុងកិច្ចការការទូតពេលបម្រើការងារនៅក្រសួងការបរទេសថៃ ។ នៅទីបញ្ចប់មិនមានការនិយាយគ្នាអ្វីទៀតទេអំពីដំណើរទស្សនកិច្ចទៅប៉ៃលិន ហើយនៅក្នុងឆ្នាំ២០០៧ ឧត្តម ក៏ស្លាប់ ។

នួន ជា បាននិយាយថា ក្នុងចំណោមជនជាតិថៃដែលគាត់បានទាក់ទងយ៉ាងសកម្មជាមួយកាលនៅទីក្រុងបាងកកគឺ ឧត្តម ចារិនវ៉េត ជាមនុស្សដំបូងបង្អស់ដែលអ្នកនិពន្ធបានជួបសម្ភាសន៍ ។ ប៉ុន្តែ ឧត្តម បានធ្វើការជាមួយ នួន ដែលជា រុងឡឹត នៅឯក្រសួងហិរញ្ញវត្ថុ ហើយបានណែនាំគាត់ឲ្យចូលក្នុងបក្សកុម្មុយនីស្តថៃនៅពេលជិតដល់ចុងបញ្ចប់នៃការស្នាក់នៅរបស់ នួន ជា នៅក្នុង

ប្រទេសថៃ ហើយក៏ជាពេលដែលជិតបញ្ចប់ការរៀនសូត្រដែរ ដូច្នេះហើយធ្វើឲ្យ ខុត្តម ក្លាយជាសកម្មជនកុម្មុយនីស្តមួយរូបនៅទីក្រុងបាងកកដែលមានឥទ្ធិពលលើ នួន ជា ។ នៅក្នុងផ្នែកខាងក្រោមដែលកំណត់ឡើងនូវមនុស្សទាំងឡាយដែលសកម្មជុលជុសជាមួយ នួន ជា ក្នុងអំឡុងពេលរបស់គាត់នៅទីក្រុងបាងកក ការបង្ហាញតាមលំដាប់លំដោយនេះធ្វើឡើងតាមពេលវេលា ដោយចាប់ផ្តើមពីអ្នកដែលបានទាក់ទងជាមួយ នួន ជា ឬ វុងឡឹត ឡោវឌី នៅទីក្រុងបាងកក ។

## ៣) រួម វង់ផាន និងអង្គការយុវជនថៃ

ក្នុងពេលធ្វើសម្ភាសន៍ នួន ជា បានប្រាប់អ្នកនិពន្ធថា គាត់ត្រូវបាន រួម វង់ផាន ហៅឲ្យចូលរួមនៅក្នុងអង្គការយុវជនថៃ ហើយថា គាត់ក៏បានចូលរួមនៅក្នុងពុទ្ធសករាជ ២៤៨៧ ឆ្នាំ (១៩៤៤) ។ នៅពេលនោះអ្នកទាំងពីរបានរស់នៅជាមួយគ្នានៅក្នុងបន្ទប់មួយដែលអ្នកទាំងពីរបានជួល (នៅត្រង់ចំណុចនេះ ក្នុងពេលធ្វើសម្ភាសន៍ នួន ជា បានឆ្លើយជុយវិញថា គាត់បានដឹងពី រួម ដែលត្រូវបានសម្លាប់នៅទីក្រុងបាងកកពីបទឧក្រិដ្ឋកម្មនៃការធ្វើចលនាកុម្មុយនីស្ត) ។ ការចូលរួមនៅក្នុង អង្គការយុវជនថៃ បានកំណត់ពីការចាប់ផ្តើមអាជីពនយោបាយរបស់ នួន ជា ហើយដើម្បីឲ្យយល់បានអំពីមនុស្សម្នាក់នេះ យើងត្រូវតែធ្វើការពិពណ៌នាអំពីថាអង្គការនេះមានលក្ខណៈបែបម៉េច ។

ក្នុងអំឡុងពេលធ្វើសម្ភាសន៍ អ្នកនិពន្ធបានសួរ នួន ជា បីដងក្រែងលោគាត់មានការភាន់ច្រឡំពីឆ្នាំដែលគាត់បានចូលរួមក្នុងអង្គការយុវជនថៃ ដែល នួន បាននិយាយថា នៅក្នុងឆ្នាំ១៩៤៤ ដោយសារតែអ្នកនិពន្ធមានការសង្ស័យថា អង្គការនេះអាចកើតមានឡើងដែរនៅពេលនោះ ។ នួន បាន និយាយរពល់ៗដងថា នោះគឺនៅក្នុងឆ្នាំ១៩៤៤ មុនពេលសង្គ្រាមបានបញ្ចប់ទៅ ។ យោងតាមបទពិសោធន៍ពីការសម្ភាសន៍មនុស្សចាស់ៗជាច្រើន អ្នកនិពន្ធដឹងថា បើទោះជាមនុស្សម្នាក់មានការចងចាំបានល្អយ៉ាងណាក៏ដោយ នៅពេលនិយាយអំពីហេតុការណ៍កាលពីជាងកន្លះសតវត្សរ៍មុន ដែលសូម្បីតែហេតុការណ៍នោះសំខាន់ចំពោះអ្នកផ្តល់សម្ភាសន៍ក៏ដោយ វាគ្មានភាពចម្លែកទេ ដែលកាលបរិច្ឆេទត្រូវបានភ្លេចត្រឹមតែពីរបីឆ្នាំក្រោយមក ។ ក្នុងពេលធ្វើសម្ភាសន៍ នួន ក៏បានប្រាប់អ្នកនិពន្ធដែរថា មុនពេលចូលបក្សកុម្មុយនីស្តនៅក្នុងឆ្នាំ១៩៥០ គាត់មានសកម្មភាពក្លៀវក្លានៅក្នុងអង្គការយុវជននេះរយៈពេលបួនឆ្នាំ ។ បើសិនជាគាត់ចូលរួមនៅក្នុងអង្គការយុវជនថៃនៅក្នុងឆ្នាំ១៩៤៤ ដូចគាត់អះអាងមែននោះ ប្រហែលជាមានរយៈពេលលើសពីបួនឆ្នាំមុនពេលចូលបក្សកុម្មុយនីស្ត ។ ច្បាស់ណាស់ថា មានការខុសឆ្គងខ្លះនៅត្រង់ចំណុចនេះ ។ ដើម្បីជម្រះចម្ងល់នេះ យើងត្រូវតែស្វែងរកឲ្យឃើញនៅពេលណា ហើយអង្គការយុវជនថៃនេះត្រូវបានបង្កើតឡើងដោយនរណា ។ ការពិនិត្យទៅលើ រួម វង់ផាន ជាមនុស្សម្នាក់ដែលហៅ វុងឡឹត ឡោវឌី ឲ្យចូលរួមអង្គការនេះអាចជួយឆ្លើយសំណួរទាំងនេះបាន ។

មិនមានលទ្ធភាពធ្វើសម្ភាសន៍ជាមួយ រួម វង់ផាន ដោយសារតែគាត់ត្រូវបានបាញ់សម្លាប់នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦២ តាមបទបញ្ជាពីជនផ្តាច់ការរបស់ប្រទេសថៃដែលមានឈ្មោះថា សារិត ថាណារ៉ាត់ ។ ដោយមិនបាននាំយករូបគាត់ទៅកាន់តុលាការ សារិត បានប្រកាសថា រួម មានកំហុសពីបទ «ទទួលការណែនាំពីជនបរទេសនៅខាងក្រៅប្រទេស ហើយព្យាយាមផ្តួលរំលំប្រព័ន្ធប្រជាធិបតេយ្យនៅក្នុងប្រទេសថៃដោយមានព្រះមហាក្សត្រជាប្រមុខរដ្ឋ ដើម្បីជំនួសរបបនេះដោយប្រព័ន្ធកុម្មុយនីស្ត» ។ ក៏ប៉ុន្តែមានឯកសារនិងសម្ភារៈសឹកអំពី រួម ក៏ដូចជាប្រជាជនទាំងឡាយដែលបានស្គាល់គាត់ ដែលអាចបង្កលទ្ធភាពឲ្យធ្វើការត្រួតពិនិត្យឲ្យកាន់តែមានលក្ខណៈជាក់លាក់ជាងនេះទៅលើជីវិតនិងសកម្មភាពរបស់គាត់ ។

គាត់កើតនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៩៧ នៅភូមិម៉ាខាឡោម ក្នុងឃុំតាំបូល បាងផ្លាម៉ា នៃខេត្តសុផាប៊ូរី ដែលជាកូនប្រុសច្បងនៃគ្រួសារកសិករមួយ ។ នៅឆ្នាំ១៩៤១ បន្ទាប់រៀនឆ្នាំទី៥នៃសាលាមធ្យមសិក្សា គាត់បានចាកចេញពីសាលាដែលគាត់បានរៀនហើយផ្លាស់ទៅសាលាសួនកុលាប ជាសាលាល្បីឈ្មោះដែលគាត់បានបញ្ចប់ការសិក្សាឆ្នាំទី៦និងថ្នាក់បញ្ចប់នៃសាលាមធ្យមសិក្សា ។ សិស្សពីរនាក់ផ្សេងទៀតដែលបានផ្លាស់ទៅសាលាសួនកុលាបនៅពេលជាមួយគ្នានោះហើយដែលបានបញ្ចប់ការសិក្សាឆ្នាំទី៦នៅសាលាមធ្យមសិក្សាដែរគឺ ចារើន វ៉ាំង៉ាម (១៩២៥-១៩៧៩) និង សុធី ណាវូវ៉ាថា (កើតនៅឆ្នាំ១៩២៧) ។ ចារើន

ស្វែងរកការពិត-វេទិកាពិភាក្សាសាធារណៈ

គឺជាអគ្គលេខាបក្សកុម្មុយនីស្តថៃពីឆ្នាំ១៩៦១ រហូតដល់គាត់ស្លាប់នៅឆ្នាំ១៩៧៩ ខណៈពេលដែល សុធី ជាប្រធាននាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិនៅក្រសួងពាណិជ្ជកម្ម ហើយក្រោយមកគឺជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៅខុទ្ទកាល័យនាយករដ្ឋមន្ត្រី ថានិន ក្រៃវិឆៀន ។ សិស្សពីរនាក់ផ្សេងទៀតដែលបានសិក្សារយៈពេល៣ឆ្នាំចុងក្រោយនៅសាលាមធ្យមសិក្សាសួនកុលាប (ដែលបានសិក្សាតាមប្រព័ន្ធរយៈពេល៣ឆ្នាំនៅឆ្នាំទី៤ ទី៥ និងទី៦ នៅសាលាមធ្យមសិក្សា) ហើយដែលនៅឆ្នាំទី៦និងឆ្នាំបញ្ចប់ នៅពេលដែល រួម, ចារើន និង សុធី បានផ្លាស់ចូលមក គឺ ថានិន ក្រៃវិឆៀន (កើតនៅឆ្នាំ១៩២៧) ហើយនិង ស៊ុមខ្វាន ភិរ៉ៃគុល (កើតនៅខែកញ្ញា ឆ្នាំ១៩២៦) ។ ថានិន គឺជានាយករដ្ឋមន្ត្រី (១៩៧៦-១៩៧៧) ហើយ ស៊ុមខ្វាន គឺជាសមាជិកគណៈកម្មាធិការកណ្តាលនៃបក្សកុម្មុយនីស្តថៃ ។ សិស្សទាំងនេះគឺជាសិស្សដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំសិក្សា១៩៤១ ដែលមាននិយាយថាពួកគេបានបញ្ចប់ការសិក្សាពីសាលាសួនកុលាបនៅពាក់កណ្តាលឆ្នាំដំបូងនៃឆ្នាំ១៩៤២ ។ ដោយពោរពេញទៅដោយកូនអ្នកមានស្តុកស្តម្ភមកពីទីក្រុងបាងកក បានបង្កើតជាក្រុមកូនសិស្សមួយដ៏ធំនៅសាលាសួនកុលាប ប៉ុន្តែ រួម ចូលចិត្តរាប់អាន ជាមួយ ស៊ុមខ្វាន និង ចារើន ដែលបានរីកធំធាត់នៅក្នុងតំបន់ក្រីក្រជាង ។

ដើម្បីចូលរៀននៅសកលវិទ្យាល័យនៅពេលនោះ បន្ទាប់ពីបញ្ចប់ការសិក្សាឆ្នាំទី៦នៃសាលាមធ្យមសិក្សា សិស្សត្រូវបញ្ចប់វគ្គត្រៀម២ឆ្នាំដើម្បីចូលសកលវិទ្យាល័យឬត្រូវមានកម្រិតនៃការអប់រំប្រហាក់ប្រហែលនេះ ។ បន្ទាប់ពីបញ្ចប់ការសិក្សាឆ្នាំទី៦នៅឆ្នាំ១៩៤២ រួម មិនបានបន្តវគ្គត្រៀមចូលសាកលវិទ្យាល័យឡើយ ។ គាត់បានចូលរៀននៅសាលាជំនួញប្រាណាខន នៅវ៉ាងប៊ូរ៉ាផាទីក្រុងបាងកក ដែលគាត់បានសិក្សាអស់រយៈពេល២ឆ្នាំ (១៩៤២,១៩៤៣-១៩៤៣-១៩៤៤) ដោយទទួលបានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចូលរៀននៅសកលវិទ្យាល័យ បន្ទាប់មកក៏បានចុះឈ្មោះចូលរៀននៅសកលវិទ្យាល័យធម្មាសាតនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៤៤ ។ លេខសម្គាល់កូនសិស្សរបស់គាត់ គឺ១៧៨៥៧ ។

នៅខែឧសភា ឆ្នាំ១៩៤៤ ក្នុងខណៈពេលសិក្សានៅសាលាជំនួញ រួម បានចូលរួមវគ្គសិក្សានាល្ងាចមួយស្តីពីសារពត៌មាននៅសកលវិទ្យាល័យជូឡាឡុងកន ។ ក្នុងចំណោមសិស្សទាំងអស់ដែលរៀនវគ្គសិក្សានេះគឺជាមិត្តរួមថ្នាក់ចាស់របស់គាត់នៅសួនកុលាប ចារើន វ៉ាំង៉ាម និងសមាជិកបក្សកុម្មុយនីស្តម្នាក់ឈ្មោះ វីរ៉ូត អាំផៃ ។ វាអាចទៅរួចដែលថានេះគឺជាចំណុចដែល រួម អាចមកទាក់ទងជាមួយបក្សកុម្មុយនីស្តថៃ ។

ដោយនិយាយអំពីលទ្ធភាពដែលអាចទៅរួចនេះទៅកាន់អ្នកនិពន្ធ ដាវី រួងសូថាំ ដែលជាមេដឹកនាំពលករនិងមនុស្សដែលមានឥទ្ធិពលនៅក្នុងបក្សកុម្មុយនីស្តថៃ បានប្រាប់ថា វីរ៉ូត បានដឹកនាំផ្នែកមួយក្នុងចំណោមផ្នែកការងារជាច្រើនថានៅក្នុងបក្សកុម្មុយនីស្តថៃ ដែលមានឈ្មោះថា សៃ មានន័យថា «ជួរ» ។ សមាជិកបក្សត្រូវបានរៀបចំជាក្រុមតាមមុខងារក្នុងជួរផ្សេងៗគ្នា ។ មានជួរ


វន វេត

សម្រាប់កម្មករ កសិករ ស្ត្រី សិស្ស មន្ត្រីរាជការ និងជួរផ្សេងៗទៀត ហើយ វីវ៉ូត បានដឹកនាំជួរបញ្ញាវន្ត ដែលទទួលខុសត្រូវចំពោះអគ្គភាពបក្សមហាជន ។ ដាវី បានពន្យល់ថា ជួរដឹកនាំដោយ វីវ៉ូត នោះហើយ ដែលបាននាំយក រួម ចូលក្នុងបក្សកុម្មុយនីស្ត ។ ហេតុការណ៍នេះកើតឡើងបន្ទាប់ពីសង្គ្រាម នៅពេលដែលសាលា ចិន ឈី គួង បានបើកទទួលសិស្សឲ្យចូលរៀន ហើយ រួម បានក្លាយជានាយកសាលាដែលនិយាយភាសាថៃ ។ អំឡុងពេលនោះហើយដែល រួម បានក្លាយជាសមាជិកបក្ស ។

ដោយយល់ស្របថា រួម បានចូលរួមបក្សកុម្មុយនីស្តថៃ បន្ទាប់ពីសង្គ្រាមបានបញ្ចប់គឺ ឡាមចៀក (សាបស៊ុនថុន) សុងខាវ៉ាក់ ដែលបានប្រាប់អ្នកនិពន្ធថា រួម បានចូលរួមក្នុងបក្សមុនការចូលរបស់បងប្រុសរបស់គាត់ ប្រាសិទ្ធិ សាបសុនថុន ដែលការចូលបក្សរបស់ខ្លួនត្រូវបានចេញផ្សាយនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៤៧ ។ មនុស្សម្នាក់ផ្សេងទៀតដែលបានចង្អុលបង្ហាញដូចគ្នានេះគឺ ប៉ា ផុង (សុមផុន អាងខាថាវង់) ជាប្រពន្ធរបស់ វីវ៉ាត អាងខាថាវង់ ១៩២១-១៩៩៧ ហើយក៏អាចស្គាល់បានតាមរយៈឈ្មោះ ហ្សាង យ័ន ដែលត្រូវបានទទួលស្គាល់ថាជាមនុស្សមានអំណាចបំផុតនៅក្នុងបក្សកុម្មុយនីស្តថៃរហូតដល់គាត់ស្លាប់ ។ ប៉ា ផុង បាននិយាយថា មិនមែនក្នុងអំឡុងសង្គ្រាមទេប៉ុន្តែបន្ទាប់ពីសង្គ្រាមបញ្ចប់ភ្លាមៗដែល រួម បានក្លាយជាមេដឹកនាំបក្សដែលមានទំនាក់ទំនងនឹងចលនានិស្សិតនៅសកលវិទ្យាល័យធម្មសាត្រ ។

អស់រយៈពេលជាច្រើនបន្ទាប់ពីមរណភាពរបស់ រួម ប្រពន្ធរបស់គាត់មិនបានយកសាកសពគាត់ទៅបូជាឡើយ ។ រហូតដល់ថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩៥ ទើបគាត់បានយកសាកសពប្តី



នួន ជា

របស់គាត់ទៅបូជា ហើយលេខចេញផ្សាយពីពិធីបុណ្យរំពុកដល់សពត្រូវបានបោះពុម្ពនៅពេលនោះមានដូចខាងក្រោមៈ «សមមិត្ត រួម បានចូលរួមចលនាបដិវត្តន៍បន្ទាប់ពីចប់សង្គ្រាមលោកលើកទី២ ។ ក្នុងអំឡុងពេលនោះ នៅពេលដែលសារព័ត៌មាន មហាជន ត្រូវបានបោះពុម្ពជាសាធារណៈ គាត់បានចូលរួមរៀបចំក្រុមសិក្សាមួយ ។ ក្នុងអំឡុងពេលសមាគមយុវជនថៃ គាត់បានចូលរួមចលនានោះដើម្បីប្រឆាំងនឹងភាពផ្តាច់ការហ្វាស៊ីស ។ គាត់បានចូលរួមនៅក្នុងចលនានិស្សិតដំបូងបង្អស់នៅសកលវិទ្យាល័យធម្មសាត្រ ។

នៅពេលដែលមានការអះអាងថា រួម វង់ផាន បានមកទាក់ទងជាមួយ វីរ៉ូត អាំងៃ និងមនុស្សរបស់គាត់នៅក្នុងបក្សកុម្មុយនីស្តថៃនៅក្នុងពេលសង្គ្រាម ការចូលរួមរបស់គាត់នៅក្នុងសកម្មភាពបដិវត្តន៍បានកើតឡើងនៅក្រោយសង្គ្រាមលោកលើកទី២បានបញ្ចប់ ហើយភ័ស្តុតាងបង្ហាញថា ការចូលរួមរបស់គាត់ក្នុងបក្សកុម្មុយនីស្តថៃប្រហែលជានៅពាក់កណ្តាលឆ្នាំ១៩៤៦ ។ វាលេចឡើងដែលថា វីរ៉ូត ជាមនុស្សដែលបានចុះបញ្ជីជាមួយរដ្ឋាភិបាលជាម្ចាស់អង្គភាពរបស់បក្ស មហាជន រួមជាមួយ ចារើន វ៉ាន់ង៉ាម ជាអ្នកកាសែតដែលជាមិត្តភក្តិនិងអតីតមិត្តរួមថ្នាក់នៅសាលាសួនកុលាប បានពាក់ព័ន្ធជាមួយការចូលរួមក្នុងបក្ស ។

ចេញពីព័ត៌មាននៅក្នុងបទសម្ភាសន៍ នួន ជា បានចាប់ផ្តើមចូលរួមក្នុងចលនាយុវជន រាប់ចាប់ពីពេលលេខចេញផ្សាយស្តីពីបុណ្យសពរបស់ រួម ដែលមានចំណងជើងថា «អំឡុងពេលដែល សារព័ត៌មាន មហាជន ត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ» ជាពេលដែល រួម វង់ផាន «បានចូលរួមក្នុងការរៀបចំក្រុមសិក្សា» ។ នួន ជា បញ្ជាក់ច្បាស់ផងដែរថា គាត់បានចូលរួមក្នុងអង្គការយុវជនថៃ ។ នេះលើកឡើងជាសំណួរថាតើអង្គការនេះដូចគ្នានៅនឹងអង្គការដែលត្រូវបានយោងទៅដល់លេខចេញផ្សាយស្តីពីពិធីបុណ្យរំពុកសាកសពរបស់ រួម ថាជាសមាគមយុវជនថៃដែរឬអត់ ។

ក្របខណ្ឌពេលវេលារបស់សំណួរនេះគឺ «អំឡុងពេលដែល សារព័ត៌មាន មហាជន ត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ» ចាប់ពីខែតុលា ឆ្នាំ១៩៧៥ សូមមើលកំណត់ចំណាំនៅចុងបញ្ចប់លេខ១២ រហូតប្រហែលឆ្នាំ១៩៥០ ហើយនៅពេលដែល រួម វង់ផាន «បានចូលរួមចលនាយុវជនដើម្បីប្រឆាំងភាពផ្តាច់ការហ្វាស៊ីស» ដូចជាភាពផ្តាច់ការខាងយោធាដែលបានត្រឡប់ចូលមកកាន់អំណាច បន្ទាប់ពីរដ្ឋប្រហារនៅខែវិច្ឆិកា ឆ្នាំ១៩៤៧ ។

អត្ថបទទស្សនាវដ្តីប្រចាំសប្តាហ៍នៅខែមករា ឆ្នាំ២០០៥ សរសេរដោយ សាណុះ ជានិតចារើន ផ្តល់ឲ្យនូវគន្លឹះសំខាន់ស្តីអំពីចលនាយុវជនរបស់បក្សកុម្មុយនីស្តថៃក្រោយសង្គ្រាម «ដើម្បីប្រឆាំងនឹងភាពផ្តាច់ការ» ។ នៅក្នុងអត្ថបទនោះ សាណុះ បានសរសេរថា នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៤៧ (ជាក់ស្តែងនៅថ្ងៃទី៧ ខែមេសា) តាមបញ្ជារបស់បក្សកុម្មុយនីស្តថៃ ក្នុងនាមជាក្រុមយុវជនថៃ គាត់បានរៀបចំការប្រជុំមួយនៅក្នុងមូលដ្ឋានស្ថិតនៅចំពីមុខរាជវាំងធំ (សាណាមហ្លួង) ដើម្បីជំទាស់ទៅនឹងផែនការរដ្ឋប្រហារដើម្បីស្តារអំណាចផ្តាច់ការយោធា យោងតាមរបាយការណ៍ព័ត៌មានចេញផ្សាយនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៤៧ របស់សារព័ត៌មានមហាជនបានបញ្ជាក់ថា ការប្រជុំបានរៀបចំឡើងនៅថ្ងៃទី៧ ខែមេសា ដែលមាន វឹង មេឃដៃបុល ជាប្រធាននៃការប្រជុំ ខណៈពេលដែល សាណុះ ធ្វើជាអ្នកចាត់ចែងពិធីការ ។ ទោះបីជាឈ្មោះរបស់ រួម វង់ផាន មិនត្រូវបានសរសេរនៅក្នុងអត្ថបទនោះក៏ដោយ ក៏អត្ថបទនេះបញ្ជាក់ថា ក្រុមយុវជនដែលជំរុញដោយកុម្មុយនីស្តប្រឆាំងនឹងហ្វាស៊ីសបានកើតមានឡើងត្រឹមរដូវផ្ការីកឆ្នាំ១៩៤៧ ។

នៅខែមីនា ឆ្នាំ២០០៥ បទសម្ភាសន៍ជាមួយអ្នកនិពន្ធ សាណុះ បានផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតអំពីអំឡុងពេលឆ្នាំ១៩៤៧ ។ គាត់និយាយថា នយោបាយក្នុងស្រុកបន្ទាប់ពីសង្គ្រាមគឺស្ថិតនៅក្នុងស្ថានភាពច្របូលច្របល់ ពាក្យចចាមអារ៉ាមអំពីរដ្ឋប្រហារយោធារសាត់តាមខ្យល់ ហើយ ភីប៊ុន បានធ្វើឲ្យពាក្យចចាមអារ៉ាមនោះយល់ថា គាត់មានបំណងត្រឡប់ចូលប្រឡូកក្នុងនយោបាយវិញ ។ ក្នុងការឆ្លើយតបទៅវិញ សាណុះ បាននិយាយថាគាត់បានរៀបចំការប្រជុំប្រឆាំងនឹងរដ្ឋប្រហារនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៤៧ ជាថ្មីម្តងទៀត ដោយផ្តល់ឲ្យនូវកាលបរិច្ឆេទខុស ។ បន្ទាប់ពីការប្រជុំ អង្គការយុវជនថៃ ដែលស្គាល់យ៉ាងល្បីល្បាញថាជា «យុវជន» ត្រូវបានរៀបចំឡើង ។ មេដឹកនាំនៃអង្គការនេះឈ្មោះ រួម វង់ផាន ។ អង្គការនេះត្រូវបានធ្វើឡើងជា

*សាធារណៈ ហើយដំបូងមានតែមនុស្សបីនាក់ដែលជាសមាជិកបក្សកុម្មុយនីស្តថៃប៉ុណ្ណោះ នៅក្នុងអង្គការនេះមានដូចជា រួម សាណុះ ខ្លួនគាត់ផ្ទាល់ និង វីង មេឃដៃបុល ។ វីង ជាអតីតនាយទោនៅក្នុងកងទ័ពបានចូលរួមក្នុងបក្ស បន្ទាប់ពី សាណុះ ហើយជាសិស្សច្បងរបស់ សាណុះ ៨ឆ្នាំ ព្រមទាំងចូលចិត្តផឹកស៊ី ។ ក្រោយមក ស៊ុមខាន ភិនៃគុល កាន់ជា ស៊ុនផុនចាមុន ជាកូនស្រីរបស់ វ៉ាត ស៊ុនផុនចាមុន និងសមាជិកបក្សម្នាក់ឈ្មោះ នីខន ដែលបានបញ្ឈប់សកម្មភាពរបស់ខ្លួនភ្លាមៗបន្ទាប់ពីចូលរួមក្នុងបក្ស បានចូលរួមជាមួយអ្នកទាំងអស់ខាងលើ ។ ភាគច្រើនបំផុត សាណុះ បាននិយាយថា មានសមាជិកបក្សកុម្មុយនីស្តថៃ១០នាក់ដែលពាក់ព័ន្ធនៅក្នុងអង្គការយុវជន ។ និយាយដល់ វុងឡឺត ដែលមិនទាន់ក្លាយជាជនកុម្មុយនីស្តនៅឡើយ សាណុះ បាននិយាយថា គាត់និយាយភាសាបារាំងបានល្អ ដូច្នេះហើយ គាត់ (សាណុះ) បានឲ្យ វុងឡឺត ជួបជាមួយជនបរទេសដែលមានទំនាក់ទំនងជាមួយអង្គការយុវជន ។*

*ភ័ស្តុតាងបន្ថែមទៀតដែលបញ្ជាក់ថា អង្គការយុវជនថៃបានលេចចេញជារូបរាងត្រឹមពាក់កណ្តាលឆ្នាំ១៩៤៧ ហើយធ្វើសកម្មភាពជាចំហនោះត្រូវបានផ្តល់ដោយអត្ថបទមួយ នៅក្នុងកាសែតបាងកកប៉ុស្ត៍ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៤៧ ។ នៅក្រោមចំណងជើង «ការប្រជុំគ្នារបស់ក្រុមនិស្សិតបានទទួលដំណឹងអំពីការប្រគល់ព្រំដែនតាមការអំពាវនាវ» អត្ថបទសរសេរថា ៖*

*សន្និមថា សៀមនៅតែអាចយកទឹកដីនៅតាមព្រំដែនឥណ្ឌូចិនមួយផ្នែកដែលធ្លាប់បានប្រគល់ទៅឲ្យបារាំងមកវិញតាមរយៈការអំពាវនាវទៅអង្គការសហប្រជាជាតិ ឬតាមរយៈការចរចាជាមួយបារាំង ត្រូវបានបញ្ជាក់ដោយវាគ្មិន៣-៤នាក់កាលពីម្សិលមិញនៅក្នុងការប្រជុំជាសាធារណៈដែលគាំទ្រដោយអង្គការយុវជនសៀម ឧទាហរណ៍អង្គការយុវជនថៃ នៅក្នុងសាវ៉ាំរុំមយ៉ាហ្គាឌិន ។ ណៃ រួម វង់សេបានខ្ចី ភាសាបាលីដែលប្រកបនាមត្រកូលរបស់ រួម វង់ផាន និស្សិតនៅសកលវិទ្យាល័យផ្នែកសីលធម៌និងវិទ្យាសាស្ត្រនយោបាយ ឈ្មោះជាភាសាអង់គ្លេសហៅថា សាកលវិទ្យាល័យធម្មសាស្ត្រ បានបើកការប្រជុំនៅម៉ោង១១ព្រឹក ។ គាត់បានពន្យល់ថា ការប្រជុំបានលើកឡើងនូវទស្សនៈយល់ឃើញរបស់អ្នកដែលមានអារម្មណ៍ថា ទឹកដីនៅតាមព្រំដែនគឺជាផ្នែកមួយដ៏សំខាន់របស់សៀម ហើយដែលមានអារម្មណ៍ថា មធ្យោបាយមួយចំនួនអាចត្រូវបានរកឃើញដើម្បីយកទឹកដីនោះត្រឡប់មកវិញ...»*

*នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៤៧ លេខចេញផ្សាយរបស់សារព័ត៌មានមហាជនមាននិយាយពីរបាយការណ៍ការប្រជុំនោះ ។ នៅក្នុងអត្ថបទនោះ រួម ត្រូវបានគេហៅថាជា «ប្រធានអង្គការយុវជនថៃ» ។*

*សារព័ត៌មានបន្ថែមស្តីពីអង្គការយុវជនថៃត្រូវបានផ្តល់ឲ្យដោយ ស៊ុមខាន ភិនៃគុល (អ្នកដទៃទៀត ដែលបានផ្តល់សារព័ត៌មានបន្ថែមនឹងលើកមកនិយាយនៅពេលក្រោយ) នៅក្នុងកិច្ចសម្ភាសន៍មួយនៅខែមេសា ឆ្នាំ២០០៥ ជាមួយអ្នកនិពន្ធ ។ សារព័ត៌មានទាក់ទិននឹង ស៊ុមខាន ត្រូវបានសង្ខេបដូចខាងក្រោម៖*

*នៅពេលសន្និសីទស្តីពីសហព័ន្ធពិភពលោកដែលគាំទ្រសូវៀតរបស់យុវជនប្រជាធិបតេយ្យបានរៀបចំឡើងនៅទីក្រុងឡុងដ៍ ប្រហែលជាសន្និសីទដែលបង្កើតឡើងដោយសហព័ន្ធដែលត្រូវបានរៀបចំឡើងនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៤៥ គ្រូបង្រៀននៅសកលវិទ្យាល័យជូឡាឡុងកន សាណុះ តាំប៊ុនយុន ដែលក្រោយមកស្នាក់នៅប្រទេសអង់គ្លេស បានចូលរួមក្នុងសន្និសីទតំណាងឲ្យយុវជនប្រចាំប្រទេសថៃ ។ បន្ទាប់ពីត្រឡប់មកផ្ទះវិញ គាត់បានបង្កើតគម្រោងដើម្បីរៀបចំចលនាយុវជនប្រជាធិបតេយ្យមួយនៅក្នុងប្រទេសថៃ ។ មុនរដ្ឋប្រហារខែវិច្ឆិកា ឆ្នាំ១៩៤៧ មនុស្សមកពីប្រទេសអង់គ្លេសបានមកកាន់ទីក្រុងបាងកក ដែលពួកគេបានរៀបចំសន្និសីទយុវជនប្រជាធិបតេយ្យអន្តរជាតិនៅសារមន្ទីរជាតិ ដោយនាំយកតំណាងយុវជនមកពីប្រទេសឡាវ កម្ពុជា វៀតណាម និងម៉ាឡេស៊ី ។ សាណុះ តាំប៊ុនយុន ធ្វើជាប្រធាននៃសន្និសីទនេះ ។ គ្រូជាច្រើននៅសកលវិទ្យាល័យជូឡាឡុងកន បានចូលរួមដោយនាំយកនិស្សិតរបស់ខ្លួនមកជាមួយដែរ ។ និស្សិតសកលវិទ្យាល័យធម្មសាស្ត្រជាច្រើននាក់ក៏បានចូលរួមដងដែរ ។ ទៀង សិរិខាន់ អតីតរដ្ឋមន្ត្រីខុទ្ទកាល័យ បានឡើងថ្លែងសុន្ទរកថានៅក្នុងពិធីបើកសន្និសីទ ។ នៅពេលដែលសន្និសីទនេះបានចាប់ផ្តើមឡើង អង្គការយុវជនថៃក៏បានចាប់ផ្តើមឡើង ។ តាំង*

ពីដើម អង្គការនេះត្រូវបានហៅថា អង្គការយុវជនប្រជាធិបតេយ្យ ប៉ុន្តែពាក្យ «ប្រជាធិបតេយ្យ» គឺជាពាក្យបង្កហេតុ ដូច្នេះហើយ អង្គការនេះក៏ឈប់ប្រើឈ្មោះនេះ ហើយប្រើតែពាក្យ «យុវជន» ។ រួម និង ស៊ុមខ្វាន បានចូលរួមនៅក្នុងចលនាយុវជន ។ សុធី ណារុំរ៉ាថាត ជាមិត្តរួមថ្នាក់របស់ពួកគេនៅសាលាសួនកុលាប ក៏បានចូលរួមដែរ ប៉ុន្តែ ស៊ុមខ្វាន មិនបានដឹងថាគាត់បានក្លាយជាអ្នកចូលរួមដោយរបៀបណាឡើយ ។ ក្រោយមក សុធី បានទៅសិក្សានៅប្រទេសអាមេរិក ហើយមិនដែលបានចូលរួមបក្សកុម្មុយនីស្តទៀតឡើយ ។ វុងឡឹត ប្រហែលជាសកម្មនៅក្នុងអង្គការយុវជន ប៉ុន្តែនៅពេលនោះ ស៊ុមខ្វាន មិនដែលស្គាល់គាត់ឡើយ ។ យោងតាម ស៊ុមខ្វាន ការរីកចម្រើនរបស់សមាជិកភាពបក្សកុម្មុយនីស្តថៃកើតឡើងបន្ទាប់ពីរដ្ឋប្រហារខែវិច្ឆិកា ឆ្នាំ១៩៤៧ ។ មុនពេលនោះ ឥទ្ធិពលរបស់បក្សទៅលើយុវជនដើម្បីធ្វើចលនាអ្វីមួយនោះគឺមានភាពកម្រិត ។

សន្និសីទយុវជនប្រជាធិបតេយ្យអន្តរជាតិនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៤៧ ដែល ស៊ុមខ្វាន បានឡើងនិយាយមិនត្រូវបានធ្វើឡើងនៅសារមន្ទីរជាតិដូចដែលគាត់បានបញ្ជាក់ឡើយ ។ សន្និសីទនោះធ្វើឡើងនៅមហោស្រពជាតិរបស់នាយកដ្ឋានវិចិត្រសិល្បៈ ដែលស្ថិតនៅជាប់នឹងសារមន្ទីរជាតិ ។ យោងតាមរបាយការណ៍ចុះថ្ងៃទី១២ ខែកញ្ញា របស់សារព័ត៌មានមហាជន មួយសប្តាហ៍បន្ទាប់ពីសន្និសីទ ហើយរបាយការណ៍ផ្សេងទៀតចុះថ្ងៃទី១៥ ខែកញ្ញា នៅក្នុងកាសែត គ័ន មិនបាវ ថា យុវជនមកពី៧ប្រទេសបានចូលរួមនៅក្នុងការជួបជុំនោះ ។ ពួកគេបានសុំឲ្យយុវជនរួបរួមគ្នាដើម្បីលើកកម្ពស់សន្តិភាពពិភពលោកនិងប្រជាធិបតេយ្យ ហើយគាំទ្រចលនាជាតិដើម្បីភាពឯករាជ្យ ។ ក្នុងនាមជាតំណាងអង្គការយុវជនថៃ រួម វង់ផាន ធ្វើជាប្រធានការពិភាក្សាតាមក្រុមដែលបង្កើតបានជាតំណាងមកពីតាមបណ្តាប្រទេសមួយៗដែលបានចូលរួមនិងដឹកនាំសន្និសីទនោះ ។

នៅក្នុងការពិភាក្សាដើមដំបូង អំឡុងពេលវេលាដែលបានកំណត់ «នៅពេលសារព័ត៌មានមហាជនត្រូវបានបោះពុម្ពជាសាធារណៈ» ប្រភពឯកសារទាំងអស់លើកលែងតែមួយដែលត្រូវបានលើកឡើងអំពីការកើតមានអង្គការយុវជនថៃ និងប្រភពឯកសារមួយចំនួនទៀតបញ្ជាក់ច្បាស់ថា រួម ជាប្រធានឬបានពាក់ព័ន្ធនៅក្នុងអង្គការនោះ គឺមានតែលេខចេញផ្សាយអំពីបុណ្យរំឭកសព រួម វង់ផាន ប៉ុណ្ណោះ ដោយប្រើពាក្យថា សមាគមយុវជនថៃ ។ នេះចង្អុលបង្ហាញយ៉ាងច្បាស់ថា ការចងចាំរបស់ នួន ជា ដែលថាគាត់មានភាពសកម្មនៅក្នុងអង្គការយុវជនថៃគឺត្រឹមត្រូវ ដែលនេះគឺជាអង្គការដែល រួម វង់ផាន មានភាពសកម្ម (ជាមួយសមាជិកបក្សកុម្មុយនីស្តថៃ សាណុះ ផានិតឆារើន និង ស៊ុមខ្វាន ភីឆៃគុល មានភាពគួរឲ្យកត់សម្គាល់) ហើយលេខចេញផ្សាយអំពីបុណ្យសពរបស់ រួម នេះបើយោងតាមអង្គការយុវជនថៃ ។ ទោះបីជាឈ្មោះមិនត្រឹមត្រូវក៏ដោយ តែមានភាពស្រដៀងគ្នាដែរ ។

នៅក្នុងបទសម្ភាសន៍ នួន ជា បាននិយាយថា អង្គការយុវជនថៃស្ថិតនៅក្រោមបក្សកុម្មុយនីស្តថៃ ប៉ុន្តែនេះគឺជាការយល់ខុសដែលប្រហែលជាដោយសារគាត់រំឭកឡើងវិញនូវហេតុការណ៍ដែលបានកើតឡើងជាងកន្លះទសវត្សរ៍មុន ។ អង្គការយុវជនថៃទោះបីមានសមានចិត្តចំពោះកុម្មុយនីស្តនិងរួមមានសមាជិកដែលជាសមាជិកបក្សកុម្មុយនីស្តក៏ដោយ មិនមែនជាអង្គការយុវជនដែលត្រូវបានត្រួតត្រាដោយកុម្មុយនីស្តឡើយ ។ ភាពប្រហាក់ប្រហែលគ្នារបស់បក្សកុម្មុយនីស្តថៃជាមួយអង្គការយុវជនថៃដែលជាសម្ព័ន្ធយុវជនថៃ (សន្និបាតយុវជនប្រទេសថៃ ឬ អង្គការសេអាតូ) មិនត្រូវបានបង្កើតឡើងរហូតដល់ចុងឆ្នាំ១៩៤៩ និងដើមឆ្នាំ១៩៥០ ។ មុននេះ ដូចដែលបានគូសបញ្ជាក់នៅក្នុងការសិក្សា បន្ទាប់មកនេះ មានក្រុមយុវជនរបស់បក្សកុម្មុយនីស្តមួយក៏ប៉ុន្តែនេះជាក្រុមក្រៅផ្លូវការសម្រាប់យុវជនដែលបានចូលរួមនៅក្នុងបក្សរួចហើយ ។ នេះមិនមែនជាក្រុមយុវជនដែលមានសមាជិកមិនមែននៅក្នុងបក្សទេ ។ ដូច្នេះហើយ មុនពេលបង្កើតសេអាតូ មិនមានអង្គភាពដែលគ្រប់គ្រងដោយបក្សកុម្មុយនីស្តក្នុងការនាំយុវជនទាំងអស់ឲ្យជួបជុំគ្នានោះទេ ។ ប្រការនេះមានន័យថា សមាជិកអាចចូលរួមក្នុងបក្សផ្ទាល់ដោយមិនចាំបាច់ឆ្លងកាត់អង្គការយុវជនកុម្មុយនីស្តឡើយ ។

ការពិភាក្សាខាងលើក៏បានបង្ហាញដែរថា ការអះអាងរបស់ នួន ជា នៅក្នុងបទសម្ភាសន៍មួយដែលគាត់បានចូលរួមនៅក្នុង

អង្គការយុវជនថៃនៅក្នុងឆ្នាំ១៩៨៤មិនត្រឹមត្រូវទេ ។ ខណៈពេលដែល រួម វង់ផាន ជាមនុស្សដែលហៅ នួន ជា ឲ្យចូលរួមក្នុងអង្គការយុវជនថៃ រួម ខ្លួនឯងក៏មិនបានក្លាយទៅជាសមាជិកបក្សកុម្មុយនីស្តថៃដែរ លុះរហូតដល់ពាក់កណ្តាលឆ្នាំ១៩៨៦ ។ ការបង្កើតអង្គការយុវជនថៃមិនត្រូវបានបង្កើតឡើងទេរហូតដល់ឆ្នាំ១៩៨៧ ។ អាស្រ័យហេតុនេះហើយ នៅឆ្នាំ១៩៨៤ រួម មិនបានចាប់ផ្តើមសកម្មភាពនយោបាយរបស់ខ្លួនទេ ហើយអង្គការយុវជនថៃក៏មិនបានចាប់បដិសន្ធិឡើងដែរ ។ ការអះអាងបញ្ជាក់របស់ នួន ជា ក៏មានលក្ខណៈផ្ទុយពី សាណុះ ផានិតចារើន ដែល នួន បានចាត់ទុក សាណុះ ថាមានសកម្មភាពក្លៀវក្លាជាមួយគាត់នៅក្នុងអង្គការយុវជនថៃ ។ តាមការគូសបញ្ជាក់នេះ នៅក្នុងបទសម្ភាសន៍មួយជាមួយអ្នកនិពន្ធ សាណុះ បានចង្អុលបង្ហាញថាគាត់មានសកម្មភាពនៅក្នុងចលនាយុវជនក្នុងអំឡុងឆ្នាំ១៩៨៧ (ប្រហែលជាពាក់កណ្តាលឆ្នាំនោះ) ។ នៅក្នុងបទសម្ភាសន៍មួយ នួន ជា ក៏បាននិយាយថា មុនពេលចូលរួមក្នុងបក្សកុម្មុយនីស្តថៃក្នុងឆ្នាំ១៩៥០ គាត់មានសកម្មភាពក្លៀវក្លានៅក្នុងអង្គការយុវជនអស់រយៈពេល៨ឆ្នាំ ។ ប្រសិនបើគាត់ចូលរួមក្នុងអង្គការយុវជនថៃនៅក្នុងឆ្នាំ១៩៨៤ដូចដែលគាត់អះអាងមែន នោះការជាប់ពាក់ព័ន្ធរបស់គាត់នៅក្នុងអង្គការនឹងមានរយៈពេលរហូតដល់៧ឆ្នាំ មិនមែន៨ឆ្នាំនោះទេ ។ តែទោះជាយ៉ាងណាក៏ដោយ ប្រសិនបើឆ្នាំដែលគាត់បានចូលរួមគឺជាឆ្នាំ១៩៨៧មែន នេះមានន័យថាវាមានរយៈពេល៨ឆ្នាំពិតប្រាកដណាស់មុនពេលដែលគាត់បានក្លាយទៅជាសមាជិកបក្ស ។

ដោយពិនិត្យមើលត្រួសៗទៅលើការងាររបស់ រួម បន្ទាប់ពីចូលរួមនៅក្នុងបក្សកុម្មុយនីស្តថៃនៅក្នុងខែឧសភា ឆ្នាំ១៩៨៩ គាត់បានចេញទៅប្រទេសចិនក្នុងចំណោមសមាជិកក្រុមដំបូងដែលបក្សកុម្មុយនីស្តថៃបញ្ជូនទៅឲ្យបក្សកុម្មុយនីស្តចិនដើម្បីធ្វើការបណ្តុះបណ្តាល ។ រហូតមកដល់ពេលនោះ គាត់នៅតែជានាយកសាលាចិន ឈី គួង ។ នៅទីនោះគាត់បានរៀបការជាមួយគ្រូម្នាក់បានរយៈពេលជិត២ខែ មុនពេលចាកចេញទៅប្រទេសចិន ។ មិត្តភក្តិដ៏ល្អនិងជាសមាជិកបក្សកុម្មុយនីស្តឈ្មោះ ស៊ុមខុន ភិនៃគុល បានបន្តតំណែងពីគាត់ជានាយកសាលា ។ ក្នុងខណៈពេលនៅប្រទេសចិន គាត់បានចូលប្រឡូកជាមួយនយោបាយក្នុងចំណោមកសិករនៅក្នុងតំបន់ជនជាតិតៃនៃតំបន់ស៊ីឈ័នបាណាក្នុងខេត្តយូណាម ។ គាត់បានត្រឡប់មកប្រទេសថៃវិញនៅក្នុងឆ្នាំ១៩៥៧ ដែលគាត់បានប្រើបទពិសោធន៍ដែលទទួលបាននៅក្នុងប្រទេសចិនដើម្បីចាប់ផ្តើមរៀបចំការងារកសិករនៅក្នុងខេត្តសុផានបូរី ដែលជាខេត្តកំណើតរបស់គាត់ ។ នៅក្នុងសមាជលើកទី៣នៃបក្សកុម្មុយនីស្តថៃក្នុងឆ្នាំ១៩៦១ គាត់ត្រូវបានជ្រើសតាំងជាអ្នកកាន់ការិយាល័យនយោបាយរបស់បក្ស ។ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៦២ គាត់ត្រូវបានប៉ូលិសចាប់ បន្ទាប់ពីរត់គេចវេះពីការចាប់ខ្លួនកាលពីប៉ុន្មានថ្ងៃមុនៗ ។ នៅថ្ងៃទី២៨ ខែមេសា គាត់ត្រូវបាននាយករដ្ឋមន្ត្រី សារិត ថាណារ៉ាត់ សួរចម្លើយរយៈពេល១ម៉ោង ក៏ប៉ុន្តែគាត់បដិសេធមិនព្រមបកស្រាយរឿងអាថ៌កំបាំងនានា ដែលធ្វើឲ្យនាយករដ្ឋមន្ត្រីខឹងយ៉ាងខ្លាំង ។ នៅម៉ោង៦ល្ងាចថ្ងៃដដែល នៅឯមន្ទីរឃុំឃាំងបាងខ្វាង រួម វង់ផាន ត្រូវបានប្រហារជីវិតដោយក្រុមបាញ់សម្លាប់ ។ ការបង្ក្រាបធ្ងន់ធ្ងរនៃរបបផ្តាច់ការយោធារបស់ សារិត បានជំរុញឲ្យបក្សកុម្មុយនីស្តធ្វើការតស៊ូប្រដាប់អាវុធប្រឆាំងនឹងរដ្ឋាភិបាល ។

## ៤) ការចងចាំរបស់ ប្រាសិទ្ធិ សាបស៊ុនថុន

មនុស្សផ្សេងទៀតដែល នួន ជា បានលើកឡើងគឺ ប្រាសិទ្ធិ សាបស៊ុនថុន (១៩១៣-១៩៩៨) ដែលសៀវភៅរបស់គាត់មានចំណងជើងថា ទស្សនៈនៃជីវិតមានឥទ្ធិពលលើការគិតរបស់គាត់លើកដំបូងជាជនឆ្វេងនិយម ។ បទសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ប្រាសិទ្ធិ បានធ្វើឡើងនៅទីក្រុងបាងកកនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៨១ គឺជាបទសម្ភាសន៍មួយក្នុងចំណោមបទសម្ភាសន៍ជាច្រើនដែលគាត់មានជាមួយអតីតសមាជិកបក្សកុម្មុយនីស្តថៃ ។ ប្រាសិទ្ធិ បានប្រាប់អ្នកនិពន្ធថា គាត់គឺជាបញ្ញវន្តម្នាក់ក្នុងចំណោមបញ្ញវន្តដំបូងដែលបានចូលបក្ស ។ គាត់ត្រូវបានចិញ្ចឹមបីបាច់នៅក្នុងគ្រួសារអ្នកដឹកនាំមួយនៅខេត្តសុរ៉ាថានីនៅភាគត្បូងប្រទេសថៃ ។ គាត់ធំពេញវ័យនិងក្លាយជាបញ្ញវន្ត ដោយរស់នៅក្នុងវត្តរ៉ាចាធីវ៉ាត នាទីក្រុងបាងកកខណៈពេលសិក្សានៅមហាវិទ្យាល័យវិទ្យាសាស្ត្រ និងសិល្បៈរបស់សកលវិទ្យាល័យជូឡាឡុងកន ដែលគាត់រៀនខាងផ្នែកប្រវត្តិសាស្ត្រជាមួយគ្រូ រុង ស៊ីយ៉ាម៉ាណានដា ។

នៅក្នុងឆ្នាំបញ្ចប់សកលវិទ្យាល័យនៃព.ស ២៤៧៩ (១៩៣៦-៣៧) គាត់បានក្លាយជាប្រធានក្រុមប្រឹក្សានិស្សិតប្រចាំសាកលវិទ្យាល័យជូឡាឡុងកន ។ នៅខែកញ្ញា ឆ្នាំ១៩៤៦ ក្នុងនាមជាសមាជិកសភាតំណាងប្រជាជនថៃ គាត់បានបង្ហាញច្បាប់មួយដើម្បីលុបបំបាត់ច្បាប់ដែលដាក់របបកុម្មុយនីស្តឲ្យនៅក្រៅច្បាប់ដែលសភាបានអនុម័តរួចរាល់ ។ ដើម្បីឆ្លើយតបទៅវិញ ប្រាសិទ្ធិ បាននិយាយថា ឥស្សរជនសំខាន់ៗគួរឲ្យកត់សម្គាល់នៅក្នុងបក្សកុម្មុយនីស្តថៃមាន វីរ៉ូត អាំដៃ, ខុត្តម ស៊ីសុវ៉ាន អ្នកនាំពាក្យរបស់បក្សឈ្មោះ ប្រាដាន វីរ៉ាសាក់ និង សុង ណូដាខន បានអញ្ជើញគាត់ឲ្យចូលរួមក្នុងបក្សនោះ ។ ដោយទទួលឥទ្ធិពលពីគោលគំនិតព្រះពុទ្ធសាសនា ប្រាសិទ្ធិ បាននិយាយថា គាត់មានសមានចិត្តជាមួយមនោគមន៍វិជ្ជាកុម្មុយនីស្ត ហើយនៅចុងឆ្នាំ១៩៤៦ គាត់ក៏បានចូលរួមក្នុងបក្សដែរ ។ រួមជាមួយរដ្ឋប្រហារខែវិច្ឆិកា ឆ្នាំ១៩៤៧ និងការត្រឡប់មកកាន់អំណាចយោធា សភាជាតិត្រូវបានរំលាយ ហើយ ប្រាសិទ្ធិ បានបាត់បង់តំណែងជាអ្នកតំណាងប្រជាជន ។ ប៉ុន្តែការបោះពុម្ពផ្សាយសារព័ត៌មានមហាជន របស់បក្សមិនត្រូវបានទទួលរងឥទ្ធិពលឡើយ ដូច្នេះគាត់បានពង្រីងបុគ្គលិកក្នុងអំឡុងពេលសរសេរសៀវភៅរបស់គាត់មានចំណងជើងថាទស្សនៈនៃជីវិត ដែលត្រូវបានចុះផ្សាយបន្តបន្ទាប់នៅក្នុងសារព័ត៌មាន (មហាជន) ។ ការិយាល័យរបស់បក្ស ដែលជាការិយាល័យសារព័ត៌មានមហាជនផងដែរ បានបញ្ចប់ការចងក្រងស្នាដៃរបស់ម៉ាក្សនិងលេនីនដោយប្រែជាភាសាអង់គ្លេស ។ ប្រាសិទ្ធិ បាននិយាយថាការពិតគាត់គឺជាមនុស្សតែម្នាក់ប៉ុណ្ណោះនៅក្នុងបក្សដែលបានប្រើប្រាស់លេខចេញផ្សាយទាំងនោះ ហើយអានស្នាដៃរបស់ម៉ាក្សនិងលេនីនជាភាសាអង់គ្លេស ។ មេដឹកនាំកំពូលរបស់បក្សមិនចូលចិត្តអានទ្រឹស្តីម៉ាក្សនិងលេនីនឡើយ ពួកគេគ្រាន់តែអានស្នាដៃរបស់ ម៉ៅ សេទុង ជាភាសាចិន ។ នេះមានន័យថាប្រភពចំណេះដឹងរបស់គាត់ខុសពីគំនិតរបស់មេដឹកនាំបក្សដទៃទៀត ។ គាត់បានចាប់ផ្តើមអានស្នាដៃរបស់ម៉ាក្សនិងលេនីន បន្ទាប់មកអានស្នាដៃរបស់ ម៉ៅ សេទុង ជាភាសាអង់គ្លេស ។ ដូច្នេះហើយ ភាពជាអ្នកដឹកនាំរបស់បក្សទទួលស្គាល់ថា គាត់មានចំណេះដឹងច្រើនជាងមេដឹកនាំបក្សផ្សេងទៀតក្នុងការយល់ដឹងទ្រឹស្តីរបស់ម៉ាក្សស៊ីសលេនីន ។ នៅខែឧសភា ឆ្នាំ១៩៤៩ គាត់ត្រូវបញ្ជូនទៅប្រទេសចិនជាមួយក្រុមដំបូងរបស់សមាជិកបក្សដែលបក្សកុម្មុយនីស្តថៃបានបញ្ជូនទៅប្រទេសចិន ។ អ្នកដទៃទៀតនៅក្នុងក្រុមមាន ដារី រួងស៊ូថាំ រួម វង់ផាន និង សុង ណូដាខន ។ នៅឯសមាជលើកទីពីររបស់បក្សនៅឆ្នាំ១៩៥២ ដែលត្រូវបានរៀបចំឡើង១០ឆ្នាំបន្ទាប់ពីការបង្កើតបក្ស ប្រាសិទ្ធិ ត្រូវបានជ្រើសរើសប្រចាំគណៈកម្មាធិការមជ្ឈិមជាជំនួយការ ។ នៅពេលគាត់ចូលរួមក្នុងបក្សកុម្មុយនីស្តថៃ ប្រាសិទ្ធិ កត់សម្គាល់ថា បក្សនេះប្រកាន់យកប្រជាធិបតេយ្យរួចទៅហើយ ដូច្នេះមិនមានការលំបាកអ្វីរវាងគាត់និងបក្សឡើយ ។ ប្រជាធិបតេយ្យគឺជារឿងល្អដែលគាត់យល់ស្របជាមួយ ហើយគាត់បាននិយាយថា គាត់គ្មានការខ្វល់ខ្វាយក្នុងចិត្តអំពីការចូលរួមក្នុងបក្សឡើយ ។ ប៉ុន្តែក្រោយមក ខ្សែបណ្តាញរបស់បក្សក៏ផ្លាស់ប្តូរដើម្បីធ្វើការតស៊ូដោយប្រដាប់អាវុធដែលគាត់បានជំទាស់ ។ នៅអំឡុងឆ្នាំ១៩៥៤ មានការជជែកដេញដោលដ៏ក្តៅគគុកមួយអស់រយៈពេលជិត១ឆ្នាំក្នុងចំណោមសមាជិកបក្សកុម្មុយនីស្តថៃ ដែលស្នាក់នៅទីក្រុងប៉េកាំង ប៉ុន្តែនៅទីបញ្ចប់អានុភាពរបស់បក្សមិនទទួលយកខ្សែប្រជាធិបតេយ្យរបស់គាត់ឡើយ ហើយក្រោយមក ប្រាសិទ្ធិ បាននិយាយថា គាត់បានដើរផ្លូវផ្សេង ។ គាត់បានវិលត្រឡប់មកប្រទេសថៃនៅឆ្នាំ១៩៥៨ ហើយត្រូវបានចាប់ខ្លួន ។ ប៉ុន្តែខណៈពេលនៅក្នុងមន្ទីរឃុំឃាំង គាត់ត្រូវបានស្ងើចសរសើរដោយសារការបង្ហាត់បង្រៀនទ្រឹស្តីកុម្មុយនីស្តដែលគាត់បានផ្តល់ទៅឲ្យសាខាពិសេសរបស់ប៉ូលិស ហើយគាត់ក៏ត្រូវបានដោះលែង ។

### ៤) ការចងចាំរបស់ សាណុះ ដានិតចារើន និង ឡាំចៀក (សាប ស៊ុនថុន) សុងខារ៉ាក់

សាណុះ ដានិតចារើន បានលេចឡើងជាច្រើនដងនៅក្នុងការសិក្សានេះ ។ គាត់គឺជាអតីតសមមិត្តម្នាក់ទៀតដែល នួន ជា បានលើកឡើងនៅក្នុងបទសម្ភាសន៍ជាមួយគាត់បានធ្វើឡើងនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៥ មានរយៈពេល៣ម៉ោងកន្លះនៅឯសាកលវិទ្យាល័យធម្មសាត្រ ។

កើតនៅខែឧសភា ឆ្នាំ១៩២៧ សាណុះ បាននិយាយថា គាត់បានធំធាត់នៅស្រុកបាងបាន ខេត្តអយុធ្យា ប្រទេសថៃភាគ

កណ្តាល ។ ជីតាខាងឪពុករបស់គាត់គឺជាជនជាតិចិនដែលបាន ធ្វើអន្តោប្រវេសន៍ពីហៃណានចូលមកប្រទេសថៃ ហើយឪពុករបស់ គាត់គឺជាជនជាតិចិនដែលកើតនៅប្រទេសថៃ ។ ជីតាខាងម្តាយ របស់គាត់បានរស់នៅខេត្តអយុធ្យាហើយមានខ្សែស្រឡាយដូនតា មកពីខាងតំបន់ឈូងសមុទ្រពែក ខណៈដែលជីដូនខាងម្តាយរបស់ គាត់គឺជាជនជាតិឡាវដែលបានធំធាត់នៅទីក្រុងវៀងច័ន្ទ ។ ប៉ុន្តែ សាណុះ បាននិយាយថា ឪពុកម្តាយរបស់គាត់រស់នៅដូចជាជន ជាតិថៃទាំងស្រុង ។ គាត់គឺជាកូនពៅក្នុងចំណោមកូន៦នាក់ ។ បងប្រុសបង្អស់របស់គាត់បានក្លាយជាអាចារ្យនៅវត្ត បូវ៉ូនីវេត ដែលជាវត្តល្បីឈ្មោះប្រចាំទីក្រុងបាងកក ដូច្នេះហើយចាប់ពីឆ្នាំ ទី៤នៃសាលាបឋមសិក្សា រហូតដល់ឆ្នាំទី៦នៃសាលាមធ្យមសិក្សា សាណុះ អាចមានលទ្ធភាពចូលសាលាដែលគ្រប់គ្រងដោយរដ្ឋា-ភិបាល នៅទីតាំងបរិវេណវត្ត ខណៈពេលរស់នៅក្នុងនិវេសនដ្ឋាន របស់អាចារ្យជាមួយបងប្រុសគាត់ ។ បន្ទាប់ពីបញ្ចប់ការសិក្សា ថ្នាក់មធ្យមសិក្សាគាត់បានចុះឈ្មោះចូលរៀននៅសកលវិទ្យាល័យ ធម្មសាត្រក្នុងថ្នាក់បញ្ចប់ឆ្នាំសិក្សានៃវគ្គត្រៀមចូលសកលវិទ្យាល័យ ចូលរៀនក្នុងឆ្នាំសិក្សា១៩៨៣ ហើយបញ្ចប់នៅឆ្នាំ១៩៨៤មុន នួន ជា ។ នៅខែកក្កដា ឆ្នាំ១៩៩៨ ភីប៊ុន និងមនុស្សនៅក្នុង ខុទ្ទកាល័យរបស់គាត់ទាំងមូលត្រូវបានលាលែង ។ បន្ទាប់ពីនេះ សាណុះ បាននិយាយថា គាត់បានសរសេរអត្ថបទរិះគន់ឲ្យ ភីប៊ុន ដែលបានចូលរួមចំណែកក្នុងសារព័ត៌មាន សុវណ្ណភូមិ ។ ប្រការ នេះនាំទៅរកការផ្សារមួយនៅក្នុងសំណេរនេះ ។ អំឡុងពាក់កណ្តាល ឆ្នាំ១៩៨៦ គាត់បានខ្ចីអត្ថបទបកប្រែដែលមានចំណងជើងថា សេចក្តីប្រកាសរបស់កុម្មុយនីស្តពី ចារើន ឆៃឆាណា ១៩០៧-១៩៨៣ និពន្ធនាយករបស់សារព័ត៌មាន អ៊ីសារ៉ាថាំ ដែលបកប្រែ ជាភាសាថៃ បន្ទាប់មកក៏បោះពុម្ពសេចក្តីថ្លែងការណ៍តាមលំដាប់ លេខដូចគ្នានៅក្នុងសារព័ត៌មាន ។ ក្រោយមក គាត់បានបោះពុម្ព សេចក្តីប្រកាសនោះជាសៀវភៅ ។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៨៦ ថ្ងៃបុណ្យចូលឆ្នាំសកល ឧត្តម ស៊ីសុវ៉ាន បានអញ្ជើញ សាណុះ ឲ្យចូលរួមក្នុងបក្សកុម្មុយនីស្តថៃ ដែលគាត់បានចូលបន្ទាប់ ពីបម្រើជាបេក្ខភាពរយៈពេល៣ខែ ។ មនុស្សពីរនាក់ដែលបាន គាំទ្រការចូលបក្សរបស់គាត់គឺ ឧត្តម ស៊ីសុវ៉ាន និង វីរ៉ូត អាំផៃ ។ សាណុះ បាននិយាយថា បន្ទាប់មកគាត់បានចូលប្រឡូកក្នុងអង្គការ យុវជនថៃ ហើយក្នុងអំឡុងឆ្នាំ១៩៨៧ និង ១៩៨៨ គាត់បាន ក្លាយជាឥស្សរៈជនសំខាន់រួមជាមួយ រួម វង់ផាន នៅក្នុងក្រុម យុវជនដែលរៀបចំនៅក្នុងបក្សកុម្មុយនីស្តថៃ ។ ក្រុមនេះបាន បោះពុម្ពសារព័ត៌មានដោយប្រើម៉ាស៊ីនរូណេអូ ដែលមាន ចំណងជើងថា សំឡេងសៀម ហើយ ស៊ុមខ្វាន ភីឆៃគុល និង វុងឡឹត ឡោឌី គឺជាអ្នកដែលបានចែកផ្សាយសារព័ត៌មាននោះ ។ សាណុះ បាននិយាយថាមនុស្សដែលជិតស្និទ្ធជាមួយ វុងឡឹត បំផុត គឺ ស៊ុមខ្វាន ដូច្នេះហើយចំពោះគាត់ វាហាក់ដូចជាចម្លែកដែល ស៊ុមខ្វាន មិនបានពាក់ព័ន្ធនឹងការចូលក្នុងបក្សរបស់ វុងឡឹត ហើយ បែរជា ឧត្តម ចារើនរ៉ាត ដែលបានចូលក្នុងបក្សក្រោយ ស៊ុមខ្វាន ជាអ្នកណែនាំ វុងឡឹត ឲ្យចូលក្នុងបក្សទៅវិញ ។ បន្ទាប់ពីរដ្ឋប្រហារ ខែវិច្ឆិកា ឆ្នាំ១៩៨៧ តាមរយៈសេចក្តីណែនាំពី វីរ៉ាត អាងខា ថាវុន សាណុះ បាននិយាយថា គាត់ទទួលបានការផ្សារមួយនៅ ឯសាលាមធ្យមសិក្សាចិនណានយ៉ាង ។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៥១ គាត់បានចាកចេញពីទីក្រុងបាងកកទៅប្រទេសចិន ដែលគាត់បាននៅទីនោះរយៈពេល៤២ឆ្នាំ ដោយមិនត្រឡប់មក ទីក្រុងបាងកករហូតថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ។ ប៉ុន្តែគាត់បាន ធ្វើការរិះគន់ទៅលើភាពដឹកនាំរបស់បក្សចំពោះការឆ្លើយតបយ៉ាង លឿនចំពោះរដ្ឋប្រហារខែវិច្ឆិកា ឆ្នាំ១៩៨៧ ដែលធ្វើឲ្យគាត់មាន បញ្ហា ។ ការតវ៉ារបស់គាត់ធ្វើឲ្យពួកគេមានការប្រុងប្រយ័ត្នហើយ មេដឹកនាំបក្សទាំងឡាយបានបាត់បង់ជំនឿចិត្តលើគាត់ ។ ដើម្បី ដោះស្រាយជាមួយអ្នកបង្កបញ្ហាបែបនេះ ពួកគេបានបញ្ជូនគាត់ តាមកប៉ាល់ទៅប្រទេសចិនដើម្បីបំបិទមាត់ ។

មនុស្សម្នាក់ទៀតដែល នួន ជា បាននិយាយថា គាត់មាន ភាពសកម្មជាមួយគឺ ឡាំ ចៀក (សាបសុនថុន) សុងខារ៉ាក់ (កើត នៅខែកក្កដា ឆ្នាំ១៩២៦) ។ អ្នកនិពន្ធបានសម្ភាសគាត់នៅផ្ទះ របស់ គាត់នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៣ ។ គាត់គឺជាប្អូនស្រីរបស់ ប្រាសិទ្ធិ សាបសុនថុន ដែលជាអ្នកនិពន្ធសៀវភៅ ទស្សនៈនៃជីវិត ហើយគាត់បានចាប់ផ្តើមបទសម្ភាសន៍ដោយនិយាយថា ក្នុងចំណោម បងប្អូនស្រីប្រុសទាំង៨នាក់ ប្រាសិទ្ធិ គឺជាកូនទី២ដែលធំជាងគេ លំដាប់ទី២ ហើយគាត់គឺជាកូនទី៧ ដែលតូចជាងគេលំដាប់ទី២ ។

គាត់បានចូលរួមបក្សកុម្មុយនីស្តថៃនៅដើមឆ្នាំ១៩៤៧ រយៈពេល ១ខែបន្ទាប់ពីប្រាសិទ្ធិ ។ ប្អូនស្រីបន្ទាប់របស់គាត់ឈ្មោះ សុងស្រី ដែលជាកូនពៅបង្អស់នៅក្នុងគ្រួសារ ហើយវិលត្រឡប់មកផ្ទះនៅសុវ៉ាថានី ក៏បានចូលរួមក្នុងបក្សដែរ ។ គាត់នៅតែជាសមាជិកបក្សរហូតដល់គាត់ស្លាប់នៅសុវ៉ាថានីក្នុងឆ្នាំ១៩៥៤ ។

ឡាំចៀក រៀនផ្នែកគណនេយ្យនៅសកលវិទ្យាល័យជូឡាឡុងកនអស់រយៈពេល៣ឆ្នាំ ប៉ុន្តែគាត់បាននិយាយថា គាត់បានឈប់រៀនហើយធ្វើការនៅក្រុមហ៊ុនអឺរ៉ុបដែលប្រកបរបរច្នៃនិងលក់ត្បូង ។ គាត់បានធ្វើការនៅទីនោះអស់រយៈពេលប្រហែលមួយឆ្នាំ នៅពេលគាត់បានចូលរួមក្នុងបក្សកុម្មុយនីស្ត ។ យោងតាមសម្តីរបស់គាត់ សមាជិកវ័យក្មេងរបស់បក្សជួនកាលជួបជុំគ្នានៅក្នុងក្រុមយុវជននៅក្នុងបក្សដើម្បីពិភាក្សានិងផ្លាស់ប្តូរយោបល់អំពីនយោបាយ ។ សមាជិកនៃក្រុមនេះរួមមាន រួម វង់ផាន មេដឹកនាំបក្សដែលចាស់ជាងអ្នកដទៃទៀតនិងត្រូវបានគេផ្តល់ការទុកចិត្តខ្ពស់ និង ផុង ដាបដេត អនុប្រធានបក្ស ហើយចាប់តាំងពីសង្គ្រាមមកគឺជាសមាជិកបក្សដែលមានឋានន្តរស័ក្តិខ្ពស់ជាងគេ ព្រមទាំង សាណុះ ផានិតចារើន និខន ដែលជាមន្ត្រីរដ្ឋាភិបាលនិងសមាជិកបក្សដែលបញ្ឈប់ភាពសកម្ម ពីព្រោះប្រពន្ធរបស់គាត់បានជំទាស់នឹងការចូលប្រឡូកក្នុងបក្សរបស់គាត់ ស៊ុមខ្វាន ភិនៃគុល មន្ត្រីនៅក្នុងនាយកដ្ឋានជម្រះបញ្ជីទូទៅរបស់ក្រសួងហិរញ្ញវត្ថុដែលបន្ទាប់ពីត្រូវបានបញ្ជូនទៅប្រទេសចិន មានភាពសកម្មនៅភាគឦសាននៃប្រទេសថៃរហូតដល់ត្រូវចាប់ខ្លួន កានដា សុនថុនចាមុន ជាកូនស្រី របស់ វ៉ាត សុនថុនចាមុន ព្រមទាំង ឡាំចៀក ។ នៅពេលដែលសួរអំពីជនជាតិខ្មែរដែលប្រើឈ្មោះថៃ រុងឡឹត ឡោឌី ឡាំចៀក បាននិយាយថា គ្មានមនុស្សបែបនេះនៅក្នុងក្រុមរបស់គាត់ទេ ។ ចាប់ពីពេលចាប់ផ្តើមដំបូងគ្មានសមាជិកជាជនជាតិខ្មែរឡើយ ។ ក្រៅពីក្រុមយុវជនរបស់សមាជិកបក្ស គាត់ក៏បានផ្តល់យោបល់ផងដែរថា បក្សមានក្រុមនិស្សិតដែលបានរៀបចំឡើង ។ ដោយសំដៅទៅលើនិស្សិតទាំងឡាយណាដែលជាសមាជិកបក្ស ឬមិនមែនជាសមាជិកបក្ស សមាជិកសំខាន់ៗមួយចំនួននៅក្នុងក្រុមនេះ គឺ ប៉ាងហុង ដែលក្រោយមកបានរៀបការជាមួយ វីវ៉ាត់ អាងខាថាវុន និង នីខន ចាន់ថូវ៉ាវិថុន (១៩២៥-២០០១) ដែលជានិស្សិតរៀនថ្នាក់បញ្ចប់ជំនាន់ទី៤នៃវគ្គត្រៀមនៅសកលវិទ្យាល័យធម្មសាត្រ ដែលមិនធ្លាប់ចូលរួមក្នុងបក្សនេះទេ ហើយក៏ជាអ្នកដែលនឹងក្លាយទៅប្រធាននាយកដ្ឋានការងារនៅក្នុងក្រសួងមហាផ្ទៃ ។ ក្រុមទាំងពីរនេះធ្វើការរួមគ្នានៅពេលណាមានការប្រារព្ធពិធីសំខាន់ៗដូចជាទិវាខែឧសភាជាដើម ។ បន្ទាប់មក ឡាំចៀក បាននិយាយបន្ថែមទៀតថា ចារើន វ៉ាំង៉ាម បានធ្វើការឲ្យសារព័ត៌មានរបស់អង្គភាពបក្សឈ្មោះមហាជន ហើយមិនមានជាប់ពាក់ព័ន្ធនៅក្នុងក្រុមណាមួយឡើយ ។ គាត់ជាមនុស្សម្នាក់ស្ងៀមស្ងាត់និងបេះគួរសម ។ នោះគឺជាអ្វីដែលជនជាតិថៃហៅថា រ៉ៃប្រូយ ។ ដោយមានការនិយមចូលចិត្តពីសំណាក់ វីវ៉ាត ហើយនិងឥស្សរជនសំខាន់ៗផ្សេងទៀតនៅក្នុងបក្ស គាត់បានឡើងឋានៈនៅក្នុងជួរបក្សយ៉ាងឆាប់រហ័ស ។


នួន ជា

ដោយបន្តសាច់រឿងផ្ទាល់របស់ខ្លួន ឡាំចៀក បាននិយាយនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៨៩ថា ដោយសារតែគ្មានលិខិតឆ្លងដែន និងមានការអមដំណើរពីស្ត្រីជនជាតិថៃម្នាក់ផ្សេងទៀតឈ្មោះ នងយោ ប្រាថាថិត ព្រម

ទាំងអ្នកនាំផ្លូវជនជាតិចិនម្នាក់ផង គាត់បានចាកចេញពីទីក្រុងបាងកកតាមកប៉ាល់ឆ្ពោះទៅប្រទេសចិនដើម្បីចូលរួមក្នុងសន្និសីទស្តីពីស្ត្រីអាស៊ីដែលនឹងរៀបចំឡើងនៅក្នុងទីក្រុងប៉េកាំង នៅថ្ងៃទី៦ ដល់ថ្ងៃទី១០ ខែធ្នូ ក្នុងឆ្នាំដដែល ។ បន្ទាប់មករយៈពេលប្រហែល១ឆ្នាំ គាត់ស្ថិតនៅក្នុងក្រុមបណ្តុះបណ្តាលយុវជនដែលរៀនជាមួយនឹងក្មេងៗជនជាតិចិនមកពីបរទេសដូចជាប្រទេសថៃ ប្រទេសម៉ាឡេស៊ី និងសិង្ហបុរី ដែលធ្វើដំណើរមកកាន់ប្រទេសចិន ។ បុរសនិងស្ត្រីនៅក្នុងក្រុមបណ្តុះបណ្តាលនេះមានអាយុចន្លោះពី២០-៣០ឆ្នាំ ព្រមទាំងមានចំនួនពី១០០-២០០នាក់ ។ បន្ទាប់មកគាត់បានចូលរៀននៅឯវិទ្យាស្ថានម៉ាក្សលេនីនរហូតដល់ឆ្នាំ១៩៥៦ ។ គាត់ធ្វើការឲ្យវិទ្យុប៉េកាំង ប្រហែល១០ឆ្នាំ ហើយក៏បានក្លាយទៅជាស្ត្រីមេផ្ទះ ។ ប្តីរបស់គាត់ជានិស្សិតនៅសកលវិទ្យាល័យធម្មសាត្រដែលបានចូលរួមនៅក្នុងការប៉ុនប៉ងធ្វើរដ្ឋប្រហារ ព្រីឌី ផាណុមយុង នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៤៩ រួចហើយក៏បានភៀសខ្លួនទៅកាន់ប្រទេសចិន ដែលនៅទីនោះប្តីរបស់គាត់បានក្លាយទៅជាគ្រូបង្រៀនភាសាថៃនៅសកលវិទ្យាល័យក្រុងប៉េកាំង ។ នៅឆ្នាំ១៩៨២ គាត់បានត្រឡប់មកប្រទេសថៃម្តងដែលជាការត្រឡប់មកលើកដំបូងបង្អស់ចាប់តាំងពីចាកចេញពីប្រទេសថៃនៅឆ្នាំ១៩៤៩ ។ បន្ទាប់មកគាត់បានធ្វើដំណើរទៅវិញទៅមករវាងប្រទេសទាំងពីរនេះជាច្រើនដងរហូតដល់ឆ្នាំ១៩៩២ ជាឆ្នាំដែលគាត់ចាកចេញពីទីក្រុងប៉េកាំងចុងក្រោយបង្អស់ ហើយត្រឡប់មករស់នៅប្រទេសថៃវិញ ។ ដោយស្តែងចេញពីការនិយាយរបស់អ្នកទាំងពីរដែល នួន ជា ចាត់ទុកថាមានសកម្មភាពក្បៀវក្លាជាមួយគាត់នៅក្នុងអង្គការយុវជនថៃ ដែលនេះជាភ័ស្តុតាងបញ្ជាក់ច្បាស់ថា សាណុះ នៅចាំ រុងឡឹត (នួន ជា) ក៏ប៉ុន្តែ ឡាំចៀក មិនបានចាំទេ ។ សាណុះ បានលើកមកនិយាយអំពីការធ្វើការងារជាមួយអង្គការយុវជនថៃ ហើយបញ្ជាក់យ៉ាងច្បាស់ថា រុងឡឹត មានទំនាក់ទំនងខ្លះៗជាមួយនឹងក្រុមយុវជនរបស់សមាជិកបក្សតាមរយៈភារកិច្ចចែកចាយព្រឹត្តិបត្រ បោះពុម្ពផ្សាយ ឈ្មោះ សំឡេងសៀម ។ ម្យ៉ាងវិញទៀត ឡាំចៀក មិនដែលនិយាយអំពីអង្គការយុវជនថៃឬមិនមានទំនាក់ទំនងជាមួយអង្គការនេះតែម្តងផុយ ទៅវិញគ្រាន់តែនិយាយលម្អិតខ្លះៗអំពីការដែលគាត់ធ្លាប់ជាសមាជិកនៅក្នុងក្រុមយុវជនរបស់សមាជិកបក្ស ។ គាត់មិនបានចាំមនុស្សឈ្មោះ រុងឡឹត នោះទេ ហើយទំនងជាថាគាត់មិនដែលឮឬមិនដែលស្គាល់មនុស្សនេះទាល់តែសោះ ។ ក៏ប៉ុន្តែ នួន ជា នៅចាំឈ្មោះ ឡាំចៀក នេះ ហើយនៅចាំបានថា ធ្លាប់ធ្វើសកម្មភាពជាមួយនឹង ឡាំចៀក ទៀតផង ។ អាស្រ័យហេតុនេះហើយ វាទំនងជាថា នួន ជា ចាំឈ្មោះរបស់ ឡាំចៀក ពេលធ្វើសកម្មភាពណាមួយដែលគាត់មកទាក់ទងជាមួយក្រុមយុវជនរបស់សមាជិកបក្ស ដូចជាការបែងចែកព្រឹត្តិបត្រ បោះពុម្ពផ្សាយរបស់ក្រុមឈ្មោះថា សំឡេងសៀម ឬក៏នៅក្នុងការប្រារព្ធទិវាខែឧសភា ដែលនៅពេលនោះអង្គការយុវជនថៃរបស់ រុងឡឹត បានសហការជាមួយក្រុមយុវជនរបស់បក្ស ។ នៅក្នុងបទសម្ភាសន៍ទំនងជាថា នួន ជា បានចាំសកម្មភាពរបស់គាត់ជាមួយ ឡាំចៀក ហើយ ឡាំចៀក បានធ្វើឲ្យ នួន មានការចាប់អារម្មណ៍ ។ ក៏ប៉ុន្តែ ឡាំចៀក មិនមានការចាប់អារម្មណ៍ទៅលើ នួន ទេ ។ ហេតុផលជាយថាហេតុទំនងជាថា រុងឡឹត ឡោឌី ដែលជាជនជាតិខ្មែរមានឈ្មោះជាថៃស្ថិតនៅក្នុងចំណោមយុវជនក្មេងៗជាច្រើនដែលជាប់ពាក់ព័ន្ធនៅក្នុងការធ្វើសកម្មភាពជាមួយ ឡាំចៀក ព្រមទាំងក្រុមយុវជនបក្សរបស់ ឡាំចៀក ។ ចំពោះ ឡាំចៀក វិញ រុងឡឹត មិនមែនជាមនុស្សម្នាក់ប្លែកជាងគេនោះទេ ។ ***(នៅមានត)***

**អ៊ីជី ម្យ៉ាស៊្រីម៉ា**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀត ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# ចាំថ្ងៃស្អែក

ក្នុងនាមខ្ញុំបាទជាអ្នកនិពន្ធម្នាក់ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលបានស្តាប់ព្រលោក សុធា អរុណ ជាប្រធានអង្គការ «សុវណ្ណកុមារ» បានមានប្រសាសន៍មកកាន់ខ្ញុំនូវប្រយោគមួយឃ្លាថា «ខ្ញុំមិនដឹងថាខ្លួនឯងមានអាយុប៉ុន្មានឲ្យពិតប្រាកដនោះទេ» ពេលដែលខ្ញុំជួបគាត់នៅក្នុងការិយាល័យរបស់គាត់នៅសង្កាត់ជ្រោយចង្វារ ខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ កាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៥ ។ នេះជារឿងមួយកម្សត់ណាស់ ប្រសិនបើមនុស្សម្នាក់មានខ្សែជីវិតចាប់ផ្តើមចេញពីកុមារកំព្រាតាំងពីកុមារភាពមក ពីព្រោះគេអាចនឹងមិនដឹងថាតើគេមានអាយុប៉ុន្មានឲ្យបានច្បាស់លាស់ឡើយ ។ គាត់បានមានប្រសាសន៍ប្រាប់បន្តថា ឪពុកម្តាយ ជីដូន ជីតា មាមីង និងបងប្អូនជិតឆ្ងាយរបស់គាត់ជាង៣០នាក់ បានស្លាប់បាត់បង់ជីវិត ហើយមួយចំនួនទៀតបាត់ដំណឹងរហូតមកដល់ពេលបច្ចុប្បន្ន ។ ខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំងនៅពេលព្រថាគាត់បានបាត់បង់ញាតិសន្តានរបស់ខ្លួនអស់បែបនេះ ។

នៅឆ្នាំ១៩៧៤ ទោះបីជាលោក អរុណ មានការចងចាំមិនច្បាស់លាស់យ៉ាងណាក៏ដោយ ក៏ព្រឹត្តិការណ៍នេះនៅតែធ្វើឲ្យគាត់មានការឈឺចាប់និងដក់ជាប់ក្នុងចិត្តរបស់គាត់ជានិច្ច ។ សង្គ្រាមរវាងខ្មែរនិងខ្មែរបានធ្វើឲ្យប្រជាពលរដ្ឋទទួលរងនូវទុក្ខវេទនា ហើយម្យ៉ាងទៀត ផ្ទះដែលធ្លាប់តែមានមនុស្សមួយគ្រួសាររស់នៅបែរជាត្រូវមកទទួលមនុស្សដល់ទៅ៣-៤គ្រួសារ ជួនកាល១០គ្រួសារ ចំណែកអ្នកដែលរស់នៅទីក្រុងភ្នំពេញវិញត្រូវបានជម្លៀសចេញដើម្បីគេចពីសង្គ្រាម ។ គ្រួសាររបស់ សុធា មានសមាជិកចំនួន៤នាក់ដែលមានឪពុកឈ្មោះ កែវ ហៀង តួនាទីជានាយទាហានស័ក្តិបី ម្តាយឈ្មោះ សាម៉េត ជាគ្រូបង្រៀននៅសាលាបឋមសិក្សាមួយក្នុងទីក្រុងភ្នំពេញ និងមានប្អូនស្រីម្នាក់ឈ្មោះ សោភ័ណ អាយុប្រហែលជាងមួយឆ្នាំ បាននាំគ្នាចាកចេញពីទីក្រុងភ្នំពេញមករស់នៅជាយក្រុងក្នុងផ្ទះមួយប្រក់ក្បឿងរបស់អ្នកភូមិម្នាក់ដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ចម្ងាយប្រហែល៥០០ម៉ែត្រ ។

ការបាញ់សម្លាប់គ្នាទៅវិញទៅមកបានធ្វើឲ្យម្តាយ ប្អូនស្រី និង សុធា មានការភ័យតក់ស្លុតយ៉ាងខ្លាំង ។ គ្រួសារ សុធា ក៏ដូចជាគ្រួសារទាហានដែលរត់តាមស្វាមីមករស់នៅជិតវត្តនិរោធរង្សីដែរ នៅពេលមានការទម្លាក់គ្រាប់ផ្លោង ម្តាយរបស់ សុធា បាននាំកូនៗរត់ទៅរកលេណដ្ឋានដើម្បីគេចខ្លួន ។ សុធា នៅចាំបានថារៀងរាល់ពេលដែលគាត់រត់ចូលទៅពួនក្នុងលេណដ្ឋាន គាត់មានការភ័យខ្លាចយ៉ាងខ្លាំង ពីព្រោះសំឡេងគ្រាប់ផ្លោងលាន់ព្រមិនឆ្ងាយពីកន្លែងដែលគាត់ពួន ជួនព្រសូរគ្រាប់ផ្លោងហើរកាត់ពីលើក្បាល ជួនធ្លាក់នៅខាងឆ្វេង ស្តាំ ឬខាងមុខ ដែលធ្វើឲ្យទ្រូងគាត់លោតក្តុកក្តាក់មិនឈប់ ។ ពេលកំពុងភ័យ សុធា តែងព្រម្តាយនិយាយថា «ស្អែកយើងនឹងបានសុខហើយ» ។ ការបាញ់ផ្លោងនេះបានធ្វើឲ្យមនុស្សជាច្រើនស្លាប់បាត់បង់ជីវិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ។ ពេលនោះ លោកយាយ ហេង ដែលជាជីដូនរបស់ សុធា និងជាស្ត្រីមេម៉ាយមានអាយុប្រហែលជាង៥០ឆ្នាំ រស់នៅភូមិព្រែកតាសរ ស្រុកពារាំង ខេត្តព្រៃវែង បានសរសេរសំបុត្រផ្ញើមកកូនប្រុសលោក កែវ ហៀង និងកូនប្រសា ព្រមទាំងចៅទាំងពីរឲ្យរកវិធីធ្វើដំណើរមកកាន់ភូមិដែលគាត់រស់នៅក្នុងជីវំដោះ ។ ប៉ុន្តែលោកយាយមិនដែលបានទទួលសំបុត្រឆ្លើយតបពីកូននិងកូនប្រសាវិញទេ ហើយគាត់ក៏មិនដែលឃើញគ្រួសាររបស់កូនគាត់ធ្វើដំណើរមកកាន់ភូមិនេះដែរ ។ ដោយឃើញថាពីមួយថ្ងៃទៅមួយថ្ងៃស្ថានភាពសង្គ្រាមកាន់តែខ្លាំងឡើងៗ ជាពិសេសទាហាន លន់ នល់ ហាក់ដូចជាឈានទៅរកការចាញ់សង្គ្រាមបន្តិចម្តងៗ ដូច្នេះលោកយាយ ហេង ក៏សម្រេចចិត្តជួលមនុស្សម្នាក់ឲ្យនាំសំបុត្ររបស់គាត់មកប្រគល់ឲ្យកូនប្រសា និង លោក កែវ ហៀង ជាកូនប្រុសឲ្យនាំគ្រួសាររត់មកកាន់ជីវំដោះឲ្យបានឆាប់ ។

**ពលិកម្មជីដូន**

*ពេលកំពុងមានការផ្ទុះអាវុធនោះ សំបុត្ររបស់លោកយាយ ហេង ក៏បានមកដល់ដៃលោកអនុសេនីយ៍ឯក កែវ ហៀង និងអ្នកគ្រូ សាម៉េត ដែរ។ បន្ទាប់ពីពិភាក្សារួចឪពុករបស់ សុធា បានសម្រេចចិត្តថាគាត់នឹងមិនរត់ទៅណាចោលអគ្គភាពទ័ពរបស់គាត់បានទេ។ ប៉ុន្តែគាត់ក៏បានផ្តាំម្តាយ សុធា ថា «ប្រសិនបើមានករណីចាំបាច់ណាមួយកើតឡើង គាត់នឹងភៀសខ្លួនទៅតាមក្រោយនៅភូមិព្រែកតាសរ»។ អត្ថបទសំបុត្រនោះនិយាយថាលោកយាយ ហេង មាននាទីជាអ្នករង់ចាំទទួលអ្នកទាំងបីនៅកំពង់ចម្លងល្វាសរ ជិតភូមិទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល។*

*នៅម៉ោងប្រហែល៦ព្រឹក លោក កែវ ហៀង បានបើករថយន្តហ្ស៊ីបដឹកប្រពន្ធនិងកូនទាំងពីរចេញពីវត្តនិរោធរង្សីដោយមិនឲ្យនរណាម្នាក់ដឹងឡើយ។ ចាប់ពីពេលនោះមក ព័ត៌មានរបស់លោកសត្តិបីចំពោះ សុធា គឺជារឿងមួយស្រពេចស្រពិលទាំងអស់ ពីព្រោះគាត់មិនបានដឹងច្បាស់ទេថាតើឪពុករបស់ខ្លួននៅរស់ឬស្លាប់នោះទេ។ ក្រោយពីបែកគ្នា អ្នកគ្រូ សាម៉េត និងកូនទាំងពីរបានជិះរ៉ឺម៉កទៅកាន់កំពង់ដ ដែលស្ថិតនៅក្នុងឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។ សុធា នៅចាំបានថា ពេលកំពុងធ្វើដំណើរ រ៉ឺម៉កបើកនៅតាមដងផ្លូវជាតិលេខ១ កាត់តាមភូមិបឹងឈូក ភូមិបឹងស្នាយ និងភូមិដទៃទៀតជាច្រើន ដែលអាចមើលឃើញទឹកទន្លេបានយ៉ាងច្បាស់ ចំណែកចរាចរតាមផ្លូវក៏មិនសូវស្ងាត់ដែរ។ ទៅដល់ភូមិគាសរបានមួយរយៈ ទើប សុធា ដឹងថា អ្នកដែលធ្វើដំណើរលើដងផ្លូវនោះភាគច្រើនជាអ្នកដែលមកពីតំបន់រំដោះទាំងអស់ ដែលអ្នកទាំងនោះរស់នៅត្រើយខាងកើតទន្លេមេគង្គស្ថិតក្នុងតំបន់ខ្មែរក្រហម។ នៅទីនោះ គ្រួសាររបស់ សុធា និងប្រជាជនប្រហែល៥០ទៅ១០០នាក់ បានឈររង់ចាំកាណូត ដើម្បីធ្វើដំណើរឆ្លងទៅកាន់កំពង់ដល្វាសរ។*

*ទាហាន លន់ នល់ សង្ស័យថា កាណូតដែលដឹកមនុស្សពីឃុំល្វាសរ គឺមកយកស្បៀងទៅចិញ្ចឹមទ័ពរំដោះ។ ចំណែកទាហានរំដោះវិញយល់ឃើញថា ប្រជាពលរដ្ឋដែលរស់នៅក្រោមរបបរបស់លោកសេនាប្រមុខ លន់ នល់ គឺសុទ្ធតែជាខ្មាំងទាំងអស់ ហេតុនេះហើយ រាល់កាណូតទាំងអស់ដែលឆ្លងទៅកាន់កំពង់ដល្វាសឬទឹកឃ្លាំង ត្រូវតែមានព័ត៌មាន បើមិនដូច្នេះទេ ទាហានទាំងនោះនឹងបាញ់កាំភ្លើងធំពន្លិចកាណូតនោះភ្លាម ព្រោះគេខ្លាចទាហាន លន់ នល់ បង្កប់ខ្លួននៅក្នុងកាណូត។*

*ដើម្បីឲ្យគ្រួសាររបស់ សុធា បានរួចផុតពីសេចក្តីស្លាប់ លោកយាយ ហេង បានក្រោកតាំងពីយប់ងងឹតដើរកាត់ពីភូមិមួយទៅភូមិមួយទៀត ដោយត្រូវឆ្លងកាត់ព្រៃនិងវាលទឹកទាំងយប់ងងឹតដើម្បីឲ្យបានទៅដល់ភូមិទឹកឃ្លាំងទទួលកូនប្រសានិងចៅ។ នេះជារឿងមួយគ្រោះថ្នាក់បំផុតសម្រាប់គាត់ដែលគាត់ហ៊ានលួចចេញពីភូមិមួយទៅភូមិមួយទៀតដោយគ្មានលិខិតអនុញ្ញាត។*

*រង់ចាំអស់រយៈពេលប្រហែលជាងមួយម៉ោង កាណូតចម្លងក៏បានមកដល់។ នៅពេលជិះលើកាណូត មានលោកយាយម្នាក់បានឲ្យក្រមាមួយដល់ សុធា ដណ្តប់ ពីព្រោះនៅពេលនោះត្រជាក់ខ្លាំងណាស់។ សុធា នៅតែចាំមិនទាន់ភ្លេចនូវគុណរបស់លោកយាយនោះនៅឡើយទេ ទោះបីជានៅពេលនោះ គាត់មិនបាននិយាយពាក្យថាអរគុណទៅកាន់លោកយាយនោះក៏ដោយ។ រលកបានបោកបក់យ៉ាងខ្លាំងមកលើកាណូតនេះម្តងហើយម្តងទៀត ជាហេតុធ្វើឲ្យកាណូតឃ្លេងឃ្លោង ដូចជាចង់លិច ដែលធ្វើឲ្យអ្នកជិះលើកាណូតទាំងអស់មានការភិតភ័យយ៉ាងខ្លាំង។ ឃើញសភាពបែបនេះ សុធា មានការភ័យតក់ស្លុតជាខ្លាំង ដោយមិនដឹងថាត្រូវនិយាយអ្វីជាមួយម្តាយនោះទេ គឺបានត្រឹមតែនៅស្ងៀមប៉ុណ្ណោះ។ ក្រោយពីបានឆែកឆេររកអាវុធនិងទាហាន លន់ នល់ រួច អង្គការក៏បានអនុញ្ញាតឲ្យយើងទាំងអស់គ្នាធ្វើដំណើរបន្តទៅមុខទៀត។ ចំណែកអ្នកគ្រូ សាម៉េត ពេលកំពុងធ្វើដំណើរ ក៏បានមកជួបលោកយាយ ហេង នៅភូមិទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល។ ពេលនោះដោយសារសម្លៀកបំពាក់ត្រូវទទឹកជោកនិងជិះកាណូតហាលខ្យល់ជងនោះ សុធា ក៏មានជំងឺគ្រុន។*

*ប៉ុន្មានម៉ោងក្រោយមក មេឃក៏ងងឹត។ ពេលនោះលោកយាយ ហេង មិនទាន់ចូលសម្រាន្តនៅឡើយទេ ដោយគាត់នៅជជែកលេងជាមួយម្ចាស់ផ្ទះដែលបានបែកគ្នាអស់រយៈពេលជាច្រើនឆ្នាំមកហើយ ពីព្រោះអ្នកដែលរស់នៅក្នុងដីរំដោះទាំងអស់គ្មានសិទ្ធិទៅណាមកណាដោយសេរី ហើយឆ្លងពីភូមិមួយទៅភូមិមួយដើម្បី*

ទៅលេងមិត្តភក្តិឬសួរសុខទុក្ខសាច់ញាតិឡើយ ។ ដូច្នេះបើមានប្រជាជនណាម្នាក់ចង់ធ្វើដំណើរទៅទីណាមកណា គាត់ត្រូវតែសុំការអនុញ្ញាតពីអង្គការជាមុនសិន ប៉ុន្តែក៏មានប្រជាជនខ្លះអាចទទួលបានការអនុញ្ញាតពីអង្គការក្នុងការធ្វើដំណើរទៅក្រៅដែរ ។

ស្អែកឡើង លោកយាយ ហេង បានឲ្យថ្នាំ សុធា លេបម្តងទៀតដើម្បីព្យាបាលជំងឺគ្រុនចាញ់ ។ ថ្ងៃនោះ គ្រួសារ សុធា មិនទាន់ចាកចេញពីភូមិទឹកឃ្លាំងភ្លាមទេ ដោយត្រូវរង់ចាំរហូតដល់ពេលយប់សិន ទើបអាចចេញដំណើរទៅភូមិព្រែកតាសរបាន ប៉ុន្តែមិនទាន់ដល់ពេលព្រលប់ផង គ្រួសាររបស់ សុធា និងម្ចាស់ផ្ទះបានបរិភោគអាហារពេលល្ងាចរួចទៅហើយ ដើម្បីទៅសម្រាកពីព្រលប់ងាយស្រួលភ្ញាក់នៅពាក់កណ្តាលអធ្រាត្រចេញដំណើរ ។ នៅល្ងាចថ្ងៃនោះ លោកយាយ ហេង បានដាំបាយនិងរៀបចំម្ហូបទុកហូបតាមផ្លូវនៅថ្ងៃស្អែក ពីព្រោះការធ្វើដំណើរនេះត្រូវចំណាយអស់រយៈពេលជាច្រើនម៉ោងទើបបានទៅដល់គោលដៅ ។

នៅពាក់កណ្តាលអធ្រាត្រ លោកយាយ ហេង បានលើក សុធា ដាក់លើខ្នងនិងកាន់កញ្ចប់បាយ ចំណែកអ្នកគ្រូ សាម៉េត វិញ ស្ពាយបង្វេចមួយនៅលើស្មានិងព សោភ័ណ ដោយធ្វើដំណើរកាត់ព្រៃលិចទឹកនិងហែលឆ្លងទឹកជ្រៅ ។

ពេលមកដល់វត្តសំពោច សុធា ភ័យខ្លាចយ៉ាងខ្លាំងពីព្រោះនៅទីនោះមានផ្នូរខ្មោចជាច្រើនដែលទើបតែកប់ថ្មីៗ ។ ក្រោយពីបានឆ្លងទឹកនិងដើរជាច្រើនម៉ោងមក ពួកគាត់ក៏បានឡើងមកសម្រាកនៅក្នុងសាលាឆទាន ។ ដោយសារតែធ្វើដំណើរអស់កម្លាំងខ្លាំងពេក ទាំងអស់គ្នាបានគេងលក់ដោយមិនដឹងខ្លួន ។ ស្អែកព្រឹកឡើង សុធា ឃើញម្តាយដាស់ប្អូនស្រី ចំណែកលោកយាយវិញរៀបចំម្ហូបអាហារដែលបានយកមកជាប់នឹងខ្លួនតាំងពីយប់ដើម្បីហូបបន្តដំណើរទៅមុខទៀត ។ សុធា មិនបានចងចាំពីមុខម្ហូបទាំងនោះទេ ប៉ុន្តែគាត់នៅចាំបានថាអាហារពេលនោះ ទោះបីជាឆ្ងាញ់ឬមិនឆ្ងាញ់យ៉ាងណាក៏ដោយ វាមានតម្លៃខ្លាំងណាស់សម្រាប់យើងទាំងអស់គ្នា ។

ដោយមានពន្លឺព្រះអាទិត្យចាំងចូលមក អ្នកជម្លៀសទាំងអស់បានឃើញបំណែកខោអាវរបស់កងទ័ពខ្មែរក្រហមប្រឡាក់សុទ្ធតែស្នាមឈាមគ្រប់ទីកន្លែង សូម្បីតែនៅលើសាលាឆទានដែលគាត់បានសម្រាកកាលពីយប់មិញនិងនៅកន្លែងដែលយើងអង្គុយបរិភោគអាហារក៏មានដែរ ។ លោកយាយ ហេង គិតថា ប្រហែលជាឈាមរបស់ទាហានខ្មែរក្រហមដែលរត់ចូលមកសម្រាកនៅក្នុងសាលាឆទាននេះ ពេលកំពុងរត់គេចពីទាហាន លន់ នល់ ហើយ ។

ដើរលុយទឹកបានមួយសន្ទុះធំ គាត់ក៏បានមកដល់វត្តមួយឈ្មោះវត្តព្រែកគង់រាជ ។ នៅទីនោះ គេអាចមើលឃើញភូមិតាសរដែលជាកន្លែងអ្នកជម្លៀសខ្លួនស្នាក់នៅនិងជាកន្លែងណាត់ជួបរវាងម្តាយ និងឪពុក សុធា ហើយក៏ជាផ្ទះរបស់លោកយាយ ហេង ផងដែរ ។ អ្នកជម្លៀសទាំងអស់មិនអាចឆ្លងកាត់ទន្លេនៅភូមិព្រែកគង់រាជនេះបានទេ ព្រោះត្រូវឆ្លងកាត់ភូមិព្រែកក្រូច ស្រុកល្វាឯម ខេត្តកណ្តាលជាមុនសិន ។ ពេលមកដល់ជិតវត្តវិហារខ្ពស់ ក្នុងភូមិព្រែកក្រូច ទើបអាចធ្វើដំណើរតាមទូកបន្តទៅកាន់ភូមិព្រែកតាសរដែលស្ថិតនៅក្នុងខេត្តព្រៃវែង រួចបានទៅដល់គោលដៅ ។

ពេលមកដល់ភូមិព្រែកតាសរ សុធា សប្បាយចិត្តខ្លាំងណាស់ ប៉ុន្តែ ផ្ទះនៅទីនោះមិនដូចជាផ្ទះនៅទីក្រុងភ្នំពេញដែល សុធា ធ្លាប់ឃើញទេ ពីព្រោះវាគ្មានសណ្តាប់ធ្នាប់ ។ ក្រោយមក អ្នកទាំងបួននាក់ក៏បានមកដល់ខ្ទមលោកយាយ ហេង ដែលជាខ្ទមមួយមានជញ្ជាំងស្លឹកដូង ដំបូលប្រក់កក់ សសរឫស្សី និងក្រាលរនាបឫស្សី មានទំហំប្រហែល៨ម៉ែត្រគុណនឹង៦ម៉ែត្រប៉ុណ្ណោះ ។ ខ្ទមនោះស្ថិតក្នុងដីឡូត៍ទំហំ១០ម៉ែត្រគុណនឹង១៥០ម៉ែត្រ បែរមុខទៅមាត់ទន្លេជាប់របងវត្តសាមគ្គីរង្សីដែលជាវត្តតែមួយគត់នៅក្នុងភូមិព្រែកតាសរនេះ ។ មួយសន្ទុះក្រោយមក មានបងប្អូនមាមីងមួយចំនួនបានលួចមកសួរសុខទុក្ខគ្រួសារ សុធា ប៉ុន្តែធ្វើឡើងដោយលួចលាក់ប៉ុណ្ណោះ ព្រោះខ្មែរក្រហមមិនអនុញ្ញាតឲ្យដើរទៅណាមកណាដោយសេរីទេ ។

## ជីវភាពរស់នៅក្នុងភូមិព្រែកតាសរ

ប្រជាជនដែលរស់នៅតាមដងទន្លេនានាក្នុងប្រទេសកម្ពុជាភាគច្រើនមានជីវភាពធូរធារដោយប្រកបរបរធ្វើស្រែប្រាំង និងធ្វើចម្ការដូចជាដាំសណ្តែក ល្ង ថ្នាំជក់ និងនេសាទត្រី ។ ទោះបីជាភូមិព្រែកតាសរនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមតាំងពីឆ្នាំ១៩៧៣ក៏ដោយ ក៏ប្រជាជនទាំងនោះនៅតែប្រកបរបររកស៊ីដដែល និងទោះបីជាការហូបចុករបស់ប្រជាជនមានលក្ខណៈ

ឯកជនយ៉ាងណាក៏ដោយ ក៏អង្គការនៅតែតាមដានពីសកម្មភាពរបស់ប្រជាជនក្នុងភូមិដដែលដើម្បីកំណត់មុខសញ្ញាខ្មាំងបដិវត្តន៍ ។

នៅក្នុងភូមិព្រៃកគាសរ លោកយាយ ហេង ក៏ដូចជាអ្នកភូមិដទៃទៀតដែរ គឺសុទ្ធតែជាអ្នករកស៊ីដូរញដូរ ចំណែកម្តាយ សុធា វិញ នៅផ្ទះមើលថែទាំកូនទាំងពីរ ។ នៅពេលនោះការរកស៊ីរបស់អ្នកភូមិព្រៃកគាសរទៅកាន់ទឹកដីដែលគ្រប់គ្រងដោយ លន់ នល់ ស្ទើរតែត្រូវបានហាមឃាត់ទាំងស្រុង ដូច្នេះហើយបានជាអ្នកភូមិទឹកឃ្លាំងទាំងអស់នាំគ្នាលួចឆ្លងទៅកំពង់ជស័ក្តិពីរ ដើម្បីទិញអីវ៉ាន់ ។ កាលលួចឡើងមកទិញទំនិញបែបនេះពុំមែនជាមធ្យោបាយរកស៊ីងាយស្រួលនោះទេ ពីព្រោះអ្នកទាំងនោះត្រូវសូកប៉ាន់ទាហានខ្មែរក្រហមដែលគ្រប់គ្រងនៅទីនោះជាមុនសិន មុនពេលឆ្លងកាត់ ។ សុធា នៅចាំថា ពេលគាត់រស់នៅម្តុំវិត្តនិរោធរង្សី ឪពុករបស់គាត់ធ្លាប់បានជួយសម្រុះសម្រួលជាមួយមេបញ្ជាការទាហាននៅស្រុកកៀនស្វាយ ដើម្បីឲ្យដោះលែងប្រជាជនដែលមកពីភូមិព្រៃកគាសរទាំងអស់ ទើបអ្នកភូមិទាំងនោះអាចរួចជីវិតផុតពីការសម្លាប់របស់ទាហាន លន់ នល់ ។ នៅពេលនោះ ការចរាចរលុយនៅក្នុងភូមិនៅតែមាន ដោយលោកយាយ ហេង ក៏ដូចជាអ្នកភូមិព្រៃកគាសរដែរ តែងតែយកប្រហុក ត្រីងៀត និងរបស់របរផ្សេងៗទៀតទៅដូរយកស្រូវនិងអង្ករពីភូមិផ្សេងៗទៀត ។

ចាប់ពីឆ្នាំ១៩៧៣មក ប្រុសៗជាច្រើននៅក្នុងភូមិព្រៃកគាសរបាននាំគ្នារត់ចូលព្រៃ ដើម្បីបង្កើតចលនារំដោះជាតិដែលមានឈ្មោះថាកងទ័ពប្រជាជាតិ ។ ទ័ពទាំងនោះមានតួនាទីចេញទៅប្រយុទ្ធជាមួយទ័ពសាធារណរដ្ឋខ្មែរ ដែលស្ថិតនៅក្នុងខេត្តព្រៃវែង ខេត្តកណ្តាល និងនៅតាមបណ្តោយផ្លូវជាតិលេខមួយ ។

មកដល់ឆ្នាំ១៩៧៥ អង្គការបានក្លាយជាសត្រូវជាមួយនឹងកងទ័ពប្រជាជាតិដែរ ដោយអង្គការចោទថាកងទ័ពប្រជាជាតិគឺជាខ្មាំង ។ ចាប់តាំងពីពេលនោះមក អង្គការចាប់ផ្តើមសម្លាប់ប្រជាជនដែលមានអតីតភាពជាកងទ័ពប្រជាជាតិ ទោះបីជាប្រជាជនទាំងនោះបានវិលមករស់នៅក្នុងស្រុកភូមិវិញក្នុងនាមជាប្រជាជនយ៉ាងណាក៏ដោយ ពីព្រោះអ្នកទាំងនោះមានជាប់និន្នាការជាកងទ័ពប្រជាជាតិ ។ ម្ល៉ោះហើយ អ្នកទាំងនោះតែងតែលាក់ប្រវត្តិរបស់ខ្លួន និងសម្ងំនៅក្នុងផ្ទះដោយមិនហ៊ានបង្ហាញមុខឲ្យអ្នកដទៃឃើញឡើយ ចំណែកឯប្រជាជនថ្មីដែលមកពីដីរបស់ លន់ លន់វិញ ក៏ជាសុទ្ធតែជាខ្មាំងរបស់អង្គការដែរ ដូចជាគ្រួសាររបស់ សុធា ក៏ជាមុខសញ្ញាដែលអង្គការកំពុងតាមដាន ។ នៅទីនោះ សុធា ក៏ដូចជាកុមារដទៃទៀតដោយមិនបានចូលសាលារៀនទេ ពីព្រោះសាលារៀននៅពេលនោះត្រូវលុបបំបាត់ចោលនិងតម្រូវឲ្យកុមារទាំងនោះធ្វើជាកុមារបដិវត្តន៍ ។ នៅពេលនោះ កុមារទាំងអស់គឺជាកូនរបស់អង្គការ មិនមែនជាកូនរបស់ឪពុកម្តាយទៀតឡើយ ដោយកុមារទាំងអស់ត្រូវតែទទួលការបំពាក់បំប៉នពីទ្រឹស្តីបដិវត្តន៍ ហើយត្រូវតែរាយការណ៍ប្រាប់អង្គការពីអ្វីដែលឪពុកម្តាយបានធ្វើខុសពីមាគ៌ាបដិវត្តន៍ ចំណែកការរៀបអាពាហ៍ពិពាហ៍រវាងប្រជាជនថ្មីនិងប្រជាជនចាស់វិញត្រូវហាមឃាត់ ប៉ុន្តែមកដល់ឆ្នាំ១៩៧៧ ការរៀបអាពាហ៍ពិពាហ៍នេះត្រូវបានអង្គការអនុញ្ញាត ។ ចំណុចនេះហើយ ទើបធ្វើឲ្យយើងបានដឹងយ៉ាងច្បាស់ពីភាពខុសគ្នារវាងប្រជាជនថ្មីនិងប្រជាជនមូលដ្ឋាន ដោយប្រជាជនមូលដ្ឋានមានសិទ្ធិរៀបការចាប់តាំងពីមុនឆ្នាំ១៩៧៧មក ទង្វើបែបនេះបានធ្វើឲ្យមានការបែងចែកវណ្ណៈរវាងប្រជាជនថ្មីនិងចាស់ ។ នៅមានចំណុចខុសគ្នាជាច្រើនទៀត ដូចជាការរស់នៅរបស់ប្រជាជនចាស់មានលក្ខណៈធូរស្រាលជាងប្រជាជនថ្មី ទាំងការហូបចុក មនោសញ្ចេតនា ការនិយាយស្តី ការស្លៀកពាក់ និងអ្វីផ្សេងៗទៀតជាច្រើន ចំណែកប្រជាជនថ្មីវិញ គឺគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់ ។ លើសពីនេះទៅទៀត គឺហាមឃាត់ដាច់ខាតមិនឲ្យមានទំនាក់ទំនងស្នេហារវាងមនុស្សប្រុសនិងស្រីមុនពេលរៀបការទេ ដូច្នេះបើប្រជាជនណាហ៊ានស្រឡាញ់គ្នា ហើយត្រូវអង្គការដឹង អ្នកទាំងពីរនោះនឹងត្រូវមានទោសពីបទខុសសីលធម៌ ដែលតម្រូវឲ្យរែកដីក្នុងមួយថ្ងៃប្រហែលជា៥-៦ម៉ែត្រគូប ឬយកទៅដាក់គុក និងវាយធ្វើបាបយ៉ាងដំណំមុនពេលយកទៅសម្លាប់ចោល ។ នៅពេលត្រូវការយកប្រជាជនថ្មីទៅសម្លាប់ អង្គការតែងតែចាត់តាំងអ្នកស្រុកដែលជាប្រជាជនចាស់ឲ្យបររទេះដឹកអ្នកទោសទៅកាន់មន្ទីរសន្តាត់កំពង់ប្រាំងនៅពេលព្រឹកព្រលឹមម៉ោង៧ ដោយបររទេះក្នុងល្បឿនយឺតៗតាមធម្មតា ធ្វើឲ្យប្រជាជនថ្មីដែលជិះលើរទេះមិនបានចាប់ភ្លឹកថាគេដឹកយកទៅសម្លាប់នោះទេ ដោយការសម្លាប់

នោះចំនួនដល់ទៅ៣០-៤០រទេះ ។ នៅក្នុងរទេះនីមួយៗ គេដាក់ប្រជាជនឲ្យអង្គុយជាលក្ខណៈគ្រួសារ ដោយមានគ្រួសារមួយចំនួនយកបបរមកបញ្ចុកកូននៅលើរទេះ មួយចំនួនទៀតជជែកគ្នាយ៉ាងសប្បាយដោយគិតសង្ឃឹមក្នុងថាទីលំនៅថ្មីនៅភូមិខាងមុខរបស់គេអាចធ្វើឲ្យគេរស់នៅបានសុខស្រួល ហើយក៏មានប្រជាជនមួយចំនួនទៀតបានគៀនអ្នកបររទេះឲ្យស្រូតដំណើរដើម្បីឆាប់បានទៅដល់គោលដៅ ប៉ុន្តែនៅពេលដែលរទេះបរចូលមកដល់ក្បែរមន្ទីរសន្តាត់កំពង់ប្រាំង សំឡេងស្រែកយំអង្វរឲ្យទុកជីវិត សំឡេងភ័យខ្លាចនិងឈឺចាប់ សំឡេងអាណិតប្តីដែលត្រូវអង្គការសម្លាប់នៅចំពោះមុខ និងសំឡេងទារកដែលគេបោកនឹងគល់ឈើ ឬបោះទៅលើរួចចាក់សម្លាប់នឹងចំពុះទង់បានលាន់ឮឡើងដូចជាសួរជួងមរណៈមកប៉ះនឹងត្រចៀកប្រជាជនថ្មីដែលកំពុងតែអង្គុយនៅលើរទេះ ។ មិនតែប៉ុណ្ណោះ រូបភាពកងឈ្លបលើកចំពុះទង់ចាក់ទម្លាយទ្រូងតាចាស់ ឬលើកត្បូងចបសំពងក្បាលមនុស្សស្រីនិងធាក់ទម្លាក់អ្នកទោសចូលក្នុងរណ្តៅបានលេចឡើងនៅចំពោះមុខប្រជាជនថ្មីដែលគេប្រាប់ថាត្រូវផ្លាស់ទីលំនៅមកកាន់ទីនេះ ។ អ្នកទោសរបស់អង្គការមានការភ័យតក់ស្លុតស្ទើរចុះពីលើរទេះមិនរួច ប៉ុន្តែភាសារបស់កងឈ្លបជាមួយនឹងចុងកាណុងបានភ្ជង់បង្ខំឲ្យអ្នកទាំងនោះចុះពីលើរទេះទាំងញ័រញ៉ូរ រួចដើរសំដៅទៅរករណ្តៅប្រហារជីវិតដែលទោសរបស់គាត់គឺជាប្រជាជនថ្មីមាននិន្នាការជាប់កម្ពែលខ្មាំងដូចជាគ្រូបង្រៀន ប៉ូលិស កងរាជអាវុធហត្ថ មន្ត្រីរាជការនិងជាខ្មាំងប្រឆាំងអង្គការ ។ ការសម្លាប់មួយប្រភេទទៀតរបស់អង្គការទៅលើប្រជាជនថ្មីគឺដឹកប្រជាជនដាក់ក្នុងរទេះតម្រង់ទៅកាន់ស្ទឹងស្លាយពល ស្រុកពារាំង ខេត្តព្រៃវែង ហើយចងព្យួរប្រជាជនទាំងនោះទៅនឹងរ៉កនៅលើដើមឈើ ដែលដុះប្របមាត់ស្ទឹង ហើយវាយសម្លាប់ប្រជាជនទម្លាក់ពីខ្សែរ៉កបញ្ចូលក្នុងទឹកស្ទឹងដែលកំពុងហូរ ។

ពេលនោះគ្រួសារ សុផា ត្រូវរស់នៅក្នុងសភាពភ័យខ្លាចគ្រប់ដង្ហើមចេញចូលទាំងអស់ ។ គ្រួសារ សុផា ខិតខំរស់នៅដោយលាក់នូវប្រវត្តិរូបរបស់លោកស័ក្តិបី កែវ ហៀង និងអ្នកគ្រូ សាម៉េត មិនឲ្យលេចឮដំណឹងដល់អង្គការ ។ អ្នកគ្រូនិងកូនៗប្រឹងអត់ប្រឹងឃ្លានមិនហ៊ានមាត់កអ៊ីទាំងអស់ ហើយក៏មិនហ៊ានស្វែងរកអ៊ីមកហូបឲ្យខុសពីរបៀបរបបរបស់អ្នកភូមិដែរ ដោយខិតខំរៀបចំខ្លួនឲ្យក្លាយទៅជាវណ្ណៈកសិករក្រីក្រនិងមិនស្លៀកសម្លៀកបំពាក់ដែលមានពណ៌ឆើត ឬសម្លៀកបំពាក់ណាដែលល្អជាងអ្នកភូមិឡើយ ។ ម្តាយ សុផា បានអប់រំ សុផា ឲ្យចេះនិយាយកុហកនិងពាក្យចម្លែកៗ ហាមឃាត់ដាច់ខាតមិនឲ្យនិយាយប្រាប់នរណាម្នាក់អំពីតួនាទីជាទាហានរបស់លោកប៉ា និងមុខងារជាគ្រូបង្រៀនរបស់ម្តាយ ។

ក្រោយពីរស់នៅភូមិព្រែកតាសរបានមួយរយៈ ក៏មានបងប្អូនរបស់លោកយាយ ហេង ម្នាក់ បានលបមកប្រាប់លោកយាយថាអង្គការបានស៊ើបដឹងពីប្រវត្តិរូបរបស់គ្រួសារអ្នកគ្រូ សាម៉េត រួចហើយ ហើយក៏ដឹងដែរថាឪពុករបស់ សុផា គឺជាទាហានស័ក្តិបី ចំណែកគាត់វិញគឺជាគ្រូបង្រៀន ។ នៅសម័យនោះ ទាហាននិងគ្រូបង្រៀន គឺសុទ្ធតែជាខ្មាំងរបស់អង្គការ ដូច្នេះគ្រាន់តែឮដំណឹងនេះភ្លាម លោកយាយ ហេង និងគ្រួសារ សាម៉េត មានការភិតភ័យជាខ្លាំង ហើយខិតខំស្វែងរកវិធីចាកចេញពីភូមិព្រែកតាសរនេះឲ្យបានឆាប់ ។ ទោះបីជាលោកយាយ ហេង ជាស្ត្រីមេម៉ាយម្នាក់យ៉ាងណាក៏ដោយ ក៏គាត់បានចិញ្ចឹមកូន៩នាក់ឲ្យរស់នៅប្រកបដោយជីវភាពសមរម្យដែរ ហើយអាចឲ្យកូនៗបានទៅរៀនសូត្រគ្រប់ៗគ្នារហូតដល់ចប់វិទ្យាល័យក្នុងសម័យ លន់ នល់ ។ ក្រៅពីលោកស័ក្តិបី កែវ ហៀង លោកយាយមានកូនចំនួនបួននាក់ទៀតកំពុងរស់នៅក្នុងស្រុកចម្ការលើ ខេត្តកំពង់ចាម ដែលជាខេត្តមួយគ្រប់គ្រងដោយទាហានខ្មែរក្រហម ហើយលោកយាយមកកាន់ទីនេះគឺដើម្បីមកទទួលលោក កែវ ហៀង ជាកូនច្បងទៅរស់នៅខេត្តកំពង់ចាមជុំជាមួយលោកយាយនិងកូនបួននាក់ទៀត ។ ដោយសារលោកយាយ ហេង ជាមនុស្សឆ្លាតនិងម៉ត់ចត់ គាត់បាននឹកឃើញមធ្យោបាយមួយ គឺធ្វើក្បូនដើមចេកដើម្បីរត់ចេញពីភូមិដែលគួរឲ្យខ្លាចនេះ ក្នុងគោលបំណងរត់ទៅកាន់ភូមិព្រៃស្នៀត ស្រុកពារាំង ខេត្តព្រៃវែង រួចទើបរកវិធីបន្តដំណើរមកកាន់ស្រុកចម្ការលើ ខេត្តកំពង់ចាម ។

## ការភៀសខ្លួនម្តងទៀត

ពេលមាន់រងាវ លោកយាយ ហេង បានដាស់ សុផា និងសោភ័ណ ឡើងអង្គុយលើក្បូនដើមចេក ដោយនៅលើក្បូននោះមានសម្ពាយខោអាវ ចានឆ្នាំងនិងរបស់ប្រើប្រាស់មួយចំនួនទៀត

ចេញដំណើរទៅកាន់ភូមិព្រៃស្មៀត ។ ដោយសារពេលនោះជារដូវមានភ្លៀងធ្លាក់ខ្លាំង ជាហេតុធ្វើឲ្យមានទឹកជំនន់ជន់លិចពេញភូមិព្រែកតាសរនេះទាំងមូល សូម្បីតែផ្ទះរបស់លោកយាយ ហេង ក៏លិចដែរ ដូច្នេះក្បូនដើមចេកនេះត្រូវចេញដំណើរពីក្រោយផ្ទះទៅកាន់បឹងមួយ ដោយមានជីដូននិងម្តាយ សុធា ជាអ្នកអូសក្បូន ។

ពេលវេលាចេះតែបន្តទៅមុខ ក្បូនដើមចេកក៏បានមកដល់ទួលមួយដែលមានសភាពដូចជាកូនភូមិមួយ ហើយមានផ្ទះតូចៗប្រហែល៤-៥ផ្ទះ ។ ពេលក្រឡេកមើលជុំវិញ សុធា ឃើញមានវាលស្រែនិងដើមត្នោតជាច្រើន ប៉ុន្តែមិនឃើញមានព្រៃដូចជាភូមិដទៃដែលគាត់ធ្លាប់ឃើញពីមុននោះទេ ។ លោកយាយបាននិយាយប្រាប់ថា នៅទីនេះគេហៅទួលព្រៃដែលជាកន្លែងអ្នកនេសាទត្រីជាច្រើនតែងតែមកសង់ខ្ទមសម្រាកបណ្តោះអាសន្ន ពីព្រោះអ្នកនេសាទត្រីទាំងនោះត្រូវចំណាយរយៈពេលប្រហែលជាមួយខែឬមួយរដូវទើបវិលត្រឡប់ទៅកាន់ភូមិរបស់គេវិញ ។ ក្រោយពីហូបបាយរួច អ្នកគ្រូ សាម៉េត បានបំបៅដោះកូន ពីព្រោះទឹកដោះគោដែលបានត្រៀមទុកអស់ហើយ ។ ប៉ុន្តែ ដោយសារទឹកដោះរបស់គាត់ខះមិនអាចឲ្យកូនបៅបាន អ្នកគ្រូ សាម៉េត ក៏សម្រេចចិត្តកិនបាយបញ្ចុកកូនជំនួសវិញ ។ នៅពេលយប់ ស្ត្រីទាំងពីរនាក់ក៏ចាប់ផ្តើមរុញក្បូនដើមចេកបណ្តែតនៅលើផ្ទៃទឹកសាជាថ្មីដើម្បីចេញដំណើរបន្តទៀត ។

ស្អែកព្រលឹមឡើង គ្រួសារ សុធា បានមកដល់ភូមិព្រៃស្មៀត ស្រុកពារាំង ខេត្តព្រៃវែង ដែលស្ថិតនៅជិតស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ គ្រាន់តែមកដល់ទីនេះភ្លាម គ្រួសារ សុធា បានសម្រេចចិត្តរស់នៅក្នុងភូមិនោះបណ្តោះអាសន្នសិន ។

## ជីវភាពរស់នៅក្នុងភូមិព្រៃស្មៀត

នៅភូមិព្រៃស្មៀតនេះ អង្គការបានបែងចែកភូមិជាពីរប្រភេទខុសគ្នា គឺភូមិប្រជាជនចាស់និងប្រជាជនថ្មី ដោយភូមិប្រជាជនចាស់មានផ្ទះធ្វើពីឈើប្រក់ក្បឿងឬផ្ទះសង់ខ្ពស់ផុតពីដីដែលមានជញ្ជាំងធ្វើពីដីឥដ្ឋលាយចំបើង ប្រក់ស្បូវឬស្លឹក ហើយផ្ទះទាំងនោះស្ថិតនៅក្នុងដីឡូត៍ធំៗដែលអាចដាំដំណាំបានជាច្រើន ដូចជាដាំដំឡូងជ្វា ដំឡូងឈើ ត្រាវនិងចេក ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ផ្ទះទាំងអស់នោះមានទំហំតូចជាងផ្ទះរបស់អ្នកភូមិព្រែកតាសរដែរ ។ ដោយសារតែភូមិព្រៃស្មៀតនេះជាភូមិមួយក្រីក្រនិងមិនសូវសម្បូរត្រី ហេតុនេះហើយទើបអង្គការតម្រូវឲ្យហូបបាយរួម ។ ចំណែកដំណាំនិងសត្វដែលប្រជាជនមូលដ្ឋានដាំនិងចិញ្ចឹមមិនអាចយកមកហូបបានទេ ពីព្រោះរបស់ទាំងអស់នេះសុទ្ធតែជារបស់អង្គការទាំងអស់ បើសិនជាមាននរណាហ៊ានបេះដំណាំដែលខ្លួនបានដាំយកមកហូប នោះនឹងត្រូវមានទោស ។

ផ្ទះរបស់គ្រួសារ សុធា ស្ថិតនៅក្នុងភូមិប្រជាជនថ្មី ដែលមានជញ្ជាំងសង់ពីឥដ្ឋលាយចំបើង ដំបូលប្រក់ស្លឹកត្នោត សង់ឡើងដោយលោកយាយនិងម្តាយរបស់ សុធា ។ ដំបូងអង្គការអនុញ្ញាតឲ្យប្រជាជនទាំងអស់នៅក្នុងគ្រួសាររស់នៅជុំគ្នាក្នុងផ្ទះតែមួយ ប៉ុន្តែមិនទាន់ចាត់តាំងឲ្យប្រជាជនទាំងនោះធ្វើការងារនៅក្នុងសហករណ៍ណាមួយឡើយ ។ ប៉ុន្តែមិនយូរប៉ុន្មាន លោកយាយ ហេង ត្រូវបានអង្គការចាត់តាំងឲ្យធ្វើការនៅមណ្ឌលយាយៗ មានតួនាទីជាអ្នកត្បាញកន្ទេលត្នោតនិងក្រងស្បូវ ។ ដោយសារការងារនោះជាការងារសម្រុក ទោះបីជាលោកយាយ ហេង អស់កម្លាំងឬឈ្លានយ៉ាងណាក៏ដោយ ក៏គាត់មិនអាចសុំច្បាប់ឈប់សម្រាកឬបង្អែបង្អង់ការងារដោយលើកហេតុផលណាមួយមកធ្វើជាលេសបានឡើយ បើមិនអ៊ីចឹងទេ គាត់នឹងត្រូវទាហានខ្មែរក្រហមយកទៅសម្លាប់ ។ ចំណែកម្តាយរបស់ សុធា វិញ ក៏ត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅកងចល័តស្ត្រីវ័យកណ្តាលដែលជាកងសម្រុកជងដែរ រួមមានការងារដកស្ទូង ច្រូតស្រូវ និងលើកទំនប់ ដោយភាគច្រើនកងនេះតែងតែចុះទៅជួយធ្វើការតាមភូមិនានា ហើយសម្រាកពេលយប់នៅតាមភូមិទាំងនោះ ។ ដូច្នេះហើយទើបម្តាយរបស់ សុធា មិនសូវបានជួបមុខកូនរបស់គាត់ទេ ដោយទុកឲ្យក្មេងទាំងពីរនៅជាមួយនឹងជីដូន ។

ការធ្វើការរហូតដល់ពាក់កណ្តាលអធ្រាត្រ បានធ្វើឲ្យប្រជាជនម្នាក់ៗហេវហត់និងអស់កម្លាំងរហូតគ្រាន់តែប្រាស់ខ្នងដល់កន្ទេលក៏គេងលក់ភ្លាម ប៉ុន្តែគេងមិនទាន់ស្កប់ផងសំឡេងកងនារីក៏ប្រកាសដាស់កងស្ត្រីឲ្យងើបទៅធ្វើការបន្ត ។ ពេលនោះម្តាយរបស់ សុធា សម្លឹងមើលទៅជើងមេឃដែលងងឹត ហើយគិតក្នុងចិត្តថាហេតុអ្វីបានជាគេចាត់ទុកមនុស្សដូចជាឧបករណ៍ប្រើប្រាស់

ដែលមិនចេះហត់ មិនចេះឃ្លាន ហើយម្នាក់ៗបរិភោគបានតែបបររាវលាយជាមួយគល់ចេកនិងគ្រាប់អង្ករមួយគ្រាប់ៗប៉ុណ្ណោះ ចំណែកម្ហូបវិញមានតែឆែប៉ូវនិងសម្លបង់ប្រហុកជាមួយបន្លែដូចជាស្លឹកបាស គល់ចេក ឬត្រកួនជាដើម ។ ទោះបីជាប្រជាជនទទួលបានអាហារបរិភោគមិនគ្រប់គ្រាន់យ៉ាងណាក៏ដោយ ក៏អង្គការនៅតែបញ្ជាឲ្យគ្រប់កងទាំងអស់ធ្វើការចាប់តាំងពីម៉ោង៣ឬ៤ទៀបភ្លឺ រហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបឲ្យឈប់ប្រហែល២០នាទីសម្រាកហូបបាយ បន្ទាប់មកត្រូវធ្វើការរហូតដល់ម៉ោង៦ល្ងាច ទើបបានឈប់សម្រាក ។ ហេតុនេះហើយទើបធ្វើឲ្យម្តាយរបស់ សុធា និងប្រជាជនទាំងឡាយមានរាងកាយទ្រុឌទ្រោម និងចុះខ្សោយជាលំដាប់ ។

ជារៀងរាល់ព្រឹក ព្រលឹមស្រាងៗម៉ោងប្រហែល៣ឬ៤ទៀបភ្លឺ សំឡេងកញ្ចែបានលាន់រំពងដាស់កុមារទាំងឡាយនៅក្នុងភូមិឲ្យក្រោកពីដំណេកដើម្បីធ្វើពលកម្ម ដោយនៅក្នុងនោះក៏រួមមាន សុធា ផងដែរ មានតួនាទីកើបអាចម៍គោនៅតាមក្រោលគោនិងនៅតាមផ្ទះប្រជាជន ហើយយកមកផ្តុំគ្នាទៅតាមទីកន្លែងដែលប្រធានកងកុមាបានកំណត់ឲ្យ ។ គំនរអាចម៍គោទាំងអស់នោះគឺជាខ្នាតមួយសម្រាប់វាស់ពីទំហំការងាររបស់កុមារទាំងនោះ ដូច្នេះបើសិនជាគំនរនោះតូច កុមារទាំងនោះនឹងត្រូវទទួលទណ្ឌកម្ម ប៉ុន្តែបើសិនជាគំនរទាំងនោះធំ នោះអាចបញ្ជាក់ថាកុមារទាំងនោះសកម្ម ហើយនឹងត្រូវបានអង្គការលើកសរសើរ និងរាយការណ៍ទៅកាន់រោងបបរឲ្យផ្តល់របបដល់ក្មេងទាំងនោះចំនួនបីពេល ដែលវាជារបបអាហារមួយច្រើនជាងក្មេងដទៃទៀត ។ ប៉ុន្តែក្នុងចំណោមកុមារទាំងនោះគ្មាននរណាម្នាក់ធ្វើបានលើសពីផែនការណ៍ដែលអង្គការបានកំណត់ឡើយ ពីព្រោះផែនការដែលដាក់ចុះសម្រាប់ឲ្យកុមារធ្វើ វាធ្ងន់ធ្ងរលើសពីកម្លាំងដែលក្មេងអាចធ្វើបាន ហើយបើក្មេងនោះអាចធ្វើបានលុះត្រាតែក្មេងនោះប្រឹងប្រែងធ្វើការឲ្យអស់ពីសមត្ថភាព ហើយក្មេងនោះជាក្មេងមូលដ្ឋានដែលអាចបន្លំភ្នែកអង្គការបានពីព្រោះគេជាកូននិងក្មួយរបស់អង្គការ ។ ហេតុដូច្នេះ ការងារកើបអាចម៍គោរបស់កងកុមារ គឺជាការងារមួយដែលមានការប្រណាំងប្រជែងខ្លាំង ពីព្រោះបើធ្វើមិនបានល្អនិងមិនគ្រប់តាមផែនការ អង្គការនឹងដាក់ទណ្ឌកម្មដោយកាត់បន្ថយរបបអាហារឬធ្វើបាបតាមវិធីផ្សេងៗទៀត មានពេលខ្លះអាចឈានទៅដល់ការដាក់គុកថែមទៀតផង ។ លើសពីនេះទៅទៀត ការចាប់យកទៅដាក់គុកនេះមិនដែលមានកុមារណាម្នាក់បានវិលត្រឡប់មកកាន់លំនៅដ្ឋានរបស់គេវិញទេគឺបាត់ខ្លួនរហូត ។ ចំណែក សុធា វិញ មិនដែលបានធ្វើការគ្រប់តាមផែនការដែលបានដាក់ឲ្យដូចជាក្មេងមូលដ្ឋាននោះទេ ពីព្រោះ សុធា ធ្លាប់ជាក្មេងដែលរស់នៅក្នុងគ្រួសារមានជីវភាពគ្រាន់បើនៅទីក្រុងភ្នំពេញ ហើយមិនធ្លាប់ធ្វើការធ្ងន់ គេងច្រើនរហូតដល់ភ្លឺនិងហូបឆ្ងាញ់ ប៉ុន្តែក្រោយមកដោយសារតែការបង្ខិតបង្ខំរបស់អង្គការ សុធា ត្រូវក្រោកតាំងពីម៉ោងបីឬម៉ោងបួនយប់មកធ្វើការងារដែលខ្លួនមិនធ្លាប់ធ្វើពីមុនមក រហូតធ្វើឲ្យធ្លាក់ខ្លួនស្គមនិងខ្សោយកម្លាំងប្រៀបដូចជាមនុស្សមានជំងឺ ។

នៅវេលាម៉ោងជិត៨ជិតភ្លឺនាថ្ងៃមួយ សំឡេងកញ្ចែលាន់ទ្រហឹងពេញភូមិដើម្បីដាស់ក្មេងៗឲ្យងើបទៅកើបអាចម៍គោ ។ ប៉ុន្តែ សុធា នៅតែមិនទាន់ក្រោកពីដំណេកនៅឡើយទេ ដោយសារតែយប់មិញ សុធា ហូបមិនឆ្អែត និងធ្វើការរហូតដល់យប់ជ្រៅដើម្បីឲ្យគ្រប់ផែនការរបស់អង្គការ ។ ព្រោះតែឃើញ សុធា លង់ក្នុងដំណេកប្លែកជាងសព្វមួយដង លោកយាយ ហេង បានងាកសម្លឹងទៅចៅដោយក្រសែភ្នែកអាណិតនិងមិនហ៊ានដាស់ចៅឲ្យក្រោកនោះទេ ដោយទុកពេលឲ្យចៅបន្តក្នុងដំណេកបន្តិចទៀត ។ គិតរួចគាត់ក៏ចេញទៅធ្វើពលកម្ម ។ ម៉ោងប្រហែល១០ព្រឹក អង្គការបានហៅគាត់យកទៅអប់រំកសាងនៅក្នុងអង្គប្រជុំពីបទលាក់កម្លាំងពលកម្មចៅមិនឲ្យទៅកើបអាចម៍គោដូចក្មេងដទៃ ។ ក្នុងទឹកដីរំដោះ ទោះជាប្រជាជនណាដែលមិនជាប់និន្នាការប្រវត្តិជាខ្លាំងក៏ដោយ ប៉ុន្តែឲ្យតែត្រូវអង្គការហៅទៅកសាងជាច្រើនលើកនោះមុខជានឹងត្រូវយកទៅកម្ទេចចោលនាពេលក្រោយជាមិនខាន ។

នៅទីនេះ ទោះបីជាប្រជាជនឈឺក៏អង្គការមិនបានអនុញ្ញាតឲ្យឈប់សម្រាកនៅផ្ទះឡើយ បើមិនអ៊ីចឹងទេ អ្នកទាំងនោះនឹងត្រូវទទួលទណ្ឌកម្មដោយផ្តាច់របបអាហារ យកទៅកសាងឬយកទៅសម្លាប់ ។ ខ្មែរក្រហមបង្ខំឲ្យប្រជាជនធ្វើការទាំងឈឺដោយចោទថាប្រជាជនឈឺពុតឬឈឺសតិអារម្មណ៍ ។ ការខ្លាចស្លាប់បានជំរុញឲ្យប្រជាជនទៅធ្វើការទាំងឈឺ រហូតពេលខ្លះប្រជាជនមួយចំនួនដួល

សន្ធប់នៅតាមស្រែចម្ការ ទើបបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យសង្គមកិច្ចដែលស្ថិតនៅក្នុងវត្តព្រៃស្នៀត ។ ពេលនោះ ដោយសារតែ សោភ័ណ មិនអាចទ្រាំបាននូវរបបអាហារបែបនេះបាន ក៏ស្រាប់តែធ្វើឲ្យមានជំងឺហើមកាន់តែធ្ងន់ធ្ងរឡើង ។ ដូច្នេះ លោកយាយ ហេង ត្រូវនៅមើលថែរក្សាចៅស្រីដោយមិនអាចមានចេញទៅក្រៅដើម្បីរកអាហារនិងថ្នាំមកព្យាបាលជំងឺឡើយ ។ ដោយសារឃើញស្ថានភាពកាន់តែធ្ងន់ធ្ងរ លោកយាយ ហេង ក៏បានស្នើអង្គការភូមិយកចៅរបស់គាត់ទៅមន្ទីរពេទ្យសង្គមកិច្ចថ្នាក់ភូមិ ។ នៅទីនោះ ការព្យាបាលមានតែប្រើថ្នាំអាចម៍ទន្សាយនិងសេរ៉ូមដែលធ្វើអំពីទឹកដូងខ្លះៗប៉ុណ្ណោះ ទោះបីជាជំងឺប្រភេទណាមួយក៏ដោយ ។ ប៉ុន្មានថ្ងៃក្រោយមក សោភ័ណ ក៏បានស្លាប់ ។ កាលណោះ សុធា មិនដឹងថា លោកយាយកំពុងតែគិតពីអ្វីនោះទេ ប៉ុន្តែ សុធា ឃើញមុខលោកយាយមានសភាពខុសពីពេលមុន ព្រោះគាត់អង្គុយនៅមួយកន្លែង រួចនិយាយតែពាក្យថា «ចៅជីដូនស្លាប់ហើយ» ។ ចាប់តាំងពីពេលនោះមក សុធា ក៏លែងឃើញប្អូនស្រីរបស់គេរហូត ។ ប៉ុន្មានថ្ងៃក្រោយមក សុធា ដឹងថា លោកយាយ ហេង បានសរសេរសំបុត្រផ្ញើទៅប្រាប់អ្នកម្តាយរបស់គេពីដំណឹងមរណភាពរបស់ សោភ័ណ ។

ច្រើនខែកន្លងផុតទៅ រាងកាយរបស់ សុធា កាន់តែស្គមស្លេកស្លាំងទៅ ហើយត្រូវអង្គការបង្ខំឲ្យធ្វើការសម្រុកយ៉ាងខ្លាំងក្លាទៀត ។ ដោយសារតែអាហារដែលអង្គការចែកឲ្យហូបមិនឆ្អែត សុធា ត្រូវដើរចាប់សត្វផ្សេងៗយកមកហូបបន្ថែម និងបានគេចពីកើបអាចម៍គោ ទៅបេះត្របែកដែលដុះនៅតាមផ្ទះអ្នកមូលដ្ឋានយកមកហូបសម្រន់ការអត់ឃ្លាន ។ កំពុងតែលួចបេះ ស្រាប់តែមេកងកុមារបានដើរមកឃើញ ហើយបញ្ជាឲ្យចុះពីចុងត្របែកដោយចោទថាក្បត់សមូហភាព និងលួចគេចវេះមិនចូលរួមធ្វើពលកម្ម ។ អង្គការបានវាយផ្តិនខ្នង សុធា ដោយកាំភ្លើង រួចបញ្ជាឲ្យលុតជង្គង់នៅលើរងើកភ្លើងចំបើងដែលកំពុងឆេះដែលជើងរបស់គាត់នៅមានស្នាមដំបៅរហូតមកដល់សព្វថ្ងៃ ។

ក្រោយពីទទួលទណ្ឌកម្ម លោកយាយ ហេង ក៏បានសុំច្បាប់អង្គការដើម្បីឲ្យ សុធា សម្រាកពីការងារ ព្រោះជើងរបស់ សុធា មិនអាចដើរបាននោះទេ ។ លោកយាយ ហេង យំអាណិតចៅជាខ្លាំង តែគាត់មិនហ៊ានយំឲ្យចេញសំឡេងឡើយ ។ ក្នុងរយៈពេលដែល សុធា មានជំងឺ លោកយាយ ហេង ត្រូវអង្គការផ្លាស់ការងារឲ្យទៅចាំចាបនៅវាលស្រែវិញ ។ ដោយសារមិនអាចទុក សុធា សម្រាកនៅផ្ទះតែម្នាក់ឯងបាន លោកយាយ ហេង ត្រូវអៀវចៅទៅវាលស្រែជារៀងរាល់ព្រឹក ។ ពេលទំនេរបន្តិចបន្តួច លោកយាយ ហេង តែងតែលួចធ្វើឧបករណ៍ដេញចាបមួយប្រភេទមានឈ្មោះថាក្រពះ ដើម្បីលួចបូតស្រូវសើកចូលទៅក្នុងក្រពះដែលធ្វើពីឫស្សីនោះ ។ ចំណែក សុធា ពិតមែនតែជើងមិនអាចដើរបាន តែអាចយកដៃទៅលូករន្ធក្តាម ឬចាប់ត្រីនៅក្នុងវាលស្រែ ជិតៗនោះបានដែរ ។ ពេលមកដល់ផ្ទះ លោកយាយ ហេង បានលបជីកដីនៅក្នុងផ្ទះ ដើម្បីធ្វើជាត្បាល់បុកស្រូវដែលលួចបាន ។ បន្ទាប់មក គាត់បានយកអង្ករដែលបុករួចទៅដាំជាបបរនិងយកត្រី ឬក្តាមយកទៅធ្វើម្ហូប ។ មិនយូរប៉ុន្មាន ក្រោយពីអង្គការបានស៊ើបដឹង គាត់ក៏ត្រូវបានហៅទៅកសាង ហើយបញ្ឈប់លែងឲ្យនៅចាំចាបដូចពេលមុន ។

ចូលមកដល់ឆ្នាំរោង ដែលជាឆ្នាំមានទឹកជំនន់ធំជន់លិចចូលភូមិ គណៈកងក៏បានកំណត់ឲ្យប្រជាជនទាំងអស់ធ្វើផ្នើរដាក់ជង្រុកស្រូវ និងតម្រូវឲ្យកងកុមារហែលទឹកដើម្បីកើបស្រូវមកដាក់ក្នុងជង្រុកធ្វើផ្នើរ ។ ដោយសារតែ សុធា ប្រកែកមិនព្រះចុះទឹក មេកងកុមារបានបញ្ជាឲ្យកុមារ ៣-៤ នាក់ចាប់សែងកុមារ សុធា បោះទម្លាក់ទៅក្នុងទឹកបីងក្នុងមួយថ្ងៃពីរដង ។ ដោយសារតែខ្លាច សុធា លង់ទឹក លោកយាយ ហេង លុតជង្គង់សំពះអង្វរមេកងកុំឲ្យធ្វើបែបហ្នឹងទៀត ។ ប៉ុន្តែការអង្វរនេះមិនទទួលបានការអាណិតពីមេកងទេ រហូតដល់ចុងក្រោយ សុធា ក៏ចេះហែលទឹក ។

ចំណែកការរៀនសូត្រវិញ អង្គការអនុញ្ញាតឲ្យ សុធា រៀននៅម៉ោងប្រហែល១០ព្រឹកជារៀងរាល់ថ្ងៃ បន្ទាប់ពីកើបអាចម៍គោរួច ។ នៅពេលរៀន គ្រូតែងតែទះមាត់របស់ សុធា ជាញឹកញាប់ ព្រោះតែ សុធា បញ្ចេញសំឡេងមិនច្បាស់ពេលប្រកបអក្សរ ។ ទោះជាគ្រូព្យាយាមឲ្យ សុធា ខំអានអក្សរយ៉ាងណាក៏ដោយ ក៏ សុធា នៅតែអានមិនច្បាស់ដែរ ព្រោះតែ សុធា គ្មានធ្មេញដើម្បីទប់ការបញ្ចេញសំឡេង ។ ដោយសារភ័យខ្លាចខ្លាំងពេក សុធា បានលួចទៅលាក់ខ្លួនក្នុងជង្រុកស្រូវដើម្បីគេចពីរៀន ។ ប៉ុន្តែ

នៅទីបំផុត សុធា ក៏សុខចិត្តចេញពីជង្រុកដែរ ដោយសារអង្គការតាមរកជាច្រើនកន្លែងមិនឃើញ រួចបានស្ដីបន្ទោសឲ្យលោកយាយ ហេង ។ ពេលនោះមេកងបានវាយ សុធា ជាច្រើនរំពាត់ ។ ឃើញដូច្នេះ លោកយាយ ហេង បានអង្វរមេកងនិងសន្យាថានឹងនាំចៅទៅរៀនជារៀងរាល់ថ្ងៃ ។ ក្រោយព្រឹត្តិការណ៍នេះ សុធា មិនដែលគេចទៅរៀនទេ ។ ដោយសារតែរៀនរយៈពេលជាច្រើនថ្ងៃ សុធា នៅតែមិនចេះអានមិនច្បាស់ទៀត ពេលខ្លះអង្គការបានយកចំពុះទុងនៃកាំភ្លើងមកកោសអណ្ដាតរបស់ សុធា ទាល់តែបែកឈាមពេញមាត់ រួចចោទថាអណ្ដាតធំពេក ទើបមិនអាចអានអក្សរបានច្បាស់ និងថា សុធា មិនមែនជាកូនខ្មែរទេ ទើបនិយាយខ្មែរមិនច្បាស់ ។

អង្គការបង្រៀនអក្សរដល់កុមារមិនសូវច្រើននោះទេ ភាគច្រើនគឺអប់រំតែអំពីទ្រឹស្ដីនយោបាយ បំពាក់សតិអារម្មណ៍កុមារឲ្យប្រឆាំងជាមួយចក្រពត្តិអាមេរិក វណ្ណៈសក្ដិភូមិនិងមូលធននិយម អប់រំឲ្យកុមារឲ្យក្លាយជាកូនរបស់អង្គការ ធ្វើឲ្យកុមារក្លាយជាអ្នករាយការណ៍ដ៏ល្អរបស់អង្គការ និងជាពិសេសបង្រៀនកុមារឲ្យចេះច្រៀងចម្រៀងបដិវត្តន៍ដ៏ក្រហមឆ្អិនឆ្អៅ ។

មិនយូរប៉ុន្មាន សុធា បានគេចមិនទៅធ្វើការម្ដងទៀត ដោយលួចដើរទៅផ្ទះរបស់តាម្នាក់ដែលជាប្រជាជនមូលដ្ឋានដើម្បីសុំដំឡូងស្ងោរពីគាត់ ព្រោះធម្មតាប្រជាជនមូលដ្ឋានមានលទ្ធភាពអាចលួចគាស់ដំឡូងដែលគាត់ដាំនៅក្នុងដីរបស់គាត់ឬមួយមានលទ្ធភាពអាចដោះដូរគ្រឿងហូបចុកដោយលួចលាក់យកមកទុកក្នុងផ្ទះបាន ។ ដើរមកដល់វាលស្រែមួយ សុធា ស្រាប់តែបានជួបកុមារ៤-៥នាក់ ដូចជា សាល និង ពន្ទក មកឃាត់ដំណើរឲ្យទៅរើសមើមដំឡូងដែលគេភ្ជួរចោល ។ ពេលនោះ សុធា បដិសេធដោយប្រាប់ថា ចង់ទៅមុខទៀតដើម្បីរកត្រីមកធ្វើម្ហូប ដែលពាក្យនេះគ្រាន់តែជាពាក្យកុហកទេ ។ ក្រោយមក សុធា ស្រាប់តែឃើញកូនថ្កុកតូចមួយដែលមានក្របីមួយក្បាលកំពុងត្រាំនៅក្នុងនោះ រួចក៏ខំដេញក្របីដើម្បីចាប់ត្រី ។ ស្រាប់តែក្រឡេកទៅឃើញកងឈ្លបម្នាក់ដែលឈរកាន់កាំភ្លើងភ្ជង់តម្រង់មកក្បាលរបស់ សុធា ចម្ងាយប្រហែល៤-៥ម៉ែត្រ រួចស្រែកប្រកាសហៅគ្នាបន្ថែមទៀតឲ្យជួយចាប់ ។ ពេលចាប់ សុធា បាន កងឈ្លបបានចងដៃជើងរបស់ សុធា រួចនាំទៅឃុំទុកនៅក្នុងវត្តព្រៃខ្វា ។ មកដល់កុដិមួយ កងឈ្លបបានធាក់ សុធា បញ្ចូលទៅក្រោមកុដិលោកសង្ឃដ៏ងងឹតដែលមានតែពន្លឺថ្ងៃចាំងចូលតាមប្រហោងក្ដារតែបន្តិចប៉ុណ្ណោះ ។ មន្ទីរនេះ សុធា ឃើញមានក្មេងៗប្រហែលជាង២០នាក់ ដែលក្នុងនោះមាន សាល និង ពន្ទក ជាប់នៅក្នុងគុកនេះដែរ ដោយអ្នកទាំងពីរមានទោសពីបទរើសដំឡូងនិងគេចមិនទៅធ្វើការ ។ ពេលនោះ សុធា គិតថាខ្លួនពិតជាស្លាប់ហើយ ព្រោះបន្តិចក្រោយមក កងឈ្លបពីរនាក់បានយកកងដែកធំៗពីរមកបំពាក់លើដៃនិងជើងរបស់ សុធា ដើម្បីកុំឲ្យលួចរត់ ។

ជារៀងរាល់ថ្ងៃ នៅវេលាម៉ោងប្រហែល៧យប់ អង្គការតែងតែមកធ្វើទារុណកម្មក្មេងៗ ដល់បន្ទប់ឃុំឃាំងតែម្ដងដោយចងព្យួរទៅនឹងរ៉កមួយ ដែលព្យួរនៅនឹងធ្នឹមបន្ទប់ឃុំឃាំង រួចយករំពាត់ខ្សែតីយ៉ាងធំមកវាយលើរាងកាយក្មេងជាច្រើនរំពាត់ជាមួយនឹងការសួរចម្លើយ ។ ពេលឮសំឡេងស្រែកយំ សុធា ងាកមុខចេញដោយខ្លួនញ័រ ដៃជើងត្រជាក់ដូចទឹកកក និងបេះដូងលោតមិនឈប់ ថែមទាំងមិនហ៊ានកម្រើកខ្លួនទៀត ។ ការធ្វើទារុណកម្មនេះ អង្គការអនុវត្តន៍នៅចំពោះមុខក្មេងទាំងអស់ ។ ស្នូររំពាត់វាយទៅលើអ្នកទោសនេះហាក់ដូចជាកំពុងវាយទៅលើអ្នកទោសជាង២០នាក់ ដែលកំពុងអង្គុយជាប់ខ្នោះដៃជើងនៅក្នុងទីឃុំឃាំងនេះដែរ ។ ទាំងក្មេងមិនទាន់ធ្វើទារុណកម្មនិងកំពុងធ្វើទារុណកម្មតក់ស្លុតដូចៗគ្នា ដោយជួនកាលក្មេងមួយចំនួនបានឆ្លើយសារភាពប្រាប់អំពីទោសរបស់ឪពុកម្ដាយដែលបានធ្វើក្នុងន័យក្បត់នឹងអង្គការ ។ គ្មានអ្នកណាអាចដឹងថា ចម្លើយដែលបានប្រាប់ទៅអង្គការជាចម្លើយពិតឬយ៉ាងណានោះទេ ព្រោះប្រសិនបើក្មេងរូបណាមិនឆ្លើយនឹងសំណួរដែលអង្គការចង់បានក្មេងនោះប្រាកដជាត្រូវរំពាត់រហូតទាល់តែសន្លប់ ។ ប៉ុន្តែ ទោះជាក្មេងដែលបានឆ្លើយតាមបំណងឬមិនតាមបំណងរបស់អង្គការ ក៏ក្រោយមកក្មេងទាំងនោះត្រូវបានសែងយកចេញទៅក្រៅបាត់ដែរ ។ គ្មាននរណាដឹងថាគេយកក្មេងទាំងនោះទៅធ្វើអ្វីនៅទីណាឡើយ ប៉ុន្តែអ្វីដែលអាចដឹង គឺអ្នកទាំងនោះមិនដែលឃើញត្រឡប់មកវិញទេ ។

ថ្វីបើមិនទាន់ដល់វេន សុធា ត្រូវយកទៅវាយសួរចម្លើយ តែតាំងពីក្រោយថ្ងៃទីមួយដែល សុធា ជាប់ឃុំឃាំងមក អង្គការ

ផ្តល់របបបបរនិងទឹកឲ្យអ្នកទោសតែបន្តិចបន្តួចប៉ុណ្ណោះ និងឮតែស្នូររំពាត់ដែលវាយធ្វើទារុណកម្ម ។ សុធា គិតថា មិនយូរទេរំពាត់នេះនឹងវាយលើខ្លួនរបស់គេជាមិនខាន ។ សុធា ភ័យខ្លាំងណាស់ ដោយពេលយប់ដេកស្រមៃឃើញតែក្មេងត្រូវអង្គការធ្វើទារុណកម្ម ។ ទោះបីជាជើងនិងដៃត្រូវជាប់ខ្នោះក៏ដោយ ក៏ សុធា ព្យាយាមរកកន្លែងណាដែលអាចរត់ចេញបានដែរ ប៉ុន្តែគ្មានច្រកណាដែលអាចរត់រួចទេ ។ រាល់យប់និងរាល់ថ្ងៃ ទាំង សុធា និងក្មេងដទៃទៀតដែលមិនទាន់ទទួលទណ្ឌកម្ម តែងតែផ្ទៀងត្រចៀកស្តាប់សម្រិបជើងមនុស្សដែលដើរនៅខាងក្រៅបន្ទប់ឃុំឃាំង ព្រោះបើមានស្នូរជើងមនុស្សមកកៀកបន្ទប់នេះ នោះអង្គការនឹងមកវាយធ្វើទារុណកម្មទៀតហើយ ។ ជួនកាល សុធា លបរំកិលខ្លួនមកលួចមើលតាមប្រហោងរន្ធសោទៅផ្នែកខាងក្រៅបន្ទប់ឃុំឃាំង ដើម្បីឲ្យដឹងថាអ្នកសម្លាប់មកដល់ហើយឬនៅ ។

អង្គការតែងតែវាយធ្វើបាបអ្នកទោសកុមារជារៀងរាល់ថ្ងៃ ។ ឥឡូវនេះអ្នកទោសនៅសល់តែ សុធា និង ពន្លក ទេដែលមិនទាន់ត្រូវបានធ្វើទារុណកម្ម ។ សុធា កាន់តែភ័យខ្លាំងឡើងៗ ព្រោះអាចជាថ្ងៃស្អែកប្រហែលជារូបគេដែលត្រូវអង្គការវាយនឹងរំពាត់ខ្សែតី ។ ដូច្នេះ សុធា បន់មិនឲ្យថ្ងៃរះ មិនចង់ឲ្យថ្ងៃស្អែកមកដល់ទេ ។ ព្រលឹមឡើង កងឈ្លបមួយរូបបានដើរតម្រង់មក សុធា ដែលធ្វើឲ្យខ្លួនរបស់ សុធា ងើបឈរទាំងញ័រទទ្រើកស្ទើរដើរទៅមុខមិនរួច ។ ប៉ុន្តែសំណាងណាស់ ដោយកងឈ្លបបែរជានាំ សុធា ដើរហួសកន្លែងធ្វើទារុណកម្ម ។ បន្ទាប់មក សំឡេងមួយឃ្លារបស់កងឈ្លបបានប្រាប់ សុធា ថាអង្គការដោះលែងហើយ ។ គ្រាន់តែឮភ្លាម សុធា វិលវល់ស្មារតី ស្ទើរមិនជឿត្រចៀកខ្លួនឯងថាបានរស់ជាថ្មីម្តងទៀត ។

មកដល់ផ្ទះ សុធា តក់ស្លុតរហូតធ្លាក់ខ្លួនឈឺជាទម្ងន់ ដោយរវើរវាយស្រែកថា «កុំឲ្យអង្គការសម្លាប់គេ កុំឲ្យអង្គការវាយគេ គេឃ្លានណាស់ទើបគេចាប់ត្រី» ។ លោកយាយ ហេង ស្រវាឱប ចៅ រួចនិយាយលួងលោមថា «ចៅអើយត្រូវប្រឹងរស់ណាចៅ ស្អែកយើងបានស្រួលហើយ ស្អែកបានស្រួលហើយ ស្អែកបានហូបឆ្អែតហើយចៅ» ។ សភាពជំងឺរបស់ សុធា ធ្វើឲ្យគាត់ព្រួយបារម្ភជាខ្លាំង ដែលហាក់ដូចជាធ្វើឲ្យគាត់នឹកឃើញដល់ការស្លាប់របស់ចៅស្រី សោភ័ណ ។ ដូច្នេះ លោកយាយ ហេង បានទៅសំពះអង្គការ ដើម្បីយក សុធា ទៅព្យាបាលនៅមន្ទីរពេទ្យ ។

មកដល់មន្ទីរពេទ្យ សុធា ត្រូវបានពេទ្យសង្គមកិច្ចឲ្យដេកនៅលើគ្រែឫស្សីដែលក្រាលដោយកន្ទេលកក់ចាស់មួយជាមួយភួយនិងខ្នើយមួយ ។ នៅទីនេះ គ្រូពេទ្យមិនអនុញ្ញាតឲ្យមានអ្នកមកដេកកំដរបានទេ ដូច្នេះ លោកយាយ ហេង អាចមកសួរសុខទុក្ខ សុធា បានតែពេលល្ងាចប៉ុណ្ណោះ ពេលយប់ត្រូវវិលត្រឡប់ទៅភូមិវិញ ។ រាល់ពេលមកជួប សុធា លោកយាយ ហេង តែងតែលួចពោលពាក្យលួងចៅថា «គង់មានថ្ងៃស្អែកដែលយើងនឹងស្រួល ដែលយើងបានហូបឆ្អាញ់ ដែលយើងនឹងជួបជុំគ្រួសារ» ។ ឮសម្តីលួងលោមបែបនេះ សុធា ស្រាប់នឹកឃើញដល់សម្តីម្តាយដែលធ្លាប់និយាយប្រាប់កាលពីពេលជ្រកពួននៅលេណដ្ឋានដើម្បីគេចពីគ្រាប់កាំភ្លើង ។

នៅក្នុងមន្ទីរពេទ្យនេះ មានអ្នកជំងឺខ្លះហើម ខ្លះគ្រុនក្តៅនិងមួយចំនួនទៀតដំបៅរលួយជាច្រើនកន្លែងនៅលើរាងកាយដែលជាហេតុធ្វើឲ្យគេមិនអាចដើរបាន ។ មន្ទីរពេទ្យនេះគ្មានអនាម័យទេ គឺមានតែក្លិនស្អុយនិងឆ្អាបកាយចេញពីខ្លួនអ្នកជំងឺ ប៉ុន្តែទោះបីជាអ្នកជំងឺឈឺអ្វីក៏ដោយ ក៏គ្រូពេទ្យរបស់អង្គការព្យាបាលដោយចាក់ទឹកដូង ឬលេបថ្នាំអាចម៍ទន្សាយពណ៌ខ្មៅប៉ុណ្ណោះ ដែលជាហេតុធ្វើឲ្យអ្នកជំងឺស្លាប់ស្ទើររៀងរាល់ថ្ងៃ ។

មួយខែក្រោយពីជាសះស្បើយហើយ សុធា ក៏បានវិលមកសម្រាកនៅផ្ទះវិញ ។ រូបរាងចៅលោកយាយ ហេង មានតែស្បែកគ្របដណ្តប់ឆ្អឹង ដោយសារតែរបបបបររបស់អ្នកជំងឺមានតែមួយវែកប៉ុណ្ណោះតិចជាងរបបរបស់អ្នកដែលទៅបំពេញពលកម្មទៅទៀត ។ លោកយាយអាណិតចៅខ្លាំងណាស់ ដែលភាពអាសូរនេះទើបជំរុញចិត្តលោកយាយឲ្យលែងខ្វល់ពីជីវិតខ្លួនឯង ហើយបំពានបម្រាមរបស់អង្គការ ដោយសម្រេចចិត្តថា យប់នេះគាត់នឹងទៅលួចកាប់មាន់ដែលគាត់ចិញ្ចឹមយកធ្វើម្ហូបឲ្យចៅបរិភោគ ដោយមាន សុធា ជាអ្នកមើលផ្លូវក្រែងអង្គការមកទាន់ ។ យប់នោះ អ្នកទាំងពីរមានមាន់ស្ងោរហូប ហើយគេងលង់លក់យ៉ាងស្កប់ស្កល់ ។

ស្អែកព្រលឹមឡើង កងឈ្លបចំនួន៣នាក់បានមកដល់មុខផ្ទះ

លោកយាយ ហេង រួចនិយាយប្រាប់គាត់ថា អង្គការហៅលោកយាយទៅប្រជុំ ។ វត្តមានកងឈ្លបដែលមកដល់ទាំងព្រហាម និងពាក្យប្រជុំដែលមានន័យថាហៅយកមកកសាង ។ ឃើញសភាពបែបនេះ លោកយាយនិងចៅភ័យខ្លាំងណាស់ ពីព្រោះគាត់គិតថាអង្គការប្រហែលជាដឹងពីរឿងលួចកាប់មាន់យកស្ងោរហូបជាមិនខាន ។ ពេលនោះ សុធា ពួននៅកៀនជញ្ជាំងផ្ទះ ហើយលួចសម្លឹងមកជីដូនទាំងទឹកភ្នែក ចំណែកលោកយាយវិញស្ទើរតែទន់ជង្គង់ដួលទៅដី ។ ប៉ុន្តែ គាត់នៅតែក្លាហាន ហើយឈានជើងដើរទៅជួបកងឈ្លបនោះដោយមិនងាកក្រោយមើលចៅទេ ។ នៅចំពោះមុខអង្គការ អ្នកទាំងនោះបានបន្ទោសលោកយាយ ហើយគំរាមថានឹងយកគាត់ទៅរៀនសូត្រ បើគាត់នៅតែធ្វើខុសនឹងមាគ៌ាបដិវត្តន៍របស់អង្គការម្តងទៀត ។

នៅឆ្នាំ១៩៧៧ ក្នុងខែនេះ ជារៀងរាល់យប់តែងតែមានឮសំឡេងចម្រៀងមីក្រូចេញពីវត្តព្រៃស្នៀត ។ ចម្រៀងនេះមិនបានជួយអ្វីដល់ប្រជាជនទេ ពីព្រោះពេលថ្ងៃអង្គការប្រើប្រជាជនឲ្យធ្វើការយ៉ាងលំបាកជាងសត្វគោក្របីទៅទៀត ហើយថែមទាំងមិនឲ្យហូបឆ្អែតទៀត ហើយពេលយប់វិញឲ្យប្រជាជនគេងបានតែបីបួនម៉ោងប៉ុណ្ណោះ ស្រាប់តែពេលនេះបែរជាមកបំពងសំឡេងតាមមីក្រូខ្លាំងៗជាហេតុធ្វើឲ្យម្នាក់ៗមិនបានសម្រាកទៅវិញ ។ នេះជាទារុណកម្មមួយដ៏ឃោរឃៅដែលហាក់ដូចជាចង់ឲ្យមនុស្សស្លាប់អស់ពីភូមិ ព្រោះប្រជាជនហូបមិនបានគ្រប់គ្រាន់ ហើយថែមទាំងមានសំឡេងមីក្រូមករំខានទៀត ។ ដោយសារថ្ងង់នឹងសំឡេងគួរឲ្យធុញទ្រាន់និងសេចក្តីឃ្លានរុករានផង សុធា ទ្រាំលែងបានរហូតងើបពីដំណេកដើរចេញពីផ្ទះដោយមិនឲ្យជីដូនដឹង ។ សុធា មានបំណងលួចដកដំឡូងឬត្រាវរបស់អ្នកមូលដ្ឋានយកមកស្ងោរហូប ។ ជាសំណាងល្អ ពេលដើរកាត់ភូមិគ្មានឆ្កែប្រុសធ្វើឲ្យភ្ញាក់កងឈ្លប ។ ជាធម្មតា សុធា ខ្លាចខ្មោចខ្លាំងណាស់ ប៉ុន្តែពេលនេះសេចក្តីស្រេកឃ្លានបានធ្វើឲ្យជើងរបស់ សុធា នៅតែទៅមុខដើម្បីរកកន្លែងលួចត្រាវឬដំឡូង ។

កំពុងតែដើរ សុធា ឮសម្លេងមនុស្សថ្ងូរតិចៗលាន់មកស្រាលៗពីគុម្ពឫស្សីក្បែរវត្តព្រៃខ្លា ដែលវត្តនេះមានចម្ងាយប្រហែលជា៣០០ម៉ែត្រពីផ្ទះ ។ ពេលឮសម្លេងកាន់តែច្បាស់ សុធា ចូលកាន់តែជិតក្នុងគុម្ពឫស្សីដើម្បីលាក់ខ្លួនរកមើលប្រភពសំឡេង ។ បន្តិចក្រោយមក សុធា ក៏បានឃើញកងឈ្លបកំពុងវាយប្រជាជនជាច្រើននាក់ទម្លាក់ក្នុងទឹកស្រះនៅខាងក្រោយគុម្ពឫស្សីនេះ ។ ព្រមជាមួយនោះ សំឡេងមីក្រូក៏លាន់ឮដើម្បីបន្ទប់សម្រែកស្រែកយំឬសំឡេងឈឺចាប់ ។ ពេលបានឃើញកងឈ្លបសម្លាប់មនុស្សផ្ទាល់ភ្នែក សុធា ភ័យតក់ស្លុតរហូតដល់ដើរដួលជាច្រើនកន្លែងទម្រាំតែមកដល់ផ្ទះ ។ ពេលដើរមកដល់ផ្ទះ លោកយាយ ហេង ស្មានតែកងឈ្លបមកហៅគាត់និងចៅទៅសម្លាប់ តែបែរជាឃើញ សុធា សន្ធប់នៅមុខខ្ទមទៅវិញ ។ ពេលនោះ លោកយាយ ហេង ស្រវាឱបចៅផ្ទប់ដើមទ្រូង រួចសួរអំពីមូលហេតុដែលនាំឲ្យមានសភាពបែបនេះ ។ បន្ទាប់មក សុធា និយាយទាំងរដាក់រដុបពីហេតុការណ៍ដែលអង្គការសម្លាប់មនុស្សទាំងខ្សែប្រាប់លោកយាយ ។

**(នៅមានត)**

**ប៉ាល់ ខណ្ឌារក្ស**

# ដំណឹងស្វែងរកឪពុក

ខ្ញុំបាទឈ្មោះ លាភ ចាន់ភារម្យ សព្វថ្ងៃរស់នៅភូមិអ្នកលឿង ឃុំអ្នកលឿង ស្រុកពាមរ ខេត្តព្រៃវែង ។ សូមសួររកឪពុកឈ្មោះ ម៉ុច ចាន់ណារី ហៅ លាភ មានស្រុកកំណើតនៅភូមិបឹងព្រះ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង ដែលបានបាត់ខ្លួនពីស្រុកពាមជរ ក្នុងខែមេសា ឆ្នាំ១៩៧៧ ដោយសារអង្គការបានបញ្ជូនគាត់ឲ្យទៅយកអង្ករនៅទីរួមស្រុកពាមជរ ។ នៅពេលនោះឪពុករបស់ខ្ញុំគឺជាអតីតគ្រូបង្រៀននៅសម័យរាស្ត្រសង្គមនិយម ។ ឥឡូវនេះ ខ្ញុំមិនដឹងថាគាត់ស្លាប់ឬនៅរស់នៅកន្លែងណាទេ ។

ប្រសិនបើលោកឪពុកបានឃើញដំណឹង ឬញាតិមិត្តណាបានស្គាល់ឈ្មោះខាងលើនេះ សូមមេត្តាទំនាក់ទំនងមកអាសយដ្ឋានខាងលើ ឬទូរស័ព្ទលេខ ០១៥ ៦៧៣ ០០០ ឬ ០៩៧ ៨៧៧ ៧០០៦ ឬមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រ១១១០ ភ្នំពេញ ។

***សូមអរគុណ!***

# ១៧ មេសា

ដោយ ណុប ច័ន្ទតារា

១៧មេសាចារក្នុងចិត្ត
ភពខ្មោងងឹតអន្ធកាលអន្ធការ
១៧មេសាអស់រស្មី
ក្មេងចាស់ប្រុសស្រីរស់រងកម្ម ។
១៧មេសាពតយង់ឃ្នង
កាប់ចាក់សំពងខ្មែរប្រេះស្រាំ
១៧មេសាចិតសិបប្រាំ
ខ្ញុំនៅចងចាំរៀងរាល់ថ្ងៃ ។

សំឡេងថ្ងូចថ្ងូរមុនពេលស្លាប់
ប៉ុលពតសម្លាប់គ្មានសំចៃ
ត្បូងចបធាងត្នោតគល់ឬស្សី
ប៉ុលពតអប្រីយ៍សម្លាប់ខ្មែរ ។
ឆ្អឹងគរដូចភ្នំយំមិនចេញ
ស្លាប់គ្មានវិលវិញពេញវាលស្រែ
រណ្ដៅរាប់ម៉ឺនដាឆ្អឹងខ្មែរ
ទុក្ខគ្មានល្ហើយល្ហែដាងបួនឆ្នាំ ។

ខ្ញុំអូសរទេះដឹនួសគោ
ឈាមខ្ញុំស្រក់ហូរខ្ញុំនៅចាំ
ជំនាន់ក្រោយៗខ្ញុំសូមផ្ដាំ
ទោះរយលានឆ្នាំចាំកុំភ្លេច ។
ហេវពេកដេកនឹកស្រមៃហូប
ឃ្លានចង់ស្រស់ស្រូបនឹកឃើញខ្មុច
កំដរខ្លួរក្បាលព្រោះខ្លាចភ្លេច
រសជាតិយ៉ាងម្ដេចមុននឹងក្ស័យ ។

១៧មេសាព្រាត់បងប្អូន
ពុកម៉ែព្រាត់កូនចិត្តមមៃ
១៧មេសាខ្មែរទុក្ខភ័យ
ព្រាត់ប្រាសគ្មានថ្ងៃជួបទៀតទេ ។
ខ្ញុំជាកសិណមើលឃើញច្បាស់
ពិបាកខ្លាំងណាស់គ្មានទំនេរ
ជាកងយុវជនខ្ញុំខុសគេ
អង្គការស្ដីជេរវាយទាត់ធាក់ ។

ក្បាលខ្ញុំហូរឈាមព្រោះគេវាយ
ឈឺចិត្តជាងកាយនៅចាំជាក់
ស៊ូទ្រាំញញឹមឲ្យគេធាក់
ធ្វើដូចជាស្ម័គ្រនឹងអង្គការ ។
ខោមួយចង្កេះដាច់រយ៉ៃ
ក្រោមកម្ដៅថ្ងៃព្រះសុរិយា
គ្មានអាវស្បែកខ្នងឡើងក្ដៅផ្សា
សម័យអស្ចារ្យមហាលោតផ្លោះ ។

រាល់យប់ខ្ញុំយំព្រោះខ្ញុំព្រាត់
បងប្អូនខ្លាយខ្លាត់បាត់ទៅអស់
ពតគេសម្លាប់អ្នកទាំងរស់
ទឹកភ្នែកខ្ញុំខ្សោះលុះមរណា ។
ខ្មែរអើយកុំភ្លេចវាលពិឃាដ
កុំឲ្យយល់ទៀតជាតិខេមរា
ក្មួយជំនាន់ក្រោយសូមកត់ត្រា
រឿងខ្ញុំខ្លោចផ្សាលុះថ្ងៃសូន្យ ។












ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 112, April 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.